ព្រះរាជាណាចក្រកម្ពុជា

UNDP
Cambodia

# របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា ឆ្នាំ ២០០៧






# បង្កើនជម្រើស សម្រាប់ប្រជាជននៅជនបទ

ក្រសួងផែនការ

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ព្រះរាជាណាចក្រកម្ពុជា

UNDP
Cambodia

# របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា ឆ្នាំ ២០០៧

# បង្កើនជម្រើស
# សម្រាប់ប្រជាជននៅជនបទ

ក្រសួងផែនការ

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

រក្សាសិទ្ធិ © ឆ្នាំ ២០០៧ ក្រសួងផែនការ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំប្រទេសកម្ពុជា

រក្សាសិទ្ធិគ្រប់បែបយ៉ាង ។ គ្មានផ្នែកណាមួយនៃរបាយការណ៍នេះត្រូវបានបោះពុម្ពឡើងវិញ ឬថតចម្លងដោយគ្មានការអនុញ្ញាត ។
បុគ្គលណាដែលប្រព្រឹត្តិបទល្មើស នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ។

បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧
បោះពុម្ពដោយ ក្រសួងផែនការ និងយូអ៊ិនឌីភី កម្ពុជា



# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះជាលទ្ធផលនៃការប្រឹងប្រែងរួមរបស់ក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអ៊ីនឌីភី)។ របាយការណ៍នេះ រៀបចំឡើងតាមរយៈដំណើរការពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយក្រុមសាស្ត្រាចារ្យនៃមហាវិទ្យាល័យ អ្នករៀបចំគោលនយោបាយ និងអ្នកជំនាញវិជ្ជាជីវៈ។ ការពិគ្រោះយោបល់ជាក្រុម បានប្រព្រឹត្តទៅជាងដប់លើក និងមានជំនួបពិភាក្សាជាច្រើនទៀតជាលក្ខណៈបុគ្គល ជាក្រុមតូចៗ និងជាក្រុមមន្ត្រីជំនាញសំខាន់ៗ ដើម្បីជួយសម្រួលដល់កិច្ចការនេះ។

នៅខែ តុលា ឆ្នាំ ២០០៦ មានការបង្កើតក្រុមពិគ្រោះយោបល់លើបច្ចេកទេសមួយ ដែលមានមន្ត្រីជាន់ខ្ពស់ សាស្ត្រាចារ្យ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកជំនាញវិជ្ជាជីវៈសំខាន់ៗជាច្រើន ដែលបំពេញការងារនៅកម្ពុជា។ ក្រុមពិគ្រោះយោបល់បានណែនាំក្នុងការរៀបចំរបាយការណ៍នេះឱ្យសម្រេចបានលទ្ធផលសមស្រប។ ក្រុមនេះបានជួបប្រជុំជាច្រើនលើក ដើម្បីពិនិត្យពិភាក្សា និងផ្តល់ការឯកភាពលើទម្រង់នៃរបាយការណ៍ ផ្តល់គំនិតថ្មីៗ និងសម្រិតសម្រាំងអ្វីៗដែលបានរកឃើញ។ សមាជិកក្រុមនេះ បានអានសេចក្តីព្រាងរបាយការណ៍មុនៗពីរលើក និងបានផ្តល់ជាយោបល់កែសម្រួល។ សមាជិកខ្លះបានផ្តល់មតិផ្ទាល់ខ្លួន ព្រមទាំងចែករំលែកឯកសារស្រាវជ្រាវរបស់ខ្លួនថែមទៀត បន្ថែមទៅលើការចូលរួមប្រជុំដែលប្រើរយៈពេលយូរ។

សមាជិកក្រុមពិគ្រោះយោបល់មាន ឯកឧត្តម ងី ច័ន្ទ្រផល (អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ) ឯកឧត្តម សៅ ជីវ័ន្ត (អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ) ឯកឧត្តម ហង់ ជួន ណារ៉ុន (អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) លោក ស សុវណ្ណ (អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់) លោកស្រី ហ៊ាង សៀវ លី (អគ្គនាយករងក្រសួងផែនការ) លោក គិត សេង (ប្រធាននាយកដ្ឋានផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ឯកឧត្តម អេង វ៉ុឡុង (ឯកអគ្គរាជទូតគោចរ និងជាទីប្រឹក្សារាជរដ្ឋាភិបាល) អ្នកស្រី ប៉ុក បញ្ញាវិចិត្រ (នាយកអង្គការស៊ីដា) លោក ឌិក សេរី សោភក្តិ ទីប្រឹក្សា (CDRI) លោក រូសេល គេចឹសាន់ (ទីប្រឹក្សាវេទិកា NGO) លោក វ៉ន មុនិន្ទ (ព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម) លោក កង ច័ន្ទតារ៉ាវុត្ថ (នាយកវិទ្យាស្ថានកម្ពុជាសិក្សាអភិវឌ្ឍន៍) លោក ច័ន្ទ សុផល (នាយកស្រាវជ្រាវជាន់ខ្ពស់ CDRI) លោក ហួត ពុំ (សេដ្ឋកិច្ចវិទូជាន់ខ្ពស់នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) លោក ហោ សុនាថ (មន្ត្រីកម្មវិធីអភិវឌ្ឍវិស័យឯកជនតំបន់ទន្លេមេគង្គ) លោក ធីម ខនវ៉េយ (អ្នកឯកទេសធនាគារពិភពលោក) លោកស្រី ម៉ៃ ភាស្ស (GTZ ប្រចាំកម្ពុជា) លោក ភិតធី ខយ (សមាជិកគណៈអភិបាលធនាគារអេស៊ីលីដា), តំណាងក្រុមហ៊ុន ម៉ុង រិទ្ធី, បណ្ឌិត យ៉ង សាំង កុមារ (ប្រធាន CEDAC) កញ្ញា ឌេហ្វីនី វ៉ាន់រ៉ូ (Oxfam GB) លោក ដាក់គ្លីស ហ្គាដឈើ (អ្នកសម្របសម្រួលប្រចាំប្រទេសនៃអង្គការសហប្រជាជាតិ និងតំណាងប្រចាំប្រទេសនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) លោកស្រី អាន់អ៊ីសាប៉ែល ឌឺគ្រីសប្លាតូ (នាយកនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) លោក រ៉ូប៊ឺត ហ្គូឈេស្គី (សេដ្ឋកិច្ចវិទូជាន់ខ្ពស់ UNDP ប្រចាំកម្ពុជា ឡាវ វៀតណាម) លោក សុត ឡឺបភី (ទីប្រឹក្សាជាន់ខ្ពស់នៃកម្មវិធី UNDP) និងលោកស្រី អាន ខូលីន ហ្វក (ទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយ UNDP)។

ប្រធានបទនិងលទ្ធផលដំបូង ត្រូវបានដាក់ជូនអង្គប្រជុំនៃក្រុមការងារសហប្រជាជាតិប្រចាំកម្ពុជា អង្គការក្រៅរដ្ឋាភិបាលផ្នែកអភិវឌ្ឍន៍ មន្ត្រីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មន្ត្រីជាន់ខ្ពស់ក្រសួងផែនការ និងក្រុមមន្ត្រីជំនាញអន្តរក្រសួង។ មតិរបស់លោក លោកស្រីម្នាក់ៗ ត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍នេះ។

របាយការណ៍នេះបានទទួលការពិនិត្យយ៉ាងល្អិតល្អន់ពីជំនាញការអន្តរជាតិ ៤ រូប គឺបណ្ឌិត អេដជិន (អតីតរាជទូតប្រទេសស៊ុយអែតប្រចាំប្រទេសវៀតណាម) លោក យ៉ក ម៉េន (នាយកប្រចាំប្រទេសនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំប្រទេសឥណ្ឌូណេស៊ី) បណ្ឌិត រ៉ាឃីវ៉ាន់ (អ្នកសម្របសម្រួលកម្មវិធីប្រចាំតំបន់ ការិយាល័យរៀបចំរបាយការណ៍អភិវឌ្ឍន៍មនុស្សនៃមជ្ឈមណ្ឌល UNDP ប្រចាំតំបន់នៅក្រុងកូឡំបូ) និងបណ្ឌិត ចន ឃ្វីន (ទីប្រឹក្សាកម្មវិធីទន្លេសាបនៃអង្គការ FAO)។

ដំណើរការរៀបចំ និងបង្ហើយរបាយការណ៍នេះស្ថិតនៅក្រោមកិច្ចចាត់ចែងទូទៅរបស់អ្នកស្រី យន ឱនរ៉ាវី អ្នកគ្រប់គ្រងគម្រោងចក្ខុវិស័យដើម្បីសកម្មភាពរបស់ UNDP ។ អ្នកសម្របសម្រួលសំខាន់ៗ រួមមាន បណ្ឌិត សាទី អាឆារីយ៉ា (UNDP) បណ្ឌិត អេនឌ្រូ ភីនី (ទីប្រឹក្សា UNDP ប្រចាំក្រសួងផែនការ) លោក មន្ត សារ៉ាត (ក្រសួងផែនការ) លោក ប៉ែន រក្សា (UNDP) លោកស្រី ម៉ាហ្គារ៉េដ ឡេមប័ (UNDP) លោក ប្រ៊ូក អ៊ីវ៉ាន (UNDP) កញ្ញា មួង សុផារ៉ាត និងអ្នកស្រី ខេ យីប៊ី ដូយី (ទីប្រឹក្សា) ។

សូមថ្លែងនូវការដឹងគុណជាពិសេសចំពោះឯកឧត្តម លោក លោកស្រីទាំងអស់ ដូចបានរៀបរាប់ខាងលើ ដែលលោកបានចំណាយពេលវេលាជាច្រើនក្នុងការរៀបចំរបាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សនេះ ។ ដោយសារការប្រឹងប្រែងរួមពីសំណាក់អស់លោក លោកស្រីទាំងអស់នេះហើយ ទើបយើងខ្ញុំអាចសម្រេចបានជារបាយការណ៍មួយប្រកបដោយវិសាលភាពទូលំទូលាយ និងស៊ីជម្រៅល្អ ដែលយើងខ្ញុំសង្ឃឹមថា នឹងជួយរួមចំណែកប្រកបដោយសារៈប្រយោជន៍នៅក្នុងការពិភាក្សាលើជីវភាពរស់នៅតាមជនបទ ធនធានធម្មជាតិ និងការអភិវឌ្ឍកម្ពុជាជាទូទៅ ។



# សង្ខេប

ការអភិវឌ្ឍមនុស្ស គឺជាការបង្កបរិយាកាសសម្រាប់ឱ្យមនុស្សអាចអភិវឌ្ឍសក្តានុពលរបស់ខ្លួនបង្កើតជម្រើសថែមទៀត សម្រាប់ខ្លួនគេ និងមានជីវិតរស់នៅប្រកបដោយសុខភាពចម្រុងចម្រើន និងអាយុយឺនយូរ។ ១៧ ឆ្នាំហើយ ដែល UNDP បានរៀបរៀងរបាយការណ៍អភិវឌ្ឍន៍មនុស្សនេះ មានគោលដៅលើកស្ទួយការអភិវឌ្ឍ ជាពិសេសការអភិវឌ្ឍមនុស្ស។ របាយការណ៍អភិវឌ្ឍន៍មនុស្ស (NHDRs) ជាឯកសារគាំទ្រលើការអនុវត្តដោយឈរលើមូលដ្ឋាននៃការស្រាវជ្រាវល្អិតល្អន់។ នៅលើពិភពលោកទាំងមូលមានរបាយការណ៍បែបនេះជាងបួនរយ (៤០០) ហើយនៅក្នុងប្រទេសចំនួន ១៣៥ ហើយកម្ពុជាបានផ្តើមធ្វើរបាយការណ៍នេះតាំងពីឆ្នាំ ១៩៩៧។

នេះជារបាយការណ៍ទី ៦ ដែលផ្តោតលើធនធានធម្មជាតិ និងជីវភាពរស់នៅតាមជនបទ។ របាយការណ៍នេះជាលទ្ធផលនៃការប្រឹងប្រែងរួមគ្នារវាងការិយាល័យ UNDP ប្រចាំកម្ពុជា និងក្រសួងផែនការ។ របាយការណ៍នេះពណ៌នាអំពីស្ថានភាពអភិវឌ្ឍន៍មនុស្សនៅកម្ពុជានៅថ្នាក់តំបន់ និងថ្នាក់ខេត្ត។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សផ្សេងៗគ្នា ត្រូវបានរៀបរាងឡើងសម្រាប់ខេត្តនីមួយៗ ដោយបញ្ជាក់តំបន់ដែលមានការរីកចម្រើនខ្ពស់ និងតំបន់ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ថែមទៀត។

របាយការណ៍នេះធ្វើការប៉ាន់ប្រមាណជាឯករាជ្យមួយអំពីការអភិវឌ្ឍមនុស្ស ស្ថានភាពរស់នៅតាមជនបទ និងទំនាក់ទំនងរវាងការរស់នៅ និងប្រភពធនធានធម្មជាតិនៅកម្ពុជា។ របាយការណ៍ក៏រៀបរាប់ផងដែរ អំពីអនុសាសន៍គោលនយោបាយ និងកាលានុវត្តភាពសម្រាប់ធ្វើឱ្យតំបន់ដាច់ស្រយាលមានភាពរីកចម្រើន។

សង្គម និងសេដ្ឋកិច្ចកម្ពុជាបានចម្រើនរឹងមាំជាបណ្តើរៗចាប់តាំងពីសង្គ្រាមស៊ីវិលបានចប់មកម្ល៉េះ។ សេដ្ឋកិច្ចបានកើនយ៉ាងឆាប់រហ័សដែលជាសេដ្ឋកិច្ចមួយដែលមានអត្រាកំណើនលឿនជាងគេនៅអាស៊ី — ទោះបីតែនៅមានមូលដ្ឋានតូចចង្អៀត គឺត្រឹមតែរោងចក្រកាត់ដេរសម្លៀកបំពាក់ ទេសចរណ៍ សំណង់ និងថ្មីៗនេះ គឺដំណាំស្រូវ។ ក្នុងវិស័យសង្គមវិញ មួយឆ្នាំៗអក្ខរកម្មបានកើនមួយភាគរយ ហើយអត្រាកុមារស្លាប់ ក៏បានធ្លាក់ចុះដែរ។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សកម្ពុជាមានលំដាប់ថ្នាក់ ១២៩ ក្នុងចំណោមប្រទេស ១៧៧ ដែលមានកម្រិតខ្ពស់ជាងប្រទេសជាច្រើននៅអនុតំបន់ សាហារា និងប្រទេសមួយចំនួននៅអាស៊ី។

ប៉ុន្តែនៅមានបញ្ហាខ្លះៗ ដូចជាភាពមិនស្មើគ្នាកាន់តែរីកធំឡើងចំពោះប្រាក់ចំណូល និងឱកាសទ្រទ្រង់ជីវភាព ព្រមទាំងភាពក្រីក្រនៅជនបទដែលមិនព្រមធូរស្រាលទាល់តែសោះ គឺជាការជាក់ស្តែងដែលមានការទទួលស្គាល់ទូលំទូលាយពីសំណាក់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផងដែរ។ នៅតាមជនបទ ស្ត្រីស្លាប់ក្នុងពេលសម្រាលកូននៅតែមានចំនួនច្រើន។ កុមារនៅតែខ្វះអាហារ ជាពិសេសកុមារនៅតាមតំបន់ខ្ពង់រាប និងជិតទន្លេសាប។ សិស្សក្រីក្របានចូលរៀន ប៉ុន្តែភាពក្រីក្របានបង្ខំឱ្យពួកគេឈប់រៀនវិញទាំងនៅវ័យក្មេង។ ជាចុងក្រោយ បញ្ហាដីធ្លីបន្តធ្វើទុក្ខបុកម្នេញដល់ជីវភាពរស់នៅរបស់ពលរដ្ឋសាមញ្ញ។ ដីបំបែកជាដុំតូចៗច្រើនពេក ភាពមិនស្មើគ្នា ភាពឥតដីធ្លី ព្រមទាំងវិវាទដីធ្លី គឺជាសក្តិកម្មខ្លះៗនៃការប្រកួតប្រជែងគ្នាលើធនធានធម្មជាតិ។ ដូច្នេះការអភិវឌ្ឍជនបទ ដែលជាវិស័យមួយត្រូវតែយកចិត្តទុកដាក់ខ្លាំង នៅមិនទាន់បានធ្វើគ្រប់គ្រាន់នៅឡើយ។

ការអភិវឌ្ឍនៅទីជនបទទាមទារឱ្យមានការយកចិត្តទុកដាក់លើផ្នែកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ។ សហគមន៍ជនបទត្រូវតែទទួលបានការសិក្សាអប់រំ និងសេវាសុខភាព ប្រាក់ចំណូលពួកគេត្រូវតែកើន ហើយគួរតែផ្តល់អំណាចឱ្យពួកគេក្នុងវិស័យនានាពាក់ព័ន្ធនឹងសង្គមនយោបាយ និងសេដ្ឋកិច្ច។

បើនិយាយថាតើប្រាកដជាត្រូវធ្វើអ្វីនោះ ការអភិវឌ្ឍជនបទទាមទារឱ្យកែទម្រង់ស្ថាប័ននានា ដើម្បីធានាឱ្យកសិករមានសិទ្ធិប្រើប្រាស់ដីធ្លី ប្រើប្រាស់ធនធានធម្មជាតិ កែទម្រង់ទីផ្សារដើម្បីបង្កើនប្រាក់ឈ្នួលកម្មករ រួមគ្នាវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងរួមគ្នាវិនិយោគលើសមត្ថភាពមនុស្ស ដើម្បីលើកកម្ពស់មុខជំនាញរបស់ពលរដ្ឋ និងគុណភាពនៃជីវិតរស់នៅរបស់ពួកគេ។ សេចក្តីស្នើនេះអនុលោមទៅតាមស្មារតីនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០ (NSDP) និងស្របតាមសកម្មភាពរិមជ្ឈការ វិសហមជ្ឈការដែលកំពុងតែបន្ត និងការបង្កើនអភិបាលកិច្ចដែលកំពុងធ្វើក្នុងប្រទេសសព្វថ្ងៃនេះ។

ក្រសួងផែនការ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជាជឿជាក់ថា របាយការណ៍នេះនឹងជួយរួមចំណែកដល់ការពិភាក្សាជាបន្តទៀតលើប្រការសំខាន់ៗជាច្រើននៃការអភិវឌ្ឍមនុស្សនៅជនបទ ហើយនិងជួយពង្រឹងដល់ការរៀបចំ និងអនុវត្តន៍គោលនយោបាយសម្រាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ ទាំងនៅទីជនបទ និងនៅទីប្រជុំជន។



**ឆាយ ថន**
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

**ដាក់គ្លីស ហ្គាដណឺ**
ប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអឹនឌីភី)
និងជាអ្នកសម្របសម្រួលសហប្រជាជាតិប្រចាំប្រទេសកម្ពុជា



# មាតិកា


| | | |
|---|---|---|
| *សេចក្តីថ្លែងអំណរគុណ* | | ១ |
| *បុព្វកថា* | | ៣ |
| *របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា ឆ្នាំ ២០០៧ : ទិដ្ឋភាពទូទៅ* | | ៦ |
| *ជំពូក ១* | | |
| **ការអភិវឌ្ឍមនុស្ស : សេចក្តីផ្តើម** | | ១៤ |
| ១.១ | របាយការណ៍នានាស្តីពីការអភិវឌ្ឍមនុស្ស | ១៤ |
| ១.២ | បញ្ហាប្រឈមមុខក្នុងវិស័យអភិវឌ្ឍន៍ និងមូលហេតុដែលនាំឱ្យរបាយការណ៍នេះបកស្រាយពីជីវភាពរស់នៅតាមទីជនបទ | ១៦ |
| ១.៣ | ទម្រង់នៃរបាយការណ៍ | ១៧ |
| *ជំពូក ២* | | |
| **វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស** | | ២០ |
| ២.១ | តារាងចំណាត់ថ្នាក់អភិវឌ្ឍន៍មនុស្សរបស់កម្ពុជា | ២០ |
| ២.២ | លទ្ធផលអភិវឌ្ឍន៍តាមរយៈសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | ៣៤ |
| ២.៣ | សេចក្តីសរុប | ៣៩ |
| *ជំពូក ៣* | | |
| **ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់គ្រប់គ្រងធនធានធម្មជាតិ ឆ្ពោះទៅរកកំណើនប្រកបដោយសមធម៌** | | ៤២ |
| ៣.១ | ស្ថានភាពដីធ្លីបច្ចុប្បន្ន | ៤២ |
| ៣.២ | ដីរបស់ជនជាតិដើមភាគតិច | ៥៤ |
| ៣.៣ | ដីសម្បទានសង្គមកិច្ច | ៥៦ |
| ៣.៤ | អភិបាលកិច្ច និងវិវាទដីធ្លី | ៥៧ |
| ៣.៥ | របរនេសាទត្រី និងជីវភាពរស់នៅ | ៥៩ |
| ៣.៦ | ព្រៃឈើ និងរបររកស៊ីព្រៃឈើ | ៦៣ |
| ៣.៧ | សេចក្តីសរុប | ៦៦ |
| *ជំពូក ៤* | | |
| **ទំនើបកម្មបច្ចេកវិទ្យា កំណែទម្រង់ទីផ្សារ និងពិពិធកម្មក្នុងវិស័យជនបទ** | | ៧០ |
| ៤.១ | ការលើកកម្ពស់ការប្រើប្រាស់ដីធ្លីឱ្យកាន់តែប្រសើរឡើង ដោយប្រើសម្ភារៈបរិក្ខារកសិកម្មទំនើប | ៧១ |
| ៤.២ | ការយកទឹកប្រើប្រាស់សម្រាប់ស្រោចស្រព | ៧៦ |
| ៤.៣ | បង្កើតឱ្យមានឥណទាន ដោយយកការប្រាក់ទាប | ៧៩ |
| ៤.៤ | ធានាលំនឹងតម្លៃលក់ | ៨១ |
| ៤.៥ | ទីផ្សារលក់ត្រី និងសត្វពាហនៈ | ៨៥ |
| ៤.៦ | សកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម | ៩១ |
| ៤.៧ | សេចក្តីសរុប | ៩៤ |
| *ជំពូក ៥* | | |
| **ការផ្តួចផ្តើមលើគម្រោងការខ្នាតធំ ដើម្បីលើកកម្ពស់ជីវភាពនៅជនបទ និងលើកកម្ពស់ការអភិវឌ្ឍមនុស្ស** | | ៩៨ |
| ៥.១ | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងរៀបចំទីប្រជុំជនប្រកបដោយតុល្យភាពតាមតំបន់ | ៩៨ |
| ៥.២ | ការបង្កើតហេដ្ឋារចនាសម្ព័ន្ធដោយប្រើបច្ចេកវិទ្យាស្រួបយកកម្លាំងពលកម្មច្រើន | ១០២ |
| ៥.៣ | ការអភិវឌ្ឍសង្គម | ១០៤ |
| ៥.៤ | ជនជាតិដើមភាគតិច | ១១០ |
| ៥.៥ | ការតាមដាន និងការវាយតម្លៃ | ១១០ |
| ៥.៦ | សេចក្តីសរុប | ១១១ |
| *ជំពូក ៦* | | |
| **ការប្រើប្រាស់ធនធានប្រេងជម្រុញការលើកកម្ពស់អភិវឌ្ឍន៍មនុស្ស** | | ១១៤ |
| ៦.១ | ពរជ័យ ឬបណ្តាសា ? | ១១៤ |
| ៦.២ | បទពិសោធន៍ក្នុងពិភពលោកស្តីពីបណ្តាសាធនធាន | ១១៥ |
| ៦.៣ | លក្ខណៈសម្បត្តិសម្រាប់សេចក្តីចម្រើនរុងរឿង | ១១៥ |
| ៦.៤ | ការធានានូវពរជ័យពីផលប្រេងជូនកម្ពុជា | ១១៦ |
| ៦.៥ | ការវិនិយោគដើម្បីសេចក្តីចម្រើនរុងរឿងទាំងអស់គ្នា និងស្ថិរភាពយូរអង្វែង | ១១៧ |
| ៦.៦ | សេចក្តីសរុប | ១១៨ |
| *ជំពូក ៧* | | |
| **អវសានកថា** | | ១២០ |
| **ឯកសារយោង** | | ១២៧ |



## លើកស្ទួយជីវភាពរស់នៅតាមជនបទដើម្បីសេចក្តីចម្រើនរុងរឿង និងសន្តិភាព

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងវិស័យមួយចំនួន ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមនុស្ស។ សន្តិភាព និងស្ថិរភាពសង្គមបានស្តារ និងរក្សាបានជាមួយនឹងកំណើនសេដ្ឋកិច្ចបានកើនឡើងក្នុងអត្រាខ្ពង់ខ្ពស់ស្មើនឹង ១១,២% ជាមធ្យមក្នុងរយៈពេល ៣ ឆ្នាំកន្លងមកនេះ។ ការរៀបចំបោះឆ្នោតពហុបក្សបានប្រព្រឹត្តទៅប្រកបដោយជោគជ័យនឹងត្រៀមរៀបចំសម្រាប់ការបោះឆ្នោតជាតិនាឆ្នាំ ២០០៨ ខាងមុខនេះ។ ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិល បាននឹងកំពុងរីកចម្រើនគួរអោយកត់សម្គាល់។ សិទ្ធិទទួលបានការអប់រំ និងសេវាសុខាភិបាលក៏ត្រូវបានកែលម្អ ភាពក្រីក្រត្រូវបានកាត់បន្ថយចុះជាលំដាប់ជាមួយនឹងវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ ឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា។ ទាំងនេះគឺជាសមិទ្ធកម្មចម្បងៗ ដែលសម្រេចបានដោយមានបញ្ហាប្រឈមមួយចំនួន ត្រូវពុះពារជំនះឱ្យបាន។

ទោះជាយ៉ាងនេះក្តី ភាពក្រីក្រ និងភាពក្បែរនឹងក្រីក្រ នៅតែមានកម្រិតខ្ពស់នៅឡើយ សូចនាករដទៃទៀតនៃការអភិវឌ្ឍមនុស្សបន្តឆ្លុះបញ្ចាំងពីលក្ខណៈរស់នៅដ៏លំបាក ជាពិសេសនៅទីជនបទដែលប្រជាជនកម្ពុជាភាគច្រើនកំពុងរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត។ កំណើនសេដ្ឋកិច្ចនៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ គឺស្ថិតនៅតែទីប្រជុំជន និងផ្តោតតែទៅលើការនាំចេញសម្លៀកបំពាក់ ដែលជាវិស័យមួយមានភាពផុយស្រួយ រួមទាំងវិស័យទេសចរណ៍ និងសន្ទុះកំណើននៃវិស័យសំណង់។ ប៉ុន្តែប្រជាជនកម្ពុជានៅតែទទួលផលពីការអភិវឌ្ឍនៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះក្នុងលក្ខណៈតិចតួចដដែល។

ដោយផ្អែកលើសមិទ្ធផលដែលទទួលបានថ្មីៗនេះ និងការទប់ស្កាត់ឱ្យបាននូវភាពអសកម្ម ត្រូវទាមទារឱ្យមានការពុះពារ ដើម្បីពង្រីកការចែករំលែកប្រភពធនធាន និងផលដែលទទួលបានពីកំណើនសេដ្ឋកិច្ចឱ្យបានទូលំទូលាយ ព្រមទាំងធ្វើឱ្យធូរស្រាលនូវហានិភ័យដែលកំពុងកើតមាន។

ដំណាក់កាលដំបូងនៃស្ថិរភាពនយោបាយ និងអត្រាខ្ពស់នៃកំណើនសេដ្ឋកិច្ចនៅតាមទីប្រជុំជន បានផ្តល់ឱកាសដ៏សំខាន់មួយសម្រាប់បង្កើនល្បឿនអនុវត្តកំណែទម្រង់ខ្លះៗ ដែលបានគ្រោងធ្វើជាយូរមកហើយ ហើយចែករំលែកឱ្យកាន់តែប្រសើរឡើងនូវការរីកចម្រើនដែលកំពុងកើនឡើងនេះ ជូនដល់អ្នកដែលមិនសូវមានភ័ព្វសំណាងចំនួនពាក់កណ្តាលនៃប្រជាជនកម្ពុជា ដែលភាគច្រើនរស់នៅតាមជនបទ។ មធ្យោបាយនេះអាចធានាឱ្យមានសន្តិភាព និងស្ថិរភាពបានយូរអង្វែង ដោយកាត់បន្ថយហានិភ័យដែលកំពុងកើនឡើងដោយសារកំណើនវិវាទដីធ្លី កំណើនយ៉ាងរហ័សនៃវិសមភាព ភាពអនាធិបតេយ្យយ៉ាងសម្បើមនៃអំពើពុករលួយ និងលទ្ធភាពដែលអាចកើតមាននូវបណ្តាសានៃធនធានធម្មជាតិ ដែលបណ្តាលមកពីចំណូលប្រេង និងឧស្ម័ននៅក្នុងសមុទ្រ។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ បានផ្តល់ផែនទីមគ្គុទ្ទេសក៏ធំទូលាយមួយឆ្ពោះទៅរកទិសដៅនេះ ដោយសង្កត់ធ្ងន់លើការពង្រឹងអភិបាលកិច្ចល្អ ការបង្កើនវិនិយោគសាធារណៈនៅទីជនបទឱ្យកាន់តែច្រើន និងការទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យឯកជនក្នុងការបង្កើតការងារ។ ក្នុងស្មារតីនេះ គុណភាពនៃការអនុវត្តមានសារៈសំខាន់ណាស់។

ដោយហេតុថា សមត្ថភាពស្ថាប័ននៅទន់ខ្សោយ ការប្រឹងប្រែងអនុវត្តដែលមានប្រសិទ្ធភាពបំផុត គឺត្រូវផ្តោតអាទិភាព និងទិសដៅច្បាស់លាស់លើវិស័យណា ដែលផ្តល់ផលខ្ពស់បំផុតសម្រាប់ធ្វើឱ្យប្រសើរឡើងដល់សុខុមាលភាពមនុស្ស សម្រេចឱ្យបាននូវការចែករំលែកវិបុលភាព និងការធានាបាននូវសន្តិភាព និងស្ថិរភាពយូរអង្វែង។

**លទ្ធផលវិភាគនៅក្នុងរបាយការណ៍នេះផ្តល់ការសន្និដ្ឋានថា ផលប្រយោជន៍ខ្ពស់បំផុតនឹងអាចទទួលបានតាមរយៈការខិតខំប្រឹងប្រែងជាទិសដៅសម្រេចឱ្យបាននូវចំណុចគន្លឹះសំខាន់ៗ ដូចខាងក្រោមនេះ :**

### ១. អភិបាលកិច្ចដីធ្លីប្រកបដោយសមធម៌ និងប្រសិទ្ធភាព

កត្តាដែលមិនអាចខ្វះបាន គឺការបង្កើតឱ្យមាននូវតម្លាភាពខ្ពស់បំផុតក្នុងការទទួលបានព័ត៌មានប្រកបដោយសមធម៌ និងការចូលរួមយ៉ាងសកម្មពីបណ្តាប្រជាជន និងសហគមន៍នៅទីជនបទលើបញ្ហាពាក់ព័ន្ធនឹងកំណែទម្រង់ដីធ្លី ដែលជះឥទ្ធិពលដល់ការរស់នៅ សុវត្ថិភាព

និងសុខុមាលភាពរបស់ប្រជាជនទាំងនោះ។ ពន្លឿនការចុះបញ្ជីដីធ្លី គឺជាតម្រូវការដ៏ចាំបាច់បំផុត ត្រូវផ្តល់ជូនចំពោះប្រជាជនដែលងាយរងគ្រោះមានជាងពាក់កណ្តាលនៃប្រជាជនកម្ពុជាសរុប ជាពិសេសគឺគ្រួសារកសិករតូចតាច។ បញ្ហាខាងលើនេះអាចដោះស្រាយបានតាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព និងសមធម៌។ កសិករតូចតាចអាចបង្កើនបានទិន្នផលស្រូវខ្ពស់លើផ្ទៃដីមួយហិចតា និងអាចទទួលបានផលតាមលក្ខណៈសេដ្ឋកិច្ចបានច្រើនលើទំហំផ្ទៃដីអប្បបរមាពី ៣ ទៅ ១០ ហិចតា។ ទន្ទឹមនឹងនេះការបង្កើនការទទួលបានដីធ្លី ដែលមានជីជាតិប្រសើរតាមរយៈសម្បទានដីធ្លីដល់ប្រជាជនដែលគ្មាន និងស្ទើរតែគ្មានដីធ្លីបង្កបង្កើនផល ក៏ជាតម្រូវការមួយដ៏ចាំបាច់ដែលត្រូវទ្រទ្រង់ដោយការកសាងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងការផ្តល់សេវាសាធារណៈជាសារវ័ន្ត។ ជាទូទៅ ការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ តឹងរ៉ឹង ប្រឆាំងនឹងការចាប់យកដីធ្លី និងការរំលោភទន្ទ្រានកាន់កាប់ដី គឺជាវិធានការណ៍ចាំបាច់។ ការបង្កើតច្បាប់លើពន្ធដីធ្លីមួយដែលមានប្រសិទ្ធភាពនឹងអាចជួយទប់ស្កាត់អ្នកកេងកម្រៃពីការទិញដីធ្លីទុក និងអាចផ្តល់ជាចំណូលបន្ថែមជូនរដ្ឋបាលមូលដ្ឋាន ក៏ដូចជារដ្ឋាភិបាលទុកធ្វើហិរញ្ញប្បទានក្នុងការបង្កើនគុណភាពសេវាសង្គមកិច្ចជាមូលដ្ឋាន។

*ម្ចាស់កសិដ្ឋានតូចៗ អាចផលិតទិន្នផលក្នុងមួយហិចតាបានខ្ពស់ជាង (កសិដ្ឋានធំៗ) ហើយអាចសម្រេចជោគជ័យក្នុងវិស័យសេដ្ឋកិច្ចលើទំហំដីអប្បបរមាពី ៣ ទៅ ១០ ហិចតា*

យោងតាមច្បាប់ភូមិបាលឆ្នាំ ២០០១ គេគួរតែមានការចុះបញ្ជីដីភូមិជូនដល់សហគមន៍ជនជាតិដើម ដែលមានទំនៀមទំលាប់រស់នៅពឹងផ្អែកទាំងស្រុងលើធនធានសមូហភាព ដូចជា ព្រៃព្រឹក្សាលតាជាតិ និងការអភិវឌ្ឍសមត្ថភាពក្នុងការគ្រប់គ្រងប្រភពធនធានទាំងនោះឱ្យមាននិរន្តរភាព។ ដោយឡែក ធនធាននេសាទសមូហភាពត្រូវបានកាន់កាប់ដោយឡូត៍នេសាទឯកជន ដែលគួរតែដាក់ជាតំបន់ឡូត៍នេសាទហាមឃាត់ ដើម្បីលើកកម្ពស់ការបង្កាត់ពូជត្រី និងធ្វើឱ្យបរិមាណត្រីកាន់តែសម្បូរបែបឡើងវិញ។

លើសពីនេះ កំណែទម្រង់ដែលផ្តោតជាសំខាន់លើប្រព័ន្ធសម្បទានដីតាមលក្ខណៈសេដ្ឋកិច្ច គឺជាតម្រូវការចាំបាច់ និងបន្ទាន់បំផុតក្នុងការលើកស្ទួយសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពសមធម៌ និងសុខុមាលភាពជាតិ។ តម្រូវការបន្ទាន់ក្នុងការបើកទូលាយ និងពិនិត្យឡើងវិញលើសម្បទានដីតាមលក្ខណៈសេដ្ឋកិច្ច ដោយហេតុថាសម្បទានដីនេះផ្តល់ផលអរិជ្ជមានលើតម្លៃបន្ថែមរបស់ដី។ ទន្ទឹមនឹងនេះសម្បទានដីតាមលក្ខណៈសេដ្ឋកិច្ច គួរត្រូវបានទុកជានិរាករណ៍លើសម្បទានណា ដែលផ្តល់ជូនដោយពុំមានចែងច្បាស់លាស់នៅក្នុងច្បាប់ ឬចំពោះសម្បទានទាំងឡាយណា ដែលមិនបានព្រមព្រៀងផ្តល់ជូនឱ្យបានត្រឹមត្រូវ។ ដូចគ្នានេះដែរ ចំពោះការផ្តល់សម្បទានដីតាមលក្ខណៈសេដ្ឋកិច្ចថ្មី គួរត្រូវផ្អាកយ៉ាងហោចណាស់រហូតដល់មានការពិនិត្យឡើងវិញលើស្ថាប័ន និងសមត្ថភាពក្នុងគ្រប់គ្រងដីសម្បទានឱ្យបានត្រឹមត្រូវ។ មធ្យោបាយបែបនេះ អាចកាត់បន្ថយហានិភ័យនៃការទន្ទ្រានកាន់កាប់ដីតាមទម្រង់សម្បទានដី តាមលក្ខណៈសេដ្ឋកិច្ចលើដីធ្លី និងធនធានសមូហភាពរបស់សហគមន៍ជនបទដែលងាយរងគ្រោះ។ ក្នុងលំនាំនេះ ការការពារប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពនឹងរារាំងដល់ការប្រើប្រាស់សម្បទានដី តាមលក្ខណៈសេដ្ឋកិច្ចធ្វើជាវិធីក្នុងការកេងកម្រៃលើដី ឬធ្វើជាវិធីបិទបាំងក្នុងការកាប់ឈើខុសច្បាប់។ ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយប្រកបដោយប្រសិទ្ធភាពនឹងជួយជំរុញការខិតខំប្រឹងប្រែងខាងលើ និងឱ្យមានច្រកចេញយ៉ាងឆាប់បំផុត។

## ២. ការបង្កើនវិនិយោគសាធារណៈប្រកបដោយចីរភាពនៅក្នុងផលិតភាពកសិកម្ម

កត្តាចម្បង គឺការទទួលបានសេវាផ្សព្វផ្សាយប្រកបដោយគុណភាព ដែលសេវាមួយចំនួនមានរួចជាស្រេចហើយនៅក្នុងប្រទេសជិតខាង និងភាពងាយស្រួលទទួលបានព័ត៌មានទាន់សភាពការណ៍អំពីទីផ្សារ ការពង្រីកប្រព័ន្ធស្រោចស្រពសំខាន់ៗ ការដំឡើងបណ្តាញអគ្គិសនីនៅទីជនបទ ការវិនិយោគលើបណ្តាញផ្លូវថ្នល់ និងការប្រើប្រាស់សេវាឥណទាន ដែលមានការប្រាក់សមរម្យ។ ទន្និផលស្រូវដែលបានកើនឡើង ត្រូវបានផ្តល់ព័ត៌មានមកថា ដោយសារការប្តូរពីការបង្កបង្កើនផលស្រូវជាលក្ខណៈប្រពៃណីទៅប្រព័ន្ធបង្កបង្កើនផលស្រូវតាមបែបប្រពលវប្បកម្ម (SRI) ដែលជាឧទាហរណ៍នៃការទាមទារឱ្យមានចំណេះកាន់តែប្រសើរ ដើម្បីអនុវត្តប្រព័ន្ធបែបនេះ។ សេវាផ្សព្វផ្សាយអាចសម្រួលដល់ការអនុវត្តបែប "ប្រព័ន្ធកសិកម្ម" ដែលមានដំណាំច្រើនយ៉ាង (រួមទាំងដំណាំផ្លែឈើហូបផ្លែ) បសុសត្វ និងការចិញ្ចឹមត្រី ត្រូវបានធ្វើឡើងជាមួយគ្នា។ ប្រព័ន្ធនេះអាចពង្រីកសកម្មភាពការងារជាច្រើនលើសពីការធ្វើស្រែស្រូវតែមួយមុខគត់។ ដូចបានបង្ហាញរួចមកហើយនៅក្នុងប្រទេសជិតខាងនានា ដូចជា ថៃ និងវៀតណាម ដែលប្រព័ន្ធកសិកម្មមានដំណើរការយ៉ាងប្រសើរសម្រាប់កសិករតូចតាច និងជួយឱ្យគ្រួសារកសិករមានជីវភាពខ្ពស់ពីខ្សែបន្ទាត់ភាពក្រីក្រ។ ដូចគ្នានេះដែរ ការលើកទឹកចិត្តចំពោះក្រុម និងសមាគមកសិករស្ម័គ្រចិត្ត អាចរួមចំណែកក្នុងការចរចាថ្លៃឱ្យបានកាន់តែប្រសើរចំពោះវត្ថុធាតុដើម និងទិន្នផលពីកសិដ្ឋាន និងអាចសម្រួលដល់ការអភិវឌ្ឍការរៀបចំកសិដ្ឋានតាមកិច្ចសន្យាលើដំណាំជ្រើសរើស។

លក្ខខណ្ឌលើការសម្រេចចិត្តធ្វើការវិនិយោគសាធារណៈ រួមមាន ប្រសិទ្ធភាពនៃថ្លៃដើម និងការអាចទទួលយកបានរបស់អ្នកប្រើប្រាស់នៅទីជនបទ។ ការធានាឱ្យមាននូវសមត្ថភាពសមស្របនៃថ្នាក់មូលដ្ឋានសម្រាប់ប្រតិបត្តិការ ការថែរក្សា និងការធ្វើឱ្យមានចីរភាព គឺជាកត្តាសំខាន់បំផុត។

## ៣. ការបើកទូលាយ និងពង្រីកប្រភពបង្កើតការងារសម្រាប់កំណើនទាំងនៅតំបន់ជនបទ និងទីប្រជុំជន

ដើម្បីធានាសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងមូល និងអនាគតនៃជីវភាពរស់នៅរបស់ពួកគេ ឫសគល់នៃការចំណាយថ្លៃដើមខ្ពស់មិនចាំបាច់ក្នុងសេដ្ឋកិច្ចកម្ពុជា ត្រូវតែដកចេញឱ្យផុតទាំងស្រុងពីតម្លៃហួសហេតុសម្រាប់ការដឹកជញ្ជូន សេវាកម្មកំពង់ផែ ថាមពល និងសេវាកម្មអាជីវកម្មសំខាន់ៗផ្សេងទៀត។ ថ្លៃដើមក្រៅផ្លូវការទាំងនេះនឹងសង្កត់កតែលើប្រជាជនក្រីក្រខ្លាំងបំផុត។ ឧទាហរណ៍យ៉ាងជាក់ច្បាស់មួយ គឺតាមការអង្កេតស្រាវជ្រាវប្រៀបធៀបរវាងតំបន់ជុំវិញបឹងទន្លេសាប និងទីផ្សារក្នុងប្រទេសថៃ ដែលអ្នកនាំចេញផលនេសាទទទួលបានផលចំណេញ ២៨ ដងលើសអ្នកនេសាទ។ នេះបង្ហាញឱ្យឃើញថា អ្នកនេសាទទទួលបានផលត្រឹមតែ ២៥ ទៅ ៣៥ ភាគរយ នៃថ្លៃលក់ឱ្យអ្នកប្រើប្រាស់។

ការបង្កើនគុណភាពនៃការគ្រប់គ្រងសេដ្ឋកិច្ចប្រកបដោយចីរភាព រួមមាន ការកាត់បន្ថយអំពើពុករលួយ និងការលុបបំបាត់ឱ្យបាននូវចំណាយក្រៅផ្លូវការ ដែលចាំបាច់បំផុតសម្រាប់បន្ទាបចំណាយថ្លៃដើម និងលើកទឹកចិត្តការវិនិយោគនៃវិស័យឯកជននៅក្នុងការពង្រីកវិស័យកសិកម្ម ដំណាំសម្រាប់ពាណិជ្ជកម្ម កសិឧស្សាហកម្ម និងការបង្កើតចំណូលពីសកម្មភាពក្រៅពីកសិកម្ម និងការបង្កើតការងារនៅក្នុងវិស័យកម្មន្តសាល។ កម្មវត្ថុសំខាន់ និងបន្ទាន់បំផុតនោះ គឺត្រូវធានាថា ចំណាយថ្លៃដើម និងថ្លៃសម្រាប់សេវាកម្មខាងលើនេះយ៉ាងហោចណាស់អាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន។ ជាថ្មីម្តងទៀត ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយប្រកបដោយប្រសិទ្ធភាពនឹងជួយជំរុញការខិតខំប្រឹងប្រែងខាងលើ និងច្រកចេញយ៉ាងឆាប់បំផុតសម្រាប់ទ្រទ្រង់បរិស្ថានសម្រាប់ការវិនិយោគឯកជននៅក្នុងការបង្កើតការងារ។

## ៤. ការវិនិយោគប្រកបដោយចីរភាពនៅក្នុងការកសាងសមត្ថភាពមនុស្ស

កំណើននៃអត្រាអក្ខរកម្ម និងការចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ថ្នាក់បឋមសិក្សានិងមធ្យមសិក្សា គឺជាកត្តាអាទិភាពក្នុងការពង្រីកសមត្ថភាពប្រកួតឈ្នះសេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក។ ការលើកទឹកចិត្តឱ្យសិស្សបន្តការសិក្សាមានជាអាទិ៍ កម្មវិធីផ្តល់របបអាហារនៅសាលា និងការជំរុញលើកទឹកចិត្តគ្រូបង្រៀនដោយការផ្តល់ប្រាក់បៀវត្សរ៍សមរម្យ និងការវិនិយោគលើមធ្យោបាយធ្វើឱ្យមានភាពងាយស្រួលនៅតាមសាលារៀនឱ្យបានសមស្រប រួមមាន ទឹក និងអនាម័យ ដែលជាកត្តាទ្រទ្រង់ដល់ការប្រឹងប្រែងខាងលើនេះ។ ការផ្សារភ្ជាប់ការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍជំនាញផ្នែកអាជីវកម្មក៏ជាកត្តាចាំបាច់។ ការអភិវឌ្ឍសកលវិទ្យាល័យផ្នែកជលវិទ្យា និងប្រព័ន្ធធារាសាស្ត្រ និងវគ្គបណ្តុះបណ្តាលជាមូលដ្ឋាននៅថ្នាក់ខេត្តនឹងជាជំនួយបង្គ្រប់ដល់ជំនាញដែលខ្វះខាតក្នុងការគ្រប់គ្រងធនធានទឹក។ ការអាចស្វះស្វែងរកបាន និងប្រសិទ្ធភាពលើសេវាសុខាភិបាលមានតម្លៃសំខាន់បំផុតសម្រាប់សុខុមាលភាព និងផលិតភាពនៃកម្លាំងពលកម្មនៅទីជនបទ។ វិធីសាស្ត្រតម្លៃទាបនានា ដើម្បីទទួលបានទឹកស្អាត ដូចជា តាមរយៈការប្រើប្រាស់កាំរស្មីអ៊ុលត្រាវីយ៉ូលេនៃពន្លឺព្រះអាទិត្យត្រូវបានរកឃើញ ហើយនិងត្រូវផ្សព្វផ្សាយឱ្យមានការនិយមប្រើប្រាស់ឱ្យបានទូលំទូលាយ។

## ៥. ការធានាឱ្យបានពរជ័យពីប្រេង និងឧស្ម័ន

ការចៀសឱ្យផុតពីបណ្តាសាធនធានពីចំណូលបានមកពីប្រេង និងឧស្ម័ននាពេលអនាគត និងការធានាឱ្យបានការទទួលពរជ័យ នឹងគ្មានមធ្យោបាយដោយស្វ័យប្រវត្តិណាមួយក្រៅពីការរៀបចំផែនការ និងការត្រៀមទុកជាស្រេចនូវការគាំពារផ្នែកស្ថាប័ន ដើម្បីធានាឱ្យមានតម្លាភាព និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការវិនិយោគលើប្រភពចំណូលដែលបានមកនេះ។

តម្រូវការជាបន្ទាន់ក្នុងការរៀបចំផែនការគ្រប់គ្រងតាមបែបស្ថាប័ន ដើម្បីទប់ទល់នឹងបណ្តាសាធនធានកើតចេញមកពីប្រេង និងឧស្ម័នក្នុងសមុទ្រ។ តម្រូវការការពារទាំងនោះ រួមមាន ច្បាប់គ្រប់គ្រងចំណូល និងការគ្រោងរៀបចំឱ្យបានត្រឹមត្រូវ ប្រកបដោយតម្លាភាពសម្រាប់មូលនិធិប្រេង ដែលរួមមានគ្រប់ចំណូលទាក់ទងនឹងប្រេង (ប្រាក់កក់ចុះហត្ថលេខា សួយសារអាករ ការចែករំលែកផលិតកម្ម និងភាគលាភ) នឹងត្រូវបម្រុងទុកមុន និងទុកជាប្រាក់ចំណាយជាថវិកាដោយអនុលោមតាម NSDP និងអត្រាសនិទានកម្មវិនិយោគ។ ម្យ៉ាងទៀត កម្ចីដោយសម្អាងលើចំណូលដែលបានមកពីប្រេងនិងឧស្ម័នមិនច្បាស់លាស់បង្ហាញថា មានសភាពគ្រោះថ្នាក់បំផុតចំពោះស្ថិរភាពផ្នែកហិរញ្ញវត្ថុចំពោះប្រទេសកំពុងអភិវឌ្ឍនាំប្រេងចេញ និងអាចត្រូវការវិធានការណ៍ការពារ។ លទ្ធផលដំបូងនៃគំរូសំណាកផ្នែកបរិមាណបង្ហាញឱ្យឃើញថា ការវិនិយោគក្នុងបរិមាណភាគហ៊ុនច្រើននៃចំណូលប្រេង និងឧស្ម័ននានាពេលអនាគតលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងមូលធនមនុស្សនឹងផ្តល់ទិន្នផលក្នុងអត្រាខ្ពស់ក្នុងការធានាប្រកបដោយចីរភាពនៃកំណើនសេដ្ឋកិច្ច ពិពិធកម្ម ការអភិវឌ្ឍមនុស្ស និងសុខសន្តិភាព និងស្ថិរភាពយូរអង្វែង។

## *លទ្ធផលដែលទទួលបាននាពេលថ្មីៗនេះ*

កម្ពុជាត្រូវបានកត់ត្រាទុកថា ទទួលបានលទ្ធផលគួរជាទីមោទននៅប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេស គឺការធូរស្រាលពីបញ្ហាប្រឈមនានាដែលកើតមាននៅទសវត្សរ៍កន្លងទៅ។ ជាពិសេស សន្តិភាព និងស្ថិរភាពត្រូវបានស្តារឡើងវិញ ដែលនាំមកនូវកំណើនសុខសុវត្ថិភាពសម្រាប់ប្រជាជន។ សមិទ្ធផលនេះ រួមផ្សំនឹងកម្លាំងសេដ្ឋកិច្ចដ៏រឹងមាំនៅក្នុងតំបន់និងពិភពលោក បាននាំឱ្យមានកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុងពេល ១០ ឆ្នាំកន្លងមកនេះ។

ទោះបីជាមានគំនិតទុទិដ្ឋិនិយមលើការនាំចេញផ្នែកសម្លៀកបំពាក់បន្ទាប់ពីកិច្ចព្រមព្រៀងលើ Multi-Fibre Agreement ត្រូវបានបញ្ចប់ ប៉ុន្តែការនាំចេញនេះ ត្រូវបានរក្សាក្នុងជំហរវិជ្ជមានដដែលសម្រាប់កំណើនរយៈពេលខ្លី និងបង្កើតការងារ និងចំណូលដែលរកបានដោយពលការិនីមកពីទីជនបទ។ ចំនួនភ្ញៀវទេសចរបរទេសមកដល់ប្រទេសកម្ពុជាបានកើនឡើង ២៥ ភាគរយក្នុងមួយឆ្នាំ និងកើនឡើងដល់ ២ លាននាក់ នៅឆ្នាំ ២០០៧។ សន្ទុះកំណើននៃវិស័យឧស្សាហកម្មសំណង់ និងប្រជាជនដែលសំណាងបានកាន់កាប់ដីធ្លីនៅតំបន់អភិវឌ្ឍ ពេញចិត្តនឹងទទួលបាននូវផលចំណេញជាទ្រព្យសម្បត្តិឯកជនរបស់ពួកគេ។ វិស័យកសិកម្មក៏បានបង្ហាញនូវសក្តានុពលខ្ពស់ផងដែរ ដោយសារអំណោយផលនៃអាកាសធាតុ និងការផ្តួចផ្តើមវិនិយោគលើប្រព័ន្ធធារាសាស្ត្រ។ ក្នុងក្របខ័ណ្ឌនយោបាយ ប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាពយ៉ាងពេញលេញ ហើយបានបញ្ចប់ការបោះឆ្នោត ឃុំ-សង្កាត់ លើកទី ២ នៅដើមឆ្នាំ ២០០៧ និងត្រៀមរៀបចំសម្រាប់ការបោះឆ្នោតជាតិអាណត្តិទី ៣ នៅទូទាំងប្រទេសនាឆ្នាំ ២០០៨ ខាងមុខនេះ។

ប្រការដែលសំខាន់នោះ គឺភាពក្រីក្របានបន្តធ្លាក់ចុះជាលំដាប់នៅក្នុងកម្រិតថេរស្មើនឹង ១ ភាគរយក្នុងមួយឆ្នាំ។ អត្រាមរណទារក និងកុមារ ទោះបីជាមានកម្រិតខ្ពស់នៅឡើយ តែបានថយចុះដល់ ៦៦ និង ៨៣ ក្នុងកំណើតរស់ ១០០០ នាក់។ អត្រាចុះឈ្មោះចូលរៀនពិតនៅថ្នាក់បឋមសិក្សាបានកើនឡើងគួរឱ្យកត់សម្គាល់ដល់ ៧៦ ភាគរយ។ អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យក៏បានកើនឡើងដល់ទៅ ៧៤ ភាគរយផងដែរ ហើយគម្លាតយេនឌ័រលើផ្នែកអក្ខរកម្មត្រូវបានកាត់បន្ថយ។ អាហារូបត្ថម្ភកុមារ ត្រូវបានធ្វើឱ្យប្រសើរឡើង។ មេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័ស។ សមិទ្ធផលទាំងនេះ និងសមិទ្ធផលដទៃទៀត ត្រូវបានរួមចំណែកដោយកំណើនខ្ពស់មធ្យមសម្រាប់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ក្នុងប្រទេស ដែលនាំឱ្យកម្ពុជាស្ថិតនៅក្នុងលំដាប់ទី ១២៩ ក្នុងចំណោម ១៧៧ ប្រទេស។

## *ទោះបីទទួលបានសមិទ្ធផលជាច្រើនក៏ដោយ ក៏កំណើនត្រូវរាប់បញ្ចូលប្រជាជននៅទីជនបទផងដែរ...*

គម្លាតខុសគ្នាមាននៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរវាងទីជនបទ និងទីប្រជុំជន ជាពិសេស នៅតំបន់ជនបទដាច់ស្រយាល។ ប្រជាជនប្រមាណជា ១ ភាគ ៣ រស់នៅក្រោមបន្ទាត់ភាពក្រីក្រមាន ៩០ ភាគរយ រស់នៅ និងប្រកបរបរចិញ្ចឹមជីវិតនៅទីជនបទ ជាពិសេស នៅតំបន់ភ្នំនិងខ្ពង់រាប តំបន់ទំនាបជនបទ និងតំបន់ជុំវិញបឹងទន្លេសាប។ បញ្ហាគួរឱ្យកង្វល់បំផុតនោះ គឺគម្លាតនៃជីវភាពរស់នៅរវាងប្រជាជនក្រីក្រដ៏ច្រើននៅទីជនបទ និងអ្នកមាននៅទីប្រជុំជនបានរីកឡើងយ៉ាងឆាប់រហ័ស ដូចគ្នានឹងគម្លាតរវាងអ្នកក្រនៅទីជនបទ និងអ្នកមានមួយចំនួននៅទីជនបទដែរ។

ប្រជាជន ២០ ភាគរយនៃប្រទេសស្ថិតនៅក្នុងស្ថានភាពក្រីក្រ ដោយខ្វះអាហារបរិភោគ និងមិនបានទទួលនូវកម្រិតអប្បបរមា ២១០០ កាឡូរី ក្នុង ១ ថ្ងៃ ដើម្បីបង្គ្រប់តម្រូវការអាហារូបត្ថម្ភមូលដ្ឋានប្រចាំថ្ងៃ។ កត្តាគ្រោះថ្នាក់មួយទៀត ដែលនាំឱ្យប្រជាជនដែលរស់នៅលើបន្ទាត់ភាពក្រីក្រនៅតែមានភាពងាយរងគ្រោះនោះ គឺអំណោយផលមិនល្អនៃអាកាសធាតុ សុខភាពមិនល្អ និងហានិភ័យដទៃទៀត។ ជម្ងឺគ្រុនចាញ់ គ្រុនឈាម រាករូស និងជម្ងឺបង្កឡើងដោយទឹកនានាបានរាតត្បាតឥតឈប់ឈរ នាំឱ្យកុមារជាង ៣០.០០០ នាក់ ស្លាប់ដោយសារជម្ងឺដែលអាចទប់ស្កាត់បានទាំងនេះ។ ការទទួលបានទឹកសម្រាប់ទទួលទានមានប្រមាណតែ ៤០ ភាគរយប៉ុណ្ណោះ នៅទីជនបទ និងអ្វីដែលគួរឱ្យបារម្ភបំផុតនោះ គឺមានពាក់កណ្តាលនៃប្រជាជនក្រីក្របំផុតទទួលបានតិចជាង ១០ ភាគរយនៃទឹកសម្រាប់ទទួលទាន។

អត្រាមរណមាតានៅតំបន់ជនបទនៅតែមានកម្រិតខ្ពស់នៅឡើយ ដែលមានជាង ៤៥០ លើ ១០០.០០០ កំណើតរស់។ ស្ត្រីនៅទីជនបទបន្តការអនុវត្តការងារប្រចាំគ្រួសារក្នុងចំណែកខ្ពស់ ហើយការសិក្សាបានបង្ហាញឱ្យឃើញថា អំពើហិង្សានៅតែបន្តគំរាមកំហែងដល់ស្ត្រី និងកុមារដដែល។ សន្ទស្សន៍នៃការផ្តល់សិទ្ធិអំណាចស្ត្រី នៅមានកម្រិតទាប ដោយចំណែកស្ត្រីនៅក្នុងអសនៈនយោបាយ និងឋានៈនៃការសម្រេចចិត្តក្នុងវិស័យសាធារណៈ។

ខណៈដែលអត្រាចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាបានកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ អត្រារៀនចប់ថ្នាក់សិក្សា បែរជាស្ថិតនៅក្នុងកម្រិតទាបគួរឱ្យបារម្ភបំផុត។ កុមារតិចជាង ៥០ ភាគរយ ដែលបានចុះឈ្មោះបានរៀនចប់ថ្នាក់ទី ៦ ដែលបញ្ជាក់អំពីកម្លាំងពលកម្មគ្មានការអប់រំសម្រាប់អនាគតកាល ដែលចំណេះដឹងជាមូលដ្ឋានមិនអាចប្រកួតប្រជែងបាននៅក្នុងតំបន់ និងសេដ្ឋកិច្ចពិភពលោក។

*ក្នុងចំណោម ១ ភាគ ៣ នៃ ពលរដ្ឋកម្ពុជា ដែលរស់ក្រោម បន្ទាត់នៃភាពក្រីក្រ ៩០ភាគរយរស់នៅ និងធ្វើការនៅជនបទ... កត្តាដែលគួរឱ្យបារម្ភបំផុតនោះ គឺគម្លាត... រវាងអ្នកក្រនៅតាមជនបទ និងវរជននៅទីក្រុង បានឃ្លាតពីគ្នាកាន់តែធំឡើងយ៉ាងរហ័ស*

*នៅពីក្រោមផ្ទៃនៃអត្រាកំណើនខ្ពង់ខ្ពស់នេះ មានសក្តានុពលនៃអតុល្យភាពធ្ងន់ធ្ងរ និងបញ្ហាមួយចំនួនកំពុងប្រឈមទៅនឹងសមិទ្ធកម្មថ្មីៗកន្លងមក*

បច្ចុប្បន្ននេះស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចនៅតំបន់ជនបទផ្តល់នូវពេលវេលាដ៏ល្អប្រសើរសម្រាប់អនុវត្តកម្មវិធីកំណែទម្រង់ ដើម្បីចែករំលែកវិបុលភាពដល់ប្រជាជនដែលគ្មានភ័ព្វជាងពាក់កណ្តាលរស់នៅទីជនបទ។ អត្ថប្រយោជន៍ជាច្រើននៃការអនុវត្តគោលនយោបាយរួមមាន សន្តិភាព និងស្ថិរភាព តាមរយៈការកាត់បន្ថយសម្ពាធពីដីធ្លី វិសមភាព ការគ្រប់គ្រងមិនចំទិសរបស់រដ្ឋាភិបាល និងសក្តានុពលភាពនៃបណ្តាសាធនធានបណ្តាលមកពីចំណូលបានមកពីប្រេង និងឧស្ម័ននាពេលអនាគត។ ដោយឡែក ការចាប់យកដីធ្លី និងការទន្ទ្រានយកដីដោយអ្នកមានអំណាចសម្រាប់ធ្វើពាណិជ្ជកម្ម បានបង្កើននូវភាពមិនប្រាកដប្រជា និងអសុវត្ថិភាពសម្រាប់ប្រជាជនក្រីក្រនៅទីជនបទ។

## *ការវិនិយោគនៅទីជនបទមានការយឺតយ៉ាវ...*

ដោយមូលហេតុជាច្រើន ដែលការវិនិយោគនៅវិស័យសាធារណៈ ដើម្បីទ្រទ្រង់ដល់ផលិតភាពកសិកម្ម និងវិស័យពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធជនបទមានភាពអសកម្មនៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ជាលទ្ធផល ផលិតភាព និងចំណូលនៅជនបទមានកម្រិតទាប ហើយភាពក្រីក្រមានកម្រិតខ្ពស់។ ជាពិសេស ការវិភាគផ្នែកស្ថិតិបានបង្ហាញឱ្យឃើញច្បាស់អំពីសហសម្ព័ន្ធរវាងទិន្នផលស្រូវទាប និងការកើតឡើងខ្ពស់នៃភាពក្រីក្រនៅក្នុងគ្រួសារកសិករតូចតាច។

សេវាផ្សព្វផ្សាយជាសាធារណៈបានទៅដល់គ្រួសារកសិករតិចជាង ១០ ភាគរយ។ ចំណែកនៃដីធ្លីអាចបង្កបង្កើនផលបាន និងដីធ្លីគ្របដណ្តប់ដោយប្រព័ន្ធធារាសាស្ត្រមានកម្រិតទាបបំផុតត្រឹមតែ ៧ ភាគរយ ដែលនាំឱ្យទិន្នផលស្រូវនៅកម្ពុជាផ្តល់ផលតិចជាងពាក់កណ្តាលនៃទិន្នផលស្រូវនៃប្រទេសវៀតណាម ដែលមានផ្ទៃដីបង្កបង្កើនផលបាន ៤៥ ភាគរយ មានប្រព័ន្ធធារាសាស្ត្រ។ លទ្ធភាពនៃការប្រើប្រាស់អគ្គិសនីនៅតំបន់ជនបទមានកម្រិតទាបបំផុតប្រមាណ ១០ ភាគរយ ដែលជាឧបសគ្គរាំងស្ទះដល់ផលិតភាព និងការអភិវឌ្ឍមនុស្ស។

ទំនាក់ទំនងនៃអតីតកាល និងអនាគតទៅនឹងប្រភពនៃកំណើនខ្ពស់នៅតំបន់ទីប្រជុំជនមានកម្រិតខ្សោយនៅឡើយ។ ខណៈដែលចំនួនភ្ញៀវទេសចរបានកើនឡើងចំនួន ២៥ ភាគរយក្នុងមួយឆ្នាំ និងបង្កើតការងារដោយផ្ទាល់នៅក្នុងវិស័យសំណង់ សណ្ឋាគារ និងឧស្សាហកម្ម ទេសចរណ៍ ទំនាក់ទំនងខាងដើមទៅនឹងតំបន់ជនបទ ដែលហ៊ុំព័ទ្ធទៅដោយការស្រូបទាក់ទាញទេសចរយ៉ាងសំខាន់ ត្រូវតែបានអភិវឌ្ឍឡើង។ គួរឱ្យកត់សម្គាល់ ខេត្តសៀមរាប ទីប្រជុំជនអង្គរនៅតែជាខេត្តមួយ ដែលក្រីក្របំផុតនៅកម្ពុជា។

ទោះបីការនាំចេញសម្លៀកបំពាក់មានការកើនឡើង និងបានផ្តល់កំណើនការងារច្រើនដល់ស្ត្រីជាង ៣០០.០០០ នាក់ មកពីទីជនបទ តែចំនួននេះនៅតែបង្ហាញអំពីចំណែកនៃកម្លាំងពលកម្មដែលផ្តល់ប្រាក់កម្រៃតិចតួច។ ខណៈដែលកម្មការិនីកាត់ដេរសម្លៀកបំពាក់ទាំងនេះផ្ញើចំណែកនៃប្រាក់កម្រៃរបស់ពួកគេទៅឱ្យក្រុមគ្រួសារនៅទីជនបទនេះ ក៏បង្ហាញឱ្យឃើញពីចំណូលដ៏ស្តួចស្តើងសម្រាប់គ្រួសារនៅតំបន់ជនបទផងដែរ។ ជាទូទៅ មានគ្រួសារជនបទតែ ១៣ ភាគរយប៉ុណ្ណោះ ដែលទទួលបានប្រាក់បញ្ញើពីសាច់ញាតិដែលធ្វើការនៅទីប្រជុំជន ហើយប្រាក់បញ្ញើនេះមានចំណែកតិចជាង ១០ ភាគរយនៃចំណូលគ្រួសារទទួលបាននោះ។

ដូច្នេះភាពជឿនលឿននៃការអភិវឌ្ឍនៅជនបទ ទាមទារឱ្យមានការវិនិយោគសាធារណៈក្នុងទ្រង់ទ្រាយធំ ដើម្បីបង្កើនផលិតភាពកសិកម្ម និងពិពិធកម្មតាមរយៈការពង្រីកការទទួលបានសេវាសាធារណៈ ការពង្រឹងសម្ព័ន្ធសេដ្ឋកិច្ច និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធឱ្យបានច្រើនបំផុត ដូចជា ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព និងបណ្តាញចែកចាយអគ្គិសនី។ ការផ្លាស់ប្តូរទាំងនេះ ត្រូវការជាបន្ទាន់សម្រាប់កំណើនដ៏ឆាប់រហ័សនៃចំនួនយុវជន ដែលកំពុងក្លាយជាកម្លាំងពលកម្ម និងកាលានុវត្តភាពការងារដែលមានកំណត់។

## *បញ្ហាប្រឈម និងហានិភ័យដែលកំពុងកើតមានឡើង និងទម្រង់ថ្មីនៃអសន្តិសុខ...*

ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពង់ខ្ពស់ អតុល្យភាពដ៏គួរឱ្យភ័យខ្លាច និងបញ្ហាប្រឈមជាច្រើនក៏បាននឹងកំពុងកើតឡើងផងដែរ។ ទាំងនេះទាមទារឱ្យមានវិធានការណ៍ជាបន្ទាន់ក្នុងការពង្រឹង និងកសាងដោយឈរលើផលចំណេញពីពេលមុន និងការធានាស្ថិរភាពសេដ្ឋកិច្ចសង្គមឱ្យកាន់តែប្រសើរ និងយូរអង្វែង។ ទិន្នន័យដែលដកស្រង់បានបង្ហាញឱ្យឃើញថា ការប្រើប្រាស់ ចំណូល និងទ្រព្យសម្បត្តិត្រូវបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងនាដំណាក់កាលដំបូងនៃសម័យអន្តរកាលរបស់កម្ពុជាក្នុងដំណើរឆ្លងកាត់ពីសង្គមមួយ ដែលធ្លាក់ក្នុងអន្លង់នៃភាពក្រីក្រ និងពឹងផ្អែកតែតាមរយៈការធ្វើកសិកម្មជាមូលដ្ឋាន ទៅជាទទួលបាននូវវិបុលភាពជាទីប្រជុំជនមួយ ដែលមានលក្ខណៈបើកទូលាយ និងមានមនុស្សថ្នាក់កណ្តាលច្រើន។ ដោយហេតុថា ប្រទេសកម្ពុជាមានចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗនៅទាប មេគុណ Gini នៃការប្រើប្រាស់មានកម្រិតខ្ពស់រួចស្រេចទៅហើយ គឺស្មើនឹង ០,៤២។ ការប្រើប្រាស់ពិតសម្រាប់មនុស្សម្នាក់ៗនៃប្រជាជនក្រីក្របំផុត ១ ភាគ ៥ បានកើនឡើងត្រឹមតែ ៨ ភាគរយប៉ុណ្ណោះ នៅទសវត្សរ៍កន្លងទៅនៅពេលដែលអ្នកមានបំផុត ១ ភាគ ៥ នៃប្រជាជនសរុបបានកើនឡើងរហូតដល់ ៤៥ ភាគរយ។

*ការធ្វើសេរីភាវូបនីយកម្មទីផ្សារដីធ្លីយ៉ាងតក់ក្រហល់ ... ដោយពុំមានយន្តការការពារគ្រប់គ្រាន់ ... បានធ្វើឱ្យសមាជិកសង្គមដែលទន់ខ្សោយ និងមិនសូវយល់ដឹង ងាយរងគ្រោះជាខ្លាំង*

ក្តីបារម្ភបែបនេះមានកាន់តែខ្ពស់ឡើង ដោយសារការប្រមូលផ្តុំនៃការកាន់កាប់ដីធ្លី ដែលនៅតែជាទម្រង់មួយដ៏សំខាន់នៃការសន្សំតាមបែបគ្រួសារ និងជាប្រភពសេដ្ឋកិច្ច និងសុវត្ថិភាពសង្គមនៅកម្ពុជា។ ដោយគ្មានវិធានការណ៍ដោយផ្ទាល់ ឬប្រយោលណាមួយ ការប្រមូលផ្តុំដីធ្លីនេះ នឹងបង្កើតឡើងដោយស្វ័យប្រវត្តិនូវគម្លាតកាន់តែធំឡើងជាចំណូលទ្រព្យសម្បត្តិ និងឱកាសនាថ្ងៃអនាគត។ ទិន្នន័យដែលទទួលបានបង្ហាញថា អ្នកមានបំផុត ១ ភាគ ៥ នៃប្រជាជនសរុបបានកាន់កាប់ដីធ្លី រហូតដល់ ៧០ ភាគរយនៃផ្ទៃដីសរុប។ លើសពីនេះ ជម្លោះដីធ្លីតែងតែកើតមានដោយសារតែការចាប់យកដីធ្វើជាកម្មសិទ្ធិ និងការទន្ទ្រានយកដីសម្បទានសេដ្ឋកិច្ច ដែលភាគច្រើនធ្វើឡើងដោយអ្នកមានអំណាច ហើយកេងកម្រៃលើដីធ្លី និងជាអ្នកដែលអាចបណ្តេញឱ្យអ្នកទន់ខ្សោយ និងប្រជាជនជនបទដែលពុំបានទទួលព័ត៌មានច្បាស់លាស់បង្ខំចិត្តចាកចេញពីដីរបស់ខ្លួន។

ប្រសិនបើពិនិត្យមើលមកក្រោយវិញ ការធ្វើសេរីភាវូបនីយកម្មទីផ្សារដីធ្លីពីឆ្នាំ ១៩៨៩ មក ដោយគ្មានការត្រៀមរៀបចំបង្កើតស្ថាប័នគ្រប់គ្រងឱ្យបានត្រឹមត្រូវ គ្មានច្បាប់ និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព បានបណ្តោយឱ្យអ្នកទន់ខ្សោយ និងប្រជាជនជនបទដែលពុំបានទទួលព័ត៌មានច្បាស់លាស់នៅក្នុងសង្គមមានភាពងាយរងគ្រោះកាន់តែខ្លាំងឡើង និងនាំឱ្យមានកម្លាំងទីផ្សារ ដែលមិនអាចគ្រប់គ្រងឱ្យរៀបរយបាន និងព័ត៌មានដែលមិនបានផ្សព្វផ្សាយឱ្យបានទូលំទូលាយប្រកបដោយសមធម៌ បានផ្តល់ឱកាសល្អសម្រាប់អ្នកដែលទទួលបានព័ត៌មានច្បាស់ការណ៍ មានឥទ្ធិពល និងអំណាច។ ភាពគ្មានដីធ្លីក្នុងចំណោមគ្រួសារជនបទបានកើនឡើងដល់ទៅ ២០ ភាគរយ និងអាចកើនឡើងបន្ថែមទៀតក្នុងអត្រា ២ ភាគរយក្នុងមួយឆ្នាំៗ។ ជាងនេះទៅទៀត គ្រួសារភាគច្រើនចំនួន ៨០ ភាគរយ ដែលកាន់កាប់ដីធ្លីដែលពុំមានការចុះបញ្ជីត្រឹមត្រូវ នាំឱ្យពួកគេងាយរងគ្រោះដោយសារការចាប់ដីធ្លី និងការទន្ទ្រានយកដីដូចដែលបានរៀបរាប់ពីខាងលើ។

ការប្រើប្រាស់ប្រភពធនធានសមូហភាព ដូចជា ត្រី និងព្រៃឈើ ដែលផ្តល់ដែនសុវត្ថិភាព និងការធានាតាមបែបប្រពៃណីសម្រាប់ប្រជាជនក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រ ដើម្បីទប់ស្កាត់បច្ច័យអវិជ្ជមាន ដូចជា ធាតុអាកាសមិនអំណោយផល និងការទទួលទិន្នផលតិចដែលកំពុងតែត្រូវបានកាត់បន្ថយដោយសារការទន្ទ្រានកាន់កាប់ដីធ្លី និងការទាញយកផលហួសហេតុពីព្រៃឈើ។ ជាការពិតណាស់ ដែលបណ្តាខេត្តនៅភាគឦសានមានប្រជាជនជាតិដើម នៅមិនទាន់ទទួលបានប្លង់ដីសហគមន៍លើដីប្រពៃណីរបស់ពួកគេនៅឡើយ ថ្វីត្បិតតែមានច្បាប់ភូមិបាលតាំងពី ២០០១ មកម្ល៉េះនោះ។ ទិន្នន័យដែលទទួលបានបង្ហាញថា ក្រុមជនជាតិដើមភាគតិចបានបាត់បង់ផ្ទៃដីប្រពៃណីរបស់ពួកគេអស់ ៣០ ភាគរយរួចទៅហើយ ហើយភាពក្រីក្របានកើនឡើងពី ៤០ ភាគរយ ទៅ ៥៨ ភាគរយ នៅតាមខេត្តនៅតំបន់ភ្នំ និងខ្ពង់រាប ដែលជាតំបន់តែមួយគត់នៅក្នុងផ្ទៃប្រទេស ដែលភាពក្រីក្រនៅតែកើនឡើងក្នុងទសវត្សរ៍កន្លងទៅនេះ។

ភាពគ្មានដីធ្លី និងការស្វែងរកជីវភាពរស់នៅថ្មី បានបង្កើតជាសម្ពាធលើប្រភពធនធានមច្ឆជាតិ ដូចជាបឹងទន្លេសាប។ ជាលទ្ធផល ភាពងាយរងគ្រោះ និងអសុវត្ថិភាពនៃសេដ្ឋកិច្ចចំពោះគ្រួសារនេសាទក្រីក្របំផុតបានកើនឡើងជាលំដាប់។ ខណៈដែលរដ្ឋាភិបាលបានសម្រេចលុបចោលឡូត៍អាជីវកម្មជាងពាក់កណ្តាលនៅឆ្នាំ ២០០១ តាមរបាយការណ៍វិភាគឃើញថា ឡូត៍នេសាទនេះផ្តល់នូវផលិតភាពបានត្រឹមតែជិតពាក់កណ្តាល និងបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រក្នុងកម្រិតស្តួចស្តើងប៉ុណ្ណោះ។

កម្រិតម៉ាក្រូសេដ្ឋកិច្ច អត្រាកំណើនពុំមានមូលដ្ឋានទូលាយ ដែលផលកំណើនសេដ្ឋកិច្ចនៅតែមានភាពងាយគ្រោះថ្នាក់នៅឡើយ ក្នុងការទប់ស្កាត់ចំពោះភាពអសកម្ម ដែលបង្កឡើងដោយកត្តាខាងក្រៅនានា ដូចជា ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក/តំបន់ ការបញ្ចប់វិធានការណ៍ការពាររបស់សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ចំពោះការនាំចេញសម្លៀកបំពាក់ពីប្រទេសចិន ដែលនឹងផុតកំណត់នៅឆ្នាំ ២០០៨ កំណើននៃសមត្ថភាពប្រជែងពីប្រទេសវៀតណាម ក្រោយពីបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ឬអាចជាការរាតត្បាតរបស់មេរោគផ្តាសាយបក្សី H5N1 ដែលអាចនឹងជះឥទ្ធិពលមិនល្អដល់វិស័យសុខភាព ទេសចរណ៍ រួមទាំងវិនិយោគបរទេសមកក្នុងប្រទេស។ ដូច្នេះ ការពង្រីកសកម្មភាពសេដ្ឋកិច្ចទាំងនៅទីប្រជុំជន និងជនបទ គឺជាកត្តាចាំបាច់ក្នុងការពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងផ្តល់នូវការធានាឱ្យកាន់តែប្រសើរឡើង ដើម្បីទប់ទល់នឹងសក្តានុពលប៉ះទង្គិចពីខាងក្រៅ។

សម្ពាធបន្ថែមលើកាលានុវត្តភាព និងបញ្ហាប្រឈមដែលកំពុងកើតឡើងនោះ គឺសក្តានុពលនៃចំណូលដែលបានមកពីប្រេងនិងឧស្ម័នក្នុងសមុទ្រ ដែលនឹងទទួលបាននាអនាគតខាងមុខ រួមនឹងការទាញយកសារធាតុរ៉ែដទៃទៀតពីក្នុងដី ដូចជា រ៉ែបុកស៊ីត ជាដើម។ ចំពោះប្រទេសកំពុងអភិវឌ្ឍដទៃទៀត កំណើនចំណូលដ៏ឆាប់រហ័សពីបណ្តាឧស្សាហកម្មចម្រាញ់យករ៉ែប្រភេទនេះ មានផលប៉ះពាល់ជាអវិជ្ជមានដល់កត្តាប្រកួតប្រជែង និងកំណើននៃវិស័យបង្កើតការងារ (ជម្ងឺហុល្លង់ដ៏) អំពើពុករលួយកាន់តែឆាបឆេះឡើង ដែលនាំឱ្យប្រជាជនភាគច្រើនកាន់តែក្រទៅៗ និងបង្កើនករណីអស្ថិរភាពក្នុងសង្គម។ កម្ពុជាមានសមត្ថភាពស្ថាប័ននៅទន់ខ្សោយនៅឡើយ រួមផ្សំនឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពុំមានលក្ខណៈរួមផ្តុំផងនោះនឹងអាចបង្កឱ្យមានហានិភ័យនៃ "បណ្តាសាធនធានធម្មជាតិ" ខណៈពេលដែលគ្មានវិធានការណ៍គ្រប់គ្រងច្បាស់លាស់។

---

*(១) សន្ទរកថារបស់លោកស្រី Nisha Agrawal ក្នុងពិធីបើក "របាយការណ៍សមធម៌នៅកម្ពុជាឆ្នាំ ២០០៧ : ការចែករំលែកផលកំណើនសេដ្ឋកិច្ច", ធនាគារពិភពលោក, ភ្នំពេញ, កម្ពុជា ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧។http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/ CAMBODIAEXTN/0,,contentMDK:21368954~menuPK:293861~pagePK:2865066~piPK:2865079~theSitePK:293856,00.htm*

### *យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ផ្តល់នូវមគ្គុទ្ទេសក៍ដ៏ទូលំទូលាយ...*

បទពិសោធន៍ជាអន្តរជាតិចង្អុលបង្ហាញថា ពេលវេលាដ៏ល្អបំផុតសម្រាប់រដ្ឋាភិបាលក្នុងការបង្កើនល្បឿនអនុវត្តន៍កម្មវិធីកំណែទម្រង់លើការពន្យារពេលអភិវឌ្ឍ ការលំបាកក្នុងការកែទម្រង់ដោយសារបញ្ហានយោបាយ គឺនៅពេលដែលប្រទេសមានកំណើនសេដ្ឋកិច្ចខ្ពស់ និងមានប្រជាជនភាគច្រើនចាំគាំទ្រដល់កម្មវិធីកំណែទម្រង់នេះ ដោយឈរលើមូលដ្ឋានប្រសិទ្ធភាព សមធម៌ និងសុខុមាលភាពជាតិទាំងមូល។ ការពង្រឹង និងការកសាងប្រទេសអាស្រ័យលើផលចំណេញសេដ្ឋកិច្ចនាពេលថ្មីៗនេះ និងភាពធូរស្រាលនៃហានិភ័យទាំងឡាយដែលកំពុងកើតមានឡើង នឹងត្រូវការឱ្យមានអន្តរាគមន៍តម្រង់ឆ្ពោះទៅបញ្ឈប់ និងប្រែក្លាយក្តីបារម្ភទាំងឡាយឱ្យមានភាពប្រសើរឡើងវិញ។

ជាភ័ព្វសំណាងល្អ ដែលយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផយអជ បានដាក់ទិសដៅក្នុងការពង្រឹងអភិបាលកិច្ចល្អ បង្កើនការវិនិយោគនៅតំបន់ជនបទ និងការបង្កើនបរិយាកាសល្អសម្រាប់សហគ្រាសឯកជន។ ទោះយ៉ាងនេះក្តី ក៏គុណភាពនៃការអនុវត្តគឺនឹងប្រែក្លាយពីផែនការទៅជាសកម្មភាព និងធានាឱ្យទទួលបានលទ្ធផល។

ដោយសារសមត្ថភាពស្ថាប័ននៅមានភាពទន់ខ្សោយនៅឡើយ ការអនុវត្តនឹងផ្តោតទៅលើទិសដៅ ដែលនឹងមានឥទ្ធិពលជាវិជ្ជមានលើការបង្កើនសុខុមាលភាពរបស់មនុស្សជាតិ និងការធានាថែរក្សាសន្តិភាព និងស្ថិរភាពយូរអង្វែងសម្រាប់ជាតិទាំងមូល។

### *“ឱកាសនឹងកើនឡើងទ្វេគុណ កាលណាឱកាសទាំងនោះ ត្រូវបានពង្រីក...”*
### *សម្តេច ហ៊ុន សែន កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០៧*

ជាក់ស្តែង ដើម្បីឈានដៅដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅឆ្នាំ ២០១៥ និងបង្កើនសុខុមាលភាពមនុស្សជាតិនៅកម្ពុជាប្រកបដោយចីរភាពនោះ ទាមទារផ្តោតការយកចិត្តទុកដាក់លើកកម្ពស់ជីវភាពនៅជនបទ។ ក្នុងប្រទេសកំពុងអភិវឌ្ឍដែលបានទទួលជោគជ័យនៅក្នុងតំបន់ សរសៃឈាមសេដ្ឋកិច្ចជនបទពឹងផ្អែកលើគ្រួសារកសិករតូចតាច ដែលផ្តល់ជាមូលដ្ឋាននៃស្ថិរភាពសេដ្ឋកិច្ចនៅជនបទជាមួយនឹងជីវភាពសមរម្យសម្រាប់ពលករជនបទ និងផ្តល់នូវការពង្រីកសកម្មភាពសេដ្ឋកិច្ចចម្រុះកាន់តែធំឡើង រួមមានផលិតកម្មដែលផ្តល់តម្លៃបន្ថែមខ្ពស់ និងឧស្សាហកម្មសេវាកម្មតាមបែបទីប្រជុំជនដោយផ្តោតជាសំខាន់នៅទីជនបទ។

ជាភ័ព្វសំណាង នេះជាពេលវេលាល្អបំផុតដែលត្រូវអនុវត្តការសម្រេចចិត្ត និងសកម្មភាពទាំងឡាយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍនៅកម្ពុជាជាមួយការចែករំលែកវិបុលភាព និងស្ថិរភាពក្នុងរយៈពេលយូរ។ ការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់ណាស់ ហើយជាកត្តាចាំបាច់មិនអាចខ្វះបាន។ ដោយសារសមត្ថភាពស្ថាប័ននៅថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងថ្នាក់លំដាប់ក្រោមខេត្ត-ក្រុង នៅមានភាពទន់ខ្សោយនោះ ការផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការប្រើប្រាស់សមត្ថភាពដែលមានស្រាប់ក្នុងការបង្កើតបានទិន្នផលសេដ្ឋកិច្ចសង្គមកិច្ចខ្ពស់បំផុត។ ការខិតខំប្រឹងប្រែងទាំងនេះ នឹងអាចពង្រឹងបន្ថែមតាមរយៈការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងការវិនិយោគដោយប្រើប្រាស់ចំណូលដែលទទួលបានពីប្រេងនិងឧស្ម័ន ដែលនឹងទទួលបាននៅប៉ុន្មានឆ្នាំខាងមុខនេះ។ រួមជាមួយកត្តាដូចបានរៀបរាប់ខាងលើនេះ នឹងជំរុញឱ្យមានការខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសុខុមាលភាពមនុស្សជាតិ សមធម៌ និងស្ថិរភាពសេដ្ឋកិច្ចសង្គមមួយដ៏យូរអង្វែង ដែលធានាអនាគតប្រទេស និងប្រជាជនកម្ពុជា ឱ្យទទួលបាននូវពរជ័យនៅក្នុងទសវត្សរ៍ថ្មីខាងមុខនេះជាមិនខាន។

# ជំពូក ១



១
ជំពូក



# ការអភិវឌ្ឍមនុស្ស : សេចក្តីផ្តើម

គោលគំនិតនៃការអភិវឌ្ឍមនុស្សចាប់មានប្រជាប្រិយភាពតាំងពីដើមទសវត្សរ៍ទី ៩០ តាមរយៈការផ្សព្វផ្សាយរបាយការណ៍ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ ផ្នត់គំនិតនៃការអភិវឌ្ឍមនុស្ស សង្កត់ធ្ងន់លើការបំពេញសេចក្តីត្រូវការចាំបាច់របស់មនុស្ស ជាជាងគ្រាន់តែស្វែងរកអត្រាកំណើនប្រជាជនសរុប។ សេដ្ឋកិច្ចត្រូវតែកើនឡើងដើម្បីបង្កើនវឌ្ឍនភាពលើគ្រប់វិស័យ ប៉ុន្តែកំណើននេះគួរតែចែករំលែកដល់ប្រជាជនទាំងអស់ ប្រកបដោយសមធម៌ និងប្រកបដោយចីរភាព ក្នុងន័យទទួលបាននូវការអភិវឌ្ឍមនុស្សដ៏ទូលំទូលាយ។ ការអភិវឌ្ឍមនុស្សរួមបញ្ចូលជម្រើសផ្សេងៗ ដូចជា សេរីភាពក្នុងវិស័យនយោបាយនិងសង្គម ក៏ដូចជាឱកាសសម្រាប់ឱ្យមនុស្សចេះច្នៃប្រឌិត និងមានផលិតភាព ហើយរស់នៅក្រោដោយសេចក្តីថ្លៃថ្នូជាមនុស្សពិតប្រាកដ។ ផ្នត់គំនិតនេះផ្តោតលើវិស័យវិមជ្ឈការប្រជាធិបតេយ្យ សិទ្ធិមនុស្ស ព្រមទាំងការចាកផុតពីការភ័យខ្លាច និងគំរាមកំហែង។ សារៈសំខាន់នៃការអភិវឌ្ឍមនុស្សគឺការកសាងសមត្ថភាព និងពង្រីកកាលានុវត្តភាពរបស់មនុស្ស ដើម្បីកសាងបរិយាកាសមួយ ដែលអំណោយផលដល់ការបង្កើនសក្តានុពលនៃការអភិវឌ្ឍមនុស្សគ្រប់ៗគ្នានៅលើគ្រប់វិស័យ។

មូលហេតុដែលនាំឱ្យមានភាពខុសគ្នារវាងការអភិវឌ្ឍមនុស្សនឹងការបកស្រាយកន្លងមកស្តីពីការអភិវឌ្ឍនោះ គឺការអភិវឌ្ឍមនុស្សសំដៅលើមនុស្សដែលជាសម្បត្តិដ៏ពិតប្រាកដរបស់ជាតិមួយ មិនមែនគ្រាន់តែទ្រព្យសម្បត្តិ និងសេវាប៉ុណ្ណោះទេ។ ប្រទេសមួយអាចនឹងចម្រើនរុងរឿងបាន ដោយសារតែប្រជាពលរដ្ឋនៃប្រទេសនោះ មានសេរីភាព មានសិទ្ធិក្នុងការជ្រើសរើស ស្វ័យសម្រេច និងមានសិទ្ធិទទួលបាននូវអ្វីៗផ្សេងៗទៀត។

គោលការណ៍គ្រឹះសំខាន់ ៣ នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស គឺ ១-មនុស្សមានអាយុវែង ២-មានសុខភាពល្អ មានការអប់រំបណ្តុះបណ្តាលខ្ពស់ និង ៣-មានធនធានគ្រប់គ្រាន់សម្រាប់រស់នៅឱ្យបានសមរម្យនៅក្នុងសង្គម។ ថ្វីបើសន្ទស្សន៍អភិវឌ្ឍន៍មនុស្សឆ្លុះបញ្ចាំងដោយសមាសភាគសំខាន់ៗទាំង ៣ ខាងលើ ប៉ុន្តែនេះមិនអាចធ្វើការសន្និដ្ឋានសរុបលើទិដ្ឋភាពនៃការអភិវឌ្ឍមនុស្សទាំងអស់នៅក្នុងសន្ទស្សន៍តែមួយនោះឡើយ។

ជំពូក ១ នេះពន្យល់អំពី (១) ទស្សនៈស្តីអំពីរបាយការណ៍ការអភិវឌ្ឍមនុស្ស (២) ពិនិត្យលើបញ្ហាដែលកម្ពុជាបាននឹងកំពុងជួបប្រទះដែលនាំឱ្យរបាយការណ៍អភិវឌ្ឍន៍មនុស្សនេះ បរិយាយអំពីជីវភាពរស់នៅតាមទីជនបទ និង (៣) ផ្តល់ជូននូវទម្រង់ទូទៅនៃរបាយការណ៍។

## ១.១ របាយការណ៍នានាស្តីពីការអភិវឌ្ឍមនុស្ស

របាយការណ៍អភិវឌ្ឍន៍មនុស្សមានជាច្រើនផ្សេងៗគ្នា ដូចជា របាយការណ៍សកល ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ របាយការណ៍ថ្នាក់សកល ត្រូវបានរៀបរៀងឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៩០ មក។ របាយការណ៍ថ្នាក់ជាតិស្តីពីការអភិវឌ្ឍមនុស្សគឺជារបាយការណ៍ឯករាជ្យ និងជាឯកសាររបស់ជាតិ ស្តីពីស្ថានភាពនៃការអភិវឌ្ឍមនុស្ស ដែលរៀបចំឡើងដោយអ្នកជំនាញការនិងបញ្ញាវ័ន្ត ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ របាយការណ៍ទាំងនេះ គឺជាឯកសារស្វែងរកការគាំទ្រមតិ ដោយឈរលើមូលដ្ឋាននៃការស្រាវជ្រាវយ៉ាងល្អិតល្អន់ និងមានបំណងចង់ឱ្យមានការជជែកពិភាក្សាអំពីមធ្យោបាយនានា សម្រាប់ធ្វើឱ្យប្រសើរឡើងដល់ការអភិវឌ្ឍមនុស្សនៅក្នុងប្រទេស។ ប្រទេសកម្ពុជាបានធ្វើរបាយការណ៍ទីមួយរបស់ខ្លួនក្នុងឆ្នាំ ១៩៩៧ ហើយរបាយការណ៍នេះជារបាយការណ៍ទី ៦។

១៩៩៧ : ការវាយតម្លៃលើភាពក្រីក្រ
១៩៩៨ : ការចូលរួមចំណែករបស់ស្ត្រីក្នុងការអភិវឌ្ឍ
១៩៩៩ : សេដ្ឋកិច្ចភូមិ និងការអភិវឌ្ឍ
២០០០ : កុមារ និងការងារ
២០០១ : ទិដ្ឋភាពសង្គមនៃការរាតត្បាតមេរោគអេដស៍ និងជម្ងឺអេដស៍ ( HIV/AIDS )
២០០៧ : ការបង្កើនជម្រើសសម្រាប់ប្រជាពលរដ្ឋនៅជនបទ

រីឯរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាឆ្នាំនេះ គឺផ្តោតទៅលើការប្រើប្រាស់ធនធានធម្មជាតិ ហើយនិងជីវភាពរស់នៅតាមទីជនបទ។

## ប្រអប់ទី ១.១ : កម្ពុជា - ប្រវត្តិថ្មីៗខ្លះ

នៅចន្លោះទសវត្សរ៍ទី ៥០ និងពាក់កណ្តាលទសវត្សរ៍ទី ៦០ ប្រទេសកម្ពុជាជាប្រទេសរីកចម្រើននៅក្នុងតំបន់។ ចំណូលសម្រាប់មនុស្សម្នាក់ៗខ្ពស់ជាងចំណូលនៅប្រទេសថៃ ហើយនៅសម័យនោះ កម្ពុជាបានលក់អាហារចេញ។ ព្រៃឈើដែលគ្របដណ្តប់លើ ៧០% នៃផ្ទៃដីទាំងអស់ បានផ្តល់នូវផលប្រយោជន៍ដល់ជីវភាពរស់នៅតាមទីជនបទ។ ប្រជាពលរដ្ឋមានពី ៤ ទៅ ៤ លានកន្លះ ហើយអ្វីៗក៏បានចម្រើនឡើងចាប់ពីពេលដែលកម្ពុជាបានដឹកនាំប្រទេសដោយខ្លួនឯងក្រោយពីបារាំងបានចាកចេញទៅនៅឆ្នាំ ១៩៥៣។

ចាប់ពីពាក់កណ្តាលទសវត្សរ៍ទី ៦០ មក អស្ថិរភាពនយោបាយបានកើតឡើងនៅពាសពេញអាស៊ីដោយសារសង្គ្រាមនៅវៀតណាម។ នៅឆ្នាំ ១៩៧០ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដុនដាបជាមួយនឹងកម្រិតអតិផរណាដ៏ខ្លាំងក្លា។ ក្នុងឆ្នាំ ១៩៧០ វិបត្តិមួយបានផ្តើមកើតឡើងនៅពេលដែលរដ្ឋាភិបាលរបស់សម្តេចព្រះនរោត្តម សីហនុ ត្រូវគេទម្លាក់ចេញពីអំណាច ហើយរដ្ឋាភិបាលផ្តាច់ការដឹកនាំដោយកងទ័ពបានកើតឡើង។ វិបត្តិនយោបាយធំៗ និងសង្គ្រាមស៊ីវិលកើតឡើង ដែលបណ្តាលឱ្យខ្មែរក្រហមបានចូលមកកាន់អំណាចនៅឆ្នាំ ១៩៧៥។ របបនេះបានចាប់ផ្តើមកែទម្រង់រដ្ឋ និងសង្គមកម្ពុជាសារជាថ្មី។ គេប្រកាន់យករបបសង្គមនិយមពឹងផ្អែកលើកសិកម្ម ដោយគេជម្លៀសប្រជាពលរដ្ឋរស់នៅទីក្រុងឱ្យទៅនៅតាមស្រុកស្រែ ហើយសូម្បីតែកសិករក៏ត្រូវជម្លៀសទៅទីផ្សេងៗទៀតដែរ។ កម្មសិទ្ធិឯកជន និងប្រាក់កាសត្រូវបានបំបាត់លែងឱ្យមាន រចនាសម្ព័ន្ធគ្រួសារត្រូវបានរំលាយជាក្រុមសមូហភាព។ ទំនាស់ផ្ទៃក្នុង និងការមិនទទួលស្គាល់ពីខាងក្រៅបាននាំឱ្យមានអន្តរាគមន៍ពីកងកម្លាំងវៀតណាម ដែលបានបណ្តេញក្រុមខ្មែរក្រហមឱ្យបង្ខំចិត្តចាកចេញពីអំណាចនៅឆ្នាំ ១៩៧៩។

នៅចន្លោះពីឆ្នាំ ១៩៨០ ដល់ឆ្នាំ ១៩៨៩ កងកម្លាំងវៀតណាមស្ថិតនៅក្នុងប្រទេសកម្ពុជា ហើយប្រទេសទាំងអស់ ក្រៅពីក្រុមសម្ព័ន្ធមិត្តនៃសហភាពសូវៀត បានដាក់ទណ្ឌកម្មពាណិជ្ជកម្ម សេដ្ឋកិច្ច និងទណ្ឌកម្មផ្សេងៗទៀតមកលើកម្ពុជា។ នៅភូមិភាគខាងលិច និងពាយ័ព្យនៃប្រទេសមានជម្លោះប្រដាប់អាវុធពេញមួយទសវត្សរ៍ទី ៨០ ដែលរំខានយ៉ាងខ្លាំងដល់ការអភិវឌ្ឍ។ សង្គ្រាមស៊ីវិលនៅតែបន្តក្រោយពីកងទ័ពវៀតណាមបានដកចេញនៅឆ្នាំ ១៩៨៩។ រដ្ឋាភិបាលបានព្យាយាមបង្កើតស្ថាប័នអភិបាលកិច្ចសំខាន់ៗ បើកសាលាឡើងវិញ និងរៀបចំរចនាសម្ព័ន្ធកសិកម្មសារជាថ្មីតាមបែបកសិកម្មប្រមូលផ្តុំ (ក្រុមសាមគ្គី)។ ដីដែលរដ្ឋកាន់កាប់នៅពេលនោះត្រូវបានចែកឱ្យប្រជាពលរដ្ឋកាន់កាប់វិញនៅក្នុងឆ្នាំ ១៩៨៩។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១ បាននាំឱ្យមានកិច្ចសហប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិនៅកម្ពុជាក្នុងដំណើរផ្លាស់ប្តូរតាមសន្តិវិធីឆ្ពោះទៅកាន់របបប្រជាធិបតេយ្យពហុបក្ស។ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) មានភារកិច្ចត្រួតពិនិត្យលើការដាក់អាវុធ និងការរំសាយកងទ័ព សម្របសម្រួលជំនួយអន្តរជាតិសម្រាប់កសាងកម្ពុជាមួយថ្មីឡើងវិញ ព្រមទាំងការធានាឱ្យមានលក្ខខណ្ឌសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅឆ្នាំ១៩៩៣។រដ្ឋាភិបាលចម្រុះប្រជាធិបតេយ្យមួយបានត្រូវបង្កើតឡើង។ វិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យសម្លៀកបំពាក់ ព្រៃឈើ និងសេវាជំនួញផ្អែកកសិកម្ម បានហូរចូលមកក្នុងប្រទេស ហើយនៅចន្លោះឆ្នាំ ១៩៩៣ និង ១៩៩៧ ផលទុនជាតិសរុបបានកើនឡើងយ៉ាងលឿនគួរឱ្យកត់សម្គាល់។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជាបានជួបនឹងបញ្ហាមួយទៀតក្នុងឆ្នាំ ១៩៩៨ នៅពេលដែលរដ្ឋាភិបាលចម្រុះត្រូវបានដួលរលំ។ ក្នុងកំឡុងពេលបន្តិចក្រោយមក ស្ថិរភាពត្រូវបានពង្រឹងឡើងវិញ ដោយមានការបោះឆ្នោតថ្នាក់ជាតិមួយប្រកបដោយជោគជ័យ។ ចាប់ពីនោះមក សេដ្ឋកិច្ចបានកើនឡើងប្រមាណជិត ៨% ក្នុងមួយឆ្នាំ មួយផ្នែកធំមកពីផលិតផលសម្លៀកបំពាក់នៅតាមទីក្រុង ការរីកចម្រើនក្នុងវិស័យទេសចរណ៍ និងការរីកដុះដាលនៃសកម្មភាពសេវាកម្មផ្សេងៗទៀត។ វិស័យកសិកម្មនៅតែមិនបានផ្តោតការយកចិត្តទុកដាក់លើផលិតកម្មស្រូវ ទោះបីមានអំណោយផលល្អពីធាតុអាកាសដល់ដំណាំស្រូវក៏ដោយ។

កម្ពុជានៅមិនទាន់បានសះស្បើយពេញលេញនៅឡើយទេពីសង្គ្រាមរ៉ាំរ៉ៃជាងបីទសវត្សរ៍ ដែលបានបំផ្លិចបំផ្លាញរចនាសម្ព័ន្ធសង្គម និងស្ថាប័នសង្គម ដែលកំពុងតែសាងសង់ឡើងវិញនៅឡើយ។ នៅមានកិច្ចការអភិវឌ្ឍជាច្រើនដែលត្រូវពុះពារ ដោយត្រូវកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ពង្រីកធនធានមនុស្ស អភិវឌ្ឍវិស័យកសិកម្ម និងជនបទ។

*ប្រភព :* *Chandler (1993); Vickery (1984); Ear (1995); Mysliwiec (1988),* និងឯកសារប្រចាំឆ្នាំនៃក្រុមពិគ្រោះយោបល់

## ១.២ បញ្ហាប្រឈមមុខក្នុងវិស័យអភិវឌ្ឍន៍ និងមូលហេតុដែលនាំឱ្យរបាយការណ៍នេះបកស្រាយពីជីវភាពរស់នៅតាមទីជនបទ

ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមក សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ថ្វីបើនៅមានមតិខ្លះថា នៅមិនទាន់រឹងមាំក៏ដោយ ប៉ុន្តែមានសមិទ្ធិផលសំខាន់ៗមួយចំនួនដែលសម្រេចបានកន្លងមក រួមមាន ការបោះឆ្នោតជាតិឆ្នាំ ១៩៩៣ និងព្រឹត្តិការណ៍បោះឆ្នោតជាទៀងទាត់ជាបន្តបន្ទាប់ ក្រុមភាគីជម្លោះបានត្រឡប់ចូលមករួមរស់ក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យវិញ ដោយមានការរំសាយក្រុមខ្មែរក្រហមនៅឆ្នាំ ១៩៩៨ ការបោះឆ្នោតឃុំ-សង្កាត់ នៅឆ្នាំ ២០០២ និង ២០០៧ ការបើកទូលាយសេដ្ឋកិច្ចទីផ្សារសេរី និងសេដ្ឋកិច្ចប្រកបដោយកំណើនឆាប់រហ័ស ដែលបានទាក់ទាញវិនិយោគផ្ទាល់ពីបរទេសតាំងពីឆ្នាំ ១៩៩៣ និងកំណើនទេសចរណ៍ដែលកាន់តែរីកលូតលាស់ឡើង ការកើនឡើងនៃសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយយ៉ាងរស់រវើក។ កម្ពុជាក៏បានចូលជាសមាជិក ASEAN និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ពេញសិទ្ធិ។ ដូច្នេះប្រទេសកម្ពុជាបានកែប្រែបណ្តើរៗពីជាតិមួយ ដែលធ្លាប់មានជម្លោះនៅទសវត្សរ៍ទី ៧០ ទី ៨០ និងដើមទសវត្សរ៍ទី ៩០។ ប៉ុន្តែកម្ពុជាត្រូវតែប្រឹងប្រែងពុះពារច្រើនថែមទៀត ដើម្បីប្រែខ្លួនពីប្រទេសដែលមានកម្រិតអភិវឌ្ឍទាប និងពឹងផ្អែកលើជំនួយ ថែមទាំងមានប្រជាពលរដ្ឋជាងមួយភាគបីរស់ក្រោមបន្ទាត់ក្រីក្រ ដែលភាគច្រើនរស់នៅតាមជនបទ។

ពលរដ្ឋកម្ពុជាមួយផ្នែកធំប្រកបរបរចិញ្ចឹមជីវិតក្នុងវិស័យកសិកម្ម ដូចជា ធ្វើស្រែ នេសាទត្រី យកផលព្រៃឈើ និងពេលថ្មីៗនេះមានមុខរបរជាកម្មករ។ ក្នុងឆ្នាំ ១៩៩៧ ៧៦% នៃកម្លាំងពលកម្មទាំងអស់ប្រកបរបរចិញ្ចឹមជីវិតក្នុងវិស័យ កសិកម្ម ព្រៃឈើ និងនេសាទ។ នៅឆ្នាំ ២០០៤ ចំនួននេះថយចុះបន្តិចមកនៅត្រឹម ៧៤%។ បើគិតជាតួលេខវិញ មានការកើនឡើងនៃកម្លាំងពលកម្មក្នុងវិស័យនេះប្រហែល ១៧% ជាទូទៅ (ប្រុស ២៦% ស្ត្រី ១២%)។ ដូច្នេះកម្លាំងពលកម្មភាគច្រើនគឺសម្រាប់វិស័យកសិកម្ម ហើយនៅតែមានកំណើនខ្ពស់នៅឡើយសម្រាប់វិស័យនេះ[២]។

*រូបភាព ១.១ : អនុបាតផលិតភាពពលកម្មរវាងផ្នែកកសិកម្ម និងមិនមែនកសិកម្មពីឆ្នាំ ១៩៩៧ និងឆ្នាំ ២០០៤*




*ប្រភព : យោងតាមទិន្នន័យចំណូលជាតិ* (http://www.nis.gov.kh), SES-97, SES-04 and CIPS-04

ក្នុងវិស័យកសិកម្ម រួមទាំងការងារពាក់ព័ន្ធនឹងកសិកម្ម កសិករម្នាក់ផលិតបានក្នុងតម្លៃជាប្រាក់ស្មើនឹង ១.០៦០.០០០ រៀល (គិតតាមតម្លៃក្នុងឆ្នាំ ២០០០) ហើយបានចុះថយបន្តិចមកត្រឹម ១.០៥០.០០០ រៀល នៅឆ្នាំ ២០០៤។ ផ្ទុយទៅវិញ ផលិតភាពរបស់ពលករម្នាក់ក្នុងវិស័យមិនមែនកសិកម្មវិញ គឺស្មើនឹង ៤ លាន ២ ម៉ឺនរៀល ក្នុងឆ្នាំ ១៩៩៧ ហើយឡើងទៅ ៥ លាន ៥ សែនរៀល ក្នុងឆ្នាំ ២០០៤។ ជាលទ្ធផល អនុបាតនៃផលិតភាពពលកម្មរវាងកសិកម្ម និងមិនមែនកសិកម្មបានកើនឡើងពី ៤ ទៅ ៥,២ ក្នុងអំឡុង ៧ ឆ្នាំនេះ (រូបភាព ១.១)។ មូលហេតុចម្បងនៃគម្លាតនេះ គឺកំណើនយ៉ាងយឺតក្នុងវិស័យកសិកម្មនៅក្នុងរយៈពេល ៧ ឆ្នាំនេះ ដែលមិនមានកំណើនជាដុំកំភួនសោះនៃចំនួនពលករនៅក្នុងវិស័យមិនមែនកសិកម្ម ដែលមានផលិតភាពច្រើនជាង ដែលបណ្តាលឱ្យមានភាពក្រីក្រនៅតាមជនបទ

*(២) ការគណនាទាំងនេះធ្វើឡើងដោយផ្អែកលើការប៉ាន់ស្មានលើចំនួនប្រជាជនថ្មី ដោយវិទ្យាស្ថានជាតិស្ថិតិ (RGC 2005a)។ ការប៉ាន់ស្មានលើចំនួនកម្លាំងពលកម្មតាមវិស័យនៅឆ្នាំ ២០០៤ នេះ ត្រូវបានដកស្រង់ពីការអង្កេតជំរឿនប្រជាសាស្ត្រកម្ពុជា (CIPS 04)។ ចំណែកឯទិន្នន័យទាក់ទងនឹងចំណូលរួមនៃកម្លាំង គឺដកស្រង់ពីការអង្កេតសេដ្ឋកិច្ច-សង្គម ឆ្នាំ ១៩៩៧ (SES-97) និង SES-04។ SES-97 បានបង្ហាញពីអត្រាចំណូលរួមនៃកម្លាំងពលកម្មចំនួន ៦៥.៨ ភាគរយ រីឯ SES-04 បានបង្ហាញថាមាន ៧៤.៦ ភាគរយ។ ដូច្នេះវាមានការកើនឡើងនូវចំនួនពិតប្រាកដនៃចំណូលរួមនៃកម្លាំងពលកម្មច្រើនជាងកំណើននៃប្រជាជន។*

ច្រើនជាងនៅទីប្រជុំជនជានិច្ច។ បន្ទាប់មកទៀត ដីធ្លី និងធនធានធម្មជាតិនៅកម្ពុជាបានក្លាយទៅជាមុខរបរជំនួញយ៉ាងឆាប់រហ័ស ហើយបង្កើតចេញជាកម្លាំងទីផ្សារមួយ ដែលមិនស្មើភាពគ្នានៅក្នុងជីវភាពចិញ្ចឹមជីវិតភាគច្រើន ដែលមិនមានកំណត់ជាក់លាក់។ ដោយមូលហេតុនេះហើយ បានជាមិនមានការស៊ីសង្វាក់គ្នារវាងការប្រែប្រួល និងការត្រៀមលក្ខណៈរបស់ពលរដ្ឋជនបទសម្រាប់ទប់ទល់នឹងការប្រែប្រួលទាំងនោះ។ រូបភាពដែលអាចឃើញភ្លាមៗនោះ គឺបើមិនមានវិធានការណ៍ទប់ទល់ទេ ទំនោរទាំងនេះនឹងនាំទៅរកភាពក្រីក្រកាន់តែខ្លាំងឡើង ចំពោះប្រជាជននៅទីជនបទភាគច្រើន ដែលនឹងអាចប្រឈមមុខនឹងបញ្ហាដ៏គួរឱ្យបារម្ភខ្លាំងបំផុត និងភាពមិនប្រាកដប្រជាកាន់តែច្រើនឡើង ដែលពួកគាត់មានលទ្ធភាពទប់ទល់កាន់តែតិចទៅៗ។

វិសមភាពរវាងទីជនបទ និងទីប្រជុំជន រួមនឹងការដែលប្រជាជននៅទីជនបទខ្វះខាតក្នុងជីវភាព សេដ្ឋកិច្ចបានបណ្ដាលឱ្យមានភាពតានតឹង និងអំពើហិង្សានៅក្នុងប្រទេស។ ដូច្នេះការកើនឡើងវិសមភាពរវាងជនបទ និងទីប្រជុំជន និងភាពក្រីក្រ ទាមទារឱ្យមានការយកចិត្តទុកដាក់លើបញ្ហានេះជាបន្ទាន់ មុនបញ្ហានេះក្លាយទៅជាជម្លោះម្តងទៀត[៣]។

គោលនយោបាយរដ្ឋាភិបាលត្រូវជម្រុញ និងរក្សានូវកំណើនសេដ្ឋកិច្ច ដែលត្រូវចែករំលែកទៅឱ្យប្រជាជននៅគ្រប់តំបន់នានា ដើម្បីជាប្រយោជន៍ដល់ប្រជាជនក្រីក្រ ដោយត្រូវផ្តោតជាចម្បងទៅលើការអភិវឌ្ឍសង្គម ដូចជា ការអប់រំ សុខភាព លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធសង្គម និងឋានៈរបស់ស្ត្រីជាដើម ព្រមជាមួយនោះ ត្រូវសង្កត់ធ្ងន់ផងដែរលើអភិបាលកិច្ចល្អ។ ជារួម គឺត្រូវជម្រុញឱ្យមានក្របខ័ណ្ឌអភិវឌ្ឍន៍ជនបទគ្រប់ជ្រុងជ្រោយមួយជាប្រយោជន៍ដល់ប្រជាពលរដ្ឋនៅទីនោះ ដើម្បីប្រយុទ្ធប្រឆាំងនឹងវិសមភាព និងភាពក្រីក្រ។ តម្រូវការសំខាន់ៗសម្រាប់ការងារនៅជនបទ រួមមាន : សិទ្ធិទទួលបានដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លីឱ្យបានប្រសើរបំផុត ការធានាដល់សិទ្ធិកាន់កាប់ដីធ្លី ការយកផលពីប្រភពធនធានធម្មជាតិប្រកបដោយចីរភាព (ព្រៃឈើ និងត្រី) ហើយអ្វីដែលសំខាន់បំផុតនោះ គឺត្រូវផ្លាស់ប្តូរពីសេដ្ឋកិច្ច ដែលពឹងផ្អែកលើការចម្រាញ់យកផលពីធម្មជាតិទៅជាសេដ្ឋកិច្ចមួយ ដែលអាចបន្ថែមតម្លៃទៅលើផលិតផលពីធម្មជាតិ ឬទំនិញដែលចម្រាញ់ពីធម្មជាតិ។ របាយការណ៍នេះវិភាគលើស្ថានការណ៍បច្ចុប្បន្ន និងដាក់ស្នើជាចំណោទ វិធីផ្សេងៗ សម្រាប់ពង្រឹងជីវភាពរស់នៅតាមជនបទ។

*គោលនយោបាយរដ្ឋាភិបាលត្រូវបង្កលក្ខណៈឱ្យមានកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងរក្សានូវកំណើនសេដ្ឋកិច្ចនេះ ដោយត្រូវពង្រាយនៅតាមតំបន់នានា ដើម្បីជាប្រយោជន៍ដល់អ្នកក្រីក្រ ដោយមានការប្តូរផ្តាច់ខ្លាំងទៅលើការអភិវឌ្ឍសង្គម*

## ១.៣ ទម្រង់នៃរបាយការណ៍

*របាយការណ៍នេះមានទិសដៅដូចខាងក្រោមនេះ :*

ក. *សម្គាល់សញ្ញាណនៃបញ្ហាចម្បងៗដែលពាក់ព័ន្ធនឹងដីធ្លី ហើយនិងធនធានធម្មជាតិ ទាំងក្នុងវិស័យប្រវត្តិសាស្ត្រ ទាំងវិស័យភូមិសាស្ត្រ ព្រមទាំងទំនាក់ទំនងរបស់វាជាមួយនឹងជីវភាពរស់នៅរបស់មនុស្ស។* ការពិភាក្សាបានគ្របដណ្តប់លើបញ្ហាអស់ទាំងនេះ ដូចជាដីកសិកម្ម ភាពជាម្ចាស់ដីនេះនិងការប្រើប្រាស់វា ដីសម្បទាន (សេដ្ឋកិច្ច/កសិកម្ម ព្រៃសម្បទាន ឬឡូត៍នេសាទសម្បទាន) និងសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋជនបទ។ ដោយសារសម្ពាធនៃមនុស្សសាស្ត្រ ការប្រែប្រួលនៃការប្រើប្រាស់ដី និងទីផ្សារដី ការជ្រៀតចូលនៃទីផ្សារ និងការធ្វើសម្បទានដីបានបង្ខំឱ្យគ្រួសារជនបទជាច្រើន ផ្លាស់ជីវភាពរស់នៅយ៉ាងឆាប់រហ័សចេញពីទម្លាប់រស់នៅរបស់ពួកគេ ដែលជាហេតុបណ្តាលឱ្យប្រជាពលរដ្ឋជនបទជាច្រើនប្រឈមមុខនឹងភាពមិនទៀងទាត់យ៉ាងធ្ងន់ធ្ងរ។ ដូច្នេះជម្រើសគោលនយោបាយ ដើម្បីធ្វើឱ្យការផ្លាស់ប្តូរនេះមានដំណើរដោយរលូន គួរតែត្រូវបានលើកយកមកពិភាក្សា។

ខ. *ការវិភាគលើប្រាក់ចំណូលក្នុងកសិដ្ឋាន និងប្រាក់ចំណូលក្រៅកសិដ្ឋាន ក៏ដូចជាបញ្ហាផលិតភាពដី ប្រាក់ចំណូលពីកសិដ្ឋាន ឡូត៍នេសាទ និងព្រៃឈើ ហើយនិងការបង្កើតជីវភាពរស់នៅជាច្រើនទៀតក្រៅពីប្រភពធនធានធម្មជាតិ។* គោលនយោបាយសំខាន់ៗ ដែលស្នើឡើង រួមមាន ការបង្កើនការចេញប្លង់ដី និងការធានាដល់សិទ្ធិកាន់កាប់ដីធ្លី ការរៀបចំឡើងវិញនូវការកាន់កាប់ដីធ្លី ដើម្បីកាត់បន្ថយភាពខ្វះខ្នាយ (ដោយគិតអំពីដីកម្មសិទ្ធិដែលដាច់ៗពីគ្នាតូចៗ និងដីកម្មសិទ្ធធំៗដែលគ្មានផលិតភាព) ការជម្រុញឱ្យប្រើប្រាស់ទុនទំនើប (ដូចជា ជីលាមកសត្វ ប្រភេទគ្រាប់ពូជ ដែលផ្តល់ទិន្នផលខ្ពស់ ការការពារសត្វល្អិត និងការច្នៃប្រឌិតផ្សេងៗទៀត ) ការដាំដំណាំច្រើនប្រភេទផ្សេងគ្នា ការវិនិយោគលើប្រព័ន្ធស្រោចស្រព ហើយនិងការជម្រុញឱ្យមានទីផ្សារប្រកួតប្រជែង។ របាយការណ៍ក៏បានស្នើវិធីបង្កើនប្រាក់ចំណូលក្រៅពីកសិកម្ម។ ជាការសន្និដ្ឋាន របាយការណ៍នេះបានស្នើនូវបច្ចេកវិជ្ជាផ្សេងៗ សកម្មភាពថ្មីៗ និងសេវាគាំទ្រដទៃទៀតជាច្រើន។

---

*(៣) ភាពក្រីក្រនៅជនបទ និងគម្លាតរវាងទីប្រជុំជននិងជនបទ ត្រូវបានកត់ត្រាទុកចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៨៦០ មក (Mahout 1862) ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង១៩៦០ គម្លាតទាំងនេះ គឺជាមូលដ្ឋាននៃកុបកម្មដែលនាំឱ្យរបបខ្មែរក្រហមទទួលជ័យជំនះ (Ear 1995; Chanda 1986) ។ មានក្តីបារម្ភជាច្រើនថ្មីៗនេះទាក់ទងនឹងបញ្ហាគម្លាតនេះនៅក្នុងឯកសារ (EIC 2006) និង (ធនាគារពិភពលោក ២០០៥) ។*

**គ.** *អំពីបញ្ហាចម្បងៗទាក់ទងនឹងទីផ្សារសម្រាប់ទិញឥវ៉ាន់យកមកផលិត និងទីផ្សារសម្រាប់លក់ឥវ៉ាន់ដែលបានផលិតហើយ និយាយអំពីការដឹកជញ្ជូនសម្ភារៈសម្រាប់រក្សាទុកបណ្តោះអាសន្ន មូលធនមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានម៉ាក្រូដែលអំណោយផល។*

រីឯបញ្ហាអភិបាលកិច្ច យេនឌ័រ និងការបញ្ជ្រាបចូលតាមតំបន់ មានដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះជាច្រើនកន្លែងដែលមិនធ្លាប់មានសម្រាប់កម្ពុជា គឺលទ្ធភាពសម្រេចបាននូវទិសដៅអភិវឌ្ឍន៍មនុស្សដោយការវិនិយោគនៃប្រាក់ចំណូលពីប្រេងនិងឧស្ម័ន ដែលនឹងមានក្នុងពេលឆាប់ៗនេះ។ ដូច្នេះសេចក្តីស្នើជាច្រើននៅក្នុងរបាយការណ៍នេះ អាចនឹងបានសម្រេចប្រសិនបើប្រាក់ចំណូលទាំងនេះដែលសង្ឃឹមថានឹងទទួលបាននៅឆ្នាំ ២០០៩-២០១០ ខាងមុខនេះ ត្រូវយកទៅប្រើប្រាស់ដោយប្រយ័ត្នប្រយែង។ ការរៀបចំផែនការសម្រាប់ប្រើប្រាស់ប្រាក់ទាំងនេះគួរតែរៀបចំឱ្យបានឆាប់។

ដោយយកតាមទម្រង់បែបបទនៃរបៀបធ្វើរបាយការណ៍អភិវឌ្ឍន៍មនុស្ស ជាដំបូងរបាយការណ៍នេះ បកស្រាយអំពីស្ថានភាពនៃការអភិវឌ្ឍមនុស្សនៅក្នុងប្រទេស ដែលក្នុងនោះ បញ្ហាអភិវឌ្ឍន៍មនុស្សនៅតំបន់ភូមិសាស្ត្រផ្សេងៗពីគ្នាត្រូវបានរំលេចឡើង។ មានការពិភាក្សាអំពីជីវភាពនៅតាមជនបទ និងការបង្ហាញអំពីបញ្ហាដែលមានជាប់ទាក់ទងទៅនឹងការធ្វើឱ្យចម្រើនឡើងដល់ការអភិវឌ្ឍមនុស្សតាមរយៈយុទ្ធសាស្ត្រសម្រាប់ពង្រឹងជីវភាពរស់នៅ។ ដូចបានជម្រាបពីខាងដើម របាយការណ៍នេះផ្តោតជាពិសេសទៅលើការអភិវឌ្ឍមនុស្សនៅក្នុងវិសាលភាពថ្នាក់ក្រោមជាតិ។

***ជំពូក ១*** បង្ហាញជូនអំពីប្រធានបទនៃរបាយការណ៍

***ជំពូក ២*** និយាយអំពីការបង្កើតបណ្ណដាក់ពិន្ទុ ដោយរួមទាំងស្ថានភាពនៃការអភិវឌ្ឍមនុស្ស សន្ទស្សន៍ភាពក្រីក្រ ការអប់រំ សុខភាព ហើយនិងការផ្តល់លំនៅស្ថាន។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ត្រូវបានគណនាជាលើកទីមួយនៅថ្នាក់ខេត្ត។

***ជំពូក ៣*** រៀបរាប់ជាគោលៗនូវស្ថានភាពដី និងធនធានធម្មជាតិ បានដាក់ស្នើឱ្យមានកំណែទម្រង់ស្ថាប័នគ្រប់គ្រង និងពាក់ព័ន្ធផ្នែកដីធ្លី ឡូតិ៍នេសាទ និងព្រៃឈើ ដើម្បីធ្វើឱ្យរីកចម្រើនដល់ការអភិវឌ្ឍមនុស្ស និងធ្វើឱ្យរលូនដល់ការផ្លាស់ប្តូរជីវភាពរស់នៅពីទម្លាប់ចាស់មកទម្លាប់បច្ចុប្បន្នវិញ។

***ជំពូក ៤*** ដាក់ជូននូវវិធីសាស្ត្រផ្សេងៗ ដើម្បីបង្កើនប្រាក់ចំណូលពីដំណាំកសិកម្ម នេសាទត្រី និងពីផ្នែកនានាក្រៅពីកសិដ្ឋាន ឬមិនមែនមកពីកសិដ្ឋាន (ដូចជា កសិឧស្សាហកម្ម និងការបំពាក់អគ្គិសនីនៅតាមជនបទ)។

***ជំពូក ៥*** ពិភាក្សាលើជម្រើសគោលនយោបាយធំៗ : ដូចជា ការកសាងមូលធនមនុស្ស ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ការបង្កើតស្ថាប័នដែលជាទីទំនុកចិត្តដោយរៀបចំឱ្យមានអភិបាលកិច្ចល្អប្រសើរ ដែលស្ថាប័ននីមួយៗសំដៅសម្រេចឱ្យបានបរិយាកាសអំណោយផលសម្រាប់លើកកម្ពស់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋជនបទ។

***ជំពូក ៦*** បង្ហាញពីសេចក្តីសន្និដ្ឋានខ្លះ ដោយព្យាយាមរកលទ្ធភាពផ្តល់ប្រភពហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ជនបទ ជាបន្តបន្ទាប់គ្នា ជាពិសេសដោយប្រើហិរញ្ញវត្ថុ ដែលនឹងត្រូវបែងចែកពីចំណូលប្រេងនិងឧស្ម័ន ដែលកម្ពុជាទើបនឹងបានរកឃើញនាពេលថ្មីៗនេះ។

របាយការណ៍នេះ បានផ្តល់អនុសាសន៍លើការបំពេញបន្ថែមទៅលើយុទ្ធសាស្ត្រចតុកោណ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

# ជំពូក ២



២

ជំពូក

# វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស



ការអភិវឌ្ឍមនុស្ស គឺជាគំរូប្រកបដោយថាមវន្ត មានវិសាលភាពលើច្រើនវិស័យ មានរបៀបវិនិច្ឆ័យច្រើនយ៉ាង និងតាមបែបទិសដៅសកម្មភាព។ ការអភិវឌ្ឍមនុស្សមិនបកស្រាយអំពីនិយមន័យ ដែលមាននៅក្នុង និងក្រៅដែនកំណត់ឡើយ។ មូលដ្ឋានគ្រឹះនៃនិយមន័យនេះ គឺបញ្ហាមនុស្ស : ពោលគឺការផ្តល់ដល់មនុស្សនូវសិទ្ធិអំណាច សុខុមាលភាព និងគុណភាពនៃជីវិត។ សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស គឺជាសូចនាករមួយនៃសូចនាករជាច្រើន ដែលប្រើសម្រាប់វាស់ការអភិវឌ្ឍមនុស្ស។ ជំពូកនេះពិនិត្យឡើងវិញលើវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្សនៅកម្ពុជា។

កត្តាសំខាន់ចាំបាច់ក្នុងការវិភាគអភិវឌ្ឍន៍មនុស្ស គឺត្រូវប៉ាន់ប្រមាណលើលំនាំនៃការអភិវឌ្ឍបច្ចុប្បន្ន និងផលប៉ះពាល់ដល់មនុស្ស។ តើប្រជាពលរដ្ឋជនបទមានក្តីសោមនស្សនឹងសេរីភាពទាំងឡាយ ដែលទទួលបានពីរបបប្រជាធិបតេយ្យ និងការរីកចម្រើននៃសេដ្ឋកិច្ចដែរឬទេ?

ជំពូកនេះ (១) ពិចារណាលើតារាងចំណាត់ថ្នាក់អភិវឌ្ឍន៍មនុស្សរបស់កម្ពុជា កត្តាសង្គម កំណើនសេដ្ឋកិច្ច កម្រិតនៃភាពក្រីក្រ និងនិន្នាការស្ថានភាពអក្ខរកម្ម/ការអប់រំ សុខភាព គំរូលំនៅដ្ឋាន និងទឹកស្អាតសម្រាប់បរិភោគ (២) លើកបង្ហាញអំពីដំណើរនៃការអភិវឌ្ឍតាមរយៈសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ការប្រៀបធៀបដំណើរអភិវឌ្ឍន៍ជាតិជាមួយនឹងប្រទេសនៅក្នុងតំបន់ និងសេចក្តីសន្និដ្ឋានដោយវិភាគលើជំហរអភិវឌ្ឍន៍មនុស្សសម្រាប់ខេត្តនីមួយៗ នៃខេត្ត-ក្រុងទាំង ២៤ នៃព្រះរាជាណាចក្រកម្ពុជា។

## ២.១ តារាងចំណាត់ថ្នាក់អភិវឌ្ឍន៍មនុស្សរបស់កម្ពុជា

### *អំពីសង្គម*

កម្ពុជាបានក្លាយជាប្រទេសប្រជាធិបតេយ្យពហុបក្សនៅឆ្នាំ ១៩៩៣ ហើយបានរៀបចំការបោះឆ្នោតថ្នាក់ជាតិចំនួនបីដងរួចមកហើយ ដោយមានការទទួលស្គាល់យ៉ាងទូលំទូលាយថា ជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ កម្ពុជាក៏បានរៀបចំដោយជោគជ័យនូវការបោះឆ្នោតឃុំ-សង្កាត់ ចំនួនពីរដងហើយដែរនៅឆ្នាំ ២០០២ និង ២០០៧។ សង្គមស៊ីវិលបានប្រឡូកយ៉ាងសកម្មក្នុងការប្តេជ្ញាលើកកម្ពស់សិទ្ធិមនុស្ស បញ្ហាក្រុមជនជាតិភាគតិច និងយុគភាពយេនឌ័រ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើនដែលប្រតិបត្តិការនៅកម្ពុជា ហើយខ្លះទៀតធ្វើការលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច។ លើសពីនេះទៀត សារព័ត៌មាន វិទ្យុ និងទូរទស្សន៍ក៏បានចូលរួមយ៉ាងសកម្មផងដែរ។

ដូចប្រទេសជាច្រើនក្នុងទ្វីបអាស៊ីដែរ កម្ពុជាក៏មានបញ្ហាខ្លះៗនៅក្នុងការលើកស្ទួយលិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងកម្មសិទ្ធិលើទ្រព្យសម្បត្តិ។ កម្ពុជាត្រូវយកចិត្តទុកដាក់ជាពិសេសលើបញ្ហាសំខាន់ៗ ៤ គឺ :

**ក.** តម្រូវការក្នុងការអនុវត្តនីតិរដ្ឋប្រកបដោយប្រសិទ្ធភាព និងកម្រិតនៃអំពើពុករលួយទាប។

**ខ.** កង្វះការគ្រប់គ្រងដោយច្បាប់ និងហេដ្ឋារចនាសម្ព័ន្ធ ដែលធ្វើឱ្យការឈានឆ្ពោះទៅរកទីផ្សារនៅមានកម្រិត និងឥណទានមានអត្រាការប្រាក់ខ្ពស់។

**គ.** ការសម្រេចចិត្តនៅតែធ្វើឡើងដោយថ្នាក់ដឹកនាំកំពូល។ ទោះបីជាមានរចនាសម្ព័ន្ធគ្រប់គ្រងច្រើនជាន់ថ្នាក់ ការធ្វើសេចក្តីសម្រេចមានភាពយឺតយ៉ាវ តឹងតែង និងគ្មានប្រសិទ្ធភាព។ ការសម្រេចមានភាពមិនច្បាស់លាស់ ដោយសារមានអាជ្ញាធរច្រើនសម្រេចលើរឿងនីមួយៗ ដូចជា រឿងដីធ្លីជាដើម។

**ឃ.** រដ្ឋមានចំណូលទាប បុគ្គលិករាជការទទួលបានប្រាក់ខែតិច ដែលជាកត្តានាំឱ្យពួកគេមិនសូវខំធ្វើការ និងនៅតែខ្វះជំនាញ ដែលនាំឱ្យការផ្តល់សេវាសាធារណៈនៅមានគុណភាព និងកម្រិតទាប ជាពិសេស នៅទីជនបទ

ក្នុងចំណោមលទ្ធផលគួរឱ្យបារម្ភនានា ដែលកើតចេញពីភាពទន់ខ្សោយនៃអភិបាលកិច្ច គឺជម្លោះដីធ្លី ដែលផ្តាច់អ្នកក្រចេញពីប្រភពជីវភាពរស់នៅរបស់ពួកគេ។ អ្នកដែលទទួលផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ គឺនៅខេត្តខាងលិច និងឦសាន ប៉ុន្តែក៏មានសេចក្តីរាយការណ៍ពីទីក្រុងលើការបាត់បង់ដីធ្លី និងផ្ទះសម្បែងនៃជនចំណាកស្រុកផងដែរ។ រីឯការធ្វើចំណាកស្រុកពីតំបន់ជនបទមួយទៅជនបទមួយទៀត ដើម្បីស្វែងរកជីវភាពប្រសើរជាងមុនក៏មានច្រើន ហើយនេះក៏ផ្នែកមួយ ដោយសារពួកគេមិនមានសិទ្ធិកាន់កាប់ដីប្រកបដោយសុវត្ថិភាព រួមផ្សំនឹងការធ្វើចំណាកស្រុកផងដែរ។ សហគមន៍ជនជាតិភាគតិចទទួលផលប៉ះពាល់អវិជ្ជមានជាខ្លាំង ដោយសារចំណាកស្រុកប្រភេទនេះ។

## កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាបានកើនយ៉ាងឆាប់រហ័សក្នុងរយៈពេលមួយទសវត្សរ៍កន្លះកន្លងមកនេះ ។ ក្នុងខណៈដែលអត្រាកំណើនទូទៅជាមធ្យម មានប្រហែល ៨% ក្នុងមួយឆ្នាំ (២០០០រៀលក្នុងមួយដុល្លារ) មានការធ្លាក់ចុះទៅវិញនៅឆ្នាំ ១៩៩៧ ១៩៩៨ ២០០១ និងឆ្នាំ ២០០២ ដោយសារវិបត្តិហិរញ្ញវត្ថុនៅអាស៊ី វិបត្តិនយោបាយផ្ទៃក្នុង និងគ្រោះធម្មជាតិជាបន្តបន្ទាប់ ដូចជាគ្រោះទឹកជំនន់ និងភាពរាំងស្ងួត (រូប ២.១) ។ ចាប់ពីឆ្នាំ ២០០២ មក ចំណូលក៏បានកើនឡើងយ៉ាងលឿន និងយ៉ាងទៀងទាត់ ។ បើគិតជាប្រាក់ដុល្លារ កំណើននេះយឺតជាង កំណើនកាលពីទសវត្សរ៍ឆ្នាំ ១៩៩០ ថ្វីបើមានការធ្លាក់ចុះតម្លៃប្រាក់រៀលកាលពីឆ្នាំ ១៩៩៧ និង ១៩៩៨ ក៏ដោយ ។ ចាប់ពីនោះមក ការប្រើប្រាក់ដុល្លារស្ទើរតែទាំងស្រុងនៅក្នុងសេដ្ឋកិច្ចកម្ពុជា បានជួយរក្សាស្ថិរភាពនៃអំណាចទិញនៅក្នុងប្រទេស ។

*រូបភាព ២.១ : អត្រាផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០០៥ (២០០០ រៀលក្នុងមួយដុល្លារ)*



*ប្រភព : រាជរដ្ឋាភិបាល (២០០៦ខ)*

នៅក្នុងឆ្នាំមុនៗ (ប្រហែលជាក្នុងឆ្នាំ ១៩៩៦) ចំណែកនៃវិស័យកសិកម្មក្នុងផលិតផលក្នុងស្រុកសរុប (ផសស) មានជាង ៤៥% ។ ចំណែកបន្ទាប់បានមកពីសេវាកម្មផ្សេងៗ និងចំណែកពីឧស្សាហកម្មដ៏ស្តួចស្តើង គឺតិចជាង ១៥% (រូបភាព ២.២) ។ តួលេខនេះបានប្រែប្រួលយ៉ាងច្រើន ដោយមានការរួមចំណែកនៃវិស័យកសិកម្មក្នុងសេដ្ឋកិច្ច ដែលចុះថយនៅកម្រិតរវាងពី ៣០ ទៅ ៣២% នៃផសស និងការរួមចំណែកពីវិស័យឧស្សាហកម្ម ដែលបានកើនឡើងជាង ២៧% ។ ការរួមចំណែកពីសេវាកម្មទៅក្នុងសេដ្ឋកិច្ចទូទៅ នៅមានកម្រិតថេរពី ៣៥ ទៅ ៤០% ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៥ (រូបភាព ២.២) ។

*អំពីអត្រា និងការបែងចែកកំណើនសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចកម្ពុជា អាចមានការពន្យល់ ៤ :*

**ក.** ជាគោលការណ៍ ការថយចុះនៃចំណែកវិស័យកសិកម្មនៅក្នុងផសស គឺជាសញ្ញានៃវឌ្ឍនភាព ។ កសិកម្មមានភាពយឺតយ៉ាវនៅដើមសហស្សវត្សរ៍ថ្មី ទើបតែនៅឆ្នាំ ២០០៥ ដែលផលិតផលស្រូវបានកើនឡើង ៤៤% លើសពីឆ្នាំកន្លងទៅ ។ កំណើននេះមួយផ្នែកធំបណ្តាលមកពីការងើបឡើងវិញពីស្ថានភាព[៤] នៃគ្រោះរាំងស្ងួតនាពេលមុន ។ អត្រាទិន្នផលស្រូវចំនួន ២,១៨ តោន ក្នុងមួយហិចតា (ជាមធ្យមក្នុងឆ្នាំ ២០០៣-២០០៥) មានន័យថា កសិកម្មនៅមានផ្លូវដ៏វែង ដើម្បីសម្រេចបាននូវសក្តានុពល[៥] ពេញលេញរបស់ខ្លួន ។ ដោយហេតុថា កសិកម្ម និងសកម្មភាពបន្ទាប់បន្សំផ្សេងៗ ផ្តល់នូវការងារជាច្រើនដល់មនុស្សនៅទីជនបទ ។ អត្រាទិន្នផលទាប និងមិនស្មើគ្នានៅតាមតំបន់នានា មានឥទ្ធិពលទៅលើប្រាក់ចំណូលរបស់កសិករ ដែលជាកត្តាធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍមនុស្ស ។ កសិកម្ម ដែលមានភាពលូតលាស់ដុះដាលល្អ តែងតែជាមូលដ្ឋានសម្រាប់ពង្រីកសកម្មភាពសេដ្ឋកិច្ចឱ្យមានកាន់តែសម្បូរណ៍បែប ។

---

(៤) សូមមើលអត្ថបទនិពន្ធដោយ Dapice, Valley and Wilkinson (២០០៦) ។

(៥) ក្រុមការងារបច្ចេកទេស (TWG) បានធ្វើការសង្កេតស្រដៀងគ្នាមួយ ស្តីពីកសិកម្ម និងទឹក ។ សូមមើលអត្ថបទ TWG-Agriculture and Water ទំព័រ ២៤ ។

*ក្តីបារម្ភមួយ គឺថា វិស័យកាត់ដេរសម្លៀកបំពាក់ តំណាងឱ្យប្រហែលជា ៥០% នៃផលិតផលឧស្សាហកម្មទាំងអស់ នៅក្នុងឆ្នាំ ២០០៥*

*រូបភាព ២.២ : ការរួមចំណែកនៃ ផសស តាមផ្នែកនានានៅកម្ពុជា ឆ្នាំ ១៩៩៣-២០០៥*




*កំណត់សម្គាល់ : ភាគរយទាំងអស់មិនដល់១០០ ទេ ពីព្រោះពន្ធដារមិនមានបង្ហាញនៅក្នុងក្រាហ្វិក ។ ប្រភព : រាជរដ្ឋាភិបាល (២០០៦ខ)*

**ខ.** កំណើនវិស័យឧស្សាហកម្មមានលក្ខណៈគួរឱ្យស្ញើចសរសើរ ដែលក្នុងនោះ កម្រិតនៃការនាំចេញសម្លៀកបំពាក់កន្លងមក បានត្រូវរក្សាឱ្យនៅដដែល ថ្វីត្បិតតែកិច្ចព្រមព្រៀងនាំចេញសម្លៀកបំពាក់ (MFA) ត្រូវបានផុតកំណត់ហើយក៏ដោយ ។ ប៉ុន្តែមានក្តីបារម្ភមួយអំពីវិស័យកាត់ដេរសម្លៀកបំពាក់ ដែលមានប្រមាណជា ៥០% នៃផលិតផលឧស្សាហកម្មសរុបនៅឆ្នាំ ២០០៥ (៦៩% នៃផលិតផលកម្មន្តសាល) ដែលកើនឡើងពី ៤២% នៅក្នុងឆ្នាំ ២០០០ ហើយដែលមានត្រឹមតែ ៩% ទេ នៅក្នុងឆ្នាំ ១៩៩៦ ។ ការពឹងផ្អែកស្ទើរតែទាំងស្រុង និងកាន់តែកើនឡើងទៅលើវិស័យតែមួយមុខបែបនេះ គឺជាហានិភ័យដ៏ខ្ពស់បំផុត ជាពិសេស វិស័យនេះមិនមានសមាហរណកម្មតាមខ្សែបណ្តោយបាននាំឱ្យមានការដាក់កម្រិតត្រួតពិនិត្យមើលលើតម្លៃ[6] ។ ទីផ្សារសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក បានដាក់កម្រិតបរិមាណលើការនាំចូលផលិតផលពីប្រទេសចិន ប៉ុន្តែតាមវិធានអង្គការពាណិជ្ជកម្មពិភពលោក (WTO) ការកំណត់នេះប្រហែលជាមិនបន្តយូរតទៅទៀតទេ ។

**គ.** ទេសចរណ៍មានចំណែកមួយធំនៅក្នុងវិស័យសេវាកម្ម ដោយមានសកម្មភាពតែនៅតាមតំបន់ជុំវិញប្រាសាទនៃខេត្តសៀមរាបប៉ុណ្ណោះ ។ លក្ខណៈនេះមិនបានជួយបង្កើតការងារច្រើននៅក្នុងសេដ្ឋកិច្ចមូលដ្ឋានទេ ដោយសារសូម្បីតែផលិតផលបន្លែ ផ្លែឈើ និងអាហារផ្សេងៗ ដែលប្រើប្រាស់នៅតាមសណ្ឋាគារទាំងនោះ ក៏ត្រូវបាននាំចូលពីប្រទេសជិតខាងដែរ ពោលគឺមិនមែនជាដំណាំដាំដុះនៅក្នុងស្រុកទេ ។ គួរឱ្យកត់សម្គាល់ផងដែរថា សៀមរាប គឺជាខេត្តមួយក្នុងចំណោមខេត្តបី ដែលក្រីក្រជាងគេ ។

**ឃ.** សកម្មភាពមិនមែនកសិកម្មនានា ប្រមូលផ្តុំយ៉ាងខ្លាំងនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និងទីប្រជុំជន ១ ឬ ២ ទៀតនៅជិតព្រំដែន ។ តំបន់ស្រែចំការជាច្រើនទៀតនៅក្នុងប្រទេស ប្រជាពលរដ្ឋប្រកបរបបចិញ្ចឹមជីវិតដោយពឹងផ្អែកលើវិស័យកសិកម្ម ដូចជាធ្វើស្រែចំការ នេសាទត្រី និងទាញយកផលពីព្រៃឈើ ។

## *កម្រិតភាពក្រីក្រ និងនិន្នាការ*[7]

អង្កេតសេដ្ឋកិច្ចសង្គម (SES) នៅក្នុងឆ្នាំ ២០០៣-២០០៤ មានលក្ខណៈដ៏ទូលំទូលាយជាងគេក្នុងចំណោមបណ្តាអង្កេតកន្លងមក ។ ការរាប់ចំនួនអ្នកក្រីក្រ នៅថ្នាក់ខេត្ត-ក្រុង មានបង្ហាញជូននៅក្នុងរូបភាព ២.៣ ។

---

(៦) មានន័យថា : ឧស្សាហកម្មវាយនភ័ណ្ឌកម្ពុជារកឃើញការលំបាករបស់ខ្លួនក្នុងការប្រកួតប្រជែងជាអន្តរជាតិ ទន្ទឹមនឹងប្រាក់បំណាច់របស់កម្មករស្មើនឹង US$ 60-65 ក្នុងមួយខែ (កាសែតភ្នំពេញប៉ុស្តិ៍ ២១ កញ្ញា - ៥ តុលា ឆ្នាំ ២០០៦) ។

(៧) ប្រភពទិន្នន័យសម្រាប់ផ្នែកនេះ : រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ២០០៦, ធនាគារពិភពលោកឆ្នាំ ២០០៦ ។

*រូបភាព ២.៣ : ការកើតឡើងនៃភាពក្រីក្រនៅកម្ពុជា តាមតំបន់ភូមិសាស្ត្រទូលំទូលាយ ឆ្នាំ ២០០៣-២០០៤*



*ប្រភព : រាជរដ្ឋាភិបាល (២០០៦)*

**ក.** សមាមាត្រពលរដ្ឋដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រក្នុងឆ្នាំ ២០០៣-២០០៤ មានចំនួន ៣៤,៦៨%។ ការកើតឡើងនៃភាពក្រីក្រនៅតំបន់ជនបទមានកម្រិតខ្ពស់ជាង គឺប្រហែល ៣៩% ហើយនៅតាមទីប្រជុំជនក្រៅក្រុងភ្នំពេញ២៤% រីឯនៅក្នុងទីក្រុងភ្នំពេញវិញមានត្រឹមតែ ៥%។ ភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយមានកម្រិតខ្ពស់ : នៅតំបន់ខ្ពង់រាប ឬតំបន់ភ្នំ (ខាងជើង និងឦសាន) ការកើតឡើងនៃភាពក្រីក្រមានខ្ពស់ជាងគេបំផុត គឺ ៥២% បន្ទាប់មកទៀត នៅតាមតំបន់ទន្លេសាបមាន ៤៣% នៅតាមវាលទំនាបដីសណ្តទន្លេមេគង្គមាន ៣២% និងនៅតំបន់ឆ្នេរសមុទ្រមាន ២៧%។ កត្តាមួយដែលជួយសម្រាលភាពធ្ងន់ធ្ងរ គឺនៅតាមតំបន់ភ្នំពុំសូវមានមនុស្សរស់នៅទេ ប៉ុន្តែដោយសារផ្នែកជាច្រើននៅតំបន់នោះ មានជនជាតិភាគតិចរស់នៅ នោះមានន័យថា ក្នុងចំណោមប្រជាពលរដ្ឋនៅតំបន់នេះ ជនជាតិភាគតិចទាំងនោះ មានសមាមាត្រនៃអ្នកក្រីក្រខ្ពស់ជាង។

**ខ.** ក្នុងអង្កេតនៅទូទាំងប្រទេស ដែលបានធ្វើកាលពីឆ្នាំ ១៩៩៣-១៩៩៤ ឆ្នាំ ១៩៩៦ ១៩៩៧ ១៩៩៩ និងឆ្នាំ ២០០៣-២០០៤ មិនមានទិន្នន័យណាអាចប្រៀបធៀបគ្នាបានទេ ដោយសារអង្កេតទាំងនោះ មានទម្រង់ និងសំណួរខុសៗពីគ្នា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី វិទ្យាស្ថានជាតិស្ថិតិ (NIS) បានផ្ទៀងផ្ទាត់យ៉ាងយកចិត្តទុកដាក់ទៅលើវិស័យដែលត្រូវនឹងអង្កេតនៅឆ្នាំ ២០០៣-២០០៤ ជាមួយនឹងវិស័យដែលត្រូវនឹងអង្កេតនៅឆ្នាំ ១៩៩៣-១៩៩៤។ ការប្រៀបធៀបទិន្នន័យរវាងអង្កេតទាំងពីរនេះ (ឧទាហរណ៍ : ចំពោះវិស័យដែលអាចប្រៀបធៀបគ្នាបានតាមមូលដ្ឋានភូមិសាស្ត្រ : ប្រហែល ៥៦% នៃភូមិ ៨៤% នៅទីប្រជុំជនក្រៅក្រុងភ្នំពេញ និងក្នុងក្រុងភ្នំពេញ) បង្ហាញឱ្យឃើញថា ការកើតឡើងនៃភាពក្រីក្រនៅតាមតំបន់ទាំងអស់នេះបានថយចុះពី ៣៩% កាលពីឆ្នាំ ១៩៩៣-១៩៩៤ មកនៅត្រឹម ២៨% ក្នុងឆ្នាំ ២០០៣-២០០៤។ ជាការសន្និដ្ឋាន បច្ចុប្បន្ននេះ ប្រជាពលរដ្ឋបានចាប់ផ្តើមប្រើប្រាស់សម្ភារៈ (មិនមែនម្ហូបអាហារ) ច្រើនជាងកាលពី ១០ ឆ្នាំមុន ដែលនេះ គឺជាសូចនាករមួយទៀតនៃកំណើនទ្រព្យធន។ ជម្រៅនៃភាពក្រីក្រ (គឺជាគម្លាតរវាងការប្រើប្រាស់សម្រាប់ម្នាក់ៗនៃបន្ទាត់ភាពក្រីក្រ និងការប្រើប្រាស់សម្រាប់ម្នាក់ៗក្នុងគ្រួសារក្រីក្របំផុត) ក៏បានថយចុះដែរ។ ក្នុងពេលជាមួយគ្នានេះ វិសមភាពបានកើនឡើង : ការប្រើប្រាស់របស់អ្នកក្រីក្របំផុត ដែលមានចំនួន ១/៥ នៃប្រជាពលរដ្ឋបានកើនឡើង ៨% ពីឆ្នាំ ១៩៩៣-១៩៩៤ ទៅឆ្នាំ ២០០៤ ប៉ុន្តែការប្រើប្រាស់របស់ពួកអ្នកមានបំផុតបានកើនឡើងប្រហែល ៤៥% (មធ្យមភាគសម្រាប់ប្រទេសទាំងមូល : ៣២%)។ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន ដែលមានប្រាក់ចំណូលទាប មានតែប្រទេសហ្វីលីពីនទេ ដែលមានវិសមភាពខ្ពស់ជាងគេក្នុងការប្រើប្រាស់។

## ប្រអប់ ២.១ : ការតភ្ជាប់ប្រព័ន្ធទូរស័ព្ទទៅកាន់ភូមិ-ឃុំ



ជាមួយនឹងសក្តានុពលនៃឥណទានខ្នាតតូច ដែលជម្រុញឱ្យមានការផ្តល់រង្វាន់ណូបែលសន្តិភាពនៅឆ្នាំ ២០០៦ គំនិតផ្តួចផ្តើម ដែលមានអនុភាពប្រកបដោយការច្នៃប្រឌិតស្រដៀងគ្នានេះ ត្រូវបានយកមកអនុវត្តសាកល្បងនៅក្នុងបណ្តាខេត្តជាច្រើននៃប្រទេសកម្ពុជា នៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៧។

ក្នុងកិច្ចសហការជាមួយក្រុមហ៊ុនទូរស័ព្ទដៃ NOKIA-KTH សាជីវកម្មអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស (GTZ) ក្រុមហ៊ុន Camshin និងស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជាមួយចំនួន កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបានជួយធ្វើឱ្យបានសម្រេចនូវគំនិតផ្តួចផ្តើមសេវាទូរស័ព្ទឯកជននៅតាមភូមិក្នុងឃុំចំនួន ៤០ នៅខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងសៀមរាប។ កម្មវិធីនេះ ជាផ្នែកនៃគំនិតផ្តួចផ្តើម នៃកំណើនអាជីវកម្មប្រកបដោយចីរភាព (GSB) របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដែលស្វែងរក "ទីផ្សារដើម្បីដោះស្រាយភាពក្រីក្រ តាមរយៈការវិនិយោគលើអាជីវកម្មច្បាស់លាស់ ដោយលើកកម្ពស់ភាពជាដៃគូសាធារណៈ និងឯកជន"។

តាមរយៈកម្មវិធីនេះ ការីទូរស័ព្ទភូមិម្នាក់មានទូរស័ព្ទដៃមួយសម្រាប់ ដែលមានទូរស័ព្ទ និងឧបករណ៍សាកថ្មប្រើពន្លឺព្រះអាទិត្យ សៀវភៅទូរស័ព្ទមួយក្បាល និងឥណទានទូរស័ព្ទ។ បន្ទាប់មក ការីនេះផ្តល់សេវាទូរស័ព្ទក្នុងអាត្រាទាបដល់សហគមន៍របស់គេ សម្រាប់រយៈពេលសាកល្បងពីបីទៅប្រាំមួយខែ ដើម្បីរកប្រាក់ចំណូល។

សម្រាប់បងប្រុស អ៊ុំ ផល្លី ដែលជាកសិករ និងជាអ្នកតំណាងវេជ្ជសាស្ត្រនៅឃុំតាំងស្រី ស្រុកបាធាយ ខេត្តសៀមរាប ការប្រើប្រាស់ទូរស័ព្ទដ៏មានតម្លៃថោកជាប្រភពរកប្រាក់ចំណូលនៅក្នុងសហគមន៍ជាគំនិតដ៏ថ្មីស្រឡាងមួយ។ បងប្រុសដែលជាឪពុករបស់កូនពីរនាក់ និងការីថ្មីប្រចាំភូមិបានពន្យល់ថា "ខ្ញុំមានការរំភើបណាស់ ដែលអាចមានឱកាសរកប្រាក់ចំណូលបន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់គ្រួសារខ្ញុំ"។ បងប្រុស ផល្លី បានបន្ថែមទៀតថា "ខ្ញុំគិតថាអ្នកភូមិទាំងអស់នឹងអបអរចំពោះទូរស័ព្ទថ្មីនេះ ព្រោះពួកគេអាចទូរស័ព្ទទាក់ទងទៅក្រុមគ្រួសាររបស់ពួកគេ ទោះបីជានៅពេលដែលពួកគេកំពុងធ្វើការ និងរស់នៅឆ្ងាយក៏ដោយ"។

លោក ឆាលស៍ អាស្សលី (Charles Ashley) អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍អាជីវកម្មរបស់ក្រុមហ៊ុន Nokia-KTH បានគូសបញ្ជាក់ថា ការអនុវត្តគំនិតផ្តួចផ្តើមឈ្នះ-ឈ្នះនេះ មានសារប្រយោជន៍ច្រើន។ សព្វថ្ងៃនេះ មានអ្នកប្រើទូរស័ព្ទចល័តចំនួនមួយពាន់លាននាក់នៅលើពិភពលោក។ នៅពេលដែលលោក អាស្សលី និងផល្លី កំពុងតែមើលអ្នកបច្ចេកទេសស្រាយកញ្ចប់ប្រដាប់សាកថ្មដោយពន្លឺព្រះអាទិត្យ លោកពន្យល់ថា ទីផ្សារនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ នឹងមានអ្នកប្រើទូរស័ព្ទចល័តនេះមួយពាន់លាននាក់ទៀត។

ខណៈដែលគម្រោងសាកល្បងនេះ គ្រាន់តែជាដំណាក់កាលដំបូងរបស់កម្មវិធីភាពជាដៃគូចំនួន ៥០០ នេះ អាចនឹងបានសម្រេចក្នុងរយៈពេលមួយឆ្នាំ ប្រសិនបើគម្រោងមីក្រូហិរញ្ញវត្ថុមានដំណើរការទៅមុខ។ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ថ្វីត្បិតតែមានភូមិ-ឃុំចំនួន ៨០ភាគរយ អាចតភ្ជាប់បណ្តាញបាន។

លោក ហ្សង់ ប៊ុយវែរ (Jean Boisvert) ភ្នាក់ងារគម្រោងនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិឃើញនូវសារប្រយោជន៍ជាច្រើនក្នុងការនាំយកទូរស័ព្ទចល័តទៅដល់តំបន់ជនបទដាច់ស្រយាល។ លោក Borisvert បាននិយាយថា "ទូរស័ព្ទទាំងនេះអាចយកទៅប្រើ ដើម្បីបំបាត់គម្លាតខ្លះក្នុងខ្សែសង្វាក់តម្លៃសម្រាប់កសិករ"។ ការប្រើប្រាស់សេវានេះនៅក្នុងភូមិ អ្នកភូមិអាចទូរស័ព្ទជាមុនទៅទីផ្សារ និងសាកសួរតម្លៃ និងបញ្ជាទិញជាមុនជាជាងខាតពេលចូលសាកសួរ។ គម្រោងនេះ មានបំណងផ្តល់ជូនពលរដ្ឋជនបទនូវសេវាព័ត៌មានដ៏មានតម្លៃ និងជួយតភ្ជាប់ប្រព័ន្ធឌីជីថល។

**គ.** ភាពក្រីក្របានថយចុះមិនស្មើគ្នាទេក្នុងចំណោមក្រុមមនុស្ស និងក្នុងតំបន់នានា។ តំបន់ជនក្រីក្រច្រើន (មនុស្ស និងតំបន់) បានទទួលផលតិចជាងតំបន់អ្នកដែលមិនសូវក្រីក្រ និងអ្នកមិនក្រ។ ការកើតឡើងនៃភាពក្រីក្រ បានកើនឡើងនៅតំបន់ខ្ពង់រាប និងតំបន់ភ្នំ ប៉ុន្តែនៅតំបន់ដទៃទៀត ការកើនឡើងនេះបានថយចុះ។ ជាលទ្ធផល គម្លាតជីវភាពរស់នៅរវាងតំបន់ និងក្រុមមនុស្សទីទៃៗពីគ្នានេះ បានរីកធំឡើងជាខ្លាំង[៨]។

នៅប្រទេសដទៃទៀតក្នុងតំបន់អាស៊ី ភាពក្រីក្របានត្រូវកាត់បន្ថយតាមរយៈការបង្កើនទិន្នផលកសិកម្ម (ឧ. ពលរដ្ឋរកប្រាក់ចំណូលបានច្រើនពីកសិកម្ម) និងបង្កើនមុខរបរផ្សេងៗពីគ្នា (ឧ. ពលរដ្ឋមានការងារធ្វើច្រើនក្រៅអំពីរបរកសិកម្ម)។ នៅកម្ពុជា មានទំនាក់ទំនងបញ្ច្រាសគ្នារវាងការកើនឡើងនៃភាពក្រីក្រនៅក្នុងខេត្ត និងផលិតភាពកសិកម្មរបស់ខេត្ត (ស្រូវវស្សាគិតជាចំនួនតោនក្នុងមួយហិចតា) (រូបភាព ២.៤)។ ដូច្នេះការធ្វើឱ្យប្រសើរឡើងនូវអាត្រាទិន្នផលកសិកម្ម ក៏អាចជួយកាត់បន្ថយភាពក្រីក្របានដែរ (ភាពអាចផ្លាស់ប្តូរបាននៃការកាត់បន្ថយការកើតឡើងនៃភាពក្រីក្រអាស្រ័យតាមអត្រាទិន្នផលដែលស្មើនឹង ០,៩៥)។ ក្នុងន័យសង្ខេប គឺភាពក្រីក្រអាចត្រូវបានកាត់បន្ថយ ប្រសិនបើអត្រានៃទិន្នផល និងការងារនៅទីជនបទកើនឡើង។

*រូបភាព ២.៤ : ទំនាក់ទំនងរវាងអត្រារាប់ចំនួនអ្នកក្រីក្រនៅតាមខេត្ត (ឆ្នាំ ២០០៣-២០០៤ និងមធ្យមភាគនៃទិន្នផលស្រូវវស្សាប្រចាំខេត្ត (មធ្យមភាគ ឆ្នាំ ២០០៣-២០០៥)*



| ល.រ | ខេត្ត |
|---|---|
| ១ | បន្ទាយមានជ័យ |
| ២ | បាត់ដំបង |
| ៣ | កំពង់ចាម |
| ៤ | កំពង់ឆ្នាំង |
| ៥ | កំពង់ស្ពឺ |
| ៦ | កំពង់ធំ |
| ៧ | កំពត |
| ៨ | កណ្តាល |
| ៩ | កែប |
| ១០ | កោះកុង |
| ១១ | ក្រចេះ |
| ១២ | មណ្ឌលគិរី |
| ១៣ | ឧត្តរមានជ័យ |
| ១៤ | ប៉ៃលិន |
| ១៥ | ភ្នំពេញ |
| ១៦ | ព្រះវិហារ |
| ១៧ | ព្រៃវែង |
| ១៨ | ពោធិ៍សាត់ |
| ១៩ | រតនៈគិរី |
| ២០ | សៀមរាប |
| ២១ | ក្រុងព្រះសីហនុ |
| ២២ | ស្ទឹងត្រែង |
| ២៣ | ស្វាយរៀង |
| ២៤ | តាកែវ |

*សម្គាល់ :* *Correlation coefficient –r =0.446 accounting for 16.2 % of variation.*

*ប្រភព : សម្រាប់ទិន្នផលស្រូវ RGC (២០០៤, ២០០៥, ២០០៦ c); សម្រាប់ភាពក្រីក្រ RGC (២០០៦)*

## *ស្ថានភាពអក្ខរកម្ម និងការអប់រំ*

កម្ពុជាបានធ្វើឱ្យរីកចម្រើនល្អគួរឱ្យកត់សម្គាល់ក្នុងវិស័យអក្ខរកម្ម និងអប់រំ : ក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងមកគិតពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៤ មនុស្សពេញវ័យចេះអក្សរបានកើនពី ៦៧,៣% ទៅ ៧៣,៦% (ប្រុសពី ៧៩,៥ ទៅ ៨៤,៧% ស្ត្រីពី ៥៧ ទៅ ៦៤,៧%)។ ថ្វីត្បិតតែគម្លាតយេនឌ័រក្នុងវិស័យអក្ខរកម្មនៅតែមានក៏ដោយ តែក្នុងរយៈកាលប្រាំមួយឆ្នាំកន្លងមក គម្លាតនេះក៏បានថយចុះដែរ (រូបភាព ២.៥)។

---

*(៨) ផ្អែកលើប្រភពទិន្នន័យវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានបង្ហាញថា ប្រាក់ឈ្នួលរបស់កម្មករមិនបានកើនឡើងគួរឱ្យកត់សម្គាល់ទេ ក្នុងកំឡុងឆ្នាំ ១៩៩៨-២០០៦។ កំណើននេះនឹងបន្តបង្ហាញពីគម្លាតពីក្រុមអាជីពដទៃទៀត។*

*រូបភាព ២.៥ : អត្រាអក្ខរកម្មមនុស្សពេញវ័យនៅកម្ពុជា ឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៤*




*ប្រភព : អន្តរជំរឿននៅកម្ពុជា ឆ្នាំ ២០០៤*

ដើម្បីកំណត់កំណើនអក្ខរកម្មរវាងឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៤ រូបមន្តដូចខាងក្រោមនេះ ត្រូវបានប្រើប្រាស់ :

អក្ខរកម្មតាមកម្រិតនីមួយៗ(IL)=[(អ្នកចេះអក្សរ(ឆ្នាំ២០០៤) - អ្នកចេះអក្សរឆ្នាំ១៩៩៨/(ប្រជាពលរដ្ឋឆ្នាំ២០០៤-ប្រជាពលរដ្ឋឆ្នាំ ១៩៩៨)]

ប្រសិនបើ IL មានចំនួនច្រើនជាង ១ កំណើនអក្ខរកម្មកើនលឿនជាងកំណើនប្រជាពលរដ្ឋ។ ប្រសិនបើ IL ស្មើនឹង ១ នោះមិនមានកំណើនបន្ថែមលើអក្ខរកម្មទេ ហើយប្រសិនបើ IL តិចជាង ១ គឺមានន័យថា កំណើនប្រជាពលរដ្ឋកើនឡើងច្រើនជាងកំណើនអ្នកចេះអក្សរ។ ទិន្នន័យទាំងអស់ គឺជាទិន្នន័យសម្រាប់ប្រជាពលរដ្ឋអាយុពី ៧ ឆ្នាំ ឡើងទៅ។

*រូបភាព ២.៦ : អត្រាអក្ខរកម្មតាមកម្រិតប្រជាពលរដ្ឋ ក្នុងឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៤*




*ប្រភព : គណនាតាម CIPS-ឆ្នាំ ២០០៤*

មិនត្រឹមតែរាប់បញ្ចូលមនុស្សពេញវ័យប៉ុណ្ណោះទេ គឺត្រូវរាប់បញ្ចូលទាំងប្រជាពលរដ្ឋអាយុពី ៧ ឆ្នាំ ឡើងទៅផង ទើបអាចរកឃើញនូវការខំប្រឹងប្រែងថ្មីៗ ដើម្បីធ្វើឱ្យចម្រើនឡើងដល់អក្ខរកម្ម។ ក្រុងភ្នំពេញ ខេត្តកំពង់ចាម កំពង់ធំ សៀមរាប កោះកុង និងក្រុងព្រះសីហនុ ជាខេត្ត-ក្រុង ដែលមានកំណើនអក្ខរកម្មខ្ពស់ជាងគេ ហើយដែលកំណើនអក្ខរកម្មលឿនជាងកំណើនប្រជាពលរដ្ឋ។ អក្ខរកម្មក្នុងចំណោមពលរដ្ឋតាមកម្រិតនានាក៏បានកើនឡើងដែរ នៅតាមខេត្តភាគពាយ័ព្យ (ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ)។ រីឯខេត្ត-ក្រុង ដែលអត្រាអក្ខរកម្មបានថយចុះ គឺខេត្តបាត់ដំបង ក្រុងប៉ៃលិន ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។ ការមកដល់ថ្មីនៃជនអន្តោប្រវេសន៍ ដែលកូនចៅរបស់គេមិនមានលទ្ធភាពអាចចូលរៀនសាលាបាន គឺជាមូលហេតុដែលនាំឱ្យខេត្តទាំងនេះ មានកម្រិតអក្ខរកម្មមិនល្អ (រូបភាព ២.៦)។

មធ្យមភាគនៃអត្រាពិតចូលរៀនថ្មីនៅក្នុងប្រទេស (ការចូលរៀននៅសាលាបឋមសិក្សា គិតជាសមាមាត្រតាមកម្រិតអាយុ) ស្មើនឹង ៨២.៦ ក្នុងឆ្នាំ ២០០៥-២០០៦។ នេះជាអត្រាកំណើនមួយគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅតែទាបជាងឆ្ងាយពី ១០០%។ អត្រានេះស្ថិតនៅក្នុងចំណោមអត្រាទាបជាងគេបំផុតប្រចាំតំបន់អាស៊ីអាគ្នេយ៍[៩]។ បើប្រៀបទៅនឹងអត្រាជាមធ្យមនៅទូទាំងប្រទេស អត្រាពិតចូលរៀនថ្មីនៅតាមខេត្តតំបន់ព្រៃសានមានកំណើនទាបជាងគេបំផុត។ នៅខេត្តដែលបានអភិវឌ្ឍជាងគេខ្លះ ដូចជា ខេត្តបាត់ដំបងជាដើម ក៏ស្ថិតនៅក្នុងចំណាត់ថ្នាក់ទាបជាងជាមធ្យមនៅទូទាំងប្រទេសនៃអត្រាពិតចូលរៀនថ្មីនៅសាលាបឋមសិក្សាដែរ (រូបភាព ២.៨)។ ជាចុងបញ្ចប់ក្រៅពីខេត្តកំពង់ធំ កំពង់ស្ពឺ ឧត្តរមានជ័យ រតនៈគិរី និងខេត្តតាកែវ អត្រាពិតចូលរៀនថ្មីរបស់កុមារីមានទាបជាងអត្រាពិតចូលរៀនថ្មីរបស់កុមារ។ ការចុះឈ្មោះចូលរៀនមានកម្រិតទាបក្នុងពេលបច្ចុប្បន្ននេះ មានន័យថា ប្រហែលមួយទសវត្សរ៍ទៅមុខ នឹងមានមនុស្សពេញវ័យដែលមិនចេះអក្សរច្រើន។

*មធ្យមភាគនៃចំនួនឆ្នាំនៃការអប់រំក្នុងឆ្នាំ ២០០៣-២០០៤ គឺ ៣.៧។ តួលេខនេះមានកម្រិតទាបបើប្រៀបធៀបទៅក្នុងបរិបទនៃតំបន់អាស៊ីអាគ្នេយ៍*

***រូបភាព ២.៧ : អត្រាសិស្សរៀននៅថ្នាក់បឋមសិក្សាក្នុងខេត្តនីមួយៗ***



*ប្រភព : គណនាតាម CIPS-ឆ្នាំ ២០០៤*

ជាមធ្យមចំនួនឆ្នាំនៃការអប់រំក្នុងឆ្នាំ ២០០៣-២០០៤ គឺ ៣.៧ (រូបភាព ២.៩) តួលេខនេះ មានកម្រិតទាបបើប្រៀបទៅនឹងបរិបទនៃតំបន់អាស៊ីអាគ្នេយ៍។

(៩) សូមពិនិត្យមើលរបាយការណ៍ធនាគារពិភពលោក ឆ្នាំ ២០០៦ ទំព័រ ៩៧។

កត្តាសំខាន់ដែលបណ្ដាលឱ្យការអប់រំថយចុះ រួមមានពលកម្មកុមារ ដែលមានពាសពេញប្រទេសក្នុងចំនួនប្រហែល ២៣ភាគរយ ដែលជាចំនួនខ្ពស់ជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងតម្លៃយ៉ាងខ្ពស់សម្រាប់ការរៀនសូត្រ ដែលត្រូវបង់ដោយផ្ទាល់ និងដោយប្រយោល

***រូបភាព ២.៨ : អត្រាពិតចូលរៀនថ្មីក្នុងខេត្តនីមួយៗ ឆ្នាំ ២០០៥-២០០៦***



*ប្រភព : គណនាពីទិន្នន័យ EMIS ; http://www.nis.gov.kh/index.htm*

***រូបភាព ២.៩ : ចំនួនឆ្នាំជាមធ្យមដែលទទួលបានការអប់រំនៅឆ្នាំ ២០០៣-២០០៤***



*ប្រភព : SES ២០០៣-០៤*

កត្តាសំខាន់ដែលបណ្ដាលឱ្យការអប់រំថយចុះ គឺការប្រើប្រាស់ពលកម្មកុមារ ដែលមានពាសពេញប្រទេសក្នុងចំនួនប្រហែល ២៣% ដែលជាអត្រាខ្ពស់ជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងតម្លៃយ៉ាងខ្ពស់ ដែលត្រូវបង់សម្រាប់ការរៀនសូត្រទាំងដោយផ្ទាល់ និងដោយប្រយោល (ថ្លៃឯកសណ្ឋាន សម្ភារៈសម្រាប់បង្រៀន និងបង់ឈ្នួលសាលា)។ ការខ្វះខាតក្នុងផ្នែកផ្គត់ផ្គង់ រួមមាន សាលាមានគុណភាពទាប ខ្វះគ្រូល្អ និងគ្រូទទួលបានប្រាក់ខែតិច។ ដើម្បីបង្កើនការអប់រំដល់កុមារី ការសិក្សានានាក្នុងពិភពលោកបានបង្ហាញថា ការផ្ដល់បង្គន់អនាម័យ បង្កើនសាលាមធ្យមសិក្សាឱ្យច្រើនថែមទៀត រួមទាំង វិធានការណ៍គាំទ្រផ្សេងទៀតៗ ដែលអាចជម្រុញទឹកចិត្តឪពុកម្ដាយឱ្យបញ្ជូនកូនស្រីទៅសាលា។ សម្រាប់កុមារ និងកុមារី ត្រូវតែលើកទឹកចិត្តឪពុកម្ដាយឱ្យទទួលស្គាល់ថា ពួកគេនឹងមានជម្រើសតែនៅពេលណាដែលកូនប្រុស-ស្រីរបស់គាត់បានរៀនចប់បឋមសិក្សា ហើយជម្រើសនោះ គឺឱ្យកូនរកការងារធ្វើ ឬឱ្យកូននៅរៀនជាបន្តទៅទៀត។

ការសិក្សាកម្រិតខ្ពស់ និងកម្រិតបច្ចេកទេសនៅប្រទេសកម្ពុជាជាទូទៅមានភាពទន់ខ្សោយ ហើយកម្រិតនៃការអប់រំមិនដូចគ្នាទេពីស្ថាប័នសិក្សាមួយទៅស្ថាប័នសិក្សាមួយទៀត។ ក្នុងឆ្នាំថ្មីៗកន្លងមកនេះ រដ្ឋាភិបាលបានធ្វើការកែទម្រង់មួយចំនួន ដែលជាលទ្ធផលបានជួយកាត់បន្ថយការឈប់រៀនរបស់សិស្ស និងបានពង្រីកមូលដ្ឋានអប់រំនៅគ្រប់កម្រិត។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏នៅតែមានក្តីបារម្ភខ្លាំងទៅលើអាត្រាបញ្ចប់បឋមសិក្សាដែលនៅទាប (តិចជាង ៥០%) ថ្លៃឈ្នួលសិក្សា (គ្រប់កម្រិតទាំងអស់) គម្លាតយេនឌ័រ (គ្រប់ថ្នាក់) គម្លាតរវាងជនបទ និងទីប្រជុំជន គម្លាតពីខេត្តមួយទៅខេត្តមួយ និងគុណភាពនៃការអប់រំ[១០]។

ការសិក្សាថ្នាក់ខ្ពស់ និងថ្នាក់បច្ចេកទេស នៅប្រទេសកម្ពុជា ជាទូទៅមាន ភាពទន់ខ្សោយ ហើយកម្រិតនៃការ អប់រំមិនដូចគ្នាទេ ពីស្ថាប័នសិក្សាមួយ ទៅស្ថាប័នសិក្សា មួយទៀត

## ស្ថានភាពនៃសុខភាព

ដូចវិស័យអប់រំដែរ ស្ថានភាពនៃសុខភាពនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ អាយុកាលមធ្យមសម្រាប់បុរសនៅកម្ពុជាគឺ ៦០ ឆ្នាំ ក្នុងឆ្នាំ ២០០៤ ដែលបានកើនឡើងយ៉ាងច្រើនពីអាយុ ៥២ នៅឆ្នាំ ១៩៩៨ ហើយសម្រាប់ស្ត្រី គឺ ៦៥ ឆ្នាំ ដែលកើនឡើងយ៉ាងច្រើនពី ៥៦ ឆ្នាំ នាឆ្នាំ ១៩៩៨។

*រូបភាព ២.១០ : អាត្រាមរណៈទារកសម្រាប់ខេត្តនីមួយៗ*




*ប្រភព : គណនាពី CIPS - ឆ្នាំ ២០០៤*

អាត្រាមរណៈទារក (IMR) តាមរបាយការណ៍របស់អង្កេតប្រជាសាស្ត្រ និងសុខភាព (DHS) ឆ្នាំ ២០០៥ ស្មើថា ចំនួនទារកស្លាប់ត្រូវបានថយចុះពី ៩៥ មក ៦៥ ក្នុងចំណោមមួយពាន់កំណើតរស់នៅចន្លោះឆ្នាំ ២០០០ ដល់ ២០០៥ (រូបភាព ២.១១ក)។ ការថយចុះយ៉ាងខ្លាំងនេះ គឺជាការលើកទឹកចិត្តយ៉ាងច្រើន ដូចគ្នាទៅនឹងការកើនឡើងនៃអាត្រារស់របស់កុមារក្នុងរយៈពេលនេះដែរ។ លទ្ធផលនេះប្រហែលជានាំឱ្យអាយុកាលមធ្យមកើនឡើង។ ដើម្បីរកភាពខុសគ្នារវាងការស្លាប់របស់កុមារា និងកុមារី ត្រូវមើលទៅរយៈពេលដប់ឆ្នាំកន្លងមក ទើបធានាមានទំហំសំណាកគ្រប់គ្រាន់។ យើងរកឃើញថា ស្ថិតិនៃការស្លាប់នៃទារិកា និងកុមារី មានទាបជាងស្ថិតិសម្រាប់ទារក និងកុមារ នៅគ្រប់ករណីទាំងអស់ (រូបភាព ២.១១ខ)។ នេះគឺជារបាយការណ៍អំពីបាតុភូតធម្មតា។ ក្នុងពេលជាមួយគ្នានេះ អនុបាតមរណៈមាតាពេលសម្រាលកូន (MMR) មានចំនួន ៤៧២ ក្នុងចំណោម ១០០.០០០ កំណើតរស់ ដែលជាកម្រិតខ្ពស់គួរឱ្យព្រួយបារម្ភ ហើយមិនមានការរីកចម្រើនសោះក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ។ មូលហេតុនៃការរីកចម្រើនមិនដូចគ្នារវាងអត្រាមរណៈទារក និង

(១០) RGC (២០០៦ដ)

*បញ្ហាចម្បងមួយ... គឺការខ្វះទឹកស្អាតបរិភោគ*

អត្រាមរណៈម្តាយពេលសម្រាលកូន គឺដោយសារមានកំណើនក្នុងការថែទាំនៅពេលសម្រាលកូន ការបញ្ចូលទឹកតាមមាត់ និងវិធានការណ៍ផ្សេងៗទៀត ដែលបានជួយសង្គ្រោះជីវិតកុមារតូចៗជាច្រើន។ ផ្ទុយទៅវិញ មរណភាពរបស់ស្ត្រីសម្រាលកូននៅតែមាន ដោយសារការធ្លាក់ឈាម ការខ្វះឈាមធ្ងន់ធ្ងរ ហើយនិងជម្ងឺផ្សេងៗទៀត ដែលសេវាសុខភាពនៅតាមទីជនបទមិនអាចព្យាបាលបាន។

***រូបភាព ២.១១ ក : មរណៈភាពទារក និងកុមារ ឆ្នាំ ២០០០ និងឆ្នាំ ២០០៥***




***រូបភាព ២.១១ ខ : មរណភាពទារក-ទារិកា និងកុមារ-កុមារី ឆ្នាំ ១៩៩៥-២០០៥***




*ប្រភព : អង្កេតប្រជាសាស្ត្រ និងសុខភាព, វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងក្រសួងសុខាភិបាល និងវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ*

ការបំប៉នចំណីអាហារមិនគ្រប់គ្រាន់ គឺជាមូលហេតុនៃការលូតលាស់យឺតរបស់កុមារ : មានអនុបាតកម្ពស់ធៀបនឹងអាយុតូចជាង (ក្រិន) អនុបាតទម្ងន់ធៀបនឹងកម្ពស់ស្រាលជាង (ស្គាំងស្គម) និងអនុបាតទម្ងន់ធៀបនឹងអាយុ (ទំងន់ក្រោមស្តង់ដារ)។ នៅតាមជនបទមានបញ្ហាកង្វះអាហារូបត្ថម្ភច្រើនជាងនៅតាមទីប្រជុំជន ថ្វីត្បិតតែមិនមានការលំអៀងយេនឌ័រក៏ដោយ (រូបភាព ២.១២)។ ទិន្នន័យបង្ហាញថា ខេត្តដែលមានបញ្ហាអស់ទាំងនេះច្រើនជាងគេបំផុត គឺខេត្តពោធិ៍សាត់ និងខេត្តសៀមរាប បន្ទាប់មក គឺខេត្តនៅភូមិភាគឦសាន ឧត្តរមានជ័យ និងខេត្តកំពង់ធំ (រូបភាព ២.១៣)។ បញ្ហាចម្បងមួយនៅក្នុងខេត្តទាំងអស់នេះ ក៏ដូចជានៅក្នុងខេត្តដទៃទៀតក្នុងតំបន់ទន្លេសាបដែរ គឺកង្វះទឹកស្អាតបរិភោគ។ អ្នកស្រុកអ្នកភូមិនៅតាមដងទន្លេសាប (ទាំងក្នុងខេត្តពោធិ៍សាត់ និងខេត្តសៀមរាប) តែងតែទទួលទានទឹកឆៅពីក្នុងបឹង និងទន្លេ ដែលបណ្តាលឱ្យកើតជម្ងឺចុកមួលក្នុងពោះកាន់តែខ្លាំងឡើងៗ រួមទាំងរាគរូស ដែលជាកត្តានាំឱ្យថយចុះនូវការស្រូបយកសារជាតិអាហារចូលទៅក្នុងខ្លួនសម្រាប់លូតលាស់ផ្នែកសុខភាព។

*រូបភាព ២.១២ : ស្ថានភាពអាហារូបត្ថម្ភសម្រាប់កុមារតាមទីកន្លែង និងភេទ ឆ្នាំ ២០០៥*



*ប្រភព : អង្កេតប្រជាសាស្ត្រ និងសុខភាព, វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងក្រសួងសុខាភិបាល និងវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ*

*រូបភាព ២.១៣ : ស្ថានភាពអាហារូបត្ថម្ភរបស់កុមារក្នុងខេត្តនីមួយៗ ឆ្នាំ ២០០៥*



*ប្រភព : អង្កេតប្រជាសាស្ត្រ និងសុខភាព, វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងក្រសួងសុខាភិបាល និងវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ*

ថ្វីត្បិតតែការបង្ហាញប័ណ្ណព័ត៌មាន ស្តីអំពីជម្ងឺមួយមុខៗមានចំនួនច្រើនពេកសម្រាប់របាយការណ៍នេះក៏ដោយ ក៏មានការធូរស្រាលក្នុងចិត្តទៅវិញពេលដែលបានសម្គាល់ឃើញថា ការយល់ដឹងអំពីមេរោគអេដស៍និងជម្ងឺអេដស៍ (HIV/AIDS) បានកើនឡើង ហើយសមាមាត្រនៃអ្នកឆ្លងជម្ងឺនេះបានថយចុះ។ ប៉ុន្តែផ្ទុយទៅវិញអត្រាឆ្លងជម្ងឺនេះពីប្តីទៅប្រពន្ធកំពុងតែកើនឡើង ដែលតម្រូវឱ្យមានវិធីសាស្ត្រផ្សេងៗជាច្រើន សម្រាប់លើកកម្ពស់ការយល់ដឹងនេះ និងកាត់បន្ថយភាពមិនស្មើគ្នានៃយេនឌ័រ។ ជម្ងឺគ្រុនចាញ់ គ្រុនឈាម និងជម្ងឺឯទៀតៗ ដែលមានដើមកំណើតពីទឹកនៅតែបន្តធ្វើទុក្ខបុកម្នេញដល់ប្រជាពលរដ្ឋ។

លទ្ធផលអំពីអង្កេតប្រជាសាស្ត្រ និងសុខភាព (DHS) ឆ្នាំ ២០០៥ បង្ហាញថា ០,៦% នៃមនុស្សពេញវ័យអាយុពី ១៥ ទៅ ៤៩ ឆ្នាំ មានឆ្លងមេរោគអេដស៍។ ថ្វីត្បិតតែអត្រាកាត់បន្ថយការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍មានកម្រិតគួរជាទីពេញចិត្តក៏ដោយ ក៏ត្រូវតែមានការប្រុងប្រយ័ត្នឱ្យបានសមស្រប : ព្រោះកាលណាប្រទេសរីកចម្រើន ស្ត្រីអាចនឹងមានឱកាសធ្វើដំណើរច្រើន បុរសក៏អាចមានការងារធ្វើច្រើន និងមានការចេះដឹងច្រើន ហើយទ្រព្យសម្បត្តិនឹងកើនឡើងជាទូទៅសម្រាប់បុរស និងស្ត្រី។ កត្តាអស់ទាំងនេះវាជាប់ជាមួយគ្នានឹងសក្តានុពលនៃការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍កាន់តែច្រើនថែមទៀតនៅកម្ពុជា។ ហេតុដូច្នេះ ចាំបាច់ត្រូវតែបន្តការខំប្រឹងប្រែងទប់ស្កាត់ និងតាមដានត្រួតពិនិត្យឱ្យបានជិតដល់។

*នៅឆ្នាំ ២០០៤ សមាមាត្រពលរដ្ឋមានទឹកស្អាតបរិភោគមានយ៉ាងច្រើនបំផុត ៤០ភាគរយ- ដែលក្នុងនោះ១/៥ នៃប្រជាពលរដ្ឋទាំងអស់ដែលមានប្រាក់ចំណូលទាបជាងគេបំផុត មានទឹកស្អាតបរិភោគត្រឹមតែ ៤% ទេ។*

## អំពីលំនៅដ្ឋាន

តំបន់ជាច្រើននៃប្រទេសកម្ពុជាមានទឹកលិចជាទៀងទាត់នៅរដូវទឹកជំនន់។ ដោយសារហេតុនេះ មនុស្សជាច្រើននៅតំបន់ទាំងនោះរស់នៅក្នុងផ្ទះបណ្ដោះអាសន្នពីមួយឆ្នាំទៅមួយឆ្នាំ។ លើសពីនេះ ប្រជាពលរដ្ឋដែលទើបនឹងមកដល់ថ្មី រស់នៅក្នុងជម្រកបណ្ដោះអាសន្នរហូតទាល់តែគេអាចសង់លំនៅដ្ឋានអចិន្ត្រៃយ៍បាន។ ទស្សនកិច្ចតាមមូលដ្ឋានបានរកឃើញថា គ្រួសាររស់នៅក្នុងផ្ទះបែបនេះ តែងតែខ្វះសម្ភារៈប្រើប្រាស់ និងខ្វះអនាម័យមូលដ្ឋាន ហើយនៅកន្លែងខ្លះទៀត មានបញ្ហាអសន្តិសុខថែមទៀត។ ភ្នាក់ងារអភិវឌ្ឍន៍ ដែលមានកម្មវិធីអភិវឌ្ឍន៍សម្រាប់ក្រុមគ្រួសារទាំងអស់នេះ តែងតែជួបប្រទះនូវការលំបាកជាខ្លាំង។

*រូបភាព ២.១៤ : ចំនួនភាគរយនៃរចនាសម្ព័ន្ធលំនៅដ្ឋានបណ្ដោះអាសន្ន ឆ្នាំ ២០០៤*



*ប្រភព : CIPS-04*

ភាគរយនៃមនុស្សរស់នៅក្នុងផ្ទះបណ្ដោះអាសន្នប្រែប្រួលខ្លាំងពីខេត្តមួយទៅខេត្តមួយ។ ខេត្តកំពង់ឆ្នាំងនៅតាមដងទន្លេសាប និងខេត្តនៅភូមិភាគឦសានខ្លះទៀតមានសមាមាត្រប្រជាពលរដ្ឋ ដែលរស់នៅក្នុងផ្ទះបណ្ដោះអាសន្នខ្ពស់ជាងគេបំផុត។ ខេត្តនៅភូមិភាគខាងត្បូងដែលមានទីប្រជុំជនច្រើន មិនសូវមានមនុស្សរស់នៅក្នុងផ្ទះបណ្ដោះអាសន្នទាំងនេះទេ (រូបភាព ២.១៤)។

## អំពីទឹក

ពាក្យស្លោកពោលថា ទឹកជាជីវិត។ កម្ពុជាមិនខ្វះទឹកទេ បើនិយាយអំពីទឹកដែលមាននៅក្នុងប្រទេស ប៉ុន្តែនៅខ្វះខាតទឹកស្អាតសម្រាប់បរិភោគ។ ក្នុងចំណោមប្រភពចម្បងៗនៃជម្ងឺឆ្លង និងរោគាព្យាធិផ្សេងៗ គឺការទទួលទានទឹកនៅពីប្រភពទឹកដែលមិនមានសុវត្ថិភាព (គឺ ទន្លេ ស្ទឹង បឹងបួរ ស្រះ ឬអណ្ដូងដែលមិនបានការពារ)។ នៅឆ្នាំ ២០០៤ សមាមាត្រប្រជាពលរដ្ឋមានទឹកស្អាតបរិភោគ គឺ ៤០% ដែលក្នុងនោះ ១/៥ នៃប្រជាពលរដ្ឋទាំងអស់ ដែលមានប្រាក់ចំណូលទាបជាងគេបំផុតមានទឹកស្អាតបរិភោគត្រឹមតែ ៤% ទេ។

នៅក្រៅក្រុងភ្នំពេញ ខេត្តព្រៃវែង និងស្វាយរៀង ទឹកស្អាតសម្រាប់បរិភោគនៅមានកង្វះខាត (រូបភាគ ២.១៥)។ ខេត្តកំពង់ធំ ពោធិ៍សាត់ កំពត និងក្រុងកែប មានទឹកស្អាតប្រើប្រាស់តិចជាងគេបំផុត។ ជាតួលេខសរុប ថ្វីត្បិតតែមានការរីកចម្រើនតាំងពីឆ្នាំ ១៩៩៨ ក៏នៅមានតំបន់ដទៃៗទៀតជាច្រើនដែលត្រូវពិនិត្យមើល[១១]។

***រូបភាព ២.១៥ : សមាមាត្រប្រជាពលរដ្ឋមានទឹកស្អាតទទួលទានសម្រាប់ខេត្តនីមួយៗ ឆ្នាំ ២០០៤***




*ប្រភព : CIPS-04*

## *សារគន្លឹះ :*

*១. កត្តាសំខាន់សម្រាប់នាំមកនូវភាពរីកចម្រើនដល់សុខុមាលភាពមនុស្សនៅកម្ពុជា គឺអភិបាលកិច្ច ដែលមានប្រសិទ្ធភាពកាន់តែច្រើនថែមទៀតនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន រួមទាំងការបង្កើនតម្លាភាពឱ្យកាន់តែទូលំទូលាយ មានការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងមាននីតិរដ្ឋ។*

*២. ការពង្រីកផ្នែកនានា និងពង្រីកសកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មនឹងផ្តល់ឱកាសល្អឱ្យមនុស្សនៅតំបន់ដាច់ស្រយាលច្រើនថែមទៀតអាចចូលរួមចំណែក។*

*៣. ការពង្រឹងបន្ថែមនៃប្រព័ន្ធសុខភាពជនបទ គឺជាការចាំបាច់សម្រាប់ប្រមូលផ្តុំសមិទ្ធកម្មបច្ចុប្បន្ន ដោះស្រាយបញ្ហាអត្រាមរណៈមាតាគ្រាសម្រាលកូន ដែលសព្វថ្ងៃនេះនៅតែខ្ពស់ និងកាត់បន្ថយជម្ងឺដង្កូវព្រូនក្នុងរាងកាយ និងជម្ងឺដែលមានកំណើតពីទឹក។*

*៤. សមិទ្ធកម្មពិតប្រាកដក្នុងវិស័យអប់រំនៅមិនទាន់ច្បាស់។ គួរប្រឹងប្រែងពុះពារជាបន្ទាន់ក្នុងការបង្កើនអត្រាបញ្ចប់សាលាបឋមសិក្សា ជាពិសេសសម្រាប់កុមារី។*

*ការពង្រឹងបន្ថែមនៃប្រព័ន្ធសុខភាពជនបទ គឺជាការចាំបាច់សម្រាប់ប្រមូលផ្តុំសមិទ្ធកម្មបច្ចុប្បន្ន ដោះស្រាយបញ្ហាស្លាប់របស់មាតាសម្រាលកូន ដែលសព្វថ្ងៃនេះនៅតែមានអត្រាខ្ពស់ និងកាត់បន្ថយជម្ងឺដង្កូវព្រូនក្នុងរាងកាយ និងជម្ងឺដែលមានដើមកំណើតពីទឹក*

---

*(១១) ធនាគារពិភពលោកគណនាថា ប្រជាពលរដ្ឋអ្នកមានចំនួន ៥៩ ភាគរយ មានទឹកស្អាតបរិភោគ ផ្ទុយមកវិញ មានតែ ២ ភាគរយប៉ុណ្ណោះ នៃអ្នកក្រីក្រមានទឹកស្អាតប្រើប្រាស់។*

*កម្ពុជាស្ថិតក្នុងលំដាប់ថ្នាក់ទី ១២៩ ក្នុងចំណោមប្រទេស ១៧៧ នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ឆ្នាំ ២០០៦*

## ២.២ លទ្ធផលអភិវឌ្ឍន៍តាមរយៈសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស

សន្ទស្សន៍ជួយឱ្យរកបាននូវរូបភាពដែលផ្សំឡើងពីផ្នែកសំខាន់ៗខ្លះនៃការអភិវឌ្ឍមនុស្ស។ សន្ទស្សន៍ទាំងនេះ ក៏ជួយធ្វើចំណាត់ថ្នាក់លើធាតុផ្សំមួយចំនួននៃសុខុមាលភាពមនុស្សជាតិ។ ប៉ុន្តែសន្ទស្សន៍តែមួយ មិនអាចចាប់យកវិសាលភាពលើវិស័យសំខាន់ៗនៃសុខុមាលភាពមនុស្សជាតិទាំងអស់បានទេ។

### *ការប្រៀបធៀបជាអន្តរជាតិ*

កម្ពុជាស្ថិតក្នុងលំដាប់ថ្នាក់ទី ១២៩ ក្នុងចំណោមប្រទេស ១៧៧ នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ឆ្នាំ ២០០៦ យោងតាមរបាយការណ៍អភិវឌ្ឍន៍មនុស្ស (ប្រអប់លេខ ២.២)។ ប្រៀបធៀបទៅនឹងប្រទេសនៅអាស៊ីចំនួន ១២ ដែលមានចំណូលទាប និងមធ្យម (រួមទាំងប្រទេសសមាជិកអាស៊ាន លើកលែងតែសិង្ហបូរីចេញ) កម្ពុជាស្ថិតក្នុងលំដាប់ថ្នាក់ចំណោមប្រទេស ៤ នៅក្រោមគេបំផុត។ មានតែប្រទេសបង់ក្លាដេស ប្រទេសឡាវ និងប្រទេសណេប៉ាល់ ទេ ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ក្រោមកម្ពុជា។ ប្រទេសបង់ក្លាដេស និងប្រទេសណេប៉ាល់ ជាប្រទេសដែលមានប្រជាពលរដ្ឋច្រើន និងមានអភិបាលកិច្ចទន់ខ្សោយ រីឯប្រទេសឡាវ និងប្រទេសណេប៉ាល់ នៅមានបញ្ហាដែលត្រូវរពុះពារជាច្រើន ដោយសារប្រទេសទាំងពីរនេះគ្មានសមុទ្រ។ ប្រទេសឡាវ និងកម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន ប៉ុន្តែកម្ពុជាទើបនឹងបានមកវិញនូវសន្តិភាព និងស្ថិរភាពក្នុងពេលថ្មីៗនេះ។ ដូច្នេះសន្ទស្សន៍អភិវឌ្ឍន៍មនុស្សទាប គឺបណ្តាលមកពីកត្តាច្រើនផ្សំគ្នា រួមទាំងនៅតំបន់ភូមិសាស្ត្រដាច់ពីគេ មានប្រជាពលរដ្ឋច្រើនកុះករ និងមានជំនាញតិចតួច ខ្វះអភិបាលកិច្ចល្អ ឬមានវិបត្តិនយោបាយ។ កម្ពុជាដែលមានសន្តិភាព និងស្ថិរភាពជិត ១០ ឆ្នាំមកហើយនេះ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សក៏មុខតែនឹងរីកចម្រើនដែរក្នុងពេលឆាប់ៗនេះ ប្រសិនបើមានរចនាសម្ព័ន្ធអភិបាលកិច្ចសមស្រប និងមានការត្រួតពិនិត្យល្អិតល្អន់។

សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) និងសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI)[១២] ទាំងពីរនេះ យោងទៅលើវិសាលភាពនៃអាយុវែងប្រកបដោយសុខភាព មានចំណេះដឹង និងមានកម្រិតជីវភាពរស់នៅសមរម្យ។ ភាពខុសគ្នាសំខាន់ គឺសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) ឆ្លុះបញ្ចាំងលើវិសមភាពរវាងស្ត្រី និងបុរស នៅក្នុងសមិទ្ធកម្មទាំងឡាយនេះ។ សន្ទស្សន៍អភិវឌ្ឍន៍ (យេនឌ័ររបស់កម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទី ៩៧ ក្នុងចំណោមប្រទេស ១៣៦ ដែលធ្វើរបាយការណ៍ស្តីអំពីសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) (ទី៧០នៃភាគរយ) ចំណែកឯសន្ទស្សន៍អភិវឌ្ឍន៍មនុស្សស្ថិតនៅក្នុងលំដាប់ថ្នាក់ទី ១២៩ ក្នុងចំណោមប្រទេស ១៧៧ (ទី៧២នៃភាគរយ)។ ថ្វីត្បិតតែសន្ទស្សន៍អភិវឌ្ឍន៍ (យេនឌ័រ (GDI) និងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) របស់កម្ពុជាមានកម្រិតប្រហាក់ប្រហែលគ្នាដូចនៅក្នុងប្រទេសជាច្រើនដទៃទៀតក៏ដោយ ក៏គម្លាត និងវិសមភាពនៃយេនឌ័រ នៅតែមានដដែល បើប្រៀបធៀបសូចនាករទាំងមូលដែលប្រើសម្រាប់គណនាសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ជាមួយនឹងសូចនាករជាក់លាក់បន្ថែមទៀត ដែលប្រើសម្រាប់គណនាសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI)។ កម្ពុជានៅមានភាពខុសគ្នារវាងអត្រាអក្ខរកម្មបុរស និងស្ត្រី ហើយក៏មានភាពខុសគ្នារវាងអនុបាតចុះឈ្មោះចូលរៀនរបស់សិស្សប្រុស និងសិស្សស្រី (ជាពិសេស នៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា) មានប្រាក់ចំណូលខុសគ្នាតាមការប៉ាន់ស្មាន។ ទាំងអស់នេះសុទ្ធ តែមានអំណោយផលទៅបុរស។ អត្រាអាយុកាលមធ្យមរបស់ស្ត្រី វែងជាងអត្រាអាយុកាលមធ្យមរបស់បុរស ប៉ុន្តែដូចដែលបានបរិយាយខាងលើអាត្រាមរណៈមាតាគ្រាសម្រាល (MMR) នៅតែមានក្នុងចំណោមអាត្រាខ្ពស់បំផុតនៅអាស៊ី (ក្នុង ១០០,០០០ កំណើតរស់ មានស្ត្រីជាម្តាយ ៤៧២ នាក់ ស្លាប់)។

ជាធម្មតាសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ មិនអាចបកស្រាយបានទេ ប្រសិនបើរង្វាស់នៃការផ្តល់អំណាចឱ្យយេនឌ័រ (GEM) ពុំត្រូវបានរាប់បញ្ចូលទៅក្នុងសមីការ។ រង្វាស់ការផ្តល់សិទ្ធិអំណាចយេនឌ័រ (GEM) ផ្តោតទៅលើវិសមភាព ពោលគឺឱកាសរបស់ស្ត្រី (ការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រី និងការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច និងនយោបាយ) មិនសំដៅលើសមត្ថភាពរបស់ស្ត្រីទេ។ រង្វាស់ការផ្តល់សិទ្ធិអំណាចយេនឌ័រ (GEM) នៅកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទាបបំផុតក្នុងចំណោម ប្រទេសនៅអាស៊ី គឺទី ៦៨ ក្នុងចំណោមប្រទេស ៧៥ ដែលឆ្លុះបញ្ចាំងនូវកម្រិតទាបបំផុត លើភាពជាតំណាងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចផ្សេងៗ នៅក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងស្ថាប័នតុលាការ។ ទោះបីមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយគោលនយោបាយរបស់ជាតិបានឆ្លើយតបទូលំទូលាយទៅនឹងសមភាពនៃយេនឌ័រ និងទៅលើការវិវត្តរបស់ស្ត្រី និងមានរាប់បញ្ចូលទាំងមុខសញ្ញាយេនឌ័រក៏ដោយ ក៏នៅតែត្រូវឱ្យមានការប្រឹងប្រែងរួមគ្នា ដើម្បីឱ្យស្ត្រី បុរស កុមារី និងកុមារា អាចរួមចំណែក និងទទួលផលពីការអភិវឌ្ឍនៅកម្ពុជា។

សន្ទស្សន៍ភាពក្រីក្រសម្រាប់មនុស្ស (HPI) គឺជារង្វាស់ភាពក្រីក្រដែលមិនពាក់ព័ន្ធលើប្រាក់ចំណូលទេ ហើយមានអថេរ ៤ គឺ (១) ភាពមិនចេះអក្សរ (២) អាត្រាមរណៈទារក (IMR) (៣) កុមារស្គមស្គាំង និង (៤) កង្វះទឹកស្អាតបរិភោគ។ សន្ទស្សន៍នេះសង្កត់ធ្ងន់ជាងលើគុណវិបត្តិ ឬគុណសម្បត្តិ ប្រៀបធៀបទៅនឹងរង្វាស់លីនេអ៊ែរ ដូចជា សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ជាដើម ព្រោះគេកំណត់វាជាអិច្សប៉ូណង់ស្យែល មិនមែនជាលីនេអ៊ែរទេ (ប្រអប់ ២.១)។ យោងតាមរបាយការណ៍អភិវឌ្ឍន៍មនុស្សជាសាកល ឆ្នាំ២០០៦ ប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ទី ៧៣ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ១០២។ ក្នុងការពិនិត្យលើសន្ទស្សន៍ក្រីក្រសម្រាប់មនុស្សរបស់ប្រទេសអាស៊ីចំនួន ១២ ប្រទេសកម្ពុជាស្ថិតនៅលំដាប់ថ្នាក់ទាបជាងប្រទេសដទៃទៀតទាំងអស់ លើកលែងតែប្រទេសបង់ក្លាដេសចេញ ដែលមានប្រទេសឡាវ និងប្រទេសណេប៉ាល់ ធ្លាក់ក្បែរមកកម្ពុជាដែរ (រូបភាព ២.១៦)។ ទិន្នន័យទាំងនេះចង្អុលបង្ហាញលើចំណុចខ្វះខាតរបស់ស្ថាប័នសាធារណៈក្នុងការផ្តល់សេវាសុខភាព អប់រំ ទឹកស្អាតបរិភោគ និងអនាម័យនៅក្នុងប្រទេស។

---

*(១២) GDI ខុសពី HDI ត្រង់ថាធាតុផ្សំរបស់វានីមួយៗ ត្រូវបានគេគណនាដំបូងទៅតាមប្រភេទប្រុស និងស្រី រួចទើបបូកសរុបទៅតាមសមាសភាពនៃប្រជាពលរដ្ឋដោយប្រើវិធី harmonic mean ។ GDI នៅតាមខេត្តមិនអាចគណនាបាន ដោយសារពុំមានទិន្នន័យគ្រប់គ្រាន់ទាក់ទងនឹងភេទសរុបនៅតាមបណ្តាខេត្ត។*

## ប្រអប់ ២.២ : ការគណនារកសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស

សន្ទស្សន៍ ៣ ក្នុងរបាយការណ៍នេះ ដែលគណនានៅថ្នាក់ខេត្ត គឺសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស សន្ទស្សន៍អភិវឌ្ឍន៍មនុស្សពាក់ព័ន្ធនឹងភាពមិននឹងននៃលំនៅដ្ឋាន និងសន្ទស្សន៍ភាពក្រីក្រ។ រីឯសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រថ្នាក់ខេត្តវិញ គឺមិនអាចរៀបចំបានទេ ដោយសារមិនមានទិន្នន័យគ្រប់គ្រាន់ពាក់ព័ន្ធនឹងយេនឌ័រនៅថ្នាក់ខេត្ត។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅក្នុងរបាយការណ៍នេះ ត្រូវបានគណនានៅថ្នាក់ខេត្ត ដោយមានការថ្លឹងថ្លែងស្មើៗគ្នារវាងសន្ទស្សន៍ខាងក្រោមនេះ :

សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស = ១/៣ (សន្ទស្សន៍កែសម្រួលលើការប្រើប្រាស់មិនស្មើគ្នា) + ១/៣ (សន្ទស្សន៍អក្ខរកម្ម និងអត្រាពិតនៃការសិក្សា) + ១/៣ (អត្រាមរណៈទារក)។

### ការកែលម្អរបស់កម្ពុជា ដើម្បីសម្រួលដល់ការគណនារកសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស

ខាងក្រោមនេះ គឺជាការច្នៃប្រឌិតរបស់កម្ពុជាក្នុងការគណនារកសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅក្នុងរបាយការណ៍នេះ :

- ការធ្វើរបាយការណ៍អភិវឌ្ឍន៍មនុស្ស ជាធម្មតា គឺត្រូវគណនារកលោការីតប្រាក់ចំណូល ដោយហេតុថាអត្ថប្រយោជន៍លម្អៀងនៃប្រាក់ចំណូលមិនបានរួមចំណែកជាដុំកំភួនទៅលើការអភិវឌ្ឍមនុស្សទេ ក្រោយពីប្រាក់ចំណូលកើនឡើងហួសកម្រិតណាមួយ។ នៅក្នុងករណីកម្ពុជាគេនិយមយកតម្លៃដាច់ខាតនៃការប្រើប្រាស់របស់គ្រួសារ។ មិនមានខេត្តណាមួយ មានចំណូល ឬការប្រើប្រាស់ខ្ពស់ល្មម ដើម្បីធានានូវលោការីតនៃការបំលែងទេ។
- ការប្រើប្រាស់របស់គ្រួសារនីមួយៗ ត្រូវបានគេប្រើជំនួសប្រាក់ចំណូល ពីព្រោះនៅកម្ពុជាមិនមានការគណនារកទិន្នន័យប្រាក់ចំណូលនៅថ្នាក់ខេត្តទេ។ លើសពីនេះទៀត ទិន្នន័យប្រើប្រាស់តែងតែច្បាស់លាស់ជាងទិន្នន័យប្រាក់ចំណូល។ ការប្រើប្រាស់របស់គ្រួសារនីមួយៗ ត្រូវបានគេគុណនឹង [១ - (មេគុណGini)] ដើម្បីវាស់កម្រិតប្រើប្រាស់តាមភាពខុសគ្នា ក្នុងការបែងចែកការប្រើប្រាស់នៅក្នុងខេត្តនីមួយៗ។
- ដោយហេតុថាការធ្វើរបាយការណ៍អភិវឌ្ឍន៍មនុស្សជាទូទៅ គឺគ្រាន់តែរកមធ្យមភាគនៃអត្រាអ្នកចេះអក្សរ និងអនុបាតរួមនៃការសិក្សា។ កាលណាអត្រាបោះបង់ការសិក្សាខ្ពស់ពេក ការគណនាអនុបាតរួមនៃការសិក្សា (GERs) មានបញ្ហាច្រើន (ក្នុងការរកចំនួនកុមារក្នុងថ្នាក់រៀន ដោយមិនគិតពីក្រុមអាយុ)។ ដូច្នេះអថេរត្រង់នេះ ត្រូវកសាងចេញពីអត្រាពិតចូលរៀនថ្មី និងអត្រាអក្ខរកម្ម។
- ក្នុងការគណនារកសន្ទស្សន៍ភាពក្រីក្រ (HPI) អត្រាមរណៈទារក (១ថ្ងៃ-ដល់ ១ ឆ្នាំ) ត្រូវបានប្រើជំនួសអាយុកាលមធ្យមរបស់មនុស្សពីកំណើត ដោយហេតុថា នៅថ្នាក់ខេត្តមិនមានតួលេខអាយុកាលមធ្យមនេះ។
- អថេរបន្ថែមមួយទៀត គឺភាគរយប្រជាពលរដ្ឋដែលមានផ្ទះអចិន្ត្រៃយ៍ ត្រូវបានប្រើសម្រាប់គណនាជំនួសសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ដោយប្រើអថេរបួន។ ការបង្កើតរូបមន្តអថេរនេះ គឺ [១ - (សន្ទស្សន៍ភាពគ្មានផ្ទះ)] កាលណាគណនារកសន្ទស្សន៍អភិវឌ្ឍន៍មនុស្សជំនួសដែលពាក់ព័ន្ធនឹងលំនៅដ្ឋាន។

### អំពីទិន្នន័យ

ការប្រើប្រាស់ប្រចាំគ្រួសារ ត្រូវបានគណនាចេញពីទិន្នន័យរាជរដ្ឋាភិបាល (ឆ្នាំ ២០០៦) រីឯមេគុណGini សម្រាប់ខេត្តនីមួយៗ ត្រូវបានគណនាចេញពីទិន្នន័យបឋមរបស់អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ ២០០៤។

- អត្រាអក្ខរកម្មសម្រាប់ប្រជាពលរដ្ឋអាយុពី ៧ ឆ្នាំឡើងទៅ ចេញអំពីអង្កេតអន្តរជំរឿន (CIPS) ឆ្នាំ ២០០៤។
- អត្រាសិស្សចូលរៀននៅថ្នាក់បឋមសិក្សាបានមកពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ(ក្រសួងអប់រំ យុវជន និងកីឡា)។
- អត្រាមរណៈទារកថ្នាក់ខេត្តបានមកអំពីលទ្ធផលអំពីអង្កេតប្រជាសាស្ត្រ និងសុខភាព (DHS) ឆ្នាំ ២០០៥។
- ទិន្នន័យពលរដ្ឋរស់នៅក្នុងជម្រកបណ្ដោះអាសន្នបានមកពីអង្កេតអន្តរជំរឿន ឆ្នាំ ២០០៤។
- ទិន្នន័យកុមារស្គមស្គាំងបានមកពីអង្កេតប្រជាសាស្ត្រ និងសុខភាព (DHS) ឆ្នាំ ២០០៥ និងទិន្នន័យខ្វះទឹកស្អាតបរិភោគបានមកពីអង្កេតអន្តរជំរឿន ឆ្នាំ ២០០៤។

### លំដាប់ទិន្នន័យសម្រាប់កម្រិតទិន្នន័យ

មុននឹងគណនារកសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ត្រូវបង្កើតសន្ទស្សន៍សម្រាប់វិមាត្រនីមួយៗ។ ដើម្បីគណនារកសន្ទស្សន៍ទាំងនេះ ការប្រើអត្រាស្លាប់របស់ទារក អត្រាអក្ខរកម្ម និងភាពគ្មានលំនៅដ្ឋានទាមទារឱ្យមានកម្រិតអប្បបរមា និងអតិបរមា (ចំណុចគោលដៅ)។ លទ្ធផលក្នុងសូចនាករនីមួយៗ ស្ដែងឡើងជាកម្រិតរវាង 0 និង ១ ដោយប្រើរូបមន្តទូទៅ ដូចតទៅនេះ : សន្ទស្សន៍សម្រាប់វិមាត្រ = (តម្លៃពិត – តម្លៃអប្បបរមា), (តម្លៃអតិបរមា – តម្លៃអប្បបរមា)

| សូចនាករ | តម្លៃអប្បបរមា | តម្លៃអតិបរមា |
|---|---|---|
| ការប្រើប្រាស់ប្រចាំគ្រួសារ | ការប្រើប្រាស់អតិបរមាប្រចាំគ្រួសារ + ២៥% | ការប្រើប្រាស់អប្បបរមាប្រចាំគ្រួសារ + ២៥% |
| អត្រាអក្ខរកម្ម (អាយុពី ៧ ឆ្នាំឡើង) | ១00 | 0 |
| អត្រាមរណៈទារក | អត្រាមរណៈទារកអតិបរមា + ២៥% | អត្រាមរណៈទារកអប្បបរមា + ២៥% |
| ការចូលរៀនពិតៗនៅថ្នាក់បឋមសិក្សា | ១00 | 0 |
| សូចនាករលំនៅស្ថានអចិន្ត្រៃយ៍ | ១00 | 0 |

សន្ទស្សន៍ភាពក្រីក្រសម្រាប់មនុស្ស (HPI) ត្រូវបានគណនាដូចខាងក្រោមនេះ :

$$HPI = [{}^{1}/_{3}(P_1^3 + P_2^3 + P_3^3)]^{1/3}$$

$P_1$ = អត្រាមរណៈទារក (IMR, %).

$P_2$ = អត្រាមិនចេះអក្សរសម្រាប់ក្មេងអាយុពី ៧ ឆ្នាំ ឡើងលើ (%)

$P_3$ = មធ្យមភាគភាគរយនៃកុមារស្គមស្គាំង និងភាគរយនៃប្រជាពលរដ្ឋដែលមិនមានទឹកស្អាតបរិភោគ

***រូបភាព ២.១៦ : សន្ទស្សន៍ភាពក្រីក្រសម្រាប់មនុស្សក្នុងប្រទេសអាស៊ីមួយចំនួន ឆ្នាំ ២០០៤***



*ប្រភព : UNDP (2006)*

## *ការវាស់កម្រិតអភិវឌ្ឍន៍មនុស្សនៅក្នុងប្រទេសកម្ពុជា* [១៣]

រូបភាព ២.១៧ : បង្ហាញកម្រិតសន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ខេត្តនីមួយៗ ក្នុងចំណោមខេត្ត-ក្រុងទាំង ២៤ របស់ប្រទេស ដោយគណនាតាមរូបមន្ត ដែលផ្ដល់ជូនក្នុងប្រអប់ ២.២ ។

***រូបភាព ២.១៧ : សន្ទស្សន៍អភិវឌ្ឍន៍មនុស្សតាមខេត្តនីមួយៗ ឆ្នាំ ២០០៤***



*ប្រភពទិន្នន័យ : សូមមើលប្រអប់ ២.២*

*(១៣) សន្ទស្សន៍ ៣ ដែលបង្ហាញនៅក្នុងផ្នែកនេះមាន សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) សន្ទស្សន៍អភិវឌ្ឍន៍មនុស្សទាក់ទងនឹងភាពមិននឹងនរនៃលំនៅដ្ឋាន (housing – sensitive HDI) និងសន្ទស្សន៍ភាពក្រីក្រ (HPI) ។ ដូចដែលបានបង្ហាញពីខាងដើម GDI មិនអាចគណនាបាន ដោយសារពុំមានទិន្នន័យគ្រប់គ្រាន់ទាក់ទងនឹងភេទសរុបនៅតាមបណ្ដាខេត្ត ។*

## តទៅនេះ គឺជាការកត់សម្គាល់ :

**ក.** ខេត្តទាំងបួននៅភូមិភាគឦសាន-រតនៈគីរី មណ្ឌលគីរី ព្រះវិហារ និងស្ទឹងត្រែង មានកម្រិតសន្ទស្សន៍អភិវឌ្ឍន៍មនុស្សទាបជាងគេបំផុត ។ ខេត្តភូមិភាគឦសានទាំងនេះ មិនសូវមានមនុស្សរស់នៅទេ ហើយស្ថិតនៅតំបន់ដាច់ស្រយាលជាងគេក្នុងប្រទេស ។

**ខ.** ខេត្តកំពង់ស្ពឺ និងព្រៃវែង ក៏មានកម្រិតសន្ទស្សន៍អភិវឌ្ឍន៍មនុស្សទាបដែរ ។ ខេត្តកំពង់ស្ពឺស្ថិតនៅក្នុងតំបន់ដែលខ្វះភ្លៀង ដែលជាលទ្ធផលនាំឱ្យកសិកម្មទន់ខ្សោយ ។ រីឯខេត្តព្រៃវែងវិញ តែងតែមានទឹកជំនន់លិចជារៀងរាល់ឆ្នាំ ហើយដីកសិកម្មនៅដាច់ឆ្ងាយៗពីគ្នា ដែលជាមូលហេតុបណ្តាលឱ្យបានទិន្នផលទាប ។

**គ.** កម្រិតសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ខេត្តនានា នៅតាមដងទន្លេសាបស្ថិតនៅក្នុងចំណាត់ថ្នាក់មធ្យម ។

**ឃ.** ក្រុងភ្នំពេញមានលក្ខខណ្ឌអភិវឌ្ឍន៍មនុស្សខ្ពស់ជាងគេបំផុត (HDI=0.៨៣) បន្ទាប់ពីភ្នំពេញ គឺក្រុងកែប កំពត កណ្តាល និងក្រុងព្រះសីហនុ ។

សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ត្រូវបានរៀបចំបន្ថែមមួយទៀត ដោយរួមបញ្ចូលទាំងអថេរលំនៅដ្ឋានទៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ដោយមានមូលហេតុពីរយ៉ាង : ១. សហគមន៍ដែលរស់នៅតាមឆ្នេរទន្លេ និងក្បែរកន្លែងដែលមានទឹកលិច តែងតែបាត់បង់ផ្ទះសម្បែងរបស់ខ្លួន ហើយក្នុងស្ថានភាពមិនមានផ្ទះសម្បែងជាក់លាក់នេះ សបញ្ជាក់ឱ្យឃើញថា ត្រូវតែមានធនធានច្រើនថែមទៀត បើពុំនោះសោតពួកគេនឹងរស់នៅដោយគ្មានកម្មសិទ្ធិជាម្ចាស់ផ្ទះជាក់លាក់ ។ ២. ជនចំណាកស្រុកដែលបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយនៅក្នុងប្រទេស តែងតែមានគ្រួសារដែលរស់នៅគ្មានជម្រកអចិន្ត្រៃយ៍ ។ ក្រុមទាំងពីរត្រូវបានរាប់បញ្ចូលក្នុងសន្ទស្សន៍មានផ្ទះសម្បែងអចិន្ត្រៃយ៍ ដែលរួមបញ្ចូលគ្នាទៅជាសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ដែលកែសម្រួលទៅតាមភាពមិននឹងនរនៃលំនៅដ្ឋានសម្រាប់កម្ពុជា ។

*រូបភាព ២.១៨ : សន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ខេត្តនីមួយៗ ពាក់ព័ន្ធនឹងភាពមិននឹងនរនៃលំនៅដ្ឋាន ឆ្នាំ ២០០៤*




*ប្រភព : សូមមើលប្រអប់ ២.២*

រូបភាព ២.១៨ ខាងលើនេះ បង្ហាញកម្រិតសន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ខេត្តនីមួយៗនៃ ខេត្ត-ក្រុង ទាំង ២៤ ក្នុងប្រទេស ពាក់ព័ន្ធនឹងភាពមិនទឹងទនៃលំនៅដ្ឋាន ។ តម្លៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅថ្នាក់ខេត្ត គឺស្រដៀងគ្នាទៅនឹងស្តង់ដារនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (រូបភាព ២.១៥) ថ្វីត្បិតតែខេត្តខ្លះបានផ្លាស់ប្តូរចំណាត់ថ្នាក់ក៏ដោយ ។ ខេត្តកំពង់ឆ្នាំង សៀមរាប ពោធិ៍សាត់ និងព្រៃវែង មានចំណាត់ថ្នាក់ទាបជាងគេនៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សពាក់ព័ន្ធនឹងភាពមិនទឹងទនៃលំនៅដ្ឋាន ប៉ុន្តែខេត្តកំពង់ចាម និងបាត់ដំបង មានចំណាត់ថ្នាក់ល្អប្រសើរ ។ ចំពោះខេត្តទាំងឡាយ ដែលមានសន្ទស្សន៍អភិវឌ្ឍន៍មនុស្សពាក់ព័ន្ធនឹងភាពមិនទឹងទនៃលំនៅដ្ឋានទាបជាង ប្រៀបទៅនឹងស្តង់ដារ គឺខេត្តនៅតាមតំបន់ដែលរបស់មានទឹកលិច (ខេត្ត កំពង់ឆ្នាំង សៀមរាប) និងមានជនអន្តោប្រវេសន៍ (ខេត្តពោធិ៍សាត់) ជាច្រើន ។

*រូបភាព ២.១៩ : សន្ទស្សន៍ភាពក្រីក្រ (HPI) តាមខេត្តនីមួយៗ ឆ្នាំ ២០០៤*




*ប្រភព : សូមមើលប្រអប់ ២.២*

ផែនទីប្រចាំខេត្តស្តីពីសន្ទស្សន៍ភាពក្រីក្រ (រូបភាព ២.១៩) បង្ហាញថា ភាពក្រីក្រមានខ្ពស់បំផុតនៅតំបន់ជុំវិញទន្លេសាប ។ មនុស្សជាច្រើនរស់នៅក្នុងបណ្តាខេត្តជុំវិញទន្លេសាបប្រកបរបរនេសាទត្រី អ្នកខ្លះទៀតរកប្រាក់ចំណូលអំពីព្រៃឈើ ។ ប្រភពទាំងពីរនេះផ្តល់នូវប្រាក់ចំណូលពីមធ្យមទៅទាប ។ ខេត្តទាំងនេះ ក៏ខ្វះលទ្ធភាពមានទឹកស្អាតបរិភោគដែរ ។ ដូច្នេះប្រជាពលរដ្ឋទាំងនោះ ទោះបីប្រហែលជាអាចមានអាហារគ្រប់គ្រាន់ក៏ដោយ ក៏នៅតែទទួលរងនូវជំងឺបង្កឡើងដោយទឹក ដែលនាំឱ្យកម្រិតសន្ទស្សន៍ភាពក្រីក្រឡើងខ្ពស់ ។ ផ្ទុយទៅវិញ បណ្តាខេត្តនៅតាមវាលទំនាបមេគង្គ និងទីក្រុងភ្នំពេញ ខេត្តកោះកុង និងខេត្តកណ្តាល បង្ហាញចំណាត់ថ្នាក់ល្អប្រសើរនៅលើរង្វាស់សន្ទស្សន៍ភាពក្រីក្រ ដូចជា សន្ទស្សន៍អភិវឌ្ឍន៍មនុស្សដែរ ។ នៅតាមតំបន់ទាំងអស់នេះមនុស្សអាចរកប្រាក់ចំណូលបានប្រសើរជាង ព្រោះជាទីកន្លែងដែលគេប្រកបរបរធ្វើស្រែ និងរបរផ្សេងៗក្រៅពីកសិកម្ម ផ្ទុយពីការនេសាទត្រី និងកាប់អុសលក់នៅតាមដងទន្លេសាប ។ លើសពីនេះទៀត នៅក្នុងខេត្តទាំងអស់នេះ មានសេវាសាធារណៈល្អប្រសើរជាងខេត្តដទៃ ។

***សារគន្លឹះ :***

*ក្នុងចំណោមប្រទេសអាស៊ាន និងប្រទេសមួយចំនួនទៀតនៅអាស៊ី កម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទាប ។ ពីខេត្តមួយទៅខេត្តមួយ លទ្ធផលនៃការអភិវឌ្ឍមនុស្សមានគម្លាតខុសគ្នាឆ្ងាយណាស់ ។ ខេត្តដែលមានការអភិវឌ្ឍតិចជាងគេបំផុត គឺខេត្តនៅតំបន់ព្រៃសាន និងខេត្តនៅជុំវិញទន្លេសាប ។ បណ្ដាខេត្តអស់ទាំងនេះ ទាមទារឱ្យមានវិនិយោគសាធារណៈបន្ថែមទៀតលើវិស័យ សុខភាព អប់រំ និងទឹកស្អាតសម្រាប់បរិភោគ ។*

## ២.៣ សេចក្ដីសរុប

- កម្ពុជាបានក្លាយជាប្រទេសប្រជាធិបតេយ្យពហុបក្សតាំងពីឆ្នាំ ១៩៩៣ ដែលមានវត្តមានសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយដែលកំពុងអភិវឌ្ឍ ។ តែទោះជាយ៉ាងនេះក្ដី ការអនុវត្តនីតិរដ្ឋនៅមានបញ្ហាច្រើន ។ បញ្ហាដែលមានច្រើនជាងគេបំផុត គឺការគ្រប់គ្រងដីធ្លី និងសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លី ។

- កំណើនសេដ្ឋកិច្ចនៅកម្ពុជា បានកើនឡើងខ្ពស់ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ដែលជាមធ្យមជិត ៨ % ក្នុងមួយឆ្នាំ ហើយភាពក្រីក្របានថយចុះជាបន្តបន្ទាប់ប្រហែល ១% ក្នុងមួយឆ្នាំ ។ ប៉ុន្តែ ៣៤% នៃប្រជាពលរដ្ឋកម្ពុជា នៅតែរស់នៅក្រោមបន្ទាត់ភាពក្រីក្រនៅឡើយ ។ ការប្រែប្រួលប្រចាំខេត្ត ត្រូវបានគេរកឃើញនៅក្នុងតំបន់ព្រៃសាន និងនៅជុំវិញទន្លេសាបក្នុងចំណោមអ្នកក្រីក្របំផុត ។

- អត្រាអក្ខរជនបានកើនឡើងជាច្រើន ប៉ុន្តែកំណើននេះមិនបានផ្ដល់ផលប្រយោជន៍ឱ្យមនុស្សទាំងអស់គ្នាទេ ជាពិសេស នៅក្រុងប៉ៃលិន ខេត្តបាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង ។ នៅក្នុងខេត្តទាំងនេះ មានមនុស្សចំណាកស្រុកច្រើនណាស់ ហើយទីតាំងថ្មីរបស់ពួកគេតែងតែខ្វះសម្ភារៈមូលដ្ឋានសម្រាប់ប្រើប្រាស់ ។ ជាពិសេស នៅតំបន់ព្រៃសាន អត្រាបោះបង់សាលារៀននៅខ្ពស់ ។

- មានការប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីសង្គ្រោះជីវិតទារក និងកុមារអាយុក្រោម ៥ ឆ្នាំ ក៏ប៉ុន្តែអត្រាមរណៈមាតាគ្រាសម្រាលដែលនៅតែខ្ពស់ ទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ។ លើសពីនេះទៀត អាហារូបត្ថម្ភ និងទឹកបរិភោគ នៅតែមិនគ្រប់គ្រាន់នៅបណ្ដាខេត្តតាមដងទន្លេសាប ។ រីឯគ្រួសារជាច្រើនដែលរស់នៅក្នុងខេត្តមានទឹកលិច មានតែផ្ទះបណ្ដោះអាសន្នប៉ុណ្ណោះ ។

- តាមរង្វាស់អភិវឌ្ឍន៍មនុស្ស ភ្នំពេញនិងបណ្ដាខេត្តខាងត្បូងដែលមានការអភិវឌ្ឍជាង រួមទាំងទីប្រជុំជន (កណ្ដាល ក្រុងកែប និងក្រុងព្រះសីហនុ) មានកម្រិតសូចនាករអភិវឌ្ឍន៍មនុស្សខ្ពស់ជាងគេបំផុត ។ រីឯប្រជាពលរដ្ឋក្នុងខេត្តតំបន់ព្រៃសាន ដែលមិនសូវមានមនុស្សរស់នៅមានការអភិវឌ្ឍមនុស្សទាបជាងគេបំផុត ។ តំបន់ទាំងនេះ មានជនជាតិដើមភាគតិចរស់នៅ ដែលជាប្រជាពលរដ្ឋអភ័ព្វជាងគេបំផុតនៅក្នុងប្រទេស ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺខេត្តសៀមរាប មិនមានសូចនាករអភិវឌ្ឍន៍មនុស្សណាមួយឡើងខ្ពស់ទេ លទ្ធផលជាឧទាហរណ៍នៃវិស័យទេសចរណ៍នៅខេត្តសៀមរាប មិនបានផ្ដល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋានឡើយ មនុស្សមានភាពក្រីក្រខ្ពស់ជាងគេបំផុតនៅក្នុងបណ្ដាខេត្តជុំវិញទន្លេសាប ដែលស្របគ្នាទៅនឹងអត្រាខ្ពស់នៃកម្រិតភាពក្រីក្រក្នុងការប្រើប្រាស់ជាមូលដ្ឋាននៅទីនោះ ។

*កំណើនសេដ្ឋកិច្ចនៅកម្ពុជាបានកើនឡើងខ្ពស់ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ។ ប៉ុន្តែ ៣៤% នៃពលរដ្ឋកម្ពុជានៅតែរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រនៅឡើយ*

# ជំពូក ៣



# ៣

ជំពូក



# ការពង្រឹងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រងធនធានធម្មជាតិ ឆ្ពោះទៅកំណើនប្រកបដោយសមធម៌

វិស័យអភិវឌ្ឍន៍មនុស្សនៅកម្ពុជានឹងប្រសើរឡើងខ្លាំង បើមានការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋជនបទបានរួមចំណែកក្នុងសកម្មភាពដែលមានផលកម្រៃខ្ពស់ជាងសព្វថ្ងៃ។ ដើម្បីសម្រេចបាននូវកំណើនសុខុមាលភាពអតិបរមា ត្រូវដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពស្ថាប័នក្នុងការប្រើប្រាស់ធនធានធម្មជាតិ ការប្រើកម្លាំងពលកម្មមូលដ្ឋានឱ្យបានច្រើនបំផុត និងការចែករំលែកផលប្រយោជន៍។

កម្ពុជាមានប្រព័ន្ធកម្មសិទ្ធិដីធ្លី និងធនធានធម្មជាតិមិនស៊ីមេទ្រីគ្នា (ដែលមិនសមសួន/ខុសគ្នា) ដែលម្ខាងជាកសិករតូចតាច អ្នកនេសាទ និងប្រជាពលរដ្ឋឯទៀតមានដីតិចតួច និងម្ខាងទៀតជាអ្នកកាន់កាប់ដីសម្បទានធំៗ ហើយនេះជាប្រភពនាំឱ្យខ្វះប្រសិទ្ធភាព និងការប៉ះទង្គិចផលប្រយោជន៍។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ សម្ពាធប្រជាសាស្ត្រ ការជ្រៀតចូលមិនស្មើគ្នានៃកម្លាំងទីផ្សារដ៏ធំទូលំទូលាយ ដែលខ្វះការគ្រប់គ្រងល្អក្នុងសេដ្ឋកិច្ចផ្គត់ផ្គង់សម្រាប់តែចិញ្ចឹមជីវិតទីផ្សារ ដែលឥណទានមានការប្រាក់ខ្ពស់ កង្វះការអង្កេតសុរិយោដីលើដីដែលចាំបាច់ ត្រូវដឹងច្បាស់លាស់បញ្ជាក់ពីភាពជាម្ចាស់ដី ពោលគឺទាំងអស់នេះ រួមជាមួយនឹងអភិបាលកិច្ចទន់ខ្សោយផង បានបណ្តាលឱ្យអនុបាតធនធាន និងប្រជាជនចុះអន់ថយកាន់តែអាក្រក់ឡើង។

ជំពូកនេះពិនិត្យពិគ្រោះលើសមត្ថភាពទន់ខ្សោយខ្លះៗរបស់ស្ថាប័ន និងស្នើវិធីសាស្ត្រសមស្របសម្រាប់ធ្វើឱ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសាមញ្ញ។ ជំពូកនេះពិនិត្យលើ (១) ស្ថានភាពដីធ្លីបច្ចុប្បន្ន រួមមានចំណែកដីតូចៗ ដីសម្បទានសេដ្ឋកិច្ច និងភាពគ្មានដីធ្លី (២) ការដែលជនជាតិដើមភាគតិច ត្រូវពុះពារប្រឈមនឹងការខិតខំការពារសិទ្ធិកាន់កាប់ដីប្រពៃណី និង (៣) ប្រសិទ្ធភាពនៃការផ្តល់ដីសម្បទានសង្គមកិច្ចក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ។ (៤) ជំពូកនេះក៏ប្រមាណមើលអំពីបញ្ហាប្លង់ដី (សិទ្ធិលើកម្មសិទ្ធិ) (៥) របរនេសាទ និងជីវភាពរស់នៅ រួមមានទាំងការពឹងផ្អែកកាន់តែច្រើនលើការនេសាទ ព្រមទាំងផលប៉ះពាល់លើឡូត៍នេសាទ ហើយនិង (៦) ព្រៃឈើ និងជីវភាពរស់នៅ រួមទាំងព្រៃសហគមន៍ជាទម្រង់ថ្មីមួយសម្រាប់គ្រប់គ្រងព្រៃឈើ។

## ៣.១ ស្ថានភាពដីធ្លីបច្ចុប្បន្ន [១៤]

### *ផ្ទៃក្រឡា ការត្រួតពិនិត្យ និងការប្រើប្រាស់*

ផ្ទៃដីកម្ពុជាមានទំហំ ១៨,១ លានហិចតា (ឬ ១៨១.០៣៥ គីឡូម៉ែត្រក្រឡា)។ រដ្ឋជាម្ចាស់ដី ១៤,៥ លានហិចតា (៨០%) រីឯ ៣,៦ លានហិចតា (២០%) ជាដីរបស់ឯកជន។ ដីរបស់រដ្ឋមានពីរប្រភេទ គឺដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ប្រអប់ ៣.១ ផ្តល់និយមន័យ រីឯរូបភាព ៣.១ បង្ហាញលំនាំនៃភាពជាម្ចាស់ដី។

អង្កេតសុរិយោដី និងការវាស់វែងដីធ្លីឱ្យបានពេញលេញ គឺជាការចាំបាច់ និងបន្ទាន់បំផុត ដើម្បីកំណត់ឱ្យច្បាស់អំពីការប្រើប្រាស់ដីធ្លី។ ទិន្នន័យដែលមានស្រាប់បង្ហាញថា ព្រៃគ្របដណ្តប់លើទំហំដីប្រហែល ៥៨% នៃផ្ទៃក្រឡាដីទាំងអស់ (ក្នុងបញ្ជីខ្លះ ៦០%) វាលស្មៅ ព្រៃកំប៉ូត និងដីលិចទឹក ១៥% ដីកសិកម្ម ២២% និងទីប្រជុំជន ស្ទឹង ទន្លេ ត្រពាំង បឹងបួរ និងដីដទៃទៀតប្រហែល ៥%។

---

(១៤) ផ្នែកនេះត្រូវបានដកស្រង់ពី Ballard និង So (២០០៤); CDRI (២០០៥); Chan និង Acharya (២០០២); So, et al. (២០០១); និង Chan, Tep និង Acharya (២០០១)

**ប្រអប់ ៣.១ : ចំណាត់ថ្នាក់ដីធ្លី**

*ច្បាប់ដីធ្លី (ច្បាប់ភូមិបាល) ឆ្នាំ ២០០១ ចាត់ថ្នាក់ដីតាមការប្រើប្រាស់ភាពជាម្ចាស់ និងការត្រួតពិនិត្យ ។ ប្រភេទដីចម្បងៗ រួមមាន :*

ក. *សម្បត្តិសាធារណៈរបស់រដ្ឋ :*
*ដីនេះគ្រប់គ្រងដោយរដ្ឋសម្រាប់ជាប្រយោជន៍សាធារណៈ និងបរិស្ថាន ឧ. ព្រៃបម្រុងធម្មជាតិ ទន្លេ ស្ទឹង បឹងបួរ ឆ្នេរសមុទ្រ និងដីផ្សេងទៀត ។ ដីនេះលក់ដូរមិនបានទេ ថ្វីត្បិតតែអាចស្ថិតនៅក្រោមសិទ្ធិគ្រប់គ្រង/ប្រើប្រាស់បណ្ដោះអាសន្ន និងសម្បទានសម្រាប់កាប់ឈើក៏ដោយ ។*

ខ. *សម្បត្តិឯកជនរបស់រដ្ឋ :*
*ដីនេះជាដីរបស់រដ្ឋ ប៉ុន្តែមិនមែនសម្រាប់ជាប្រយោជន៍សាធារណៈទេ ។ ជាញឹកញយ ដីនេះនៅទំនេរដែលអាចយកទៅប្រើប្រាស់ ឬផ្ទេរបាន ដីទាំងនេះអាចយកទៅប្រើជាដីសម្បទាន (សម្រាប់ធ្វើចំការធំៗ/កសិដ្ឋានពាណិជ្ជកម្មយករ៉ែ ឬដីសម្បទានសង្គមកិច្ច) ។*

គ. *ដីកម្មសិទ្ធិឯកជន :*
ជាដីរបស់ឯកជន ឬអង្គភាពឯកជន ។ ដីឯកជនអាចជួល ដាក់ធានា ចែកកេរ ផ្ទេរបាន ។

ច្បាប់ព្រៃឈើបែងចែកជាព្រៃបម្រុងអចិន្ត្រៃយ៍និងព្រៃឯកជន ។ ព្រៃបម្រុងអចិន្ត្រៃយ៍ស្ថិតនៅជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ ព្រៃទាំងនេះចែកចេញជា :

ក. *ព្រៃផលិតកម្ម* (សម្រាប់ឈើហ៊ុប ផលមិនមែនឈើហ៊ុប ព្រៃរេចរិលសម្រាប់ដាំកូនឈើសារឡើងវិញជាដើម)

ខ. *ព្រៃការពារ* (សម្រាប់ជីវចម្រុះ ការពារបរិស្ថាន និងថែរក្សាប្រភពទឹក )

គ. *ព្រៃកែច្នៃ* (ដីព្រៃទំនេររបស់រដ្ឋដែលគ្របដណ្ដប់ជាចម្បងទៅ ដោយសារពើរុក្ខជាតិបន្ទាប់បន្សំ ឬព្រៃឈើបន្ទាប់បន្សំ) ។

ព្រៃឯកជន គឺជាព្រៃដែលជាសម្បត្តិកម្មសិទ្ធិឯកជន ។

ច្បាប់នេសាទចែកការនេសាទជាបីកម្រិត :

ក. ការនេសាទទ្រង់ទ្រាយធំ រួមមាន ឡូត៍នេសាទ ដែលម្ចាស់ឡូត៍នេសាទមានសិទ្ធិពេញទីក្នុងការធ្វើជំនួញនេសាទសម្រាប់រយៈពេលពីរឆ្នាំ ។ គេតែងតែប្រើឧបករណ៍នេសាទធំៗនៅក្នុងដែនទឹកដែលមានត្រីច្រើន ។

ខ. ការនេសាទទ្រង់ទ្រាយមធ្យម ប្រើឧបករណ៍នេសាទតូចជាងការនេសាទទ្រង់ទ្រាយធំ ។ កាលពីមុនការនេសាទបែបនេះ ត្រូវមានអាជ្ញាប័ណ្ណ ។ ឥឡូវនេះមិនបាច់មានអាជ្ញាប័ណ្ណទៀតទេ ។ ប៉ុន្តែមានការហាមឃាត់ប្រចាំរដូវ ។

គ. ការនេសាទទ្រង់ទ្រាយតូច ដោយប្រើឧបករណ៍នេសាទតូចៗប្រភេទឧបករណ៍តាមប្រពៃណី ។ ការនេសាទទ្រង់ទ្រាយតូចទាំងនេះអាចធ្វើបាននៅគ្រប់ទីកន្លែង លើកលែងតែនៅតំបន់ឡូត៍នេសាទសម្បទានទ្រង់ទ្រាយធំ (ក) និងទ្រង់ទ្រាយមធ្យម (ខ) ខាងលើ ។

*ប្រភព : Christian, Heou និង Kholk (២០០៥)*

*រូបភាព ៣.១ : ទិដ្ឋភាពទូទៅនៃប្រភេទដីធ្លី និងទឹកស្របច្បាប់នៅកម្ពុជា*



*ប្រភព : GTZ (២០០៦)*

**ប្រអប់ ៣.២ : ដីកសិកម្មក្នុងរយៈពេលមួយសតវត្សរ៍កន្លងមក**



នៅកម្ពុជា មានប្រវត្តិឯកសារដីតិចតួចណាស់ ។ ប៉ុន្តែនៅមុនសម័យអាណានិគម គឺក្នុងឆ្នាំ ១៨៤០ ដីទាំងអស់ជាសម្បត្តិរបស់ព្រះមហាក្សត្រ តែកសិករអាចដាំដុះតាមចិត្តប្រាថ្នា ដោយគ្រាន់តែមានជង្វាយបន្តិចបន្តួចយកទៅថ្វាយអ្នកគ្រប់គ្រង ។

ដោយមានមធ្យោបាយដាំដុះ និងមានសេចក្តីត្រូវការតិចតួច ពោលគឺសង្គមកម្ពុជាជាសង្គមកសិករ ដែលត្រូវការល្មមគ្រប់គ្រាន់សម្រាប់តែរស់ដោយមិនគិតអំពីកម្រៃចំណេញ ហើយម្នាក់ៗកាន់កាប់ដីមិនច្រើនជាង ១ ទៅ ២ ហិចតាទេ ។ ក្នុងទសវត្សរ៍ឆ្នាំ ១៨៤០ កាលនោះ មិនខ្វះដីធ្វើកសិកម្មទេ ពីព្រោះប្រជាពលរដ្ឋនៅមានចំនួនតិច (គឺតិចជាងមួយលាននាក់) ។ ហេតុនេះហើយបានជាដីមិនមានតម្លៃទីផ្សារ ។ ដីមិនមែនជាសម្បត្តិសម្រាប់លក់ទិញទេ ។

ចាប់ពីចុងសតវត្សរ៍ទី ១៩ ដល់ទសវត្សរ៍ឆ្នាំ ១៩៣០ រដ្ឋបាលអាណានិគមបារាំងបានព្យាយាមរៀបចំប្រព័ន្ធដីឯកជន និងប្រព័ន្ធកម្មសិទ្ធិដីធ្លី (ច្បាប់ដីធ្លី ឆ្នាំ ១៨៨៤) ប៉ុន្តែការប្រឹងប្រែងនេះមិនបានជោគជ័យទាំងស្រុងទេ ។ ដីស្រែនៅតាមវាលទំនាបនៃដែនដីសណ្តទន្លេមេគង្គ និងទន្លេសាប មានការរីកចម្រើនខ្លះៗ ប៉ុន្តែនៅមានតំបន់ជាច្រើនទៀតក្រៅពីតំបន់វាលទំនាប (គឺនៅប៉ែកខាងលិច ខាងជើង និងឦសាន) មិនទាន់បានរៀបចំទេ ។

ក្រោយពីសម័យអាណានិគមភ្លាមៗ (ឆ្នាំ ១៩៥៣-១៩៧៥) រដ្ឋាភិបាលបានបន្តប្រើប្រព័ន្ធដែលបារាំងបានបន្សល់ទុកឱ្យ ។ ក្នុងរយៈពេលនេះ ការយកដីទៅធ្វើអាជីវកម្ម ឬធ្វើឯកជនភាវូបនីយកម្ម និងការធ្វើច្បាប់ដីធ្លី ក៏នៅមិនទាន់បានជោគជ័យនៅឡើយដែរ ។ ផលិតភាពលើដីទាំងនោះមិនទាន់បានខ្ពស់ ប៉ុន្តែប្រទេសកម្ពុជាបាននាំស្រូវទៅលក់នៅបរទេសក្នុងតម្លៃទាប ដោយសារមានផលិតផលស្រូវច្រើនលើសលប់ តែមិនមែនដោយសារការបង្កើនទិន្នផលទេ គឺជាលទ្ធផលនៃការពង្រីកទំហំដីកសិកម្មតែប៉ុណ្ណោះ ។ របាយការណ៍និយាយថា កសិករជាប់បំណុលគេយ៉ាងធ្ងន់ធ្ងរ ហើយពួកគេភាគច្រើនបានបាត់បង់ដីធ្លីដោយឈ្មួញធ្វើពាណិជ្ជកម្មគឺរឹងរឹលើផលកសិកម្ម ។

ពេលខ្មែរក្រហមកាន់កាប់ (១៩៧៥-១៩៧៩) មានការប្រែប្រួលយ៉ាងធ្ងន់ធ្ងរ ។ ពួកខ្មែរក្រហមប្រមូលយកដីទាំងអស់ទៅដាក់រួម លុបបំបាត់ឯកសារដីធ្លី និងស្ថាប័នពាក់ព័ន្ធនឹងដីធ្លី ព្រមទាំងជម្លៀសប្រជាពលរដ្ឋពាសពេញប្រទេស ។ បង្គោលព្រំដីស្រែចំការត្រូវបានរុះរើចោលទាំងអស់ផ្ទុយទៅវិញ ខ្មែរក្រហមរៀបចំដីជាទំហំធំៗ ដើម្បីតម្រូវតាមប្រព័ន្ធធារាសាស្ត្រដែលគេបានគ្រោងទុក ។ ការប្រមូលដីទាំងអស់ធ្វើជាដីរួមនេះហើយ ដែលជាមូលដ្ឋាននៃជម្លោះដីធ្លីយ៉ាងច្រើនសម្បើមនាសព្វថ្ងៃនេះ ។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ដីធ្លីត្រូវបានរៀបចំសារជាថ្មី ជាក្រុមសាមគ្គីតូចៗ (ក្រុមសាមគ្គី ២៥-៣០ គ្រួសារ) ដែលយកធនធានទាំងនោះទៅប្រើសម្រាប់ធ្វើកសិកម្ម ។ ក្រោយមក ប្រហែលពីពាក់កណ្តាលទៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ក៏ចាប់ផ្តើមមានដីជាលក្ខណៈឯកជនឡើង ។ នៅឆ្នាំ ១៩៨៩ រដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៥ រៀបចំឱ្យមានឯកជនភាវូបនីយកម្មដីធ្លី ។ ពាក្យតវ៉ាទាំងឡាយយោងទៅលើសម័យមុនឆ្នាំ ១៩៧៩ ត្រូវបដិសេធ ។ ជាគោលការណ៍ ដីកសិកម្មត្រូវចែកជូនកសិករស្មើរតែស្មើៗគ្នា ដោយផ្អែកទៅតាមចំនួនមនុស្សនៅក្នុងគ្រួសារ (គ្រួសារដែលមានសមាជិកច្រើនទទួលបានដីច្រើន) ។ ដីកសិកម្មសម្រាប់បុគ្គលម្នាក់ៗមិនលើសពី ៥ ហិចតា ទេ ។ ចំពោះដីធំៗសម្រាប់ការដាំដុះទ្រង់ទ្រាយធំ រដ្ឋាភិបាលផ្តល់ជាដីសម្បទាន ។ មានបញ្ហាជាច្រើនដោយសារដីដែលចែកឱ្យនោះ ត្រូវបានជ្រៀកជាចម្រៀកតូចៗ ហើយគ្រួសារដែលបានទទួលដីតូចៗទាំងនោះមានដីជាច្រើន ដែលនៅដាច់ឆ្ងាយៗពីគ្នា ។ លើសពីនេះទៀត ដីតូចៗដែលចែកឱ្យគ្រួសារទាំងនោះ នៅជាប់ជំពាក់ក្នុងបណ្តឹងតវ៉ាគ្នានៅឡើយ ។ ការមិនមានសេវាផ្នែកសុរិយោដី និងការខ្វះយន្តការអាជ្ញាកណ្តាលឯទៀតៗ បណ្តាលឱ្យដំណោះស្រាយវិវាទអស់ទាំងនេះរាំងស្ទះ ។ កាលពីសម័យនោះ ច្បាប់ចែងថា ដីណាដែលទុកចោលទំនេរជាងបីឆ្នាំ ឥតប្រើប្រាស់ រដ្ឋនឹងដកហូតដីនោះយកវិញ ។ ចំណុចនោះមិនបានអនុវត្តឱ្យបានហ្មត់ចត់ទេ ។ ក្រោយមក ច្បាប់ដីធ្លីឆ្នាំ ១៩៩២ ទទួលស្គាល់តែសិទ្ធិមានដី ប៉ុន្តែមិនទទួលស្គាល់កម្មសិទ្ធិដីនៅតាមតំបន់ជនបទទេ ។ បន្ទាប់ពីការប្រកាសឱ្យប្រើប្រាស់ និងការអនុវត្តប័ណ្ណកាន់កាប់ដីធ្លី មានការទទួលស្គាល់សិទ្ធិប្រើប្រាស់ដីធ្លី ។ មានពាក្យសុំចំនួនទាំងអស់ពី ៤ ទៅ ៦ លានពាក្យ ប៉ុន្តែរហូតដល់ឆ្នាំ ២០០១ ការចេញបណ្ណ័កាន់កាប់ដី ធ្វើបានតែ ១៥% ប៉ុណ្ណោះ ដោយសារសមត្ថភាពដំណើរការកិច្ចការទាំងនេះនៅមានកម្រិត ។ ការចេញប្លង់ដីក្នុងឆ្នាំ ២០០៦ ធ្វើបានជាង ២០-២៥% នៃពាក្យសុំទាំងអស់ : ០.៥៧ លានពាក្យសុំ តាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ (តាមបុព្វសិទ្ធិរបស់រដ្ឋាភិបាល) និងពាក្យសុំចំនួន ០.៥៨ លានពាក្យ ដែលតាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ (គឺសុំដោយម្ចាស់ដីខ្លួនឯង) ដោយគិតមកដល់ ខែធ្នូ ឆ្នាំ ២០០៦ ។

ជាសង្ខេប ការវិវត្តទីផ្សារដីធ្លី និងការធ្វើពាណិជ្ជកម្មផ្នែកកសិកម្មមានការយឺតយ៉ាវ និងមិនទៀងទាត់ក្នុងរយៈមួយសតវត្សរ៍កន្លងមក ។ នៅកន្លែងខ្លះទៀត (គឺនៅតាមវាលស្រែចំការ តំបន់ដែនដីសណ្តទន្លេមេគង្គ និងនៅជុំវិញទន្លេសាប) ការដាំដុះដំណាំផ្សេងៗបានប្រព្រឹត្តទៅជាយូរយាមកហើយ - ឯកសារចែងថា សូម្បីនៅសម័យអាណានិគម ក៏មានការបង់ពន្ធលើផលស្រូវដែរ ។ នៅតាមតំបន់ឯទៀតៗ (តំបន់ព្រៃសាន និងឧត្តរ) ទម្លាប់ចាស់ដែលកាប់បំផ្លាញព្រៃឈើដើម្បីទន្ទ្រានយកដី មានតាំងតែពីយូរយាណាស់មកហើយ សព្វថ្ងៃនេះនៅមាននៅឡើយជាកន្លែងតូចៗ ។ កាលពីមុន និងសូម្បីតែសព្វថ្ងៃនេះ មនុស្សកាន់កាប់ដីជាមុនហើយ ទើបសុំអាជ្ញាធរឱ្យចេញប័ណ្ណស្របច្បាប់ជាក្រោយ ប្រសិនបើអ្នកកាន់កាប់ដីទាំងនោះដាក់ពាក្យសុំ ។ នៅតំបន់ព្រៃសាន មានធ្វើកសិកម្មពនេចរយ៉ាងខ្លាំងពីអតីតកាល ហើយសព្វថ្ងៃនេះនៅតែមានខ្លះៗនៅឡើយ ។ នៅតំបន់នោះប្រជាពលរដ្ឋកាន់កាប់ដីជាសហគមន៍ មិនមែនជាឯកជនទេ ។ ប៉ុន្តែទម្លាប់នេះកំពុងតែផ្លាស់ប្តូរជាបណ្តើរៗហើយសព្វថ្ងៃនេះ ។

សង្ឃឹមថា ការអនុវត្តគោលនយោបាយថ្មីស្តីពីដីធ្លី និងគម្រោងអភិវឌ្ឍន៍ជនបទដទៃៗទៀត នឹងនាំមកនូវការរីកចម្រើនដែលគេរំពឹងទុកជាយូរមកហើយ ។

*ប្រភព : Boserup (១៩៦៥); Thion (១៩៩៣); Chandler (១៩៩៣); Chandler (២០០៦); ប្រអប់ ១.១ ក្នុងរបាយការណ៍នេះ*

## ទំហំដីកសិកម្ម និងដីដែលដាច់គ្នាជាផ្នែកៗ

ដីកសិកម្មតូចៗមានទំហំ ២,៤៦ លានហិចតា ដែលចែកជា ៣,៥៩ លានដុំតូចៗ យោងតាមឯកសារ SES-០៤ ។ ដីតូចៗទាំងនោះមានទំហំ ០,៦៩ ហិចតា ហើយមិនមានការខុសគ្នាទេ ទោះនៅតាមតំបន់ដែលមានមនុស្សច្រើនក៏ដោយ ។ សូម្បីតែនៅខេត្តមណ្ឌលគិរី ដែលមានប្រជាពលរដ្ឋតិចតួចក៏ដោយ ក៏ដីដែលចែកឱ្យមួយដុំៗនៅតែមានទំហំតូចដដែល ។ ប្រហែល ៦៨ % នៃដីកសិកម្មដែលចែកឱ្យជាដីតូចៗមានទំហំត្រឹមតែ ០,៥ ហិចតា ឬតូចជាង រីឯដី ១៣ % ទៀត មានទំហំច្រើនជាង ១ ហិចតា (រូបភាព ៣.២) ។ ការប៉ាន់ប្រមាណផ្សេងៗគ្នាលើទំហំដីរបស់គ្រួសារនីមួយៗ មាននៅក្នុងឯកសារខុសៗគ្នា (រូបភាព ៣.៣) ។ ដោយមិនគិតពីប្រភពទិន្នន័យទំហំដីជាមធ្យមភាគដែលគ្រួសារនីមួយៗកាន់កាប់មានទំហំពី ១ ទៅ១,៤ ហិចតា ។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ តែងតែទទួលបានដីតូចជាងគ្រួសារដែលមានបុរសជាមេគ្រួសារ[១៥] ។ អនុបាតនៃតួលេខដីកសិកម្មសរុបសម្រាប់កសិករម្នាក់ៗ គឺ ០,៤៦៥ ហិចតា ។

---

*(១៥) គ្រួសារមួយអាចមានដីច្រើនដុំ ។*

*រូបភាព ៣.២ : ការចែកដីកសិកម្មជាផ្នែកតូចៗ (%) ឆ្នាំ ២០០៣-២០០៤*




*ប្រភព :* SES-04

បើសមាសភាគនៃផលិតផលក្នុងស្រុកសរុបបានមកពីដំណាំកសិកម្មចែកជាមួយនឹងចំនួនកសិករ ប្រាក់ចំណូលពីដំណាំសម្រាប់កសិករម្នាក់ៗក្នុងរយៈពេលមួយឆ្នាំ ស្មើនឹង ១២៨ ដុល្លារអាមេរិក (សម្រាប់ឆ្នាំ២០០៤គិតក្នុងតម្លៃថេរឆ្នាំ២០០០) បើរាប់បញ្ចូលទាំងការចិញ្ចឹមសត្វផង ផលិតផលក្នុងស្រុកសរុបសម្រាប់ម្នាក់ៗឡើងដល់ ១៧១ ដុល្លារអាមេរិក ដែលផ្ទុយគ្នាទៅនឹងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំនោះ ដែលមានចំនួន ៣៨០ ដុល្លារ។ តួលេខទាំងអស់នេះ និយាយអំពីបញ្ហានៃការកាន់កាប់ចំណែកដីតូចៗ (ដីតូចៗ និងការកាន់កាប់ដី) ដែលផ្ទុយនឹងអនុបាតដី និងកសិករ និងប្រាក់ចំណូលដែលមិនគ្រប់គ្រាន់។

*រូបភាព ៣.៣ : មធ្យមភាគដីកសិកម្មក្នុងគ្រួសារនីមួយៗ (ជាហិចតា) តាមអង្កេតផ្សេងៗគ្នា*[16]



## ដីសម្បទានសេដ្ឋកិច្ច

ផ្ទុយទៅវិញ រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចតាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ ម្ល៉េះ ក្នុងទំហំជាច្រើនពាន់ហិចតាក្នុងដីសម្បទាននីមួយៗ។ ការផ្តល់ដីសម្បទានបែបនេះនៅបន្តទៅទៀតក្នុងអត្រាមួយ ដែលកើនឡើងស្មើនឹងបីដងក្នុងឆ្នាំ ២០០៦ ច្រើនជាងឆ្នាំ ២០០៥។ មូលហេតុ គឺគោលនយោបាយនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ នឹងធ្វើឱ្យរីកចម្រើនខ្លាំងក្នុងវិស័យផលិតភាពពាណិជ្ជកម្មនៅលើដីឯទៀតៗក្រៅពីដីស្រែ និងជម្រុញឱ្យធ្វើការដាំដុះជាទ្រង់ទ្រាយធំ (ឈើម៉ៃសាក់ ដើមប្រេងខ្យល់ ដូងប្រេង អំពៅ ដំឡូងឈើ កៅស៊ូ ស្វាយចាន់ទី ល្ហុងខ្មែរ ស្រូវ ពោត សណ្តែក និងដំណាំឯទៀតៗជាច្រើន)។ សង្ឃឹមថា គោលនយោបាយនេះនឹងបង្កើនប្រាក់ចំណូលជូនរដ្ឋពីពន្ធដារ និងពីការជួលដី។ ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ដីសម្បទានមានទំហំ ៩៤៣.០៦៩ ហិចតា (ឱ្យទៅក្រុមហ៊ុន ៩៧ ក្រោមកិច្ចព្រមព្រៀង

---

*(១៦) អង្កេតជាបន្ទាត់មូលដ្ឋានឆ្នាំ ១៩៩៨ និងការតាមពិនិត្យបន្ថែមឆ្នាំ ២០០០ គឺជាអង្កេតធំៗ (ទោះជាមិនដំណាងឱ្យប្រទេសទាំងមូលក៏ដោយ) ធ្វើឡើងដោយ UNICEF-WFP, រីឯការអង្កេតរបស់ PET វិញ (ក៏មិនតំណាងឱ្យចំណុចគោលដៅដែលអាចមានភាពអាសន្ននៅថ្ងៃមុខ) ដែលធ្វើឡើងដោយ WFP តែឯង។ SES-៩៧ គឺជាអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ធ្វើឡើងនៅឆ្នាំ ១៩៩៧។*

ដែលមានចុះហត្ថលេខាត្រឹមត្រូវ) និង ៦៤.២០៣ ហិចតា (ឱ្យទៅក្រុមហ៊ុន ៩ ក្នុងកិច្ចព្រមព្រៀងដែលអត់មានចុះហត្ថលេខាត្រឹមត្រូវ)[១៧]។ តាមច្បាប់ ដីសម្បទាននីមួយៗមិនត្រូវមានទំហំលើសពី ១០,០០០ ហិចតាទេ ប៉ុន្តែដីសម្បទានជាច្រើនមានទំហំធំជាងនេះ (រូបភាព ៣.៤)។ ដីសម្បទានដែលធំជាងគេមានទំហំ ៣១៥,០២៣ ហិចតា ដែលមានដីសម្បទានពីរកៀរគ្នានៅក្នុងខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ដែលផ្តល់ជូនទៅក្រុមហ៊ុនតែមួយ។ ក្នុងករណីច្រើនទៀត ដីសម្បទានត្រូវបានផ្តល់ជូនដោយមានដើមឈើធំៗជាច្រើន ដែលម្ចាស់ដីសម្បទានបាននឹងកំពុងផ្តួលរំលំដើមឈើធំៗទាំងនោះ[១៨]។ ការផ្តល់ដីសម្បទាននានា តែងតែផ្តល់ដោយពុំបានគោរពតាមច្បាប់សម្បទាន និងដោយមានតម្លាភាពតិចតួច។

*ការផ្តល់ដីសម្បទានតែងតែធ្វើដោយពុំបានគោរពតាមច្បាប់សម្បទាន និងដោយមានតម្លាភាពតិចតួច។ ដីដែលក្រុមហ៊ុនទាំងនោះ បានដាំដុះមានទំហំត្រឹមតែ ១,៨% នៃចំនួនដីសម្បទានទាំងអស់*

នៅចុងឆ្នាំ ២០០៥ ក្នុងចំណោម ៣២ ក្រុមហ៊ុនដែលទទួលដីសម្បទានមានតែក្រុមហ៊ុន ៨ ប៉ុណ្ណោះ ដែលបានធ្វើការដាំដុះយ៉ាងសកម្ម ហើយដីដែលក្រុមហ៊ុនទាំងនោះ បានដាំដុះមានទំហំត្រឹមតែ ១,៨% នៃចំនួនដីសម្បទានទាំងអស់។ ខាងក្រោមនេះ គឺជាមូលហេតុដែលបណ្តាលឱ្យមានការដាំដុះតែបន្តិចបន្តួចនៅលើដីសម្បទានទាំងនោះ :

ក. ការផ្តល់សម្បទានធំៗទៅឱ្យក្រុមហ៊ុន ធ្វើឡើងដោយពុំបានពិនិត្យពិច័យពីផ្នែកសុរិយោដី ដែលជាហេតុបណ្តាលឱ្យមានទំនាស់ជាមួយកសិករ។

ខ. ដីសម្បទានខ្លះ បានត្រូវគេយកទៅទុកសម្រាប់ដោះដូរយកចំណេញ។ កន្លងមករដ្ឋាភិបាលបានលុបចោលដីសម្បទានចំនួន ៣០ ហើយ (ទំហំ ២៦៩.២៣០ ហិចតា) ដោយសារគ្មានសកម្មភាពផលិត ហើយដីជាច្រើននៅទំនេរឥតប្រើប្រាស់។

គ. ដីភាគច្រើនត្រូវគេរាយការណ៍ថា គេប្រើសម្រាប់តែកាប់យកឈើហ៊ុប។

ថ្វីត្បិតតែជាទូទៅមានការដាំដុះតិចតួចនៅលើដីសម្បទានទាំងនេះក៏ដោយ ក៏នៅតាមដីសម្បទានខ្លះ ធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានរួចទៅហើយ ដែលបណ្តាលមកពីកិច្ចការកសិកម្ម និងកិច្ចការសាធារណៈខ្លះ។ ខ្លះទៀត មានផលប៉ះពាល់អវិជ្ជមានទៅលើជីវសាស្ត្រនៅមូលដ្ឋាន និងធ្វើឱ្យខូចជាធ្ងន់ធ្ងរដល់ផលប្រយោជន៍កសិករ ក្រៅអំពីផលប្រយោជន៍សម្បទាន (ឧទាហរណ៍ : ដូចជា ការកាប់រំលំដើមឈើធំៗ ទប់ស្ទឹង ប្រឡាយ ឬបំបែរទិសសម្រាប់ទឹកហូរជាដើម)។ មានសេចក្តីបញ្ជាក់បន្ថែមថា ដីសម្បទាននេះមិនបានផ្តល់ផលប្រយោជន៍ដល់ប្រទេសទេ។ ហើយរដ្ឋក៏មិនបានទទួលប្រាក់ចំណូលធំដុំពីកិច្ចការទាំងនេះដែរ។

***រូបភាព ៣.៤ : ទំហំដីសម្បទានក្រោមកិច្ចព្រមព្រៀងដែលមានចុះហត្ថលេខាត្រឹមត្រូវ ប្រចាំខេត្តនីមួយៗ ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧***



*សម្គាល់ : តួលេខក្នុងរង្វង់ក្រចកជាចំនួនដីសម្បទានក្នុងមួយខេត្ត។ ក្រុមហ៊ុនទទួលដីសម្បទានទាំងអស់មាន ៥៧ ក្រុមហ៊ុន។*

*ប្រភព :* MAFF (http://maff.gov.kh/elc/overview.html)

*(១៧) ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។*

*(១៨) ប្រភព : UNHCHR (២០០៤); EFCT (២០០៥); Thanh (២០០៥)។*

*នៅចន្លោះពីឆ្នាំ ១៩៩៩ និងឆ្នាំ ២០០៣-២០០៤ ចំណែកដីដែលពលរដ្ឋក្រីក្រចំនួន ២/៥ នៃប្រជាពលរដ្ឋទាំងអស់កាន់កាប់បានថយចុះពី ៨.៤% ទៅ ៥.៤% ប៉ុន្តែចំណែកដីដែលកាន់កាប់ដោយអ្នកមានវិញ ដែលមានចំនួនតែ ១/៥ នៃប្រជាពលរដ្ឋក្នុងប្រទេស បានកើនឡើងពី ៥៩-៧០%*

ដីសម្បទានសេដ្ឋកិច្ច ដែលមិនបានប្រើប្រាស់ទាល់តែសោះ ឬមិនបានប្រើឱ្យពេញសក្តានុពល ជាកត្តារារាំងដល់ការរួមចំណែករបស់វិស័យកសិកម្មទៅក្នុងផលិតផលក្នុងស្រុកសរុប ព្រមទាំងមិនបានផ្តល់ឱកាសដល់គ្រួសារក្រីក្រឱ្យធ្វើការក្នុងសកម្មភាពកសិកម្ម ដែលមានផលចំណេញច្រើន និងប្រកបដោយចីរភាព។

## ការទិញដីសម្រាប់លក់ដំឡើងថ្លៃ

ដីនៅទីតាំងល្អៗខ្លះ (នៅជុំវិញទីប្រជុំជន និងតាមដងផ្លូវ) ត្រូវបានគេទិញដើម្បីទុកលក់ដំឡើងថ្លៃ។ ដីទាំងនេះត្រូវបានគេបោះបង្គោលព្រំ ហើយទុកចោលឥតដាំដុះដែលជាការខាតបង់ចំពោះសង្គម និងចំពោះសេដ្ឋកិច្ច។ ពួកអ្នកមានទ្រព្យសម្បត្តិដែលដឹងថា ដីមានសក្តានុពលពាណិជ្ជកម្ម ទិញដីទាំងនេះពីកសិករដែលមិនសូវដឹងអំពីអនាគតរបស់ដីខ្លួនដែលត្រូវមានតម្លៃខ្ពស់។ ដូច្នេះការទទួលព័ត៌មានមិនស្មើគ្នាបានធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់កសិករដែលជាម្ចាស់ដី។ ច្បាប់សម្រាប់យកពន្ធដី និងរឹបអូសដីណាដែលមិនបានប្រើប្រាស់មិនទាន់បានយកមកអនុវត្តនៅឡើយទេ។

## ភាពមិនស្មើគ្នារវាងដីកសិកម្ម និងភាពឥតដីធ្លី

កម្ពុជាមានប្រវត្តិមិនធ្លាប់ប្រើប្រាស់សិទ្ធិកាន់កាប់ដីធ្លី ដែលមានការចែកដីស្មើរតែស្មើៗគ្នានៅឆ្នាំ ១៩៨៩។ គ្រួសារនីមួយៗទទួលដីច្រើនបំផុតត្រឹម ៥ ហិចតា ដែលចែកទៅតាមចំនួនសមាជិកគ្រួសារ ប៉ុន្តែដីទាំងនោះមិនបានចែកឱ្យនៅជុំគ្នាជាដីមួយដុំទេ។ នេះក៏ដោយសារលក្ខខណ្ឌធាតុអាកាសកសិកម្មផ្សេងៗពីគ្នា ប្រភេទសមាជិកគ្រួសារទីទៃពីគ្នា លក្ខខណ្ឌទីផ្សារដែលប្រែប្រួលខុសៗពីគ្នា ស្ថានភាពប្រជាសាស្ត្រមិនស្មើគ្នា និងដោយសារមានជម្លោះដីធ្លី កសិករជាច្រើនមិនអាច ឬចង់រក្សាទុកចំណែកដីខ្លះ ឬទាំងអស់ដែលចែកឱ្យនោះបានទេ។ ដោយសារហេតុនេះ ដីខ្លះត្រូវជ្រៀកជាចំណែកតូចៗលក់ និងលក់តទៅទៀត។ អង្កេតដីធ្លីជាបន្តបន្ទាប់កន្លងមកបានរកឃើញថា ឥឡូវនេះមនុស្សមានដីតាមការទិញដូរ មិនមែនតាមការចែកដីឱ្យទៀតទេ។

ការមានដីមិនស្មើគ្នានេះកំពុងកើនឡើង។ តាមការប៉ាន់ប្រមាណរវាងឆ្នាំ ១៩៩៩ និងឆ្នាំ ២០០៣-២០០៤ ចំណែកកាន់កាប់ដីរបស់ប្រជាពលរដ្ឋក្រីក្រចំនួន ២/៥ នៃប្រជាពលរដ្ឋទាំងអស់បានថយចុះពី ៨,៤% ទៅ ៥,៤% ប៉ុន្តែចំណែកកាន់កាប់ដីរបស់អ្នកមានបំផុតដែលមានចំនួនតែ ១/៥ នៃប្រជាពលរដ្ឋក្នុងប្រទេសបានកើនឡើងពី ៥៩% ទៅ ៧០%[១៩]។ ភាពឥតដីធ្លីនៅតាមជនបទមានចំនួនប្រហែល ២០% ក្នុងឆ្នាំ ២០០៣-២០០៤ (SES-០៤ រូបភាព ៣.៥) ហើយតួលេខសម្រាប់ស្ត្រីមេគ្រួសារខ្ពស់ជាងតួលេខសម្រាប់បុរសមេគ្រួសារ។ យោងតាមនិន្នាការនៃភាពឥតដីធ្លីក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៩០ និងដើមទសវត្សរ៍ឆ្នាំ ២០០០ មានជំនឿថា ភាពឥតដីធ្លីសម្រាប់ធ្វើកសិកម្មអាចកើនឡើងប្រហែល ២% ក្នុងមួយឆ្នាំៗ ដែលជាតួលេខដូចគ្នាទៅនឹងទិន្នន័យរបស់ SES-០៤។ ប៉ុន្តែស្ថិតិទាំងនេះ អាចមិនឆ្លុះបញ្ចាំងលើភាពឥតដីធ្លីទាំងស្រុងទេ ពីព្រោះសមាជិកគ្រួសារ ឬអ្នករកស៊ីទាំងនោះ មិនសុទ្ធតែជាអ្នកនិយមកសិកម្មទាំងអស់ទេ ពីព្រោះអ្នកខ្លះយកពេលខ្លះទៅប្រកបរបរនេសាទត្រី អ្នកខ្លះទៀតរកប្រាក់ចំណូលពីប្រភពផ្សេងៗ ឬពីសកម្មភាពនានា ដែលមានប្រយោជន៍ដល់សង្គម។ លើសពីនេះទៀត អ្នកដែលឥតមានដីទាំងនោះ មិនមែនសុទ្ធតែជាអ្នកក្រទាំងអស់ទេ[២០]។

*រូបភាព ៣.៥ : ការប៉ាន់ប្រមាណលើភាពឥតដីធ្វើកសិកម្ម*

| ប្រភពទិន្នន័យ | ការប៉ាន់ប្រមាណជា % លើអាត្រាគ្រួសារគ្មានដី |
|---|---|
| LADIT ២០០៤ | ១១.៩% |
| LADIT ២០០០ | ១២.០% |
| SES-២០០៣-០៤ (គ្រួសារជនបទ) | ២០.០% |
| SES-១៩៩៩ (គ្រួសារជនបទ) | ១៥.៨% |
| SES-១៩៩៧ (គ្រួសារជនបទ) | ១៣.០% |

ទិន្នន័យរបស់ LADIT (តាមអង្កេតពីរផ្សេងគ្នា ឆ្នាំ ២០០០-២០០៤) ថ្វីត្បិតតែមិនមែនជាតំណាងរបស់ប្រទេសក៏ដោយ ក៏ជាទស្សនៈអាចយកមកប្រើសម្រាប់ពន្យល់អំពីភាពខ្វះដីធ្លីបានដែរ ពីព្រោះអង្កេតទាំងអស់នេះ បានសម្ភាសន៍សមាជិកគ្រួសារដែលជាកសិករ។ ទិន្នន័យទាំងនេះបង្ហាញអំពីភាពឥតដីធ្លីក្នុងលំដាប់ពី ១១-១២%។ ក្នុងចំណោមអ្នកដែលគ្មានដីក្នុងឆ្នាំ ២០០៤ ៨០% មិនដែលមានដីទាល់តែសោះ (ចំនួននេះកើនឡើងពី ៥៤% កាលពី ឆ្នាំ ២០០០)។ មូលហេតុ គឺគេទើបនឹងរៀបចំគ្រួសារថ្មី ឬទើបនឹងចូលមកនៅក្នុង

(១៩) *សូមមើល SNEC-Harvard University (២០០៦), ទំព័រ ១៦។*

(២០) *Anders និង Kokko (២០០៦); Ballard និង So (២០០៤); ACI (២០០៥)។*

សហគមន៍ ឬចេញពីសហគមន៍ ហើយការពិតមួយទៀត គឺអាស្រ័យដោយដីជាច្រើនដែលពួកអ្នកទាំងនោះកំពុងរស់នៅសព្វថ្ងៃ គឺជាដីលិចទឹក។ ក្នុងចំណោមអ្នកដែលបាត់បង់ដីធ្លី មូលហេតុចម្បង គឺបាត់បង់ដោយសារការបង្ខំចិត្តលក់ដីរបស់ខ្លួន ដើម្បីយកប្រាក់ទៅបង់ថ្លៃព្យាបាលជម្ងឺជាបន្ទាន់។ គួរតែយកចិត្តទុកដាក់ឱ្យខ្លាំងដល់ពួកអ្នកគ្មានដី ដែលមានចែងនៅក្នុងរបាយការណ៍របស់ LADIT ពីព្រោះកសិករទាំងនេះ សុទ្ធតែជាអ្នកពឹងផ្អែកលើមុខរបរកសិកម្ម។ ជាទីបញ្ចប់ ទិន្នន័យបង្ហាញថា មនុស្សជាច្រើនដែលមានដីតូចតាច មិនអាចរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិតបានគ្រប់គ្រាន់ទេ។ ដូច្នេះភាពក្រីក្រពាក់ព័ន្ធនឹងវិស័យដីធ្លី ក៏គួរតែយកចិត្តទុកដាក់ផងដែរ[២១]។

វិសមភាពដីកសិកម្ម និងភាពឥតដីធ្លី ដែលកំពុងលេចឡើងនេះ គឺជាបញ្ហាមួយដែលរីកកាន់តែធំឡើងមិនអាចប្រកែកបាន បញ្ហានេះធ្វើឱ្យសហគមន៍កសិករកាន់តែក្រទៅៗ ហើយបណ្តាលឱ្យវិសមភាព និងទំនាស់ក្នុងប្រទេសកាន់តែរីកធំ។ រូបភាព ៣.៦ ផ្តល់ទិដ្ឋភាពទូទៅស្តីពីមូលហេតុនៃភាពឥតដីធ្លី និងវិសមភាពដីកសិកម្ម។

***រូបភាព ៣.៦ : មូលហេតុនៃការលក់ដូរដី និងផលវិបាកនៃវិសមភាព និងភាពគ្មានដីធ្លី***



*ប្រភព : ការសិក្សាផ្សេងៗរបស់ CDRI និង Oxfam*

*(២១) សូមមើល Biddulph (២000); Biddulph (២00៤)។ ការសិក្សារបស់ Oxfam ដែលកំពុងបន្តនៅភូមិចំនួន ៣00 បានរកឃើញថា ការបំបែកដីជាដុំតូចៗ និងការក្រដីបានឡើងដល់សមាមាត្រគួរឱ្យបារម្ភ។*

## កសិដ្ឋាន / ទំហំដីធំៗ

តាមតំបន់ជាច្រើននៅអាស៊ី មានការជជែកដេញដោលគ្នាថា តើត្រូវលើកស្ទួយកសិកម្មតូចៗ ឬត្រូវប្រមូលផ្តុំដីធ្វើជាកសិកម្មធំៗ។ ការជជែកដេញដោលនេះ តែងតែយោងទៅលើបរិបទនៃការកែទម្រង់ដីធ្លីនៅក្នុងសម័យក្រោយអាណានិគម (ប្រអប់ ៣.៣)។

ដើម្បីពិនិត្យលើបញ្ហាដីធ្លីនៅកម្ពុជា ទិន្នន័យអំពី SES-០៤ ត្រូវបានយកទៅវិភាគ ដើម្បីកំណត់ទំនាក់ទំនងរវាងទំហំដីកសិកម្ម និងអាត្រាទិន្នផលស្រូវ (រូបភាព ៣.៧)។ រូបភាពនេះបង្ហាញអំពីទំនាក់ទំនងផ្ទុយគ្នារវាងទំហំដី និងផលិតភាព គឺផលស្រូវរដូវវស្សាល្អជាងផលស្រូវរដូវប្រាំង។ គេតែងតែដាំស្រូវវស្សាដោយប្រើឧបករណ៍ និងបច្ចេកវិទ្យាធម្មតា និងសម្ភារៈប្រើប្រាស់ទំនើបតិចតួច។ ទិន្នផលនៃការដាំដុះរបៀបនេះមានចំនួនពី ១ តោន ទៅ ១,៨ តោន ក្នុងមួយហិចតា យោងទៅតាមតំបន់នីមួយៗ (ឯកសារឆ្នាំ ២០០៣-២០០៤)។ តាមការប្រៀបធៀប ស្រូវប្រាំងត្រូវបានដាំដោយមានការថែទាំច្រើន ព្រមទាំងប្រើជី និងបច្ចេកវិទ្យាទំនើបថែមទៀត។ ទិន្នផលនៃការដាំរបៀបនេះបានច្រើនជាង ២ តោន ក្នុងមួយហិចតា។ ទំនាក់ទំនងផ្ទុយគ្នា គឺផ្អែកទៅលើការដាំដុះតាមបែបកសិកម្មប្រពៃណី។ សរុបសេចក្តីទៅ កសិករដែលមានការចេះដឹងតិចតួច និងមានមធ្យោបាយតិចតួច (គោ ក្របី ដើមទុនសម្រាប់ធ្វើកសិកម្មជាដើម) មិនអាចធ្វើស្រែនៅក្នុងដីស្រែធំៗឱ្យមានប្រសិទ្ធភាពបានទេ។

### ប្រអប់ ៣.៣ : កសិដ្ឋានតូចៗ និងប្រសិទ្ធភាព - ខ្លឹមសារសំខាន់សម្រាប់ការជជែកវែកញែក

ការពិភាក្សាស្តីពីកសិដ្ឋានតូច និងកសិដ្ឋានធំនៅសម័យទសវត្សរ៍ឆ្នាំ ១៩៦០ និងឆ្នាំ ១៩៧០ ដែលកាលនោះ ភាពជាក់ស្តែងពីប្រទេសនានានៅទូទាំងអាស៊ីបង្ហាញថា កសិដ្ឋានតូចៗផ្តល់ទិន្នផលច្រើនតោនក្នុងមួយហិចតាៗ។ ជាធម្មតាកសិកដ្ឋានតូចៗ គឺជាផ្នែកនៃដីកេរដែលមានជីជាតិ ព្រោះអ្នកទទួលកេរមតិកតែងជ្រើសយកដីណាដែលមានជីជាតិល្អ។ រីឯអនុបាតខ្ពស់នៃពលកម្ម-ដីធ្លី ពោលគឺជាពិសេសពលកម្មក្នុងគ្រួសារផ្តល់ឱកាសឱ្យមានការថែទាំផលដំណាំបានយ៉ាងល្អ ទោះបីជាផលិតភាពបន្ទាប់បន្សំនៃពលកម្មមិនអាចធ្វើឱ្យកើន (អាចស្មើនឹងសូន្យ) ក៏ដោយ។

លទ្ធផលនេះ គឺជាការពិតចំពោះកសិដ្ឋានសម្រាប់តែចិញ្ចឹមជីវិត ដែលតែងតែប្រើមធ្យោបាយភ្ជួររាស់តាមបែបប្រពៃណី ហើយបញ្ចេញពលកម្មផ្ទាល់ខ្លួន (ដោយឥតគិតថ្លៃ) ជំនួសកត្តាផលិតកម្មដទៃទៀត។ ការមកដល់នៃបច្ចេកវិទ្យាកសិកម្មទំនើប (Green Revolution technologies) និងអន្តរកាលឆ្លងទៅកាន់សេដ្ឋកិច្ចទីផ្សារ (ចាកចេញពីសេដ្ឋកិច្ចសម្រាប់បង្គ្រប់រស់) គេរកឃើញថា បច្ចេកវិទ្យាគីមី-ជីវ អាចយកទៅប្រើបានគ្រប់កសិដ្ឋានទាំងអស់ ដោយមិនគិតពីទំហំតូចឬធំ ដែលបច្ចេកវិទ្យាគ្រឿងយន្តមិនអាចធ្វើបាន។ សម្រាប់កសិដ្ឋានធំៗបច្ចេកវិទ្យាគីមី-ជីវនេះ ប្រើបានផលល្អជាង។

ក្រៅពីផលិតភាពការប្រើប្រាស់ដី និងទិដ្ឋភាពសមធម៌ ក៏ត្រូវបានលើកយកមកពិភាក្សាដែរ។ កសិដ្ឋានតូចៗនៅអាស៊ី ត្រូវបានគេប្រើប្រាស់យ៉ាងសកម្មជាងកសិដ្ឋានធំៗ ដែលជួនកាលត្រូវបានគេទុកចោលទាំងស្រុង ឬប្រើប្រាស់តែមួយផ្នែក។ លើសពីនេះ កសិដ្ឋានតូចៗអាចមានការដាំដុះមុខដំណាំច្រើនមុខជាងកសិដ្ឋានធំៗ។ ជាថ្មីម្តងទៀត ការឆ្លងអន្តរកាលពីសេដ្ឋកិច្ចសម្រាប់បង្គ្រប់រស់ចូលទៅកាន់សេដ្ឋកិច្ចទីផ្សារ អ្វីៗដែលជាគុណសម្បត្តិរបស់កសិដ្ឋានតូចៗ ទៅអានាគតនឹងក្លាយជាសាបសូន្យ ដោយសារប្រជាពលរដ្ឋជនបទរកបានជីវភាពល្អប្រសើរនៅក្នុងវិស័យឯទៀតៗក្រៅពីកសិដ្ឋាន។

**ដើមហេតុនៃការជជែកវែកញែកគ្នា :**

ការជជែកវែកញែកនេះត្រូវបានបង្កើតឡើងដើម្បីវាយតម្លៃថា បទពិសោធន៍មុនៗនៅអឺរ៉ុប ស្តីពីការប្រមូលផ្តុំដីកសិកម្មធំៗ អាចយកមកអនុវត្តនៅអាស៊ីបានដែរឬទេ។ ការជជែកបានផ្តើមក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ សម្រាប់អាស៊ីខាងកើត អាគ្នេយ៍ និងខាងត្បូង បានសន្និដ្ឋានថា កសិករតូចតាចប្រើប្រាស់តាមលំនាំបច្ចេកវិទ្យាបែបប្រពៃណី និងដីឱ្យផលច្រើនល្អណាស់ ប៉ុន្តែមានប្រសិទ្ធភាពកើនឡើង កាលណាប្រើបច្ចេកវិទ្យាទំនើបរួមនឹងប្រភេទដំណាំដែលផ្តល់ទិន្នផលខ្ពស់ (HYV) និងផលិតកម្មសម្រាប់ទីផ្សារ។

នៅកម្ពុជា ការផ្តល់ដីសម្បទាន គឺដើម្បីលើកកម្ពស់កសិកម្មសម្រាប់ធ្វើពាណិជ្ជកម្ម។ ទោះជាយ៉ាងណាក៏ដោយ មិនដែលឃើញមានការណែនាំឱ្យប្រមូលផ្តុំដីធ្លីតូចៗឱ្យមានទំហំធំៗ ដូចជាទំហំដីសម្បទានសេដ្ឋកិច្ចបច្ចុប្បន្ននេះឡើយ។ បើនិយាយអំពីសុខុមាលភាពវិញ កាលណាមានមនុស្សច្រើនពឹងផ្អែកលើដីធ្លី ហើយអនុបាតរវាងពលករ និងដីដាំដុះមានស្ថានភាពដូចសព្វថ្ងៃនេះ ការផ្តល់ដីសម្បទានធំៗហួស គឺមិនស័ក្តិសមឡើយ។

*ប្រភព : Bardhan (១៩៧៣); Bhardwaj (១៩៧៤); Barret (១៩៩៣)*

*រូបភាព ៣.៧ : អាត្រាទិន្នផលស្រូវ (ជាតោន/ហិចតា) តាមទំហំដីក្នុងរដូវប្រាំង និងរដូវវស្សា និងរដូវរួមគ្នា ឆ្នាំ ២០០៣-២០០៤*




*ប្រភព : គណនាចេញពី SES -04*

សម្រង់ចេញពីការសិក្សាមួយលើភូមិចំនួន ៩ នៅក្នុងតំបន់ធាតុអាកាសកសិកម្មផ្សេងៗគ្នា ទិន្នន័យលើទំហំកសិដ្ឋាន (រូបភាព ៣.៨ ប្រៀបធៀបទៅនឹងទំហំដី ដូចមានបង្ហាញក្នុងរូបភាព ៣.៧) បង្ហាញលទ្ធផលស្រដៀងគ្នា ដោយមានភាពខុសគ្នាដែលអត្រាទិន្នផលស្រូវប្រាំងមិនទទួលផលប៉ះពាល់ដោយសារទំហំដីដាំដុះទេ[២២]។

បើនិយាយអំពីផលិតភាពវិញ ទិន្នន័យទាំងពីរឈុតនេះសឱ្យឃើញថា ក្នុងស្ថានភាពបច្ចុប្បន្ននេះ គេនិយមកសិដ្ឋាន និងដីតូចៗជាង ព្រោះគេដាំដុះតែក្នុងរដូវវស្សា (៨៥% នៃដីទាំងអស់) ហើយដោយមានការប្រើសម្ភារៈកសិកម្មទំនើបតិចតួច។ កត្តានេះក៏ពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិផងដែរ : ព្រោះកសិករភាគច្រើនមានមធ្យោបាយកសិកម្មតិចតួច ហើយដីដាំដុះ ក៏មានកម្រិតដីដាំដំណាំតូចៗនឹងផ្តល់លទ្ធផលជាប្រាក់ចំណូល ដែលបែកខ្ញែករប៉ាត់រប៉ាយជាច្រើនប្រភេទ។

*បើនិយាយអំពីផលិតភាពវិញ ទិន្នន័យទាំងពីរឈុតនេះសឱ្យឃើញថា ក្នុងស្ថានភាពបច្ចុប្បន្ននេះ គេនិយមកសិដ្ឋាន និងដីតូចៗជាង*

*រូបភាព ៣.៨ : ទំហំកសិដ្ឋាន និងអាត្រាទិន្នផល (តោន/ហិចតា) លទ្ធផលសិក្សាពីភូមិ ៩*




*ប្រភព : Chan និង Acharya (២០០២)*

(២២) ធនាគារពិភពលោក (២០០៦) និង Anders និង Kokko (២០០៦) ប៉ាន់ប្រមាណទំនាក់ទំនងស្ថិតិរវាងតម្លៃផលដំណាំ និងទំហំកសិដ្ឋានក្នុងក្របខ័ណ្ឌពហុអថេរ ដើម្បីរកទំនាក់ទំនងផ្ទុយ។ ACI (២០០៥) បានវិភាគទំនាក់ទំនងរវាងទំហំដី និងផលិតភាព (តម្លៃបន្ថែមជាដុល្លារ) ដោយប្រើទិន្នន័យតាមទំហំដី ហើយបានរកឃើញថា ដីទំហំពី ៣ ទៅ ១០ ហិចតាអាចផ្តល់ផលខ្ពស់ជាងគេបំផុតនៅក្នុងប្រទេស។

ចំពោះដំណាំស្រូវវដូវវស្សា ដែលដាំតាមបែបប្រពៃណីវិញ មានលទ្ធផលផ្ទុយគ្នារវាងទំហំដី និងផលិតភាពកសិកម្ម ប៉ុន្តែចំពោះស្រូវរដូវប្រាំងវិញមិនដូច្នោះទេ បើប្រើវិធីដាំដុះទំនើប។ លទ្ធផលផ្ទុយគ្នានេះបញ្ជាក់ថា កសិដ្ឋានតូចៗទទួលបានការនិយមច្រើនជាង ប៉ុន្តែចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់ថាកសិដ្ឋានប៉ុណ្ណាដែលហៅថា តូច។ ចំណុចនេះទាមទារឱ្យពិនិត្យពិច័យ គឺមិនគ្រាន់តែលើផលិតភាពប៉ុណ្ណោះទេ ត្រូវពិនិត្យលើប្រាក់ចំណូលទូទៅពីដីផងដែរ។ ប៉ុន្តែនិយាយពីជីវភាពរស់នៅវិញ អ្វីដែលសំខាន់សម្រាប់កសិករគឺប្រាក់ចំណូលរបស់គ្រួសារ។រូបភាព ៣.៩ បង្ហាញថា នៅកម្ពុជាប្រាក់រកបានពីដំណាំស្រូវ (សម្រាប់គ្រួសារនីមួយៗ) មានចំនួនច្រើននៅក្នុងកសិដ្ឋានដែលធំទាំងរដូវប្រាំង ទាំងរដូវវស្សា ដែលមានប្រាក់ចំណូលពីស្រូវប្រាំងខ្ពស់ជាងស្រូវវស្សា។ ការសិក្សាតាមមូលដ្ឋានរកឃើញថា ដីកសិកម្មតូចជាង០.៦ហិចតាមិនអាចផ្តល់ប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការចាំបាច់ប្រចាំគ្រួសារទេ[២៣]។ ដើម្បីរក្សាជីវភាពរស់នៅក្នុងកម្រិតអប្បបរមាសមស្របពីដីធ្លី គ្រួសារកសិករត្រូវមានដីដោយមិនចាំបាច់គិតដល់ទំហំ ឬផលិតភាពកសិកម្ម ដូចដែលបានលើកឡើងក្នុងការជជែកពិភាក្សាឡើយ។

*រូបភាព ៣.៩ : ទំហំកសិដ្ឋាន និងផលកម្រៃ (ជាពាន់រៀល/គ្រួសារ) លទ្ធផលសិក្សាពីភូមិ ៩*




*ប្រភព :* Chan និង Acharya (២០០២)

កសិដ្ឋានតូចៗ មិនអាចមានធនធានគ្រប់គ្រាន់ ដើម្បីលើកកម្ពស់ផលិតភាពឡើយ ពោលគឺតាមរយៈធារាសាស្ត្រ។ ជាញឹកញយ ម្ចាស់កសិដ្ឋានតូចៗតែងតែងាយទទួលរងគ្រោះ ដោយសារវិបត្តិទីផ្សារ ឬគ្រោះមហន្តរាយនានា ដូចជា ទឹកជំនន់ ឬរាំងស្ងួត ជាដើម[២៤]។ ដោយសារបញ្ហាអស់ទាំងនេះ កសិករជួល ឬលក់ដីស្រែរបស់ខ្លួន ហើយទៅរកធ្វើកម្មករនៅខាងក្រៅ ឬធ្វើចំណាកស្រុកចេញពីភូមិកំណើតខ្លួនទៅកាប់ព្រៃឈើ ឬទៅនេសាទ[២៥]។ ដូច្នេះ ដើម្បីកសាងមូលដ្ឋានសម្រាប់រក្សាស្ថិរភាពនៃការរស់នៅរបស់គ្រួសារកសិករតូចតាច និងដើម្បីបង្កើនផលិតភាពកសិកម្ម ត្រូវមានគោលនយោបាយ ដើម្បីទប់ស្កាត់ការបំបែកដីឱ្យទៅជាកសិដ្ឋានតូចៗ និងផ្តល់នូវយន្តការសម្រាប់ប្រមូលផ្តុំដីឱ្យកើតជាកសិដ្ឋានធំៗ។

ប្រទេសដទៃទៀតជាច្រើនមានគោលនយោបាយសកម្មក្នុងការប្រមូលផ្តុំដីធ្លី ដែលនៅរាយប៉ាយដែលគ្មានប្រយោជន៍សេដ្ឋកិច្ច និងដែលបែកជាដុំតូចៗ (ប្រអប់ ៣.៤)។ បទពិសោធន៍ទាំងនេះ ជាពិសោធន៍ដែលគួរយកមកពិចារណាសម្រាប់អនុវត្តនៅកម្ពុជាឱ្យបានសមស្រប[២៦]។

---

*(២៣) EIC (២០០៦), ទំព័រ ៨*

*(២៤) ការពឹងផ្អែកលើប្រាក់សន្សំ គឺជាជម្រើសល្អបំផុតក្នុងការទប់ទល់នឹងការបាត់បង់ដោយសារទឹកជំនន់ និងរាំងស្ងួត។ ប៉ុន្តែកសិករតូចតាចអាចក្រីក្រជាងអ្នកដែលគ្មានដីដែលសម្គាល់ថា គេគ្មានប្រាក់សន្សំទេ (CDRI ២០០៦, Auffret ២០០៣)។*

*(២៥) ស្តីអំពីការជួលដីតូចៗ, សូមមើល Kim, Chan និង Acharya (២០០២។ ACI (២០០៥) រកឃើញថា លទ្ធផលនៃផលិតភាពតាមទំហំកសិដ្ឋានស្រដៀងគ្នាទៅនឹងលទ្ធផលនៅក្នុងរូបភាព ៣.៨ និង ៣.៩, ដោយប្រើទិន្នន័យឆ្នាំ ២០០៥ អំពីតំបន់ធាតុអាកាសកសិកម្មនៅកម្ពុជា។*

*(២៦) នៅកូរ៉េខាងត្បូង ដីកសិកម្មត្រូវបានប្រមូលផ្តុំ ហើយចែកឱ្យវិញនៅទសវត្សរ៍ឆ្នាំ ១៩៦០ និងឆ្នាំ ១៩៧០ ដើម្បីឱ្យមនុស្សប្រើប្រាស់ដីឱ្យបានអស់លទ្ធភាព។ គោលនយោបាយដីនៅតណ្ហាអនុញ្ញាតឱ្យប្រមូលផ្តុំដីតូចៗដាច់ពីគ្នា ដែលមិនមានប្រយោជន៍សេដ្ឋកិច្ច។*

### ប្រអប់ ៣.៤ : ការប្រមូលផ្តុំដីធ្លី និងការរៀបចំដីសារឡើងវិញ - បទពិសោធអន្តរជាតិ

ការប្រមូលផ្តុំដីធ្លីដែលធ្វើឡើង ដើម្បីតម្រូវទៅនឹងការវិនិយោគធំៗ (ឧទាហរណ៍ធារាសាស្ត្រ) និងផលិតភាពក៏ដូចជាធ្វើឱ្យជីវភាពរស់នៅរបស់កសិករល្អប្រសើរឡើង ត្រូវបានគេទទួលស្គាល់ជាង ១៥០ ឆ្នាំ កន្លងមកហើយ ។ គោលនយោបាយផ្លូវការទី១ ធ្វើឡើងនៅឆ្នាំ ១៨៤៧ ដោយរដ្ឋបាលអាណានិគមអង់គ្លេស នៅខេត្តបុំបៃ ប្រទេសឥណ្ឌា ឆ្លងតាមទសវត្សរ៍ឆ្នាំ ១៩៥០ និងទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសបែលហ្ស៊ិក ឈីលី អេហ្ស៊ីប ឥណ្ឌា អ៊ីរ៉ាក់ ជប៉ុន លីបង់ ម៉ិចស៊ិចកូ និងប្រទេសស៊ីរី ក្នុងចំណោមប្រទេសដទៃៗទៀតជាច្រើន បានអនុម័តជាផ្លូវការនូវច្បាប់ប្រមូលផ្តុំដីធ្លីនេះ ។

*ប្រទេសនីមួយៗមានប្រវត្តិខុសៗគ្នាក្នុងវិស័យដីធ្លី និងកសិបរិស្ថានវិទ្យា ។ ដូច្នេះទំហំដីកសិកម្មអប្បបរមា ដែលផ្តល់ផលសមស្រប វិធីប្រមូលផ្តុំដី និងជោគជ័យនៃគោលនយោបាយទាំងអស់នេះ ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ឧទាហរណ៍ខាងក្រោមនេះ បញ្ជាក់ថា :*

១. វិធីមួយ គឺអាជ្ញាធរស៊ុរិយោដីបដិសេធមិនចុះបញ្ជីឱ្យទេ ប្រសិនបើដីតូចជាងទំហំអប្បបរមាដែលត្រូវអនុញ្ញាតឱ្យ ។ ក្នុងន័យនេះ ប្រសិនបើដីកសិកម្មត្រូវចែកជាដុំតូចៗ ពីរឬច្រើន (ដោយសារការចែកកេរ ឬដោយសារអ្វីផ្សេងទៀត) នោះ ឯកសារច្បាប់នឹងទទួលចុះបញ្ជីតែដីដែលមានទំហំយ៉ាងតិចស្មើនឹងទំហំអប្បបរមា រីឯដីតូចៗទាំងនោះ គឺជាផ្នែកមួយនៃអំពកដីដែលនៅជាប់ៗគ្នា (ប្រទេសឥណ្ឌា) ។

២. ក្នុងករណីខ្លះ ដីតូចៗត្រូវច្របាច់បញ្ចូលជាមួយដីរដ្ឋដែលនៅទំនេរ ហើយយកទៅបែងចែកសារជាថ្មីឱ្យម្ចាស់ដីតូចៗដែលពាក់ព័ន្ធ និងអ្នកដទៃទៀតដែលគ្មានដី (ឥណ្ឌា) ។

៣. ក្នុងករណីអំពកដីកសិករក្លាយទៅជាចម្រៀកតូចៗ ពីព្រោះតែដីដែលទទួលបានមកមិនមែនជាដីកសិកម្ម ឬសម្រាប់គោលបំណងអភិវឌ្ឍន៍ផ្សេងទៀតនោះ កសិករពាក់ព័ន្ធត្រូវទទួលបាននូវការផ្តល់ដីកសិកម្មនៅកន្លែងផ្សេងទៀត ។ ក្នុងករណីគ្មានដីបែងចែកកសិករអាចទទួលបានប្រាក់សំណងជាជំនួស ។ ក្រោយមកគេរកឃើញថា កសិករមិនមានជម្រើសងាយស្រួលទៅប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀតបាន ដូច្នេះក្នុងករណីខ្លះត្រូវបានសម្រេចផ្តល់ការងារឱ្យពួកគេទាំងនេះ (ការងារគ្មានជំនាញ) នៅក្នុងគម្រោងអភិវឌ្ឍន៍ (ពោលគឺជាការងារជាប់កិច្ចសន្យារយៈពេលវែង ជាពិសេស ក្នុងខណៈដែលយកដីគាត់ទៅធ្វើជាផ្លូវរថភ្លើង ផ្លូវថ្នល់ ឬសាងសង់ទីប្រជុំជន) បន្ថែមទៅលើការផ្តល់ជាសាច់ប្រាក់ ។ បើកសិករចាប់យកការងារក្រៅកសិកម្ម កសិករទាំងនោះទទួលបានការបណ្តុះបណ្តាលជំនាញផ្សេងៗ និងការផ្តល់ឥណទាន ដែលមានការប្រាក់ទាប ឬអំណោយងាយស្រួល ដើម្បីផ្តើមបង្កើតរបររកស៊ី (ប្រទេសអាស៊ីខាងត្បូង និងចិន) ។

៤. ជួនកាលការប្រមូលផ្តុំដីធ្លីនេះ គឺក្នុងស្មារតីរៀបចំដីសារឡើងវិញ ដើម្បីបង្កលក្ខណៈឱ្យដីទាំងនោះ ទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ ។ គេប្រមូលយកដីមករៀបចំសារជាថ្មី ហើយបែងចែកឱ្យទៅកសិករវិញ (មិនចាំបាច់មានទំហំស្មើៗគ្នាដូចមុនៗទេ) ដើម្បីឱ្យដីទាំងនោះបានផលប្រយោជន៍ពីទឹក ដែលហូរតាមព្រែកជីក និងពីទឹកដែលហូរលើផ្ទៃដី (សាធារណៈរដ្ឋកូរ៉េ) ។

ក្នុងករណីនីមួយៗ ជោគជ័យអាចកើតឡើងអាស្រ័យទៅលើឆន្ទៈនយោបាយ និងភាពយុត្តិធម៌ក្នុងការចាត់ចែងការងារ ។ ជាឧទាហរណ៍ ការប្រមូលផ្តុំដីនៅរដ្ឋពន់ច្យាបនៃប្រទេសឥណ្ឌា ទទួលបានជោគជ័យច្រើន រីឯនៅរដ្ឋបឹងហ្គាល់ខាងលិចវិញ មិនសូវមានជោគជ័យទេ ។ នៅសាធារណរដ្ឋកូរ៉េ អាត្រាជោគជ័យមានកម្រិតខ្ពស់ ។ កម្ពុជាត្រូវសិក្សាលើករណីនីមួយៗ ដើម្បីជ្រើសយកគោលនយោបាយ និងឧបករណ៍ដែលល្អបំផុតសម្រាប់បរិស្ថាននៅកម្ពុជា ។

*ប្រភព : GOI (១៩៧៦) ទំព័រ ១៨៧-២៣៦ Wade (១៩៨២) ឯកសារធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មី និងការស្តារនីតិសម្បទាឡើងវិញ*

គ្រួសារកសិករតូចៗជាច្រើន រួមទាំងស្ត្រីកសិករផងមានដីតូចជាង ១/៤ ហិចតា ឬតិចជាង ។ ពេលខ្លះពួកគេទាំងនោះ អាចប្រកបរបរនេសាទត្រី កាប់អុសលក់ កាប់ឈើ ឬធ្វើកម្មករ ។ ដើម្បីជួយឱ្យជីវភាពរបស់គេប្រសើរឡើង តើត្រូវមានគោលនយោបាយយ៉ាងណា? កម្មករប្រភេទនេះ មិនអាចភ្ជួររាស់ដីកើតទេ ដោយសារខ្វះដើមទុន ដូចជា គោ/ក្របី និងឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត ហើយការរក្សាជីវភាពរស់នៅក្នុងលក្ខណៈបច្ចុប្បន្ននេះ គឺគ្រាន់តែទុកឱ្យគ្រួសារអស់ទាំងនេះបន្តរស់នៅក្នុងភាពក្រីក្រតែប៉ុណ្ណោះ ។ ប្រទេសខ្លះបានច្នៃប្រឌិតជម្រើសការងារមួយចំនួន រួមទាំងបង្កើតឱ្យមានសត្វពាហនៈសម្រាប់ជួលភ្ជួររាស់ ចែកគ្នាឱ្យប្រើប្រាស់នូវឧបករណ៍ស្រោចស្រព ទិញទឹកសម្រាប់ស្រោចស្រព និងរួមគ្នាទិញជី និងពូជ ដើម្បីកាត់បន្ថយចំណាយ ។ ប្រទេសកម្ពុជាអាចជ្រើសយកការផ្តួចផ្តើមគំនិត និងគោលនយោបាយផងទាំងឡាយណា ដែលជួយឱ្យសហគមន៍អនុវត្តបាន សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ចដល់សហគមន៍ទាំងមូល ដែលជាធម្មតាម្ចាស់កសិដ្ឋានមួយរូបៗមិនអាចសម្រេចបាន ហើយអាចយកគោលនយោបាយ និងការផ្តួចផ្តើមគំនិតនេះទៅធ្វើការល្បងពិសោធន៍ ដើម្បីរកគោលនយោបាយណា ដែលសមស្របសម្រាប់បរិបទនៃកម្ពុជា ។

ផលដំណាំមួយចំនួន ដូចជា ដំណាំសម្រាប់ពាណិជ្ជកម្មជាដើម អាចផ្តល់លទ្ធផលជាសេដ្ឋកិច្ចធំដុំ ប្រសិនបើដាំជាទ្រង់ទ្រាយធំ បើមិនរាប់ពាន់ទេ ក៏រាប់រយហិចតាដែរ។ កម្ពុជាស្ថិតនៅក្នុងតំបន់កសិបរិស្ថានវិទ្យាមួយសមស្រប សម្រាប់ផលិតផលកសិកម្មពាណិជ្ជកម្មជាមួយនឹងទីផ្សារពិភពលោក ដែលមានការអភិវឌ្ឍ។ ដូចបានឃើញរួចមកហើយ (រូបភាព ៣.៤) ច្បាប់ដែលដាក់កម្រិតលើដីសម្បទានសេដ្ឋកិច្ចមិនត្រូវបានគេគោរពតាមរាល់ករណីទាំងអស់។ ដូច្នេះគោលនយោបាយណាក៏ដោយ ដែលធ្វើឡើងសម្រាប់ដំណាំពាណិជ្ជកម្មត្រូវមានគោលការណ៍ណែនាំ ច្បាស់លាស់ស្តីពីកម្រិតទំហំខ្ពស់បំផុត សម្រាប់ដីសម្បទានសេដ្ឋកិច្ច និងតម្លាភាពនៅក្នុងការផ្តល់ដីសម្បទានទាំងនេះ សម្រាប់ទប់ស្កាត់កុំឱ្យយកដីទៅធ្វើផ្តេសផ្តាសក្រោមការអះអាងថា ជាដីសម្រាប់ជាផលប្រយោជន៍សេដ្ឋកិច្ចរួមគ្នា។

### ប្រអប់ ៣.៥ : ក្រុមសាមគ្គីកសិករតូចៗ - ប្រទេសស្រីលង្កា

កសិដ្ឋាននីមួយៗក្នុងគម្រោងរៀបចំរចនាសម្ព័ន្ធឡើងវិញ និងស្តារនីតិសម្បទានៅមហាវេលីរបស់ប្រទេសស្រីលង្កា មានទំហំមធ្យមប្រហែល ១ ហិចតា។ សមាគមអ្នកប្រើទឹក (WUA) ត្រូវបានការរៀបចំឡើង ដែលផ្តើមគិតថា តើត្រូវដាំអ្វី ហើយដាំនៅពេលណា។ ដោយសារគំនិតផ្តួចផ្តើមរបស់ពួកគេ គេសន្សំទឹកបានច្រើន និងផលិតភាពក៏កើន។ បន្ទាប់មកទៀត សមាគមអ្នកប្រើទឹក (WUA) បានរៀបចំការទិញដុំសម្រាប់ទិញជី គ្រាប់ពូជដែលមានទិន្នផលខ្ពស់ ព្រមទាំងទិញឧបករណ៍ឯទៀតៗក្នុងតម្លៃថោក។ ឧស្សាហកម្មផ្នែកកសិកម្មសណ្តែកសៀង ម្ទេស សាច់មាន់ និងបន្លែស្រស់យល់ថាគេអាចជម្រុញកសិករឱ្យដាំសណ្តែកសៀងតាមកិច្ចសន្យា។ ឧស្សាហកម្មក៏ផ្តល់ពូជសណ្តែកសៀង ដែលមានទិន្នផលខ្ពស់ ហើយធានាទិញយកផលដែលផលិតបាន។ ការរៀបចំនេះផ្តើមដំបូងជាមួយកសិករតែ ៧០ នាក់ទេ ប៉ុន្តែក្រោយមកបានកើនឡើងយ៉ាងលឿនដល់រាប់ពាន់នាក់។

*ប្រភព : ធនាគារពិភពលោក (ឆ្នាំ ២០០៥ ក)*

### *សារៈសំខាន់ៗ :*

*១. តម្រូវការចាំបាច់បន្ទាន់នូវគោលនយោបាយសកម្មមួយ ដើម្បីត្រួតពិនិត្យដីធ្លីតូចៗដាច់ពីគ្នាដ៏ច្រើនសន្ធឹកសន្ធាប់ និងភាពគ្មានដីធ្លីដែលបណ្តាលមកពីកំណើនប្រជាពលរដ្ឋដ៏ឆាប់រហ័ស តម្លៃរក្សាសុខភាពថ្លៃពេក អភិបាលកិច្ចទន់ខ្សោយ ការខ្វះលក្ខណៈសេដ្ឋកិច្ចនៅក្នុងកសិកម្មតូចតាច និងទីផ្សារទិញលក់ដី ដែលមិនមានការគ្រប់គ្រង។ គួរតែអភិវឌ្ឍ និងលើកទឹកចិត្តដល់ការផ្តួចផ្តើមរបស់សហគមន៍ក្នុងការដាំដំណាំរួមគ្នាលើដីតូចៗដែលដាច់ៗពីគ្នាជាច្រើន។*

*២. ការកែទម្រង់ដីត្រូវយកចិត្តទុកដាក់លើទំហំដីកសិកម្មធំល្មម ដើម្បីលើកកម្ពស់ទាំងផលិតភាពសម្រាប់ដីមួយដុំៗ ទាំងប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់គ្រួសារកសិករ។*

*៣. ដោយសារថាស្ត្រីជាអ្នករួមចំណែកចម្បងក្នុងផលិតកម្មកសិកម្ម ការរួមចំណែករបស់ពួកគេមានសារៈសំខាន់ណាស់ នៅក្នុងគោលនយោបាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ព្រមទាំងគម្រោងកែទម្រង់ដីធ្លី ការអនុវត្តក្នុងវិស័យកសិកម្ម ការធ្វើឱ្យប្រសើរឡើងដល់ជីវភាពរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធ។*

*៤. ការយកពន្ធដារលើដី ឬ/និងការដកយកមកវិញនូវដីសម្បទានដែលមិនប្រើប្រាស់ គឺជាមូលហេតុប្រកបដោយសមធម៌ និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្លាំងក្លា។*

## ៣.២ ដីរបស់ជនជាតិដើមភាគតិច[២៧]

សិទ្ធិរបស់ជនជាតិដើម ត្រូវបានទទួលស្គាល់ថាជាចំណុចស្នូល ដើម្បីសម្រេចបាននូវសិទ្ធិមនុស្សជាសាកល និងសិទ្ធិស្វ័យសម្រេចរបស់មនុស្សទាំងអស់គ្នា។ ជនជាតិដើមភាគតិចមានចំនួនប្រហែល ០,៩% នៃប្រជាពលរដ្ឋកម្ពុជា ដែលចែកជា ១៧ ក្រុម រស់នៅក្នុងខេត្តក្រចេះ មណ្ឌលគីរី រតនគីរី ស្ទឹងត្រែង កំពង់ធំ កោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងក្រុងព្រះសីហនុ យោងតាមការស្រង់ចំនួនប្រជាពលរដ្ឋឆ្នាំ ១៩៩៨។ ច្បាប់ភូមិបាលឆ្នាំ ២០០១ ទទួលស្គាល់សិទ្ធិកាន់កាប់ដីរួមគ្នារបស់ជនជាតិដើមភាគតិច ហើយយុទ្ធសាស្ត្របណ្តោះអាសន្ននៃក្របខណ្ឌគោលនយោបាយដីធ្លី ឆ្នាំ២០០២ ចែងថាជនជាតិដើមភាគតិច ត្រូវទទួលបាននូវសិទ្ធិជាម្ចាស់រួមគ្នាលើដីរបស់ពួកគេ។ ក្របខ័ណ្ឌនេះក៏ទទួលស្គាល់ផងដែរ នូវការអនុវត្តកសិកម្មពនេចរថាជាប្រព័ន្ធគ្រប់គ្រងដីធ្លីតាមប្រពៃណីរបស់ជនជាតិដើមភាគតិច។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅមិនទាន់បានចេញប្លង់ដីរួមនេះមួយប្លង់នៅឡើយទេ។

---

*(២៧) ផ្នែកនេះ (រួមទាំងប្រអប់ ៣.៦ផង) យោងលើមូលដ្ឋាននៃការទាក់ទងជាមួយវេទិកាសង្គមស៊ីវិលកម្ពុជា ប្រចាំនៅភ្នំពេញ និងឯកសារទទួលបានពីពួកគេ។*

កង្វះការអនុវត្តច្បាប់ បានទុកឱ្យជនជាតិដើមភាគតិចងាយរងគ្រោះដោយសារផលប្រយោជន៍ពីខាងក្រៅ ដែលកាន់តែកើនឡើងចូលមកយកផលពីសក្តានុពលសេដ្ឋកិច្ចរបស់ព្រៃឈើ ហើយនិងដីមានជីជាតិតាមតំបន់ភ្នំ។ ដីសម្បទានធំៗគ្របដណ្តប់លើតំបន់ដែលជនជាតិដើមភាគតិចទាំងអស់ ធ្លាប់រស់នៅជាប្រពៃណី។ ជាញឹកញាយ ពួកគេទទួលផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការកាប់រំលំព្រៃឈើ ថ្វីត្បិតតែមានការបញ្ឈប់សកម្មភាពមួយរយៈក៏ដោយ ក៏ការកាប់ឈើនៅតែបន្តដោយពុំមានប្រសិទ្ធភាពនៃការត្រួតពិនិត្យឡើយ។ កត្តានេះបណ្តាលឱ្យមានការបំពារបំពានលើដីធ្លីរបស់អ្នកស្រុកផ្ទុយនឹងច្បាប់ដីធ្លី ដែលជាលទ្ធផលនាំទៅរកការបំផ្លិចបំផ្លាញទាំងស្រទាប់សង្គម និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច។ បញ្ហានេះបានរីកធំឡើងដល់តំណាក់កាលមួយ ដែលនាំឱ្យសហគមន៍ខ្លះរលាយសាបសូន្យ។

ច្បាប់ព្រៃឈើឆ្នាំ ២០០២ មានបញ្ញត្តិមួយចែងពីការទទួលស្គាល់ជាផ្លូវការដល់ព្រៃសហគមន៍។ នីតិវិធីច្បាប់ និងគោលការណ៍ណែនាំសម្រាប់បញ្ញត្តិនេះបានធ្វើចប់សព្វគ្រប់ហើយ។ នីតិវិធីទាំងនេះផ្តល់ជូនសហគមន៍ជនជាតិដើម និងសហគមន៍មិនមែនជនជាតិដើមនូវឱកាសឱ្យពួកគេមានសិទ្ធិប្រើប្រាស់ និងគ្រប់គ្រងព្រៃឈើ (ក្រោមកិច្ចព្រមព្រៀង ១៥ ឆ្នាំម្តងៗ)។ យោងតាមបញ្ញត្តិច្បាប់នេះ ព្រៃឈើខ្លះត្រូវបានរាប់បញ្ចូលទៅក្នុងអចលនសម្បត្តិ រួមគ្នាសម្រាប់ជនជាតិដើមភាគតិច។ ពាក់ព័ន្ធទៅនឹងបញ្ហាសិទ្ធិប្រើប្រាស់ដីធ្លីរបស់ជនជាតិដើមភាគតិចមានការរីកចម្រើនខ្លះដែរ ប៉ុន្តែក្នុងការអនុវត្តច្បាប់នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ។

### ប្រអប់ ៣.៦ : សម្លេងរបស់ជនជាតិដើម



*សម្លេងអ្នកទី១*

ជីវភាពរស់នៅរបស់ជនជាតិដើមពឹងផ្អែកលើផលព្រៃឈើ។ ការរស់នៅរបស់យើងបែបនេះមិនមានផលប៉ះពាល់ទៅលើព្រៃឈើទេ ព្រោះយើងយល់ថាដី និងព្រៃឈើដែលដូនតាយើងបន្សល់ទុកឱ្យ គឺជាជីវិតរបស់យើង។ យើងនិយាយភាសាផ្សេងគ្នា អាស្រ័យទៅតាមជនជាតិនីមួយៗ។ យើងជនជាតិដើមប្តេជ្ញានឹងរក្សាចំណេះដឹងទាំងអស់នេះតទៅទៀត។

យើងធ្វើសំណូមពរទៅរាជរដ្ឋាភិបាល សូមឱ្យធានាដល់សន្តិសុខដីធ្លី ការពារព្រៃឈើ និងធនធានធម្មជាតិ។ សូមឱ្យផ្តល់សេវាសង្គមកិច្ចខ្លះ ដូចជា សុខាភិបាល ភាសា ការអប់រំ ហើយសូមលើកស្ទួយឱ្យបានទូលំទូលាយថែមទៀត នូវសិទ្ធិរបស់ជនជាតិដើមភាគតិចនៅកម្ពុជា។

*សម្លេងអ្នកទី ២*

ជនជាតិភាគតិចជួបប្រទះនឹងបញ្ហាបាត់បង់ដីធ្លី ដោយសារការកាប់ឈើខុសច្បាប់ ការទិញនិងលក់ដី និងការចាប់យកដីធ្វើជាកម្មសិទ្ធឯកជន។ យើងប្រឈមមុខនឹងការបាត់បង់វប្បធម៌ និងប្រពៃណី ដោយសារការទន្រ្ទានចូលនៃវប្បធម៌ពីខាងក្រៅ ហើយជនជាតិដើមភាគតិចបានត្រូវគេផាត់ចេញពីសង្គម។ យើងខ្ញុំទាំងអស់គ្នា ដែលជាប្រជាពលរដ្ឋជនជាតិដើមនៅភូមិភាគឦសាន សូមធ្វើសំណូមពរឱ្យបង្កើនល្បឿនចុះបញ្ជីដីធ្លីរបស់ជនជាតិដើម អនុវត្តច្បាប់ដែលពាក់ព័ន្ធទៅនឹងជនជាតិដើម ដូចមានចែងនៅក្នុងច្បាប់ដីធ្លីពីមាត្រា ២៣-២៨ ហើយសូមជួយធ្វើឱ្យប្រសើរឡើងដល់មាត្រា ២៦៥ និងលើកស្ទួយ និងពង្រឹងដល់វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើម។

*សម្លេងអ្នកទី៣*

យើងសូមឱ្យមានការទទួលស្គាល់ដល់សិទ្ធិរបស់ជនជាតិដើមក្នុងការកាន់កាប់ និងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិតាមរបៀបរបបនៃប្រពៃណីយើង។ រដ្ឋគួរតែទទួលស្គាល់ និងការពារសិទ្ធិស្របច្បាប់ និងការកាន់កាប់ និងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ។ អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ ILO លេខ ១៦៩ ស្នើសុំឱ្យរដ្ឋាភិបាលនានាគោរពសញ្ញាណរបស់ជនជាតិដើម ក្នុងការកាន់កាប់ដីធ្លីតាមប្រពៃណីរបស់ពួកយើងខ្ញុំ ដើម្បីធានាឱ្យការកាន់កាប់ដីធ្លីនេះមានប្រសិទ្ធភាព។ យើងទន្ទឹងរង់ចាំការចុះបញ្ជីដីធ្លីនៅតាមឃុំសង្កាត់ និងការការពារដីរបស់យើងខ្ញុំ ដែលជាប្រជាពលរដ្ឋជនជាតិដើម។

*ប្រភព : វេទិកាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា*

## សារគន្លឹះ :

*ចាំបាច់ត្រូវតែប្រគល់ទៅឱ្យជនជាតិដើមភាគតិចនូវសិទ្ធិប្រើប្រាស់ និងកាន់កាប់ដីធ្លីរបស់ពួកគេជាបន្ទាន់។ ច្បាប់ដែលធានាសិទ្ធិប្រើប្រាស់ដីធ្លី និងព្រៃឈើរបស់ពួកគេត្រូវតែអនុវត្តឱ្យបានប្រាកដប្រជា។*

*កម្ពុជានៅមានដីសេសសល់នៅឡើយ ដូច្នេះការចែកចាយដីធ្លីនេះ អាចជួយបន្ធូរបន្ថយជីវភាពរស់នៅរបស់អ្នកក្រីក្រ ដែលគ្មានដី ឬស្ទើរតែគ្មានដីធ្លី*

## ៣.៣ ដីសម្បទានសង្គមកិច្ច[២៨]

រដ្ឋាភិបាលបានចេញបញ្ញត្តិមួយ ស្តីអំពីដីសម្បទានសង្គមកិច្ចនៅក្នុងច្បាប់ដីធ្លី ឆ្នាំ ២០០១ ដើម្បីបន្ធូរបន្ថយភាពក្រីក្រ និងភាពឥតដីធ្លីនៅតាមជនបទ ។ ទិសដៅ គឺដើម្បីផ្តល់ដីធ្លីជូនអ្នកក្រីក្រ និងជនចំណាកស្រុក និងអ្នកដទៃទៀត ដែលទទួលផលប៉ះពាល់ ដើម្បីឱ្យពួកគេបានស្តារកាយសម្បទា និងតាំងទីលំនៅថ្មី ។ ដីដែលចែកឱ្យទៅអតីតទាហាន ដើម្បីសម្រួលការរំសាយកងទ័ព និងជួយកសាងមូលដ្ឋាននៃជីវភាពរស់នៅរបស់ពួកគេ ។ ដូច្នេះការចែកដីធ្លីអាចលើកស្ទួយសន្តិភាព ។

បើមើលទៅលើការប្រើប្រាស់ដីធ្លី និងអនុបាតរវាងដីធ្លីប្រជាជន កម្ពុជានៅមានដីសេសសល់នៅឡើយ ហើយការបែងចែកដីធ្លីអាចជួយបន្ធូរបន្ថយបញ្ហាជីវភាពរស់នៅរបស់អ្នកក្រីក្រ ដែលគ្មានដីធ្លីជាពិសេសគឺស្ត្រីកសិករដែលមានដី និងធនធានឯទៀតៗតិចតួច ។ ច្បាប់ចែងថា :

ក. កម្មវិធីដីសម្បទានសង្គមកិច្ចថ្នាក់មូលដ្ឋាន (ការរកដីធ្លីដើម្បីចែកចាយនៅតាមមូលដ្ឋាន គឺជាភារកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន) ។

ខ. កម្មវិធីដីសម្បទានសង្គមកិច្ចថ្នាក់ជាតិ (គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ជាតិក្នុងការរក និងចែកដីនៅក្នុងប្រទេស ។

បច្ចុប្បន្ននេះការដែលត្រូវខិតខំពុះពារជាចម្បង គឺត្រូវរកដីទំនេរ ដែលមាននៅក្នុងឃុំ និងបន្ទាប់មកនៅកន្លែងដទៃទៀត ។ នៅខែតុលា ឆ្នាំ ២០០៦ *ដីចំនួន ២៣០៣ ហិចតា បានចែកឱ្យទៅគ្រួសារចំនួន ១៧០៨៦ គ្រួសារ ដោយអនុលោមតាមបញ្ញត្តិដីសម្បទានសង្គមកិច្ចនេះ* នៅក្នុងខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងបាត់ដំបង ។ ដីទាំងនេះត្រូវបានផ្តល់ជាចម្បងជូនទៅទាហានរំសាយដើម្បីធ្វើភូមិដ្ឋាន[២៩] ។

បញ្ហាសំខាន់ ៦ សម្រាប់កម្ពុជា ក៏ដូចជាប្រទេសឯទៀតដែរ ។ ចំណុចទាំងនោះ គឺ :

១. ការរកដីសម្រាប់ចែកជូនគ្រួសារក្រីក្រ គឺជាការមួយដ៏លំបាកនៅក្នុងតំបន់ណាដែលមានពលរដ្ឋច្រើន ។ សូម្បីតែរកឃើញថាមានដីទំនេរក៏ដោយ ជួនកាលមានការតវ៉ាអំពីស្ថាប័នរដ្ឋផ្សេងៗ ឬអង្គភាពឯកជន ។ នៅកន្លែងខ្លះទៀត ដីដែលនៅទំនេរត្រូវបានគេប្រើប្រាស់ជាវាលស្មៅសម្រាប់គោក្របី ។

២. ដីទំនេរ - តាមធម្មតាជាដីខូចគុណភាពក្រោយពីកាប់ឈើធំៗអស់ - ជាញឹកញយ តែងតែនៅទីកន្លែងដែលអ្នកគ្មានដីរស់នៅ ឬក្បែរកន្លែងដែលតាំងទីលំនៅថ្មី ។

៣. គុណភាពដីសេសសល់ក្រោយពីកាប់ព្រៃអស់ទៅ តែងតែជាដីដែលមានជាតិអាស៊ីដខ្ពស់ ហើយដោយមានជាតិសរីរាង្គតិចតួច ដីនេះ ក្លាយទៅជាដីដែលដាំដំណាំមិនបានផល ។

៤. នៅថ្នាក់ជាតិ ដីសេសសល់ភាគច្រើនមាននៅភូមិភាគឦសាន ពាយ័ព្យ និងតំបន់ឆ្នេរសមុទ្រ ។ ការដែលមិនដឹងប្រាកដនោះ គឺតើគ្រួសារដែលគ្មានដីធ្លីសុខចិត្តលះបង់អ្វីៗនៅក្នុងភូមិកំណើតរបស់ខ្លួន ឬទេ ដើម្បីទៅតាំងទីលំនៅថ្មីនៅទីឆ្ងាយៗ ដើម្បីទទួលយកដីដែលមិនដឹងថាមានគុណភាពល្អ ឬមិនល្អនោះ ។

៥. បច្ចុប្បន្ននេះ នៅមិនទាន់ដឹងច្បាស់ពីថាមវន្តនៃទីផ្សារដីធ្លីនៅកន្លែងថ្មីៗទេ ប៉ុន្តែមិនមានហេតុផលណាសម្រាប់មានជំនឿថាពិតជាមិនខុសពីអ្វីៗ ដែលបានឃើញនៅតំបន់ឯទៀតៗក្នុងប្រទេសឡើយ ។ ខេត្តរតនគីរី ក៏មានការទិញលក់ដីធ្លីមួយចំនួនដែរ ថ្វីត្បិតតែជាខេត្តមួយក្នុងចំណោមខេត្ត ដែលមានពាណិជ្ជកម្មតិចជាងគេបំផុតក៏ដោយ ។

៦. ការអភិវឌ្ឍលើដីថ្មីត្រូវចំណាយច្រើន ជាពិសេស ប្រសិនបើដីទាំងនោះនៅឆ្ងាយពីរចនាសម្ព័ន្ធដែលមានស្រាប់ ។ ដើម្បីឱ្យមនុស្សអាចចេញចូល និងរស់នៅក្នុងតំបន់ថ្មីទាំងនេះប្រកបដោយចីរភាពបាន ត្រូវសាងសង់ផ្លូវភ្ជាប់ទៅតំបន់ទាំងនេះ សាងសង់សាលា និងប្រព័ន្ធសុខាភិបាល ហើយនិងសេវាឯទៀតៗដែលចាំបាច់ ។

*(២៨) សូមមើល Dinravy និង Groetschel (២០០៤) និង Halabi (២០០៥) ចំពោះបញ្ហាទាក់ទិននឹងសម្បទានសង្គមកិច្ច ។ ចំពោះអនុក្រឹត្យសូមមើល http://www.gocombodia.com/laws/pdf/ANK-១៩-០៣-social%20concessions-E.pdf*

*(២៩) តួលេខនេះ ហាក់ដូចជាមិនរួមបញ្ចូលទាំងផ្នែកមួយនៃកម្មវិធីសម្បទានសង្គមកិច្ចដែលឧបត្ថម្ភដោយធនាគារពិភពលោកទេ ។ នៅក្នុងនោះមានពីរបីរយគ្រួសារទៀត ។*

ការវិភាគទិន្នន័យរបស់អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ២០០៤ (SES-0៤) បានរកឃើញថា សូម្បីតែកសិករទាំងអស់មានដីរហូតទៅដល់ ៥ ហិចតា ម្នាក់ក៏ដោយ ក៏ប្រាក់ចំណូលរបស់ពួកគេមិនឡើងខ្ពស់ជាងបន្ទាត់នៃភាពក្រីក្រឡើយ។ តាមពិត ការកាត់បន្ថយភាពក្រីក្រដែលមានប្រសិទ្ធភាព ទាមទារឱ្យមានវិនិយោគគ្រប់គ្រាន់ក្នុងការបំពាក់អគ្គិសនីតាមទីជនបទ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចនៅទីនោះ[៣០]។ ជាក់ស្តែង ប្រសិនបើមិនមានការកែទម្រង់បន្ថែមដូចបានលើកឡើងខាងលើនេះទេ ដីធ្លីដែលចែកឱ្យតាមកម្មវិធីសម្បទានសង្គមកិច្ចនេះ នឹងត្រូវលក់ដូរតទៅទៀត ហើយកសិករទាំងនោះនឹងក្លាយទៅជាអ្នកអត់ដីវិញដដែល ដូច្នេះត្រូវតែមានគោលនយោបាយចែកដី រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ ជាជាងគ្រាន់តែចែកដីទទេប៉ុណ្ណោះ។ គោលនយោបាយនេះសម្រាប់អនុវត្តការចែកដីសង្គមកិច្ចគួបផ្សំគ្នាជាមួយនឹងផែនការរៀបចំលំនៅដ្ឋានថ្មី និងការស្តារនីតិសម្បទាឱ្យបានច្រើនជាងអ្វីៗដែលមានសព្វថ្ងៃ។

*__សារៈសំខាន់ :__*

*ដំណើរការរកដីធ្លី និងរៀបចំទីលំនៅថ្មីសម្រាប់អ្នកក្រីក្រ ចាំបាច់ត្រូវតែបង្កើនល្បឿន ពង្រីកឱ្យទូលំទូលាយ ហើយតាមដានឱ្យបានល្អ ដោយប្រើគោលនយោបាយស្តារនីតិសម្បទាយ៉ាងទូលំទូលាយ និងការតាំងទីលំនៅថ្មី រួមទាំងការវិនិយោគក្នុងវិស័យសុខាភិបាល អប់រំ និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច។*

## ៣.៤ អភិបាលកិច្ច និងវិវាទដីធ្លី[៣១]

រហូតមកដល់ ខែ ធ្នូ ឆ្នាំ ២០០៦ ប្លង់ដី ឬវិញ្ញាបនប័ត្រសម្គាល់សិទ្ធិកាន់កាប់ ទើបនឹងបានចេញមិនលើសពី ២០% ទេ។ ប៉ុន្តែរដ្ឋាភិបាលគ្រោងនឹងចេញប្លង់ដីឱ្យបានមួយលានប្លង់នៅដំណាច់ឆ្នាំ ២០០៧ តាមលក្ខណៈជាប្រព័ន្ធ (គឺជាការផ្តួចផ្តើមរបស់រដ្ឋាភិបាល។ ក្នុងខែ ធ្នូ ឆ្នាំ ២០០៦ ប្លង់ដីដែលចេញតាមប្រព័ន្ធមានចំនួន ០,៥៧ លានប្លង់ ហើយចេញតាមលក្ខណៈដាច់ដោយដុំមានចំនួន ០,៥៨ លានប្លង់ (គឺតាមការស្នើសុំរបស់ឯកជន) តួលេខនេះ នៅតូចណាស់បើប្រៀបធៀបទៅនឹងចំនួនពាក្យសុំពី ៦ ទៅ ៧ លានពាក្យ[៣២]។ អ្នកក្រីក្រ ១/៥ នៃប្រជាពលរដ្ឋបានទទួលប្លង់ដីតែពាក់កណ្តាលនៃចំនួនប្លង់ដីដែលចេញឱ្យក្រុមអ្នកមាន ដែលតំណាងឱ្យតែ ១/៥ នៃប្រជាពលរដ្ឋ។ អ្នកមានទទួលប្លង់ដី ដែលចេញតាមលក្ខណៈដាច់ដោយដុំ។ ពួកគេបង់លុយ ដើម្បីបានប្លង់ដីដែលប្រៀបបានទៅនឹងការទិញប្លង់ដែរ។ ផ្ទុយទៅវិញ អ្នកក្រត្រូវតែពឹងផ្អែកលើប្រព័ន្ធដែលទើបនឹងបានបង្កើនល្បឿនក្នុងឆ្នាំ ២០០៦។ លើសពីនេះទៀត ការចេញប្លង់ដីតាមលក្ខណៈជាប្រព័ន្ធតែងតែធ្វើឡើងនៅតាមបណ្តាខេត្ត ដែលមិនសូវមានបញ្ហាវិវាទដីធ្លី ដូចជា ភ្នំពេញ ទីប្រជុំជននៅខេត្តខាងត្បូងវាលទំនាបទន្លេមេគង្គ និងវាលទំនាបទន្លេសាបជាដើម[៣៣]។ អភិបាលកិច្ចដីធ្លីដោយពុំមានប្លង់ដីជាក់លាក់ គឺជាការមួយដ៏លំបាក និងមិនប្រាកដប្រជាដែលនាំទៅរកការសម្រេចមិនយុត្តិធម៌ក្នុងករណីមានវិវាទដីធ្លី។

យោងតាមស្ថិតិមូលដ្ឋានសម្រាប់ ឃុំ-សង្កាត់ របស់ក្រសួងផែនការនៅឆ្នាំ ២០០៥ មានវិវាទដីធ្លីចំនួន ២៨.២១៩ ករណី ប្រៀបធៀបទៅនឹងឆ្នាំ ២០០៤ ដែលមានវិវាទចំនួនតែ ២៦.៣៥៣ ករណី ឆ្នាំ ២០០៣ ២៥.៤៤២ ករណី និងឆ្នាំ ២០០២ ២៦.៥១០ ករណី[៣៤]។ ជម្លោះដីធ្លីកើតកាន់តែច្រើនឡើងៗ ដោយសាររដ្ឋអំណាចមិនមានគោលការណ៍គ្រប់គ្រាន់ និងពេញលេញក្នុងការចុះបញ្ជីដីធ្លី និងចេញប្លង់ដី ហើយក៏គ្មានវិធីសម្រាប់ដោះស្រាយវិវាទដីធ្លីឱ្យបានសមស្របរហ័ស និងក្នុងតម្លៃទាប។

វិវាទដីធ្លីនៅតំបន់ខាងលិច និងពាយ័ព្យ មានច្រើនជាងតំបន់ឯទៀតៗ គិតជាចំនួនវិវាទសម្រាប់ប្រជាពលរដ្ឋមួយពាន់នាក់ (រូបភាព ៣.១០)។ ទ្រង់ទ្រាយនៃការវិវាទដីធ្លីនៅតាមជនបទសម្រាប់ខេត្តនីមួយៗ បង្ហាញឱ្យឃើញថា អាត្រានៃការវិវាទដីធ្លីខ្ពស់ជាងគេបំផុត គឺនៅក្នុងខេត្តទាំងឡាយណាដែលឆ្ងាយពីប្រព័ន្ធស្រោចស្រពធំៗ។

ក្នុងខេត្តនានានៅតំបន់ពាយ័ព្យ អត្រានៃវិវាទដីធ្លីក៏ខ្ពស់ដែរ (ឧទាហរណ៍ អតីតតំបន់ខ្មែរក្រហមកាន់កាប់) ជាកន្លែងសម្រាប់ធ្វើកសិកម្មក្រោយពេលដំណើរការសន្តិភាពបានចប់សព្វគ្រប់តំបន់ព្រៃនៅពាយ័ព្យសាន ដែលជាដីរបស់ជនជាតិដើមភាគតិច ក៏ត្រូវបានឡើងថ្លៃ និងនៅភូមិភាគនិរតី ដូចជាដីដែលពាក់ព័ន្ធនឹងការសាងសង់ផ្លូវជាតិលេខ ៤។ រីឯតំបន់អាគ្នេយ៍ ទន្លេសាបខាងកើត និងតំបន់កណ្តាល វិវាទដីធ្លីមានកម្រិតទាប[៣៥]។

---

*(៣០) Anders និង Kokko (២០០៦)។*

*(៣១) បញ្ហានេះផ្អែកលើកាសិក្សាទូលំទូលាយនៅមូលដ្ឋាន និងនៅទីផ្សេងៗទៀត។ ការសិក្សាពិសេស រួមមានការសិក្សារបស់ Kato (២០០០); Williams (២០០០); Biddulph (២០០០); So និង al. (២០០១); EFCT (២០០៥); UNHCHR (២០០៤); ធនាគារពិភពលោក (២០០៥)។*

*(៣២) ប្រភព : NSDP; សូមមើល RGC (២០០៦ក), ទំព័រ ២០។*

*(៣៣) ប្រភព : ធនាគារពិភពលោក (២០០២)។*

*(៣៤) របាយការណ៍ថ្មីមួយស្តីអំពីការសិក្សារបស់ Oxfam ចែងថាវិវាទដីធ្លីមានកម្រិតខ្ពស់រហូតដល់ ១ ករណី ក្នុងចំនួនដប់ប្រាំគ្រួសារ (ទិន្នន័យឆ្នាំ ២០០៦)។*

*(៣៥) ទិន្នន័យទាំងនេះខុសគ្នាអំពីទិន្នន័យដែលបានមកពីអាជ្ញាធរដោះស្រាយវិវាទ ពីព្រោះអាជ្ញាធរនោះមានតួលេខតែលើករណីណា ដែលបានទៅដល់តុលាការ ឬដល់អាជ្ញាធរឯទៀតៗ។*

*ការអភិវឌ្ឍទីប្រជុំជនដ៏ឆាប់រហ័សបានបង្កើតអំណាចទិញដូរឱ្យអាជីវករ និងមនុស្សដទៃទៀត ប៉ុន្តែដោយសារពុំមានជម្រើសច្រើនសម្រាប់ធ្វើវិនិយោគ ពួកគេក៏នាំគ្នាទៅទិញដី*

***រូបភាគ ៣.១០ : វិវាទដីធ្លីជនបទ (តាមចំនួន ១០០០ គ្រួសារ ឆ្នាំ ២០០៥) សម្រាប់ខេត្តនីមួយៗ***




*ប្រភព : មូលដ្ឋានទិន្នន័យ ឃុំ -សង្កាត់ របស់ក្រសួងផែនការ* http://www.seila.gov.kh

ការយកដីធ្លីទៅធ្វើពាណិជ្ជកម្ម ពិសេស ដីនៅតាមដងផ្លូវបានកើនឡើងយ៉ាងរហ័សក្នុងឆ្នាំថ្មីៗកន្លងមកនេះ បានបណ្តាលឱ្យមានការប្រកួតប្រណាំងគ្នារវាងមនុស្សជាច្រើន មិនមែនតែកសិករប៉ុណ្ណោះទេ។ តាមពិត មនុស្សគ្រប់គ្នា លើកលែងតែកសិករចេញ ពោលគឺក្រុមហ៊ុនជីសម្បទាន និងឈ្មួញកណ្តាល ជាអ្នកដែលមានឥទ្ធិពល ហេតុនេះនៅក្នុងការវិវាទដីធ្លី កសិករតែងតែស្ថិតនៅក្នុងជំហរទន់ខ្សោយជាងជានិច្ច[៣៦]។ ការអភិវឌ្ឍទីប្រជុំជនដ៏ឆាប់រហ័សបានបង្កើតអំណាចទិញដូរឱ្យអាជីវករ និងមនុស្សដទៃទៀត ប៉ុន្តែដោយសារពុំមានជម្រើសច្រើនសម្រាប់ធ្វើវិនិយោគ ពួកគេក៏នាំគ្នាទៅទិញដី។ ជាលទ្ធផល ការទិញដីនេះធ្វើឱ្យមនុស្សត្រូវការដីកាន់តែច្រើនឡើង។ ភាពមិនស្មើគ្នាក្នុងការទទួលព័ត៌មានបានធ្វើឱ្យឈ្មួញកណ្តាលមានប្រៀបជាង : ពួកគេដឹងថា ដីនៅកន្លែងណាដែលត្រូវអភិវឌ្ឍ កន្លែងណាត្រូវសាងសង់ផ្លូវ កន្លែងណាមានមជ្ឈមណ្ឌលពាណិជ្ជកម្ម ហើយត្រូវសាងសង់នៅពេលណា ឬឯកសិករ និងអ្នកលក់ដីមិនដឹងរឿងនេះទាល់តែសោះ។ លើសពីនេះទៀត ឧប្បត្តិហេតុនៃការដណ្តើមដីធ្លីក៏កើតឡើង ដោយមានអ្នកមានអំណាចជាអ្នកប្រព្រឹត្ត[៣៧]។ សង្ខេបសេចក្តីទៅ កាលណាសេចក្តីត្រូវការ ដីធ្លីកើនឡើង ក្នុងករណីដែលមិនមានផែនទីសុរិយោដីគ្រប់គ្រាន់ និងមិនមានការអនុវត្តច្បាប់ដីធ្លីឱ្យបានខ្លាំងក្លា វិវាទលើការកាន់កាប់ និងប្រើប្រាស់ដីធ្លីក៏កើនឡើងដែរ។

ទន្ទឹមគ្នានឹងការបង្កើនកិច្ចការផ្ទេរកសុរិយោដី ប្រព័ន្ធដំណោះស្រាយវិវាទដីធ្លី ក៏ត្រូវធ្វើវិមជ្ឈការទៅថ្នាក់មូលដ្ឋាន (ឃុំឬស្រុក)។ គួរមានគោលនយោបាយពិសេសមួយ គឺរៀបចំសាលាក្តីនៅថ្នាក់មូលដ្ឋានសម្រាប់ជំនុំជម្រះឱ្យអស់ក្នុងរយៈពេលមួយឆ្នាំ នូវបញ្ជីចាស់ដែលនៅសេសសល់ពាក់ព័ន្ធនឹងវិវាទដីធ្លី។ ព័ត៌មានស្តីពីផែនការអភិវឌ្ឍនានា គួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីឱ្យមានយុត្តិធម៌សម្រាប់ទាំងអស់គ្នា។

---

*(៣៦) ពុំមានទីផ្សារភាគហ៊ុន ឬប្រូបិយប័ណ្ណ រួមទាំងប្រាក់បញ្ញើ ពុំទទួលបាននូវផលតបមកវិញជាដុំកំភួនឡើយ។*

*(៣៧) ករណីនៃការលួចដៃរបស់ស្ថានប័នរដ្ឋ គឺជាករណីធម្មតា ហើយ* NGO Forum *កម្ពុជាតែងតែលើកយកឯកសារមកបង្ហាញពីករណីនេះជាទៀងទាត់។ សូមមើលបន្ថែម* The Cambodia Daily *១៣ តុលា ២០០៦។*

### *សារគន្លឹះ :*

*ការចេញប្លង់ដី ត្រូវតែប្រញាប់ប្រញាល់ឡើង ។ លើសពីនេះទៀត ត្រូវធ្វើប្រព័ន្ធវិមជ្ឈការនៃសេវាយុត្តិធម៌មួយ ដើម្បីដោះស្រាយវិវាទដីធ្លីឱ្យបានឆាប់រហ័ស ដែលនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ដំណើរការទាំងមូល ។*

*រូបភាគ ៣.១១ :  មូលហេតុខ្លះៗនៃវិវាទដីធ្លី*



*ប្រភព : ការសិក្សារបស់* *Oxfam* និង *CDRI*

## ៣.៥   របរនេសាទត្រី  និងជីវភាពរស់នៅ

### *ស្ថានភាព*

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាច្រើនពឹងផ្អែកលើការនេសាទត្រី ។ ទន្លេសាប និងអាងទន្លេមេគង្គ រួមទាំងស្ទឹង និងបឹងឯទៀតៗជាច្រើន គឺជាប្រភពសំខាន់នៃត្រីទឹកសាប ។ បឹងទន្លេសាបដែលមានទឹកទន្លេមេគង្គ ហូរចូលជារៀងរាល់ឆ្នាំនៅក្នុងរដូវភ្លៀងមានទំហំរីកធំជាង ៤ ដង ដោយគ្របដណ្តប់លើបឹងតូចៗមួយចំនួនធំ និងកន្លែងទឹកស្ទឹងហូរចូលជាច្រើន ព្រមទាំងវាលទំនាបលិចទឹកផង ។ បន្ទាប់មកទឹកបឹងទន្លេសាបហូរត្រឡប់ចាក់ចូលទៅក្នុងទន្លេមេគង្គវិញ ក្រោយរដូវវស្សា។លក្ខណៈដែលឥតមានពីរបែបនេះ ធ្វើឱ្យទន្លេសាបស្ថិតនៅក្នុងចំណោមប្រព័ន្ធបរិស្ថានទឹកសាប ដែលសម្បូរធនធានជាងគេបំផុតនៅក្នុងពិភពលោក ។ ទន្លេសាបជាកន្លែងដែលបរិបូណ៌ទៅដោយទីតាំងសម្រាប់ជលវប្បកម្ម ពីព្រោះមនុស្សភាគច្រើនរស់នៅមាត់ទឹក ។ កម្ពុជាមានឆ្នេរសមុទ្រប្រវែង ៤៣៥ គីឡូម៉ែត្រ លាតសន្ធឹងក្នុងខេត្ត ៤[៣៨] ។ ត្រី និងផលចេញពីត្រី ផ្តល់ជាតិប្រូតេអ៊ីនចំនួន ៧៥% នៃប្រូតេអ៊ីនទាំងអស់ ដែលពលរដ្ឋកម្ពុជាត្រូវការ ។

ស្ថិតិរបស់រដ្ឋាភិបាលចាត់ទុកការរួមចំណែកនៃការនេសាទត្រីទៅលើផលទុនជាតិសរុបចំនួនពី ១០-១២% និងផ្តល់ការងារធ្វើនៅក្នុងវិស័យនេសាទត្រីចំនួន ៤.៨% នៃកម្លាំងពលកម្មទាំងអស់[៣៩] ។ តួលេខទាំងនេះ អាចតិចជាងការពិត ពីព្រោះការសិក្សានៅមូលដ្ឋានរកឃើញថាប្រាក់ចំណូលរបស់គ្រួសារនីមួយៗកើនឡើងពី ១៥-១៧% ពីការនេសាទត្រី ហើយមានចំនួន ១លាន គ្រួសារដែលប្រកបរបរនេសាត្រីជាពិសេស នៅរដូវប្រាំង (៣៦% នៃគ្រួសារនៅក្នុងភូមិតាមដងទន្លេសាបជាអ្នកប្រកបរបរចិញ្ចឹមជីវិតដោយនេសាទត្រីជាចម្បង)[៤០] ។ នៅពេលដែលមានទឹកជំនន់ ឬរាំងស្ងួត ការនេសាទត្រីផ្តល់នូវការធានាមួយច្បាស់លាស់ ។ ក្នុងមួយឆ្នាំៗ ត្រីទឹកសាបមានចំនួនពី ០,៣៥ ទៅ ០,៤០ លានតោន ដែលមានតម្លៃពី ៣០០ ទៅ ៤០០ លានដុល្លារ ។ លើសពីនេះទៀត កំពិស បង្កង ក្តាម ខ្យង កង្កែប ពស់ សត្វល្មិតមានចំនួន ៦០.០០០ តោនក្នុងមួយឆ្នាំទៀត ។ ត្រីសមុទ្រមានចំនួន ៥៥.០០០ តោន ទៀត (រូបភាព ៣.១២)[៤១] ។

*(៣៨)  ព័ត៌មានពិស្តារអំពីប្រព័ន្ធ ស្ទឹង-ទន្លេ មាននៅក្នុងរបាយការណ៍របស់ SCW/Danida (២០០៦) ។*

*(៣៩)  ទិន្នន័យសម្រាប់ឆ្នាំ ២០០៤ ជាឆ្នាំចុងក្រោយដែលមានទិន្នន័យស្តីពីពលករ ។ សូមមើល http://www.nis.gov.kh*

*(៤០)  McKenney និង Prom (២០០២); Chan និង Acharya (២០០២); CDRI (មាននៅពេលក្រោយ) ។*

*(៤១)  ប្រភព : រាជរដ្ឋាភិបាល (២០០៦ ៣) ។*

*ពីរបីឆ្នាំកន្លងទៅនេះ មានការកើនចំនួនមនុស្សចូលទៅរស់នៅក្នុងតំបន់នេសាទត្រី ហើយធ្វើឱ្យខូចប្រព័ន្ធជីវសាស្ត្រ ដែលបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបរិមាណត្រី... ជីវភាពរបស់ប្រជាពលរដ្ឋ... ក៏ទទួលផលប៉ះពាល់ដែរ*

ការនេសាទនេះ គឺជាការនេសាទត្រីដែលរស់នៅក្នុងបឹងបួធម្មជាតិ ប៉ុន្តែថ្មីនេះ មានការប្រើបច្ចេកវិជ្ជាបង្កើនផលិតភាពខ្លះ ដូចជាចិញ្ចឹមត្រីក្នុងបែ ឬចិញ្ចឹមត្រីជារបៀបជលវប្បកម្ម។ ការចិញ្ចឹមត្រីបែបនេះ អាចធ្វើបានតែចំពោះត្រីប្រភេទមួយចំនួន និងនៅតាមតំបន់ខ្លះតែប៉ុណ្ណោះ។

ប៉ុន្មានឆ្នាំកន្លងទៅនេះ មានការកើនចំនួនមនុស្សចូលទៅរស់នៅក្នុងតំបន់នេសាទត្រី ហើយធ្វើឱ្យខូចប្រព័ន្ធបរិស្ថានវិទ្យា ដែលបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបរិមាណត្រី។ ជាមួយគ្នានេះដែរ ជីវភាពរបស់ប្រជាពលរដ្ឋដែលពឹងផ្អែកលើការនេសាទទាំងនោះក៏ទទួលផលប៉ះពាល់ដែរ។ ពីមួយឆ្នាំទៅមួយឆ្នាំ បញ្ហាដែលត្រូវរពុះពារក្នុងការគ្រប់គ្រងធនធានត្រី គឺថាអ្នកណាជាម្ចាស់ និងអ្នកណាគួរមានសិទ្ធិនេសាទត្រី ហើយវិធីណាដែលត្រូវចាត់ចែងលើប្រព័ន្ធការពារត្រី។

***រូបភាគ ៣.១២ : ត្រីដែលចាប់បាននៅកម្ពុជា ឆ្នាំ១៩៨០-២០០៤***



***កំណត់សម្គាល់ :*** *មានការកើនឡើងខ្លាំងនៅឆ្នាំ ២០០១-២០០២ ពីព្រោះការនេសាទជាលក្ខណៈគ្រួសារត្រូវរាប់បញ្ចូលក្នុងចំនួនសរុបទាំងអស់។*
*ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), http://www.maff.gov.kh*

## *កំណើនការពឹងផ្អែកលើការនេសាទត្រី*

ដោយសារកំណើនប្រជាពលរដ្ឋ សេចក្តីត្រូវការលើប្រភពត្រីក៏កើនឡើងដែរ ពីព្រោះការងារចិញ្ចឹមជីវិតក្នុងវិស័យឯទៀតៗ មិនសូវរីកចម្រើន[៤២]។

បច្ចុប្បន្ននេះ មានមនុស្ស ១ លាននាក់ ប្រកបរបរចិញ្ចឹមជីវិតដោយនេសាទត្រី ហើយចំនួននេះអាចកើនឡើងថែមទៀត ដោយសារកំណើនប្រជាពលរដ្ឋ និងដោយអ្នកដែលបាត់បង់ដីកសិកម្ម ចូលមករស់នៅក្នុងតំបន់នេសាទត្រីថែមទៀត។ ប្រសិនបើមនុស្ស ១ លាននាក់ចែករំលែកផលទុនត្រីសរុបដែលមានតម្លៃ ៣៥០ លានដុល្លារ នោះអ្នកនេសាទម្នាក់ៗនឹងទទួលបានប្រាក់ចំណូលប្រចាំឆ្នាំ ៣៥០ ដុល្លារ (ចំណូលសរុប)។ ប្រសិនបើដកចំណាយផ្សេងៗចេញ អ្នកនេសាទម្នាក់ៗនៅសល់ប្រាក់ចំណូលប្រហែលពី ២០០-២២៥ ដុល្លារក្នុងមួយឆ្នាំ។ ជាញឹកញាប់ អ្នកនេសាទឯកជនដែលប្រើឧបករណ៍នេសាទអសកម្ម រកត្រីបានក្នុងតម្លៃមិនលើសពី ៤០០០-៦០០០ រៀលទេ (ពី ១-១.៥០ ដុល្លារ)[៤៣]។

ប្រសិនបើមនុស្សជាច្រើននាំគ្នាប្រកបរបរចិញ្ចឹមជីវិតដោយនេសាត្រីទឹកសាប នោះនឹងបណ្តាលឱ្យកើនការប្រកួតប្រជែងគ្នារកត្រីដែលមានតម្លៃ ឬរកត្រីធំៗ ហើយបណ្តាលឱ្យបាត់បង់ពូជត្រី។ ត្រីធំដែលមានតម្លៃខ្ពស់ ហើយដែលត្រូវការពេលយូរ ដើម្បីបន្តពូជនោះនិងកាន់តែក្រទៅៗ នៅសល់តែត្រីតូចៗ ដែលមិនសូវមានតម្លៃ ដូចគេតែងតែលើកឧទាហរណ៍អំពីហេតុការណ៍នៃប្រទេសបង់ក្លាដេស។ បញ្ហានេះក៏មាននៅក្នុងវិស័យនេសាទត្រីសមុទ្រដែរ ព្រោះមានមនុស្សច្រើនណាស់ ដែលប្រកបរបរចិញ្ចឹមជីវិតតែនេសាទត្រីមួយមុខ

(៤២) Hap, Chuenpagdee និង Kurien (2006); ICTSD (2005)។
(៤៣) ប្រភពទិន្នន័យ : Acharya, Kim, Chap និង Meach (២០០៣); ការសង្កេតដល់មូលដ្ឋានក្នុងឆ្នាំ ២០០៦។

រហូតទាល់តែធ្វើឱ្យខូចគុណភាព ពូជត្រីសមុទ្របន្សល់ទុកនៅប្រាក់ចំណូលទាបជានិច្ចរហូតតទៅ[៤៤]។ ដោយសារការនេសាទភាគច្រើនពឹងផ្អែកលើធនធាន ភាពមិនស្មើគ្នាក្នុងការរកធនធានបានធ្វើឱ្យការនេសាទកាន់តែយ៉ាប់យឺនទៅៗ។ អ្នកដែលមិនសូវសម្បូរធនធានរួមទាំងមេគ្រួសារដែលជាស្ត្រី គឺសុទ្ធតែជាអ្នកចាញ់ ដោយមិនអាចជ្រើសរើសបាន។

ជីវភាពរស់នៅរបស់គ្រួសារអ្នកនេសាទមានភាពប្រសើរជាងជីវភាពរបស់អ្នកដែលមានដីខ្លះ ឬអ្នកដែលប្រកបរបរនៅតាមមាត់ទឹក (ឧទាហរណ៍ ជលវប្បកម្ម) នេះមានន័យថា សម្រាប់មនុស្សជាច្រើន ការបង្កើតមុខរបរ និងបង្កើតការងារផ្សេងៗពីគ្នា គឺជាយុទ្ធសាស្ត្រមួយសំខាន់សម្រាប់ធ្វើឱ្យប្រសើរឡើងដល់ជីវភាពរស់នៅ។

## ផលប៉ះពាល់ពីការបំផ្លាញព្រៃឈើ និងគម្រោងអភិវឌ្ឍន៍

ការកាប់បំផ្លាញព្រៃឈើជាទ្រង់ទ្រាយធំនៅតាមតំបន់ដីទំនាបក្បែរមាត់ស្ទឹង ទន្លេ ធ្វើឱ្យប្រែប្រួលដល់លំហូរទឹក និងបរិមាណទឹកនៅផ្នែកខាងក្រោមនៃទន្លេ។ ការប្រែប្រួលនេះប៉ះពាល់ទៅដល់បរិមាណត្រី។ ការអភិវឌ្ឍកសិកម្ម និងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅជិតៗបឹងទន្លេសាប ក៏មានផលប៉ះពាល់លើការបន្តពូជត្រី និងបរិមាណត្រី ដោយផ្ទាល់ ឬដោយប្រយោលដែរ ដោយសារមានការរំខានដល់ដំណើរការបន្តពូជ និងការខូចខាតដល់លំនៅដ្ឋានរបស់ត្រី។ ឧទាហរណ៍ខ្លះ មានដូចខាងក្រោមនេះ៖

ក. ការកាប់ឈើហុបក្នុងកម្រិតខ្ពស់ និងការឈូសឆាយព្រៃលិចទឹក និងព្រៃឯទៀតៗ បានបណ្ដាលឱ្យទន្លេសាបកាន់តែរាក់ទៅៗ និងបណ្ដាលឱ្យប៉ះពាល់ដល់បរិមាណត្រី។

ខ. គម្រោងអភិវឌ្ឍន៍ដែលផ្លាស់ប្ដូរទិសឱ្យទឹកហូរ ឬក្នុងទម្រង់ណាមួយប៉ះពាល់ដល់ជម្រកត្រី នាំឱ្យបរិមាណត្រីថយចុះ[៤៥]។

គ. វិធីដាំដុះទំនើប ដែលបណ្ដោយឱ្យជីគីមី និងថ្នាំសម្លាប់សត្វល្អិតហូរចូលទៅក្នុងទឹក ក៏មានផលប៉ះពាល់អវិជ្ជមានទៅលើត្រីដែរ

ឃ. ដោយសារមានតម្រូវការដីកសិកម្មកាន់តែច្រើនឡើងអ្នកស្រែខ្លះ ដាំស្រូវនៅក្នុងស្រែលិចទឹក។ ពេលខ្លះទៀត គេកាប់បំផ្លាញព្រៃលិចទឹក និងបូមទឹកចេញពីបឹង ដើម្បីយកដីធ្វើស្រែ ដែលជាហេតុបណ្ដាលឱ្យប៉ះពាល់ដល់ជីវិតសត្វដែលរស់នៅក្នុងទឹក។

ផែនការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងទឹក និងព្រៃឈើ ត្រូវតែសហប្រតិបត្តិការគ្នា ដើម្បីជួយពង្រឹងគ្នាទៅវិញទៅមក ហើយជ្រើសរើសរវាងទង្វើណា ដែលមានឆន្ទៈផ្ទុយពីគ្នា។

*ផែនការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងទឹក និងព្រៃឈើ ត្រូវតែសហការគ្នា ដើម្បីជួយពង្រឹងគ្នាទៅវិញទៅមក ហើយជ្រើសរើសរវាងទង្វើណាដែលមានឆន្ទៈផ្ទុយពីគ្នា*

## ការនេសាទខុសច្បាប់

អ្នកនេសាទតូចតាចជាច្រើន ចាប់ត្រីលួចលាក់ ឬនេសាទត្រីខុសច្បាប់ និងប្រព្រឹត្តអំពើដែលមិនគាប់ប្រសើរចំពោះប្រព័ន្ធបរិស្ថានវិទ្យា ដូចជា គប់គ្រាប់បែក ឆក់ត្រី។ ម្ចាស់ឡូត៍នេសាទតែងតែព្យាយាមពង្រីកព្រំសីមារបស់ខ្លួនចូលទៅក្នុងដែននេសាទសាធារណៈ និងទន្ទ្រានចូលទៅក្នុងតំបន់សម្រាប់អ្នកនេសាទតូចតាច។ សរុបសេចក្ដីមក គ្រប់ៗគ្នាតែងតែចង់បានត្រីច្រើនជាងរក្សាប្រភពត្រីឱ្យមានជាប្រចាំ។ អង្កេតនៅតាមកន្លែងជាច្រើនបានរកឃើញថា បរិមាណត្រីសម្រាប់អ្នកនេសាទតូចៗប្រកបរបរចិញ្ចឹមជីវិតឥឡូវនេះ បានថយចុះជាខ្លាំងបើប្រៀបធៀបទៅ ២-៣ ឆ្នាំមុន[៤៦]។ គួររៀបចំក្រុមអ្នកឃ្លាំមើលតាមសហគមន៍ ដើម្បីគ្រប់គ្រងការនេសាទឱ្យបានល្អ។

## ឡូត៍នេសាទ

ស្ទើរតែមួយសតវត្សរ៍កន្លងមក សូម្បីតែសព្វថ្ងៃនេះក៏ដោយវិធីគ្រប់គ្រងការនេសាទឱ្យល្អ គឺការចែកឡូត៍ នេសាទ។ រដ្ឋាភិបាលផ្ដល់ឡូត៍នេសាទឱ្យក្រុមហ៊ុនសម្រាប់រយៈពេល ២ ឆ្នាំ។ ប្រវត្តិរឿងនៃឡូត៍នេសាទ គឺជរាបណានៅមានអ្នកនេសាទតូចតាចជាច្រើន ដែលប្រកបរបរចិញ្ចឹមជីវិតដោយនេសាទត្រីនោះ នឹងតែងតែមានទំនាស់រវាងពួកគេ និងម្ចាស់ឡូត៍នេសាទ។ តាមពិត រឿងនេះនឹងកើតឡើងពេលនរណាម្នាក់អះអាងថា ខ្លួនមានសិទ្ធិផ្ដាច់មុខក្នុងការនេសាទត្រីទឹកសាប (ប្រអប់ ៣.៧)។ ហើយសារៈសំខាន់មួយទៀត គឺការដំឡើងពន្ធ និងរកទីផ្សារសម្រាប់លក់ផលនេសាទ។

## សារគន្លឹះ៖

១. *ប្រាក់ចំណូលរបស់ពលរដ្ឋដែលពឹងផ្អែកលើត្រីអាចបង្កើនបានដោយធ្វើការកែច្នៃដើម្បីតម្លៃបន្ថែម។*

២. *ត្រូវផ្ដល់អំណាចដល់សហគមន៍ ដើម្បីត្រួតពិនិត្យលើការអនុវត្តណាដែលប៉ះពាល់ដល់ប្រព័ន្ធជីវសាស្ត្រ។*

៣. *ត្រូវពង្រឹងមធ្យោបាយដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយជម្លោះរវាងម្ចាស់ឡូត៍នេសាទ និងអ្នកនេសាទត្រីសាមញ្ញ។*

---

(៤៤) IMM (២០០៥); Kim (២០០៥)។

(៤៥) Mak (២០០៥); IRN (២០០២)។

(៤៦) ECFT (២០០៥); Kim, Chan និង Acharya (២០០២); CDRI (នឹងមាននៅពេលក្រោយ)។

## ប្រអប់ ៣.៧ :  ឡូត៍នេសាទ្រី - ប្រវត្តិសាវតារខ្លះៗ

ប្រព័ន្ធផ្តល់ឡូត៍នេសាទចាប់អនុវត្តនៅកម្ពុជាក្នុងឆ្នាំ ១៨៦៣ ដោយបារាំង ប៉ុន្តែត្រូវផ្អាកទៅវិញនៅឆ្នាំ ១៨៨៤ ដោយសារការតវ៉ាប្រឆាំងនឹងការយកសម្បត្តិរួមទៅធ្វើជារបស់ឯកជន។ ក្នុងឆ្នាំ ១៩០៨ មានវិធានការណ៍អភិរក្សថ្មីៗ ដែលមានសមាសភាគសំខាន់ៗ ៥ គឺកំណត់រដូវនេសាទត្រី បង្កើតជម្រកត្រី ដាក់កំហិតឧបករណ៍នេសាទតាមប្រភេទ និងអនុញ្ញាតឱ្យប្រជាពលរដ្ឋមូលដ្ឋានមានសិទ្ធិមួយចំនួនក្នុងការនេសាទត្រី (ចំនួន ៧% នៃឡូត៍នេសាទសម្បទានទាំងអស់) ហើយបង្កើតវិទ្យាស្ថានស្រាវជ្រាវវិស័យនេសាទត្រី។

ក្រោយពេលបានឯករាជ្យហើយ ច្បាប់គ្រប់គ្រងការនេសាទត្រីត្រូវបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ១៩៥៦ ដែលនៅតែរក្សាប្រព័ន្ធឡូត៍នេសាទ។ ជម្លោះដោយសារប្រព័ន្ធឡូត៍នេសាទនេះ ក៏កើតមានសារជាថ្មីនៅឆ្នាំ ១៩៦០ ហើយរដ្ឋាភិបាលបានសម្រេចលុបចោលឡូត៍នេសាទខ្លះដើម្បីបន្ធូរបន្ថយភាពតានតឹង។ នៅឆ្នាំ ១៩៧៣ លន់ នល់ លុបចោលឡូត៍នេសាទទាំងអស់ ហើយសម័យខ្មែរក្រហមឆ្នាំ ១៩៧៥-១៩៧៩ សកម្មភាពនេសាទភាគច្រើនត្រូវបានបោះបង់ចោល។

ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ អាជ្ញាធរបានព្យាយាមរៀបចំសកម្មភាពនេសាទត្រីឡើងវិញស្រដៀងគ្នាទៅនឹងសកម្មភាពរៀបចំដីធ្លី ដែលហៅថា ក្រុមសាមគ្គីនេសាទ។ ក្រុមអ្នកនេសាទត្រីអាចនេសាទត្រីបាន ប៉ុន្តែត្រូវយកត្រីស្រស់ ឬត្រីងៀតបង់ពន្ធជូនរដ្ឋ។ អ្នកនេសាទខ្លះបានតាំងទីលំនៅក្នុងបឹងទន្លេសាបដោយរស់នៅជាភូមិអណ្តែតទឹក។ ក្នុងឆ្នាំ ១៩៨៧ ប្រព័ន្ធឡូត៍នេសាទត្រីក៏ចាប់ផ្តើមប្រើប្រាស់សារជាថ្មីឡើងវិញ ក្នុងគោលបំណងធ្វើឱ្យកាន់តែមានប្រសិទ្ធភាពឡើង និងបង្កើនប្រាក់ចំណូលជូនរដ្ឋកាន់តែច្រើន។ រដ្ឋាភិបាលបានដាក់ច្បាប់រដ្ឋបាល និងគ្រប់គ្រងការនេសាទលេខ ៣៣ ឱ្យប្រើប្រាស់ដោយយកគំរូតាមច្បាប់នេសាទឆ្នាំ ១៩៥៦ ដែលចែកតំបន់នេសាទត្រីជា ៣ ប្រភេទ គឺការនេសាទទ្រង់ទ្រាយធំ (ជាការនេសាទទ្រង់ទ្រាយឧស្សាហកម្ម) ការនេសាទទ្រង់ទ្រាយមធ្យម (ដោយប្រើឧបករណ៍នេសាទ ដូចជា ថ្នង ឬអួន អញ្ចង ដែលមានអាជ្ញាប័ណ្ណ - ការនេសាទជាសហគ្រាស) និងការនេសាទទ្រង់ទ្រាយតូច (ដោយប្រើឧបករណ៍អសកម្ម ដូចជា សន្ទូចផ្លែមួយ សំណាញ់ និងមងតូចៗ ជាការនេសាទតាមគ្រួសារ)។

រហូតមកដល់ឆ្នាំ ២០០១ ទំហំទឹកបឹងទន្លេសាបជិត ១ លានហិចតា ត្រូវបានជួលឱ្យម្ចាស់ឡូត៍នេសាទ ក្នុងកិច្ចព្រមព្រៀងរយៈពេល ២ ឆ្នាំជាមធ្យម ប៉ុន្តែតួលេខនេះត្រូវបានផ្លាស់ប្តូរក្នុងឆ្នាំ ២០០១ ដោយសារ ៥៦% នៃឡូត៍នេសាទ ដែលជួលនេះត្រូវបានលុបចេញ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងឡូត៍នេសាទសហគមន៍ ដែលចេញឱ្យប្រើក្នុងឆ្នាំ ២០០៥ ដៅទៅរកការពង្រឹងប្រព័ន្ធនេសាទត្រីសហគមន៍នៅតាមតំបន់ដែលលុបចេញពីឡូត៍នេសាទ។

*រូបភាព ៣.១៣ : ឡូត៍នេសាទ : ឡូត៍នេសាទបច្ចុប្បន្ន និងឡូត៍នេសាទដែលត្រូវបានលុបចោល ក្នុងឆ្នាំ ២០០១*




*ប្រភព : ដកស្រង់ចេញពី Kurien nig Mao ឆ្នាំ ២០០៦*

## ៣.៦ ព្រៃឈើ និងរបររកស៊ីព្រៃឈើ

កម្ពុជាមានព្រៃ ៥៨% នៃទំហំដីទាំងមូល (តាមបញ្ជីខ្លះមាន ៦០%)។ ប៉ុន្តែរូបភាពផ្កាយរណបថ្មីៗនេះបង្ហាញថា ភាគច្រើននៃព្រៃទាំងនោះ មិនមែនជាព្រៃធំៗទេ ផ្ទុយទៅវិញរូបភាពជាង ៣/៤ ត្រូវបានចាត់ទុកជាតំបន់បៃតង ដែលមានការរំខាន ឬតំបន់ចម្រុះ ឬតំបន់បៃតងដែលដាច់ដោយដុំៗ។ ការកាប់ឈើទ្រង់ទ្រាយធំ និងជួនកាលខុសច្បាប់មានច្រើនណាស់ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋបានលុបចោលកិច្ចព្រមព្រៀងសម្បទានមួយចំនួន បន្ទាប់មក ផ្អាកការកាប់ឈើទាំងស្រុងក្នុងឆ្នាំ ២០០២ សម្រាប់រយៈពេល ៣-៤ ឆ្នាំ (ប្រអប់ ៣.៨)។

ក្នុងខេត្តជាច្រើន ជីវភាពរស់នៅតាមប្រពៃណីរបស់អ្នកជនបទពាក់ព័ន្ធជិតស្និតជាមួយព្រៃឈើសម្រាប់ធ្វើអុសដុត សម្ភារៈសំណង់ ឈើហ៊ុប កូនឈើ ជ័រទឹក ជ័រដុំ ថ្នាំប្រពៃណី ស្លឹក ផ្តៅ សត្វតូចតាច សត្វល្អិត ឧរង្គសត្វ និងផលដទៃៗទៀតពីព្រៃឈើ។ ពលរដ្ឋនៅតំបន់ព្លសាន នៅផ្នែកខ្លះក្នុងតំបន់ខាងលិច និងតំបន់ភ្នំពីមួយឆ្នាំទៅមួយឆ្នាំ ពឹងផ្អែកលើព្រៃឈើដើម្បីប្រកបរបរចិញ្ចឹមជីវិត។ លើសពីនេះទៀត គ្រួសារជនបទទាំងនោះ ដែលមិនមានប្រភពចំណូលច្រើនផ្សេងគ្នា គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ឬគ្រួសារដែលមានមេគ្រួសារជាមនុស្សចាស់ និងក្មេងៗ តែងតែត្រូវគេប្រើឱ្យទៅប្រមូលផលពីក្នុងព្រៃ ដើម្បីកាត់បន្ថយតម្លៃពលកម្ម។ ដូចជាការនេសាទដែរ ការប្រមូលអនុផលព្រៃឈើ គឺជាសកម្មភាពដែលអាចការពារទប់ទល់នឹងការខូចខាតផលដំណាំ ដោយសារការរាំងស្ងួត ឬក៏ទឹកជំនន់។ នៅតំបន់ខ្លះ អ្នកដើរព្រៃទាំងនេះ យកផលិតផលពីព្រៃឈើទៅលក់ដូរដែលទទួលបានជាប្រាក់ពី ១៥០០ ទៅ ២០០០ រៀល ក្នុងមួយថ្ងៃ (ទិន្នន័យដើមទសវត្សរ៍ឆ្នាំ ២០០០)។ ប្រហែល ១/៣ នៃគ្រួសាររស់នៅក្នុងភូមិតាមដងព្រៃ (ពិសេសនៅក្នុងខេត្តតំបន់ព្លសាន និងពាយ័ព្យ) ពេលខ្លះស្វះស្វែងរកអាហារក្នុងព្រៃ។

នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ជាពេលដែលចាប់ផ្តើមមានសម្បទានដីព្រៃសហគមន៍ ភូមិដ្ឋាននៅតាមកន្លែងជាច្រើន បានទទួលផលជាប្រាក់កម្រៃពលកម្មពី ៣០០០-៤០០០ រៀល ក្នុងមួយថ្ងៃ ដោយបម្រើការយ៉ាងសកម្មនៅក្នុងកិច្ចប្រតិបត្តិការកាប់ឈើ ក្រោយពេលដែលសេចក្តីត្រូវការឈើហ៊ុបកើនឡើងខ្លាំង ហើយព្រៃឈើពេលនោះ មិនទាន់មានការគ្រប់គ្រងពិតប្រាកដនៅឡើងទេ។ តាំងពីឆ្នាំ ១៩៩៨ មក សកម្មភាពទាំងនោះភាគច្រើនក៏ថយចុះ ថ្វីត្បិតតែខ្លះនៅតែមានបន្តដោយលួចលាក់ក៏ដោយ។ ប៉ុន្តែការផ្តល់ព្រៃសម្បទាននេះធ្វើឱ្យសហគមន៍ខាតបង់សិទ្ធិប្រើប្រាស់ព្រៃឈើ។ បន្ថែមទៅលើការខាតបង់ផ្នែកសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ ការដើរហើររបស់ពលរដ្ឋនៅក្នុងព្រៃ ក៏ត្រូវមានកម្រិតដែរ។ ជាបណ្តើរៗតមក សហគមន៍រាយការណ៍ថា បាត់បង់ប្រាក់ចំណូល ហើយនិងបាត់បង់ផលដែលធ្លាប់រកបានពីព្រៃឈើ ដោយសារការដាក់ព្រៃឈើជាសម្បត្តិឯកជន និងការខូចគុណភាពធម្មជាតិ។ នៅភូមិទាំងឡាយណាដែលមិនសម្បូរធនធាន ការខូចគុណភាពធម្មជាតិដ៏ធ្ងន់ធ្ងរបែបនេះ បានបណ្តាលឱ្យខ្វះអុសដុតជាខ្លាំង ដែលសព្វថ្ងៃនេះពួកគេត្រូវទិញអុសដុត។ តាមសម្តីអ្នកភូមិ ការធ្វើសម្បទានព្រៃឈើមិនមែនជាការបង្កើតការងារឱ្យពួកគេទេ ផ្ទុយទៅវិញ គឺជាការបំផ្លិចបំផ្លាញប្រព័ន្ធជីវសាស្ត្រ និងរុញច្រានពួកគេចេញពីព្រៃឈើទៅវិញទេ[៤៧]។

អ្នកភូមិនៅក្នុងព្រៃទាំងនោះអះអាងថា គេជាម្ចាស់ដើមឈើយកជ័រជាច្រើនជំនាន់មកហើយ ដែលគេតែងតែលុងដើមឈើនោះយកជ័រ មិនមែនកាប់រំលំយកឈើហ៊ុបទេ។ ការអះអាងទាំងនេះ ត្រូវបានម្ចាស់ព្រៃសម្បទានជំទាស់។ អ្នកភូមិជាច្រើនបានលក់ដើមឈើរបស់ខ្លួនឱ្យទៅម្ចាស់ព្រៃសម្បទាន ហើយនៅតែមួយចំនួនតូចទេ ដែលនៅតែអះអាងថា ខ្លួនជាម្ចាស់ដើមឈើទាំងនោះ។ ដើមឈើខ្លះ ក្នុងមួយឆ្នាំៗ អាចផ្តល់ជ័របានក្នុងតម្លៃ ២០.០០០ រៀល។ ដើមឈើទាំងនេះភាគច្រើន ដែលសព្វថ្ងៃជារបស់ម្ចាស់ព្រៃសម្បទាន ត្រូវបានគេកាប់រំលំយកឈើហ៊ុប។ នៅឆ្នាំ ១៩៩៤ មានបង្កើតព្រៃសហគមន៍ ដែលជាជម្រើសថ្មីមួយដើម្បីគ្រប់គ្រងព្រៃឈើ។ ពីនោះតមក ព្រៃសហគមន៍មួយចំនួន បានត្រូវបង្កើតដោយជោគជ័យ (ប្រអប់ ៣.៩)។ ព្រៃសហគមន៍ទាំងនេះ អាចជាមាគ៌ាមួយសម្រាប់អានាគតដ៏ល្អដល់ព្រៃឈើនៅកម្ពុជា។

សរុបសេចក្តីមក នៅក្នុងសម័យដែលមិនទាន់សម្បូរឧស្សាហកម្ម និងដែលមិនសូវមានការទិញ លក់ ផលព្រៃឈើព្រៃទាំងនោះជាប្រភពផ្តល់ឱ្យប្រជាពលរដ្ឋក្រីក្រតាមជនបទនូវផលប្រយោជន៍បន្ទាប់បន្សំសម្រាប់រស់។ ប៉ុន្តែឥឡូវនេះ ដោយប្រជាពលរដ្ឋកើនឡើង ហើយដោយសារមានការទិញលក់ផលព្រៃឈើច្រើន និងដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ ព្រៃឈើទាំងនោះជួបប្រទះនឹងការគម្រាមកំហែងកាន់តែខ្លាំងឡើងៗ។

(៤៧) USAID (២០០៥)

### ប្រអប់ ៣.៨ : ការគ្រប់គ្រងព្រៃឈើ - ការពិនិត្យលើប្រវត្តិសាស្ត្រ

ការប្រមូលផលព្រៃឈើជាចម្បង គឺឈើហ៊ុបមានធ្វើតាំងពីសម័យអាណានិគមមកម្ល៉េះ។ មានចេញអាជ្ញាប័ណ្ណសម្រាប់រយៈពេលមានកំណត់ឱ្យក្រុមហ៊ុនជំនួញ ដោយមានចំនួនឈើហ៊ុបពិតប្រាកដក្នុងតម្លៃដែលមានកំណត់មួយ។ គេធ្វើរបៀបនេះរហូតដល់ទសវត្សរ៍ឆ្នាំ ១៩៧០ នៅពេលដែលខ្មែរក្រហមបញ្ឈប់កិច្ចសន្យាកាប់ឈើទាំងអស់ ប៉ុន្តែពួកគេកាប់បំផ្លាញព្រៃលិចទឹកជាច្រើន ដើម្បីយកដីដាំស្រូវ។



ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នាយកដ្ឋានព្រៃឈើបានកាប់ឈើដោយខ្លួនឯង នៅក្នុងខេត្តជាច្រើន ជាពិសេស នៅភាគខាងកើត។ ការកាប់ឈើក៏ធ្វើឡើងដោយក្រុមសាមគ្គីដែរ ដែលលក់ផលឈើឱ្យរដ្ឋាភិបាលក្នុងតម្លៃទាបជាងតម្លៃទីផ្សារ។ ក្នុងពេលជាមួយគ្នានេះ ប្រព័ន្ធប្រមូលផលឈើតាមកិច្ចសន្យា ក៏បានត្រឡប់មកវិញបន្តិចម្តងៗ ប៉ុន្តែត្រូវបានបញ្ចប់នៅឆ្នាំ ១៩៨៨។

ការយកផលព្រៃឈើបានចាប់ផ្តើមក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នឹងដើមទសវត្សរ៍ឆ្នាំ ១៩៩០ ដោយក្រុមផ្សេងៗគ្នាជាច្រើនក្រុម នៅពេលដែលគណបក្សនយោបាយនានា ក្រុមទាហាន ក្រុមអភិបាលខេត្ត និងក្រុមអ្នករកស៊ីព្រៃឈើឯកជន ប្រកួតប្រជែងដណ្តើមធនធានព្រៃឈើគ្នា។ ដីព្រៃសម្បទានដែលមានទំហំទាំងអស់ ៦,៩ លានហិចតា (ស្មើនឹង ៣៨% នៃទំហំដីទាំងអស់) ត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុន ២៩ ក្នុងចន្លោះឆ្នាំ ១៩៩៤-២០០០។ ប៉ុន្តែក្រោយពីមានការកាប់ឈើខុសច្បាប់ជាទ្រង់ទ្រាយធំ និងការមិនប្រតិបត្តិតាមបទបញ្ជា រដ្ឋាភិបាលបានលុបចោលសិទ្ធិសម្បទានរបស់ក្រុមហ៊ុនចំនួន ១៧ ដែលគ្របដណ្តប់លើទំហំដីប្រហែល ៣,៥ លានហិចតា។ នៅឆ្នាំ ២០០៥ មានក្រុមហ៊ុនកាន់កាប់ដីសម្បទានចំនួន ១២ គ្របដណ្តប់លើដីចំនួន ៣,៤ លានហិចតា នៅតាមតំបន់ព្រៃសម្បទានចំនួនបួនកន្លែង (ដែលមានទំហំប្រហែល ១៨% នៃដីទាំងអស់)[៤៨]។

មកដល់ពេលនេះ (ក) ព្រៃមួយផ្នែកធំត្រូវខូចគុណភាព (ខ) មួយចំណែកធំនៃព្រៃទាំងអស់ក្លាយជាកម្មសិទ្ធឯកជន ហើយ (គ) សិទ្ធិរបស់កសិករក្រីក្រក្នុងការចូលទៅយកផលធម្មជាតិពីតំបន់ទាំងនោះ ក៏ត្រូវកាត់បន្ថយ។ នៅឆ្នាំ ២០០២ ការកាប់ឈើត្រូវផ្អាកទាំងអស់ ប៉ុន្តែការលួចកាប់ខុសច្បាប់នៅតែមានបន្ត។ នៅឆ្នាំ ២០០៣ ច្បាប់ព្រៃឈើថ្មីមួយត្រូវបានអនុម័ត ហើយគោលការណ៍ណែនាំនានា ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់នៅដើមឆ្នាំ ២០០៦ ដែលបើកផ្លូវឱ្យសកម្មភាពការពារព្រៃឈើសហគមន៍បានរីកចម្រើន។

*ប្រភព : UNHCHR (២០០៤); EFCT (២០០៥); McKenny និង Prom (២០០២); SCW/Danida (២០០៦); Le Billion (២០០៦)*

---

*(៤៨) តួលេខនេះ ស្រង់ចេញពីរបាយការណ៍របស់ GTZ (២០០៦)។ ព្រៃដាក់ជាព្រៃសម្បទានមានការតវ៉ាជាខ្លាំង។ របាយការណ៍ពេញលេញមួយស្តីអំពីប្រវត្តិព្រៃសម្បទានមាននៅក្នុងការសិក្សារបស់ McKenny និង Prom (២០០២)។*

## ប្រអប់ ៣.៩ ៖ ព្រៃសហគមន៍



សកម្មភាពព្រៃសហគមន៍បានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៤ នៅខេត្តតាកែវ ។ ពីនោះតមក មានបង្កើតក្រុមព្រៃសហគមន៍ជាងមួយរយក្រុមថែមទៀត ដោយមានការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងប្រទេសផ្តល់អំណោយជាច្រើន រួមទាំង អង្គការកសិកម្មនិងអាហារនៃអង្គការសហប្រជាជាតិផង ។ ព្រៃសហគមន៍ទាំងនេះ មានទំហំសរុប ២០០,០០០ ហិចតា នៅឆ្នាំ ២០០២ ។

ព្រៃសហគមន៍បង្កលក្ខណៈឱ្យពលរដ្ឋការពារព្រៃឈើ ផ្តល់សិទ្ធិអំណាចឱ្យសហគមន៍គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើដោយចីរភាព ។ វិធីនេះ គឺដើម្បីឱ្យពលរដ្ឋមូលដ្ឋានមានសិទ្ធិយកផល និងប្រើប្រាស់ព្រៃឈើទាំងនោះ ដើម្បីឱ្យពួកគេមានកម្លាំងចិត្តការពារព្រៃឈើ ។ ប្រាក់ចំណូលពីការប្រើប្រាស់ព្រៃឈើ ត្រូវរក្សាទុកនៅតាមសហគមន៍មូលដ្ឋាន ។ ធ្វើយ៉ាងនេះ ព្រៃឈើអាចដុះដាលឡើងវិញ (ដែលជាទិសដៅចម្បងនៃការបង្កើតព្រៃសហគមន៍) ហើយទន្ទឹមនឹងនេះដែរ សហគមន៍ក៏មានប្រាក់ចំណូល ។ ដោយសារតែដំណើរកិច្ចការទាំងនេះ ស្ថិតនៅក្រោមការណែនាំរបស់អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗគ្នា ទម្រង់គ្រប់គ្រងព្រៃសហគមន៍ទាំងនេះ ក៏ខុសគ្នាពីព្រៃសហគមន៍មួយទៅសហគមន៍មួយដែរ ។

នៅដើមឆ្នាំ ២០០៦ មានការដាក់ចេញគោលការណ៍ណែនាំសម្រាប់ព្រៃសហគមន៍ ក្រោយពីច្បាប់ព្រៃឈើ ត្រូវបានអនុម័តក្នុងឆ្នាំ ២០០២ ។ ផលព្រៃឈើក្រៅពីឈើហុប (NTFP) ផ្តល់ប្រយោជន៍ខ្ពស់ជាងផលឈើហ៊ុបឆ្ងាយណាស់ ដែលជារួមមាន វាលស្មៅសម្រាប់សត្វពាហនៈ ផលបន្លែពីព្រៃឈើសម្រាប់អាហារ ផ្លែឈើ និងមើមឈើ រុក្ខជាតិជាថ្នាំព្យាបាល ផ្តៅសម្រាប់ធ្វើកញ្ច្រែង និងអុសដុត ។ ក្រុមព្រៃសហគមន៍ មានអាណត្តិគ្រប់គ្រង ១៥ ឆ្នាំ ។

ព្រៃសហគមន៍ភាគច្រើនស្ថិតនៅលើតំបន់ព្រៃខូចគុណភាព ។ ដូច្នេះបើចង់ឱ្យសកម្មភាពសហគមន៍ព្រៃឈើមានចីរភាពល្អ នោះចាំបាច់ត្រូវចាយវាយលើអង្គការចាត់តាំងនៃសហគមន៍ព្រៃឈើ ។ ក្នុងស្ថានភាពបច្ចុប្បន្ននេះ ដោយសារសិទ្ធិកាន់កាប់ដីធ្លីមិនមានការធានាត្រឹមត្រូវ ហើយដោយសារព្រៃដែលឱ្យសហគមន៍គ្រប់គ្រងភាគច្រើនជាព្រៃខូចគុណភាព ការបង្កើតប្រព័ន្ធគ្រប់គ្រងព្រៃឈើដោយចីរភាពនៅតាមសហគមន៍ មិនអាចសម្រេចជោគជ័យទេ ។ បញ្ហាឯទៀតៗ រួមមាន ភាពមិនទៀតទាត់នៃសិទ្ធិលក់ផលព្រៃឈើ តម្លៃដឹកជញ្ជូនផលព្រៃឈើថ្លៃពេក ថ្លៃផលិតមានកម្រិតខ្ពស់ ហើយកង្វះយន្តការត្រួតពិនិត្យច្បាស់លាស់ ។ ចំណុចខ្វះខាតអស់ទាំងនេះ ត្រូវតែដោះស្រាយនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីលើកកម្លាំងចិត្តប្រជាពលរដ្ឋមូលដ្ឋាន ។

នៅតំបន់ដទៃទៀតដែលមិនមានព្រៃសម្បទាននៅជិតព្រៃសហគមន៍ បានទាក់ទាញការយកចិត្តទុកដាក់ពីក្រុមអ្នកកាន់សាសនា ។ ព្រះសង្ឃបាននាំមុខក្នុងការថែរក្សាតំបន់ព្រៃភ្នំនៅជុំវិញទន្លេសាប (ឧទាហរណ៍ នៅឃុំ ភូ ស្រុកកំពង់លែង ជាដើម) ។ ព្រះសង្ឃបានដាំកូនឈើក្នុងទំហំដីយ៉ាងធំទូលាយ ហើយបានរៀបចំឱ្យមានការឃាមកាមពីសំណាក់អ្នកភូមិនៅទីនោះ ។ មានគតិបណ្ឌិតបុរាណមួយថែងថា "ប្រសិនបើដូនតាយើងមិនបានការពារព្រៃឈើទេនោះ សព្វថ្ងៃនេះ ពួកយើងប្រាកដជាមិនមានព្រៃឈើឡើយ" ។ គតិបណ្ឌិតនេះ បានធ្វើឱ្យប្រជាពលរដ្ឋក្នុងសហគមន៍យកចិត្តទុកដាក់ការពារព្រៃឈើអស់ទាំងនោះ ។

*ប្រភព ៖ Heov, Khlok, Hansen និង Sloth (២០០៦); Ty, Sokh និង Lao (២០០៦); Sokh និង Ty (២០០៥); ការសង្កេតដល់មូលដ្ឋាន ៖ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។*

## *សារគន្លឹះ ៖*

*សិទ្ធិតាមប្រពៃណីរបស់ជនជាតិដើមភាគតិច ដែលពឹងផ្អែកលើព្រៃឈើត្រូវតែលើកស្ទួយឡើងវិញ ដើម្បីបញ្ចៀសកុំឱ្យវិបត្តិជីវភាពរស់នៅកាន់តែធ្ងន់ធ្ងរឡើង ។ ទៅអនាគតដ៏យូរលង់ ចាំបាច់ត្រូវតែជម្រុញឱ្យមានការបែទៅរកជីវភាពរស់នៅដែលប្រកបដោយផលកម្រៃខ្ពស់ និងមានចីរភាព ។*

*កសិករជាច្រើន ជាញឹកញាប់ គឺអ្នកដែលងាយរងគ្រោះ-ត្រូវជាប់បំណុល ក្លាយជាអ្នកគ្មានដី ឬប្រឈមមុខនឹងវិបត្តិជីវភាព*

## ៣.៧ សេចក្តីសរុប

ដីដាំដំណាំមានតែមួយផ្នែកតូចទេ ( គឺ ២២% នៃដីទាំងអស់ ) ។ ដីដទៃទៀតជាដីព្រៃ ទន្លេ ស្ទឹង បឹងបួរ និងដី សម្រាប់ភូមិដ្ឋានជនបទ និងទីប្រជុំជន ។

- ដីកសិកម្មជាច្រើន ជាពិសេស នៅតាមដងទន្លេ និងបឹង គឺជាដីមានជីជាតិ ប៉ុន្តែដីនៅកន្លែងខ្លះទៀតដែលមិននៅជិតទន្លេ ឬជិតបឹង មិនសូវមានជីជាតិល្អទេ ។ ដីកសិកម្មទាំងនោះ ជាទូទៅ មានទំហំតូចៗ ។ នេះ គឺដោយសារធ្លាប់មាននៅក្នុងប្រព័ន្ធកសិកម្មតាំងពីដើមមក ហើយសព្វថ្ងៃនេះ ដីទាំងនេះ ត្រូវលក់ ឬត្រូវចែកជាដុំតូចៗឱ្យទៅកូនចៅ ។ ថ្វីត្បិតតែដីកសិកម្មតូចៗ ត្រូវបានគេចូលចិត្តដោយសារមានផលិតភាពខ្ពស់ និងមានគុណភាពក៏ដោយ អ្នកដែលជាម្ចាស់ដីកសិកម្មតូចៗពេក មិនអាចផលិតបានគ្រប់គ្រាន់សម្រាប់ជីវភាពរស់នៅឡើយ ។

- ការលេចឡើងនៃសេដ្ឋកិច្ចទីផ្សារ ដែលភាគច្រើនមិនមានការគ្រប់គ្រងការកើនឡើងយ៉ាងរហ័សនៃប្រជាពលរដ្ឋ ការមិនមានអភិបាលកិច្ចដីធ្លីគ្រប់គ្រាន់ និងអវត្តមានស្ថាប័នពាណិជ្ជកម្ម កសិករជាច្រើន ជាញឹកញាប់ គឺអ្នកដែលងាយរងគ្រោះ ត្រូវជាប់បំណុល ក្លាយជាអ្នកគ្មានដី ឬប្រឈមមុខនឹងវិបត្តិជីវភាព ។ អ្នកភូមិជាច្រើនជួប និងបញ្ហាធំពាក់ព័ន្ធនឹងសុខភាព ។ ការមិនមានសេវារក្សាសុខភាពដែលមានតម្លៃថោក បានបង្ខំចិត្តអ្នកស្រុកអ្នកភូមិឱ្យលក់ដីធ្លីរបស់ខ្លួន ដើម្បីបង់ថ្លៃរក្សាសុខភាពដែលមានតម្លៃខ្ពស់ ។ ដោយសារកត្តាអស់ទាំងនេះហើយ បានជាជីវភាពរស់នៅរបស់កសិករតូចតាចមានភាពមិនទៀងទាត់ ដែលជាកត្តានាំឱ្យពួកគេងាយធ្លាក់ចូលទៅក្នុងអន្ទាក់នៃភាពក្រីក្រ ។

- ដីទំហំធំៗជាច្រើនអាចជាប់នៅក្នុងដីសម្បទានសេដ្ឋកិច្ចដែលអត់ប្រើប្រាស់ ។ នេះជាការខាតបង់យ៉ាងធំលើសុខុមាលភាពប្រជាពលរដ្ឋ និងសេដ្ឋកិច្ចច្រើនប្រភេទ ។

- នៅក្នុងច្បាប់ដីធ្លីឆ្នាំ ២០០១ និងច្បាប់ដីធ្លីឆ្នាំ ២០០២ មានបញ្ញត្តិជាច្រើនទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិច ក្នុងការទទួលបានប្លង់ដីសហគមន៍ និងការប្រើប្រាស់ព្រៃឈើ ។ ទោះជាយ៉ាងនេះក្តី ការចេញប្លង់ដីឱ្យសហគមន៍នៅមិនទាន់ចាប់ផ្តើមនៅឡើយទេ ។ ទន្ទឹមនឹងនេះ តំបន់ព្រៃឈើជាច្រើនរបស់ជនជាតិដើមភាគតិច ត្រូវបានយកទៅធ្វើជាព្រៃសម្បទាន ។ អំពើទាំងពីរនេះរំលោភសិទ្ធិពួកគេ និងធ្វើឱ្យពួកគេទាំងនោះកាន់តែក្រថែមទៀត ។

- ដោយសារការនេសាទត្រីទឹកសាប ជួបប្រទះនឹងតំបន់នេសាទ ដែលមានជម្លោះរវាងអ្នកនេសាទតូចតាច និងម្ចាស់ឡូត៍នេសាទ គួរតែខំពុះពារឱ្យបានម៉ឺងម៉ាត់ ដើម្បីបង្កើតរចនាសម្ព័ន្ធសមស្របសម្រាប់គ្រប់គ្រងរួមគ្នាលើការនេសាទទាំងនោះ ។ ការបង្កើតមុខរបរច្រើនប្រភេទផ្សេងៗពីគ្នា និងអភិបាលកិច្ច ក៏អាចជួយធ្វើឱ្យចម្រើនដល់ជីវភាពប្រជាពលរដ្ឋ ។

- ការធ្វើឱ្យពលរដ្ឋកាត់បន្ថយការពឹងផ្អែកលើព្រៃឈើ គឺជាបេសកម្មមួយដ៏ធំ ។ ដើម្បីធ្វើយ៉ាងនេះបាន ត្រូវបង្កើនមុខរបរកែច្នៃផលិតផលឱ្យមានតម្លៃខ្ពស់ និងមានវិធីទាក់ទាញកម្មករ ។

- ស្ត្រីដែលមានការរួមចំណែកច្រើនទៅក្នុងការផលិតផ្សេងៗ ក៏នៅមិនទាន់បានរាប់បញ្ចូលទៅក្នុងក្រុមអ្នកធ្វើសេចក្តីសម្រេចនៅឡើយដែរ ។

*រូបភាព ៣.១៤ : សេចក្តីសង្ខេបអំពីដីធ្លី ធនធានធម្មជាតិ និងជីវភាពរស់នៅតាមជនបទ*



*ប្រភព : អត្ថបទជំពូកនេះ*

# ជំពូក ៤





៤
ជំពូក

# ទំនើបកម្មបច្ចេកវិទ្យា កំណែទម្រង់ទីផ្សារ និងពិពិធកម្មក្នុងវិស័យជនបទ

ដើម្បីបង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន កសិកម្មកម្ពុជា ព្រមទាំងសកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម ត្រូវតែពង្រីកផលិតភាពរបស់ខ្លួន។ នៅកម្ពុជា ប្រព័ន្ធកសិកម្ម និងប្រព័ន្ធផលិតកម្មភាគច្រើន នៅមិនទាន់ជឿនលឿននៅឡើយទេ។ ជំពូក ៣ មានចំណាប់អារម្មណ៍ថា នៅក្នុងស្ថានការណ៍ជាច្រើន កសិករមិនអាចរក្សាទុកដីរបស់ខ្លួនតទៅទៀតបានទេ ដោយសារដីតូចៗទាំងនោះ មានកម្រិតផលិតកម្មទាបពេក ហើយឥណទានមានការប្រាក់ថ្លៃពេក។ ដូច្នេះចាំបាច់ត្រូវធ្វើអន្តរាគមន៍ ដើម្បីលើកស្ទួយការអនុវត្តបច្ចេកវិទ្យាកសិកម្មទំនើប និងកែទម្រង់ទីផ្សារ។

*រូបភាព ៤.១ : អត្រាកំណើនតាមផ្នែក-សកម្មភាពកសិកម្ម និងសកម្មភាពដទៃទៀតដែលពាក់ព័ន្ធ (ក្នុងតម្លៃ ២០០០៖) ឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៥*




*ប្រភព :* http://www.nis.gov.kh

អត្រាកំណើននៅក្នុងវិស័យកសិកម្ម (ផលដំណាំ ព្រៃឈើ នេសាទ និងចិញ្ចឹមសត្វ) គឺ ៣,៧៦ ភាគរយ ចាប់ពីឆ្នាំ ១៩៩៣ ដល់ ២០០៥ (រូបភាព៤.១)។ក្នុងរយៈពេលដដែលនេះ ចំណូលជាតិបានកើនក្នុងអត្រា ៧-៨ ភាគរយ។វិស័យដាំដុះបានកើនច្រើន ពោលគឺ ៥,៩៥ ភាគរយជាកំណើនមធ្យមប្រចាំឆ្នាំ ដោយមានកំណើនខ្ពស់ ក្នុងឆ្នាំ ២០០៥ ពេលដែលផលិតផលស្រូវឡើងដល់ ៤៤ ភាគរយ រីឯផ្នែកដទៃទៀតក៏មានការរីកចម្រើនដែរ តែមិនសូវច្រើនដូចកំណើនស្រូវនៅក្នុងឆ្នាំនោះទេ (ការចិញ្ចឹមសត្វ ១,៩៦ ភាគរយ នេសាទ ២,៩៩ ភាគរយ ព្រៃឈើថយចុះ -0,0៩ ភាគរយ នៃកំណើនមធ្យមភាគប្រចាំឆ្នាំ)។ ដោយសារតែកម្លាំងពលកម្មជាង ៧0 ភាគរយ នៅតែបន្តសកម្មភាពក្នុងផលិតកម្មដែលមានកំណើនយឺត ជាពិសេស នៅទីជនបទ។ នៅទីជនបទប្រយោជន៍ពីអត្រាកំណើនខ្ពស់នៃសេដ្ឋកិច្ចជាតិមានកម្រិតទាបជាងនៅទីប្រជុំជន[៤៩]។

ការបង្កើនប្រាក់ចំណូលពីវិស័យកសិកម្មគឺជាអាទិភាពមួយនៃយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ (NSDP)។ ដើម្បីសម្រេចបានតាមទិសដៅនេះ គោលនយោបាយសាធារណៈត្រូវដោះស្រាយបញ្ហាចម្បង ២ គឺកម្រិតនៃសេចក្តីត្រូវការ និងកម្រិតលទ្ធភាពដែលអាចផលិតជូនទីផ្សារ ដូចដែលបានពណ៌នានៅក្នុងជំពូកនេះ។ បែបបទដំណោះស្រាយក្នុងការបង្កើនផលិតផលកសិកម្មបានពិភាក្សានៅក្នុងផ្នែកនានាដូចតទៅនេះ (១) លើកកម្ពស់ការប្រើប្រាស់ដី និងលទ្ធភាពផលិតរបស់ដី ដោយប្រើសម្ភារៈបរិក្ខារកសិកម្មទំនើប (២) ប្រើប្រាស់ទឹក ដែលមានស្រាប់ឱ្យកាន់តែច្រើនសម្រាប់ប្រព័ន្ធស្រោចស្រព (៣) បង្កើតឥណទានដែលមានការប្រាក់ទាបសម្រាប់ប្រជាពលរដ្ឋជនបទ (៤) ធានាលំនឹងតម្លៃលក់ផលិតផលកសិកម្ម។

នៅក្នុងសកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្មមាន (៥) នេសាទត្រី និងចិញ្ចឹមសត្វ (៦) សិប្បកម្មកែច្នៃ និងសិប្បកម្មតាមទីជនបទ អាចជាវិសាលភាពបង្កើនប្រាក់ចំណូលនៅជនបទ។

៤
ជំពូក

## ៤.១ ការលើកកម្ពស់ការប្រើប្រាស់ដីឱ្យកាន់តែប្រសើរឡើង ដោយប្រើសម្ភារៈបរិក្ខារកសិកម្មទំនើប

កសិកម្មកម្ពុជាកំពុងតែប្រែក្លាយជាកសិកម្មទំនើបបណ្តើរៗ តាមរយៈការប្រើជីគីមី និងគ្រាប់ពូជ ដែលផ្តល់ទិន្នផលខ្ពស់ ជាពិសេសនៅវាលទំនាបទន្លេមេគង្គ និងនៅផ្នែកខ្លះនៃភូមិភាគពាយ័ព្យ ។ នៅខេត្តបាត់ដំបងមានផ្តើមប្រើប្រាស់គ្រឿងចក្រសម្រាប់ធ្វើកសិកម្មហើយ ។ ជាលទ្ធផល ក្នុងអំឡុងទសវត្សរ៍ចុងក្រោយ ផលិតផលដែលកើនខ្លាំងសម្រាប់ទីផ្សារ គឺផលិតផលស្រូវដែលដាំនៅតំបន់វាលទំនាបសំខាន់ៗ ។

*អាត្រានៃការប្រើជីទំនើប និងប្រភេទគ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់នៅកម្ពុជា នៅទាបជាងគេបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍*

***រូបភាព ៤.២ : អត្រាទិន្នផលស្រូវ (ជាតោនក្នុងមួយហិចតា ឆ្នាំ ២០០៤)***
***ទិន្នន័យពីផលិតករ និងអ្នកលក់ស្រូវចេញមួយចំនួនដែលយើងបានជ្រើសរើស***



*ប្រភព : FAOSTAT (http://faostat.fao.org/default.aspx )*

ប៉ុន្តែទោះជាយ៉ាងនេះក្តី ក្នុងការប្រើសម្ភារៈបរិក្ខារកសិកម្មទំនើបនេះ នៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើ ។ នៅកម្ពុជាអាត្រាប្រើជីទំនើប និងប្រភេទគ្រាប់ពូជ ដែលផ្តល់ទិន្នផលខ្ពស់នៅទាបជាងគេបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ប្រទេសឡាវ និងប្រទេសថៃ ប្រើជីក្នុងមួយហិចតាលើសប្រទេសខ្មែរបីដង រីឯប្រទេសវៀតណាម ប្រើជីលើសប្រទេសខ្មែរ ៦ ដង។ នៅឆ្នាំ ២០០៥ ទិន្នផលស្រូវមានចំនួន ២,៣៥ តោន ក្នុងមួយហិចតា ប៉ុន្តែមធ្យមភាគនៃទិន្នផល ៣ ឆ្នាំ សម្រាប់ឆ្នាំ ២០០៣ ទៅ ២០០៥ នៅទាបជាង គឺចំនួន ២,១៨តោនក្នុងមួយហិចតា។ អាត្រាទិន្នផលស្រូវនៅប្រទេសឯទៀតៗ ដែលផលិតស្រូវ និងលក់ស្រូវចេញ មានកម្រិតខ្ពស់ជាងឆ្ងាយណាស់ (រូបភាព៤.២) ។ ក្នុងពីរទសវត្សរ៍កន្លងមក ផលិតផលមួយផ្នែកធំដែលទទួលបាន គឺបានមកពីការពង្រីកដីធ្វើកសិកម្ម មិនមែនដោយសារការបង្កើនទិន្នផលទេ។ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៨០ មក ដីធ្វើកសិកម្មត្រូវបានប៉ាន់ប្រមាណថា កើនឡើងចំនួន ១ ភាគរយក្នុងមួយឆ្នាំ។[៥០] ។

(៤៩) ថ្មីៗនេះ កម្រងទិន្នន័យបានប្រែប្រួលច្រើនជាងមួយលើក ដោយសារមានទិន្នន័យថ្មីពីកន្លែងផ្សេងៗថែមទៀត ។ ដូច្នេះមិនគួរពឹងផ្អែកទៅលើតែតួលេខនៃអត្រាកំណើនច្រើនពេកទេ ។

(៥០) ធនាគារពិភពលោក (២០០៦) ទំព័រ ៦០ ។

*អត្រាទិន្នផលស្រូវក្នុងស្រែដែលប្រើប្រព័ន្ធប្រពលវប្បកម្មនេះ-បានកើនឡើងពី ៣,៥ ទៅ ៤ តោន ក្នុងមួយហិចតា លើសពីទិន្នផលជាមធ្យម ដែលមានចំនួន ២,២ តោន ក្នុងមួយហិចតា ដោយមិនមានចំណាយលុយបន្ថែមអ្វីទាល់តែសោះ*

*ចំណុច ៤ប្រការ ដែលគួរយកចិត្តទុកដាក់ :*

## កាត់បន្ថយថ្លៃដើមផលិត

សម្ភារៈបរិក្ខាកសិកម្មទំនើបមានតម្លៃថ្លៃពេក។ ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ជី និងប្រេងឥន្ធនៈ បានឡើងថ្លៃជាបន្តបន្ទាប់លើសពីពេលណាៗទាំងអស់ ប៉ុន្តែតម្លៃផលិតផលកសិកម្មមិនបានឡើងច្រើនដូចគ្នាទេ (រូបភាព ៤.៣)។ ប្រសិនបើមិនមានការបង្កើនផលិតផលលើវិស័យឯទៀតៗជាជំនួសទេ អនុបាតនៃតម្លៃទិញសម្ភារៈបរិក្ខា កសិកម្ម និងតម្លៃលក់ចេញ ដែលខុសគ្នាយ៉ាងខ្លាំងនេះ នឹងបណ្ដាលឱ្យកសិករបាត់បង់ផលចំណេញយ៉ាងច្រើន។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ រដ្ឋាភិបាលបានជួយផ្ដល់ជីជូនកសិករ។ ជំនួយឧបត្ថម្ភនេះបានត្រូវបញ្ចប់ក្នុង ឆ្នាំ១៩៩៧ ហើយ ឈ្មួញឯកជនចាប់ផ្ដើមលក់ជីជាជំនួសវិញ។ ការឈប់ផ្ដល់ជំនួយបន្ថែម និងឯកជនភាវូបនីយកម្ម អាចជួយឱ្យមានប្រសិទ្ធភាពខ្ពស់ និងជួយបង្កើនសុខុមាលភាពសង្គម។ ប៉ុន្តែផ្ទុយទៅវិញ ការធ្លាក់ចុះភ្លាមៗនៃតម្លៃលក់ផលិតផលកសិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ប្រាក់ចំណូលរបស់កសិករ។ ដូច្នេះលទ្ធភាពដំណោះស្រាយបញ្ហាតម្លៃខ្ពស់នៃសម្ភារៈបរិក្ខារកសិកម្ម មានដូចតទៅនេះ:

ក. ត្រូវទិញជីជាតម្លៃដុំពីប្រភពណាដែលលក់ថោកជាងគេ

ខ. ត្រូវប្រើជីលាមកសត្វ ដែលមានស្រាប់នៅក្នុងកសិដ្ឋានជំនួសជីគីមី

គ. ត្រូវលុបបំបាត់ ឬកាត់បន្ថយឱ្យទាបបំផុតនូវការបង់លុយក្រៅផ្លូវការលើការដឹកជញ្ជូនទំនិញកសិផល

ឃ. ត្រូវផ្ដល់សេវាទ្រទ្រង់កសិកម្មកម្រិតខ្ពស់ ដើម្បីប្រើប្រាស់សម្ភារៈបរិក្ខាកសិកម្មឱ្យបានច្រើនបំផុត។




***រូបភាព ៤.៣ : ចលនាតម្លៃផលិតផលកសិកម្មផ្សេងៗ និងតម្លៃប្រេងម៉ាស៊ូត និងជីអ៊ុយរ៉េ***

*ប្រភព : ក្រសួងកសិកម្ម (ទិន្នន័យដើម) EIC (២០០៦)*

## ដោះស្រាយបញ្ហាដីខ្ទះជីជាតិ

ព្រៃឈើត្រូវបានកាប់រំលំដើម្បីយកដីដាំដំណាំ។ ព្រៃឈើលូតលាស់បានល្អ ដោយសារមានរុក្ខជាតិផ្សេងៗ និងពពួកសត្វល្អិតច្រើនប្រភេទរស់នៅជាទីពឹងពំនាក់គ្នាទៅវិញទៅមក ព្រមទាំងមានសមត្ថភាពរក្សាជាតិទឹកនៅក្នុងប្រព័ន្ធជីវសាស្ត្រ។ ប៉ុន្តែដីដែលនៅពីក្រោមព្រៃឈើទាំងនោះ មិនមានជីជាតិគ្រប់គ្រាន់ទេ ដោយសារជីជាតិទាំងនោះ ស្ថិតនៅក្នុងកម្ទេចកម្ទីរុក្ខជាតិ ដែលត្រូវបានបំផ្លាញចោលជាមួយនឹងការកាប់រំលំព្រៃឈើ។ ដីដែលកាប់រំលើងព្រៃឈើថ្មីៗនេះ ជាញឹកញាប់ មិនមានជីជាតិគ្រប់គ្រាន់សម្រាប់ដាំដំណាំតែមួយមុខបានទេ។ មូលហេតុចម្បងដែលបណ្ដាលឱ្យកសិករធ្លាក់ខ្លួនក្រ និងជាប់បំណុលគេ គឺដោយសារកសិកម្មនៅតំបន់ទាំងនោះផ្ដល់នូវទិន្នផលទាបហើយការខូចខាតផលកសិកម្មមានច្រើន។ ភាគច្រើននៃដីកសិកម្មទាំងអស់នេះ ទាមទារឱ្យមានការស្ដារគុណភាព រីឯដីនៅកន្លែងឯទៀតយ៉ាងហោចណាស់ ក៏សម្រាប់រយៈពេលខ្លី គឺជាដីដែលត្រូវដាំដំណាំយកផ្លែ (ដូចជា ដូងប្រេង ល្ហុង ចេក ជាដើម )មិនត្រូវដាំដំណាំប្រចាំរដូវទេ។

### ប្រអប់ ៤.១ :  ប្រព័ន្ធប្រពលវប្បកម្មស្រូវនៅកម្ពុជា  (SRI)



រាជរដ្ឋាភិបាលបានដាក់បញ្ចូលការលើកកម្ពស់ប្រព័ន្ធប្រពលវប្បកម្មស្រូវ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់ឆ្នាំ ២០០៦-២០១០ ដោយយោងទៅលើផលប្រយោជន៍ជាច្រើន ដែលប្រព័ន្ធនេះបានបង្ហាញឱ្យឃើញនៅក្នុងវិស័យកសិកម្មពោលគឺការលើកកម្ពស់ទិន្នផលស្រូវការបង្កើនមុខផលដំណាំ (ដែលអាចធ្វើបានដោយដីមានផលិតភាពខ្ពស់) ការប្រើជីកំប៉ុសធ្វើឱ្យដីមានជីជាតិល្អ (ប្រព័ន្ធប្រពលវប្បកម្មស្រូវប្រើជីលាមកសត្វ) និងការចិញ្ចឹមត្រី (ប្រព័ន្ធនេះបើកលទ្ធភាពឱ្យមានដីនៅទំនេរសម្រាប់ជីកស្រះចិញ្ចឹមត្រី)។ រដ្ឋមន្ត្រីក្រសួងកសិកម្ម និងរដ្ឋមន្ត្រីក្រសួងបរិស្ថានបានយកចិត្តទុកដាក់ផ្ទាល់ក្នុងការជម្រុញប្រព័ន្ធប្រពលវប្បកម្មនេះ។ កសិករម្នាក់បានទទួលរង្វាន់ជ័យលាភី ដោយសារគាត់សម្រេចបានទិន្នផលខ្ពស់បំផុតពីការប្រើប្រាស់ប្រព័ន្ធប្រពលវប្បកម្មក្នុងកម្រិតទិន្នផលមធ្យម ១៤.៦ តោន ក្នុងមួយហិចតា ដោយបានផលស្រូវក្នុងមួយម៉ែត្រការេ ២ គីឡូក្រាម (ស្មើនឹង ២០ តោន ក្នុងមួយហិចតា)។ នៅក្នុងស្រែដែលប្រើប្រព័ន្ធ (SRI) ផលិតផលស្រូវមានចំនួនពី ៣,៥ ទៅ ៤ តោន ក្នុងមួយហិចតា ប្រៀបធៀបទៅនឹងទិន្នផលធម្មតាពី ១,៥ ទៅ ២ តោន ក្នុងមួយហិចតា យោងតាមព័ត៌មានពីអង្គការ CEDAC ដែលជាអង្គការជម្រុញប្រព័ន្ធប្រពលវប្បកម្មស្រូវ។ ឥឡូវនេះ កសិករកំពុងតែកែលម្អរបៀបធ្វើស្រែរបស់ខ្លួន ដោយយកតាមប្រព័ន្ធប្រពលវប្បកម្មស្រូវនេះ ដើម្បីបង្កើនផលិតផលសម្រាប់ឱ្យមានប្រាក់ចំណូលច្រើន និងមានគុណភាពអាហារូបត្ថម្ភល្អជាងមុន។

ប្រព័ន្ធនេះប្រើជីគីមីតិច ហើយត្រូវការជីធម្មជាតិច្រើនជាង។ ធ្វើយ៉ាងនេះអាចជួយកាត់បន្ថយការចំណាយសម្រាប់ដាំដុះ ដោយសារជីកំប៉ុសអាចធ្វើបាននៅតាមផ្ទះកសិករនានា ដែលមានចិញ្ចឹមគោក្របីសម្រាប់ប្រើក្នុងប្រព័ន្ធកសិកម្មរបស់ពួកគេ។

*ប្រភព :* *http://ciifad.cornell.edu/sri/countries/cambodia/index.html*

## *រៀនប្រើបច្ចេកវិជ្ជាថ្មីប្រឌិតបែបថ្មី*

ក្នុងការដាំស្រូវ មានបច្ចេកវិជ្ជាថ្មីៗជាច្រើន រួមទាំងប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ផង[៥១]។ ប្រព័ន្ធ SRI នេះ ជារបៀបដាំស្រូវងាយស្រួល អស់តម្លៃតិច ប៉ុន្តែផ្តល់ទិន្នផលខ្ពស់។ របៀបដែលត្រូវធ្វើ គឺត្រូវស្ទូងសំណាបតែមួយដើមក្នុងចន្លោះស្មើៗគ្នា លើដីស្ងួតល្មម ដែលជារបៀបផ្ទុយពីទម្លាប់ធម្មតា ដែលស្ទូងស្រូវមួយដំណោតក្នុងដីដែលមានទឹក ហើយត្រូវបោចស្មៅក្នុងស្រែជាប្រចាំថែមទៀត។ វិធីនេះត្រូវប្រើជីលាមកសត្វជំនួសជីគីមី ដែលជាការជួយកាត់បន្ថយប្រាក់ចំណាយ (រូបភាព ៤.១)។ អត្រាទិន្នផលស្រូវក្នុងស្រែដែលប្រើប្រព័ន្ធប្រពលវប្បកម្មនេះ នៅកម្ពុជាលើដីទំហំប្រហែល ៨ ម៉ឺនហិចតា ក្នុងឆ្នាំ ២០០៥ កើនលើសពី ៣,៥ ទៅ ៤ តោន ក្នុងមួយហិចតា ច្រើនជាងទិន្នផលមធ្យមនៅក្នុងប្រទេស ដែលមានចំនួនតែ ២.២ តោន ក្នុងមួយហិចតា ដោយមិនចាំបាច់ចាយលុយបន្ថែមអ្វីទាល់តែសោះ។ ភ្នាក់ងារកសិកម្មដែលមានភារកិច្ចបណ្តុះបណ្តាលកសិករ អាចជួយពង្រីកទំហំដីដាំស្រូវតាមប្រព័ន្ធ SRI នេះ ឱ្យបានច្រើនលើសពីទំហំបច្ចុប្បន្ន ដែលមានតែ ៣ ភាគរយ នៃដីកសិកម្មទាំងអស់។

## *ដាំដំណាំច្រើនមុខ*

ដីដាំដំណាំជាង ៩០ ភាគរយ គឺជាដីដំណាំស្រូវ ថ្វីត្បិតតែប្រទេសកម្ពុជាមានធាតុអាកាសសមស្របសម្រាប់ដំណាំផ្សេងៗទៀតជាច្រើនមុខក៏ដោយ ដូចជា ពោត សណ្តែកសៀង ដំឡូងមី និងពពួកសណ្តែកផ្សេងៗ រួមទាំងបន្លែបង្ការ និងដើមឈើយកផ្លែជាដើមផង។ នៅពេលមួយកន្លងមក ប្រទេសកម្ពុជាក៏បានដាំដំណាំកប្បាសដែរ (នៅខេត្តកំពង់ចាម និងក្រុងព្រះសីហនុ)។

*ឧទាហរណ៍នៃការបង់ខាតដោយសារដាំដំណាំតែមួយមុខ :* ផ្នែករោងចក្រកាត់ដេរមិនបានប្រើប្រាស់ផលដំណាំកប្បាសស្រុកខ្មែរទេ ដោយសារស្រុកខ្មែរឈប់ដាំកប្បាសប្រហែលជាង ៥ ទសវត្សរ៍កន្លងមកហើយ រីឯផ្នែកទេសចរណ៍វិញ ក៏ពុំបានប្រើផលិតផលចំណីអាហារដែលដាំដុះនៅស្រុកខ្មែរដែរ (ផ្លែឈើ បន្លែបង្ការ និងត្រី សាច់) ផ្ទុយទៅវិញ អាហារដែលផលិតនៅប្រទេសដទៃទៀត ដែលអាចផលិតបាននៅស្រុកខ្មែរដែរ ត្រូវបានយកមកប្រើក្នុងវិស័យទេសចរណ៍[៥២]។

ការដែលមិនមានដំណាំច្រើនមុខផ្សេងៗគ្នា ប្រហែលជាដោយសារខ្លាចខាតបង់នៅពេលប្តូរទៅដាំដំណាំផ្សេងវិញ។ ក្នុងចំណោមបញ្ហាដែលកសិករម្នាក់ៗខ្លាចមិនហ៊ានដាំដំណាំផ្សេងៗទៀតនោះ គឺដោយសារនៅតាមកសិដ្ឋានភាគច្រើន ផលដំណាំផ្សេងទៀតមិនមានច្រើនគ្រប់ចំនួន ដើម្បីទាក់ទាញឈ្មួញដទៃទៀតឱ្យចូលមកទិញ ក្រៅតែពីឈ្មួញដែលទិញតែស្រូវ។ ក្រៅពីស្រូវ ការមិនមានផលដំណាំផ្សេងៗទៀតគ្រប់គ្រាន់ គឺជាឧបសគ្គរារាំងមិនឱ្យវិស័យកសិឧស្សាហកម្មលូតលាស់បាន ដើម្បីផលិតម្ហូបអាហារចេញពីកសិផលខ្មែរ។ អ្វីដែលត្រូវការជាចាំបាច់នោះ គឺកសិករត្រូវរួមកម្លាំងគ្នាឱ្យបានច្រើន ហើយនាំគ្នាដាំដំណាំផ្សេងៗជាច្រើនមុខទាំងអស់គ្នា។ ធ្វើយ៉ាងនេះទៅកើត ទាល់តែផ្សព្វផ្សាយដល់ស្រទាប់មហាជន អំពីវិធីដាំដំណាំបែបជាប្រព័ន្ធកសិកម្មទំនើប និងវិធីទ្រទ្រង់បច្ចេកទេសកសិកម្ម (ប្រអប់លេខ ៤.២ ៤.៣ ៤.៤)។

---

*(៥១)  ប្រព័ន្ធប្រពលវប្បកម្មស្រូវ SRI ល្បីល្បាញហើយ ប៉ុន្តែក៏នៅមានប្រព័ន្ធផ្សេងៗទៀតដែរ។ សូមមើល (២០០១)។*

## *វិធីដាំដំណាំតាមប្រព័ន្ធកសិកម្មចម្រុះ*

នេះជាវិធីមួយដែលមានដាំដំណាំហូបផ្លែចម្រុះជាមួយដំណាំប្រចាំរដូវផង ជាមួយគ្នានឹងចិញ្ចឹមសត្វពាហនៈ និងចិញ្ចឹមត្រីក្នុងស្រះនៅក្នុងកសិដ្ឋាន ឬក្នុងដីស្រែលិចទឹកផង ដែលត្រូវមានផែនការច្បាស់លាស់ជាមុននៅក្នុង គ្រួសារកសិករ ។ វិធីនេះស្របទៅនឹងលក្ខខណ្ឌកសិដ្ឋាននៅប្រទេសកម្ពុជា ទោះបីជាសម្រាប់កសិករតូចតាចៗក៏ដោយ ព្រោះវាជួយឱ្យមានប្រាក់ចំណូលបន្ថែម ជួយការពារប្រព័ន្ធជីវសាស្ត្រ និងជួយការពារកសិករទប់ទល់នឹងគ្រោះកាចធម្មជាតិ ឬការធ្លាក់តម្លៃ ។

វិធីដាំដុះតាមប្រព័ន្ធកសិកម្មទំនើបនៅក្នុងកសិដ្ឋានតូចៗ ក៏បានផលល្អដែរ ។ ឧទាហរណ៍ ៖ ដោយមានការជួយជ្រោមជ្រែងពីអង្គការមិនមែនរដ្ឋាភិបាលមួយ កសិករនៅតំបន់ព្រៃក្នុងខេត្តពោធិ៍សាត់បានដាំដុះតាមប្រព័ន្ធប្រពលវប្បកម្មលើការដាំកូនឈើ និងដាំបន្លែ រួមទាំងបង្កាត់ពូជជ្រូក និងមាន់ ។ កសិករម្នាក់ៗមានដីមិនលើសពី ១ ហិចតា ទេ ។

### ប្រអប់ ៤.២ ៖ ជោគជ័យពីការដាំដំណាំច្រើនមុខនៅក្នុងកសិដ្ឋានកម្ពុជាមួយ

អ្នកប្រកបរបរក្នុងវិស័យកសិកម្មជាច្រើន កំពុងមើលឃើញសក្តានុពលល្អក្នុងការដាំដំណាំផ្សេងៗសម្រាប់ជាអាហារ ជាជាងដាំតែស្រូវមួយមុខ ។ នៅឆ្នាំ ២000 កសិករម្នាក់ នៅចម្ងាយពីរ-បីគីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ បានដាំដំណាំផ្សេងៗក្នុងចំការតែ 0,៥ ហិចតា ។ ក្នុងអំឡុងពេលតែមួយឆ្នាំ គាត់អាចលក់ដំណាំគាត់បាន ៤,៧ លានរៀល ហើយចំនួននេះបានកើនឡើងបីដងក្នុងរយៈពេលបីឆ្នាំ ដោយគាត់រកបានដីដាំដំណាំបន្ថែមទៀត ។

ហេតុដែលគាត់បានជោគជ័យ គឺដោយសារគាត់មើលឃើញថា ទីផ្សារត្រូវការផលដំណាំក្រៅពីស្រូវនៅក្នុងដំណាក់កាលដែលមានមនុស្សកាន់តែច្រើនចូលទៅនៅទីក្រុង ហើយសេចក្តីត្រូវការផលបន្លែបង្កា និងផលម្ហូបអាហារ ក៏កាន់តែកើនឡើងដែរ ។ កសិករច្រើនទៀតក៏ដូចគាត់ដែរ គឺគេប្រើបណ្តាញក្នុងសង្គម ដើម្បីនាំផលដំណាំទៅទីផ្សារនៅក្រុងធំៗ ដែលក្លាយជាការចាំបាច់នៅពេលមិនទាន់មានស្ថាប័នដែលជាយន្តការទ្រទ្រង់វិស័យនេះ ។

កសិកររូបនេះ បានរៀនដាំបន្លែពីអង្គការមិនមែនរដ្ឋាភិបាលមួយ ។ គាត់យល់ថា ដើម្បីផ្សព្វផ្សាយបច្ចេកវិជ្ជាកសិកម្ម (ពិសេស ជី គ្រាប់ពូជ និងថ្នាំកំចាត់សត្វល្អិត) ឱ្យបានទូលំទូលាយ ត្រូវផ្តើមពីប្រភពស្ថាប័ននៅក្នុងប្រទេស ។ បន្ទាប់មក ការផ្សព្វផ្សាយនេះ គួរតែបន្តជាលំដាប់ ។ កសិកររូបនេះដឹងដែរ អំពីបច្ចេកវិទ្យាទំនើប ដើម្បីបង្កើនទិន្នផល ប៉ុន្តែគាត់យល់ថា គាត់នៅខ្វះបច្ចេកទេស និងខ្វះថវិកា ដើម្បីអាចប្រើបច្ចេកវិទ្យានេះទាំងមូលបាន ដូច្នេះគាត់អនុវត្តតែចំណុចខ្លះប៉ុណ្ណោះ ។

ក្នុងការអនុវត្តនេះ គាត់មានដើមទុនសម្រាប់សម្ភារៈចាំបាច់ ដោយមិនបាច់ខ្ចីប្រាក់ពីស្ថាប័ន ។ ចំពោះដើមទុនសម្រាប់ដំណើរការវិញ ជួនកាលគាត់ខ្ចីពីមិត្តភ័ក្តិខ្លះ ជារបៀបពឹងពាក់គ្នាទៅវិញទៅមកក្នុងអត្រាការប្រាក់ទាប ។ គាត់មិនសូវទៅពឹងពាក់ស្ថាប័នឥណទានខ្នាតតូចទេ ដោយហេតុថាគាត់មិនធ្លាប់ស្គាល់ ។

កសិករនេះលក់ផលដំណាំគាត់ទៅឱ្យឈ្មួញកណ្តាល ឬលក់ផ្ទាល់ទៅផ្សារតែម្តង ។ នៅរដូវប្រាំង តម្លៃលក់ដូរតែងតែឡើងចុះមិនទៀងទាត់ ។ ដើម្បីទប់ទល់នឹងបញ្ហានេះ គាត់ធ្វើជ្រក់ស្ពៃ ឬប្រឡាក់អំបិល (ធ្វើតាំងឆាយ ឆៃប៉ូវ) ទុកលក់ថ្ងៃក្រោយ ។ ការរក្សាទំនាក់ទំនងល្អជាមួយឈ្មួញកណ្តាល និងជាមួយអ្នករត់ម៉ូតូឌុប គឺជាការសំខាន់ក្នុងមុខរបរលក់ដូរផលដំណាំគាត់ ។ គាត់បានរាយការណ៍ថា ការនាំផលដំណាំទៅលក់នៅផ្សារត្រូវបង់ប្រាក់ក្រៅផ្លូវការគួរឱ្យធុញទ្រាន់បំផុត ។

ការបន្តគំនិតច្នៃប្រឌិតដាំដំណាំច្រើនមុខ គឺជាគន្លឹះនៃជោគជ័យ ។ ថ្មីៗនេះ គាត់បានចាប់ផ្តើមដាំផ្សិតថែមទៀត ។

*ប្រភព ៖ ស្រង់ចេញពីអាឆាយ៉ា គីម និងមៀច (ឆ្នាំ ២00៣)*

### *សារគន្លឹះ ៖*

*១. ដើម្បីឱ្យកសិករសម្រេចជោគជ័យក្នុងការងាររបស់ខ្លួន តម្លៃលក់ផលដំណាំ ត្រូវរក្សាឱ្យបានខ្ពស់មុនតម្លៃទិញសម្ភារៈបរិក្ខារយកមកធ្វើកសិកម្ម ។ ថ្លៃល្អប្រសើរបើការទិញសម្ភារៈជាដុំ ការប្រើលាមកសត្វជំនួសជីគីមី ការអនុវត្តប្រព័ន្ធកសិកម្មទំនើប ការដាំដំណាំច្រើនមុខផ្សេងៗពីគ្នា ការអនុវត្តរបៀបផ្លាស់ប្តូរមុខដំណាំ គឺជាជម្រើសដ៏មានសារៈសំខាន់ ។ ដើម្បីសម្រេចឱ្យបាននូវផលប្រយោជន៍អស់ទាំងនេះ ចាំបាច់ត្រូវពង្រឹងប្រព័ន្ធទ្រទ្រង់បច្ចេកទេសកសិកម្ម ។ ការជម្រុញឱ្យបង្កើតសមាគម ឬសហករណ៍តូចៗរបស់កសិករ រួមជាមួយនឹងការបង្កើតមជ្ឈមណ្ឌលទិញផលដំណាំផ្សេងៗក្រៅពីស្រូវ អាចជាការលើកទឹកចិត្តឱ្យកសិករដាំដំណាំច្រើនមុខផ្សេងៗគ្នា ។*

*២. ការសម្រេចណាដែលពាក់ព័ន្ធទៅនឹងការដាំដំណាំច្រើនមុខ ឬប្រព័ន្ធគ្រប់គ្រងកសិកម្ម ត្រូវគិតដល់សម្លេង និងសេចក្តីត្រូវការរបស់ស្ត្រី ដែលជាអ្នករួមចំណែកយ៉ាងច្រើននៅក្នុងការងារកសិកម្ម ផលិតកម្ម និងការលក់ដូរផលដំណាំកសិកម្ម ។*

*៣. ប្រទេសភាគច្រើននៅក្នុងពិភពលោក ទាំងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ ផ្តល់ជំនួយគាំទ្រវិស័យកសិកម្មរបស់គេ ប្រទេសខ្លះជួយផ្តល់ទុនត្រង់ៗតែម្តងរីឯប្រទេសដទៃទៀតផ្តល់ប្រាក់បន្ថែមលើសម្ភារៈបរិក្ខារកសិកម្ម ហើយផ្តល់សេវាបច្ចេកទេសកសិកម្មទំនើបៗឯទៀតៗ ។ គួរស្រាវជ្រាវមើលថា តើការឧបត្ថម្ភសម្ភារៈកសិកម្មបែបណាខ្លះ ដែលបានផលល្អនៅក្នុងបរិបទនៃប្រទេសកម្ពុជា ។*

---

*(៥២) សូមមើល EIC (២00៦), ទំព័រ ២១ ។*

### ប្រអប់ ៤.៣ : វិធីដាំដុះតាមប្រព័ន្ធកសិកម្មទំនើប និងយន្តការជួយទ្រទ្រង់កសិកម្ម - ពិសោធន៍ពីប្រទេសថៃ កោះតៃវ៉ាន់ ខេត្តមួយនៃប្រទេសចិនដីគោក និងវៀតណាម

ចំណេះដឹងមួយចំនួនធំក្នុងការដាំស្រូវមាននៅក្នុងវិទ្យាស្ថានអភិវឌ្ឍន៍ និងស្រាវជ្រាវកសិកម្មកម្ពុជា (CARDI) ប៉ុន្តែចំណេះអស់នេះ មិនបានចែកផ្សាយដល់កសិករទេ ។ លើសពីនេះទៀត CARDI បានធ្វើការសិក្សាស្រាវជ្រាវតែបន្តិចបន្តួចលើប្រព័ន្ធដាំដំណាំក្រៅពីស្រូវនៅតំបន់ដីខ្ពស់ ។

ស្ថានប័ននានា ដូចជា ក្រុមប្រព័ន្ធកសិកម្មក្នុងសកលវិទ្យាល័យឈៀងម៉ៃ (ប្រទេសថៃ) អាចជួយចែកចាយចំណេះដឹងយ៉ាងឆាប់រហ័សអំពីការដាំដំណាំនៅលើដីខ្ពស់ ។ កោះតៃវ៉ាន់ ដែលជាខេត្តមួយនៃប្រទេសចិន មានចំណេះដឹងផ្នែកបច្ចេកទេសដាំបន្លែបង្ការនៅក្នុងវិទ្យាស្ថាននានារបស់ខ្លួន ។ វៀតណាម មានប្រព័ន្ធដាំដំណាំចម្រុះច្រើនបែបនៅតំបន់ដីខ្ពស់ រួមទាំងចិញ្ចឹមសត្វពាហនៈ និងស្រះចិញ្ចឹមត្រីផង ។ ការយកបទពិសោធន៍របស់អ្នកទាំងនេះមកអនុវត្ត អាចជាមធ្យោបាយសម្រាប់ដោះស្រាយកង្វះខាតនៅក្នុងប្រព័ន្ធកសិកម្មលើដីខ្ពស់នៅកម្ពុជា ។ ការផ្ទេរចំណេះដឹងទាំងនេះអាចធ្វើរួមជាមួយនឹងការផ្តល់ទុនសម្រាប់ដាំបង្ហាញនៅលើកសិដ្ឋានល្បងពិសោធន៍នៅក្នុងខេត្តនីមួយៗ ។

ចំពោះដំណាំស្រូវវិញ វិទ្យាស្ថាន CARDI មានបទពិសោធន៍ទូលំទូលាយណាស់ ប៉ុន្តែត្រូវតែភ្ជាប់ទំនាក់ទំនងឱ្យកាន់តែប្រសើរឡើង និងផ្សព្វផ្សាយឱ្យទៅដល់ស្ថាប័ននានានៅថ្នាក់ខេត្ត ។ ការប្រើទូរទស្សន៍ វិទ្យុ និងឯកសារបោះពុម្ព គួររួមបញ្ចូលផងដែរនូវការនាំកសិករទៅមើលឱ្យឃើញផ្ទាល់ភ្នែក ។ ប្រហែលជាគួរបញ្ចុះបញ្ចូលសាលាបឋមសិក្សានានា ឱ្យផ្តើមរៀនដាំដំណាំល្បងពិសោធន៍ ដោយមានផ្លាកសម្គាល់ប្រភេទគ្រាប់ពូជដែលប្រើពេលវេលាដាំដុះចំនួនជី និងសម្ភារៈបរិក្ខាឯទៀតៗដែលប្រើ ។ ការប្រៀបធៀបគ្នារវាងទិន្នន័យនៅសាលាជាមួយនឹងទិន្នន័យរបស់គ្រួសារសិស្សនៅឯភូមិ អាចមានប្រយោជន៍ដល់ការធ្វើឱ្យចម្រើនដល់បច្ចេកទេសដាំដុះនៅផ្ទះ ។ វិធីនេះអាចប្រើបច្ចេកទេសងាយស្រួលក្នុងការដាំស្រូវតាមរបៀបផ្សេងៗគ្នា ដើម្បីឱ្យបានទិន្នផលខ្ពស់ ដោយមិនចាំបាច់ចំណាយប្រាក់ច្រើន ហើយក៏មិនសូវបារម្ភច្រើន ។ ការសាកល្បងនេះអាចផ្តើមបានភ្លាមៗយ៉ាងហោចណាស់ ក៏ផ្តើមក្នុងលក្ខណៈពិសោធន៍មើលដែរ ។

បញ្ហាពិសេសមួយពាក់ព័ន្ធនឹងក្រុមជនជាតិភាគតិចដែលនៅតែធ្វើកសិកម្មតាមបែបពនេចរ ។ មធ្យោបាយមួយដើម្បីធ្វើឱ្យរីកចម្រើនដល់បច្ចេកទេសដាំដុះ គឺតាមរយៈការផ្តល់សម្ភារៈបរិក្ខារសម្រាប់ផ្តួចផ្តើមមួយចំនួនតូច រួមទាំងគ្រាប់ពូជ និងជី ដែលមានឯកសារណែនាំអនុវត្តន៍ចំពោះកសិដ្ឋានតូចៗទំហំ ០.១ ហិចតា ។ ប៉ុន្តែដោយសារមិនអាចគ្រប់គ្រងទឹកបាន គួរផ្តល់អាទិភាពទៅលើដំណាំយកផ្លែជាជាងដំណាំស្រូវនៅតំបន់ដីខ្ពស់ ។ ក្នុងករណីខ្លះ ការគិតគូរ និងការប្រឹងប្រែង គួរតែផ្តោតទៅជួយក្រុមជនជាតិភាគតិចឱ្យប្តូរពីទម្លាប់ដាំដុះបែបកសិកម្មពនេចរ មកជាកសិកម្មបែបធម្មតានៅកន្លែងមួយច្បាស់លាស់ ដែលអាចជាការលំបាកមួយ ។ ដើម្បីឱ្យកិច្ចការនេះសម្រេចជោគជ័យ កសិករទាំងនោះគួរតែចេះអក្សរខ្លះ ។

*ប្រភព : Dapice, Vallely and Wilkinson (2006)*

### ប្រអប់ ៤.៤ : ការធ្វើលំនឹងគុណភាពដី - វិធីដាំដុះតាមប្រព័ន្ធកសិកម្មទំនើបនៅប្រទេសចិន

នៅតំបន់ដីក្រហម Red Soils II Area Project នៅប្រទេសចិន (១៩៩៤-២០០០) បានដោះស្រាយបញ្ហាបាត់បង់ដោយទឹកហូរច្រោះ និងដីខូចគុណភាពជាង ១១ លានហិចតា ។ ទ្រង់ទ្រាយចម្បងសម្រាប់ដោះស្រាយ រួមមាន :

១. កសិដ្ឋានទាំងអស់ត្រូវតែមានចិញ្ចឹមសត្វពាហនៈនៅក្នុងប្រព័ន្ធកសិកម្ម ដើម្បីយកលាមកសត្វធ្វើជី និងបង្កើតប្រាក់ចំណូលបឋម ទម្រាំដំណាំផ្តល់ផ្លែផ្កា ។

២. កសិដ្ឋាននីមួយៗត្រូវមានប្រព័ន្ធស្រោចស្រព ដោយប្រើទុយោទឹកស្រោចដោយដៃដែលតភ្ជាប់ពីអាងទឹកនៅលើភ្នំ ។

៣. តាមជម្រាលភ្នំត្រូវធ្វើថ្នាលដាំ ដើម្បីរក្សាកុំឱ្យបាក់ដី មិនមែនដាំលើដីរាបធម្មតាតាមជម្រាលភ្នំទេ ។

៤. ត្រូវដាំដំណាំចម្រុះ មិនត្រូវដាំតែមួយមុខៗទេ ហើយត្រូវផ្តោតលើតុល្យភាពគ្នារវាងដំណាំស្រូវដីទំនាប និងដំណាំស្រូវដីខ្ពស់ រួមទាំងដំណាំផ្សេងៗទៀត បន្លែបង្ការ និងដើមឈើយកផ្លែផងដែរ ។

គម្រោងនេះ ផ្តល់ចំណូលជាប្រាក់ក្នុងអាត្រាពី ១៦ ទៅ ១៧ ភាគរយ និងកំណើនជីវភាពសេដ្ឋកិច្ចក្នុងអាត្រា ១៩ ភាគរយ ។ នៅប្រទេសកម្ពុជា វិធីនេះអាចមានប្រយោជន៍សម្រាប់ការដាំដុះលើដីដែលមានព្រៃរេចរិល ។

*ប្រភព : ធនាគារពិភពលោក (២០០៥ ក)*

*នៅតំបន់ដែលមានការដាំដុះសព្វថ្ងៃ មានតែ ៧-៨ ភាគរយទេដែលមានប្រព័ន្ធស្រោចស្រពត្រឹមត្រូវ*

## ៤.២ ការយកទឹកប្រើសម្រាប់ស្រោចស្រព

ក្នុងការបង្កើនផលិតផលកសិកម្ម បញ្ហាសំខាន់មួយ គឺកង្វះប្រព័ន្ធស្រោចស្រពដែលមានការគ្រប់គ្រងល្អនៅតំបន់ភាគច្រើន។ នៅតំបន់ដែលមានការដាំដុះសព្វថ្ងៃ មានតែ ៧-៨ ភាគរយទេ ដែលមានប្រព័ន្ធស្រោចស្រពល្អ (រូបភាព ៤.៤)[៥៣]។ សូម្បីតែត្រង់ចំណុចនេះក៏មានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយដែរ គឺនៅខេត្តតំបន់ព្រៃសាន ជាក់ស្តែងមិនមានប្រព័ន្ធស្រោចស្រពទេ។

កម្ពុជាមានទំហំផ្ទៃទឹកធំជាងប្រទេសណាៗទាំងអស់នៅក្នុងពិភពលោក ដែលយកកសិកម្មជាមធ្យោបាយសម្រាប់ជីវភាពរស់នៅរបស់ពលរដ្ឋ។ ប្រហែល ៩០ ភាគរយ នៃផ្ទៃដីកម្ពុជាសុទ្ធតែមានកន្លែងរក្សាទឹកពីទន្លេ ស្ទឹង ដែលមិនចេះរីងស្ងួត។ ប៉ុន្តែតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៧០ មក ទឹកនៅលើផ្ទៃដីក៏មិនបានពង្រីកឱ្យទូលំទូលាយ រីឯទឹកនៅក្រោមដីក៏មិនបានយកមកប្រើជាធំដុំដែរ។ សូម្បីតែក្រោយពីការបង្កើតក្រសួងធនធានទឹកហើយក៏ដោយ កិច្ចការចម្បងរបស់ក្រសួងនេះ គឺផ្តោតទៅលើការជួសជុលអាងទឹកចាស់ៗ ជាជាងការលើកផែនការសាងសង់ប្រព័ន្ធធារាសាស្ត្រធំៗ។ ថវិកាសម្រាប់ជួយគាំទ្រដល់ការស្រោចស្រពក្នុងឆ្នាំ២០០៥[៥៤] មានចំនួនតែ ១៣ លានដុល្លារអាមេរិកទេ ថ្វីត្បិតតែមានការសង្កត់ធ្ងន់ទៅលើវិស័យធារាសាស្ត្រ នៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណក៏ដោយ។

***រូបភាព ៤.៤ : ភាគរយនៃស្រែវស្សាដែលមានប្រព័ន្ធស្រោចស្រពបន្ថែម ឆ្នាំ ២០០៥***




*ប្រភព : ទិន្នន័យមូលដ្ឋានរបស់ក្រសួងផែនការ ស្តីពីក្រុមប្រឹក្សាឃុំសង្កាត់* http://www.seila.gov.kh

*(៥៣) តួលេខនេះគណនាចេញអំពីទិន្នន័យមូលដ្ឋានរបស់ក្រសួងផែនការ ស្តីពីក្រុមប្រឹក្សាឃុំសង្កាត់។ ទិន្នន័យឆ្នាំ ២០០៦ របស់ EIC ក៏ដូចគ្នានឹងតួលេខនេះដែរ។ ប៉ុន្តែផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកំណត់តួលេខនៅត្រឹម ២០ ភាគរយ (រាជរដ្ឋាភិបាល ឆ្នាំ ២០០៦ ក)។ ក្រុមការងារកសិកម្ម និងទឹក (២០០៦) រាយការណ៍ថា ការស្រោចស្រពនៅរដូវវស្សាមានប្រហែល ២០ ភាគរយ ហើយមានតែ ៧ ភាគរយ ទេ នៅរដូវប្រាំង។ តួលេខពិតប្រាកដពិបាកប៉ាន់ស្មានណាស់ បើមិនទាន់មានជំរឿនក្នុងវិស័យកសិកម្ម។ តាមពិត សមាមាត្រនៃស្រែ ដែលមានការស្រោចស្រពតូចជាងសក្តានុពលដែលគួរស្រោចស្រព។*

*(៥៤) តួលេខនេះយកតាមបទអន្តរាគមន៍របស់លោក ចាន់ សុផល ក្នុងកិច្ចប្រជុំថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៧ រៀបចំនៅភ្នំពេញ ដោយ CDRI និង ANZ-Royal។*

ព្រៃឈើត្រូវបានកាប់រំលំជាបន្តបន្ទាប់ដើម្បីយកដីធ្វើកសិកម្ម ដោយសារផ្នែកធំៗនៃព្រៃលិចទឹកទាំងនេះ ស្ថិតនៅតាមដងទន្លេសាប និងទន្លេមេគង្គ ការបាត់បង់ព្រៃឈើបណ្តាលឱ្យមានទឹកជំនន់ និងការហូរច្រោះដីកើនឡើង។ ក្នុងស្ថានភាពបែបនេះ ពេលណាខ្វះទឹកភ្លៀង ការរាំងស្ងួតធ្វើឱ្យប៉ះពាល់ដល់ផលដំណាំកសិកម្ម និងជីវភាពរស់នៅរបស់កសិករ។ ការធ្វើទំនប់ ជីកស្រះ ដើម្បីរក្សាទឹកទុកអាចជួយគ្រប់គ្រងទាំងទឹកជំនន់ ទាំងការរាំងស្ងួត។ តាមពិត មានតំបន់ជាច្រើនដែលរងគ្រោះដោយទឹកជំនន់ផង ដោយគ្រោះរាំងស្ងួតផង (រូបភាព ៤.៥ និង ៤.៦)។

*មានតំបន់ជាច្រើន ដែលរងគ្រោះ ដោយទឹកជំនន់ផង ដោយគ្រោះរាំងស្ងួតផង*

ខាងក្រោមនេះគឺវិធីសាស្ត្រ ៣ ប្រភេទ ក្នុងការប្រមែប្រមូលទឹក និងការស្រោចស្រព ៈ[៥៥]

ក. ទឹកនៅលើដី ៈ សំខាន់ត្រូវរក្សាទឹកនៅលើដីទុកឱ្យគង់វង្ស ដោយសាងសង់អាងទឹកសម្រាប់ការពារដំណាំរដូវវស្សា ហើយជម្រុញការដាំដុះរដូវប្រាំង។ ទំនប់ទឹក ឬអាងទឹកជួយការពារទប់ទល់នឹងភាពរាំងស្ងួត និងគ្រោះទឹកជំនន់ ហើយអាចជាកន្លែងបន្តពូជត្រី និងចិញ្ចឹមត្រីផង។

ខ. ទឹកក្រោមដី ៈ ទឹកក្រោមដី និងការរក្សាទុកទឹកភ្លៀង មានសារៈសំខាន់នៅពេលណាដែលមិនមានទឹកលើដី។

គ. អភិបាលកិច្ច ៈ ការបំពាក់អភិបាលកិច្ចល្អ អាចជួយថែរក្សា និងចែកចាយទឹកប្រើប្រាស់បានប្រសើរឡើង។

***រូបភាព ៤.៥ ៈ តំបន់ងាយទឹកលិច***




*ប្រភព ៈ កម្មវិធីស្បៀងអាហារពិភពលោក ប្រចាំកម្ពុជា*

(៥៥) ព័ត៌មានពិស្តារមាននៅក្នុង TGW ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក (២០០៦)។

*ប្រទេសឯទៀតៗ នៅអាស៊ី ដែលមាន កសិកម្មរឹងមាំ បានវិនិយោគទៅក្នុង ការបំពាក់អគ្គិសនី តាមទីជនបទ*

ទំនប់ទឹក ឬអាងទឹក អាចជាទ្រង់ទ្រាយធំ មធ្យម ឬតូច ហើយមានរាងផ្សេងៗពីគ្នា។ នៅទីតាំងខ្លះ ទំហំអាងទឹកផ្អែកទៅតាមស្ថានភាពដី ចំណុះទឹក និងលំហូរនៃទឹក ប៉ុន្តែក្នុងករណីដទៃទៀត ទំហំអាង និងទំនប់ទឹក អាចសម្រេចបានតាមការជ្រើសរើស។ ទំនប់ទឹកតូចៗ ប្រើបច្ចេកវិទ្យាងាយស្រួលជួសជុល ក៏ងាយស្រួលអាចគ្រប់គ្រងបាននៅថ្នាក់វិមជ្ឈការ ហើយតម្លៃសាងសង់ក៏ថោក[៥៦]។ ផ្អែកទៅលើអេកូឡូស៊ីរបស់កម្ពុជា ការសាងសង់ទំនប់ទឹក ត្រូវគិតគូរឱ្យបានល្អិតល្អន់ ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន។

បញ្ហាស្រោចស្រពអាចដោះស្រាយបានហួសពីរចនាសម្ព័ន្ធស្តុកទឹក។ នៅទីណាដែលមានទឹកនៅជិតៗ (ទាំងទឹកលើដី ទាំងក្រោមដី) មានវិធីប្រើប្រាស់ទឹកខ្នាតតូចច្រើនបែបនៅក្នុងប្រទេសនៅអាស៊ី។ សូម្បីនៅប្រទេសកម្ពុជា កន្លែងណាដែលមានស្ទឹង ឬបឹងបួរនៅជិតៗ កសិករប្រើវិធីងាយៗ បង្ហូរទឹកចូលទៅក្នុងស្រែចំការគាត់ ដោយប្រើថាមពលគ្រឿងយន្តបន្តិចបន្តួច ឬក៏មិនបាច់ប្រើ (ប្រអប់លេខ ៤.៥)។

ក្នុងការស្រោចស្រព ជម្រើសនានាក្រៅពីបង្ហូរទឹកតាមប្រឡាយចេញពីអាង គឺបូមយកទឹកពីក្រោមដី ដោយប្រើកម្លាំងដែលមិនអស់ថ្លៃច្រើន។ បច្ចុប្បន្ននេះ នៅទីតាំងខ្លះគេប្រើម៉ាស៊ីនបូមទឹកដែលអស់តម្លៃច្រើន ហើយនាំឱ្យផលកសិកម្មមានតម្លៃខ្ពស់ មិនអាចលក់យកចំណេញបាន។ ប្រទេសអាស៊ីឯទៀតៗ ដែលមានប្រព័ន្ធកសិកម្មរឹងមាំ បានវិនិយោគទៅក្នុងការបំពាក់អគ្គិសនីតាមជនបទ។ ការបំពាក់អគ្គិសនីនៅជនបទ គឺជាជម្រើសដ៏ពិតប្រាកដមួយ ប៉ុន្តែនៅចន្លោះពេលនេះ ការប្រើសត្វពាហនៈឱ្យអូសទាញប្រដាប់បូមទឹក ឬការបូមទឹកដោយដៃ អាចយកមកប្រើប្រាស់បាន។

***រូបភាព ៤.៦ : តំបន់ងាយរាំងស្ងួត***




*ប្រភព : កម្មវិធីស្បៀងអាហារពិភពលោក ប្រចាំកម្ពុជា*

(៥៦) ឯកសារលម្អិតស្តីពីទំនប់ទឹកមាននៅក្នុងរបាយការណ៍ និងឯកសារសាវតាររបស់គណៈកម្មការពិភពលោកស្តីពីទំនប់ទឹក។ សូមមើល http://www.dams.org

### ប្រអប់ ៤.៥ : ការយកទឹកប្រើប្រាស់ក្នុងតម្លៃថោកនៅកម្ពុជា

កសិករម្នាក់នៅភូមិស្វាយគន់ បានព្យាយាមរកវិធីបូមទឹកស្រោចដំណាំដែលមានតម្លៃថោក។ នៅពេលមួយនោះ ទោះបីជាគ្រួសារគាត់មានដីទំហំ ២.៥ ហិចតា ក៏ដោយ ក៏ដីនោះមិនបានផ្តល់ផលគ្រប់គ្រាន់ឡើយ ហើយជីវភាពគាត់ក្រីក្រតោកយ៉ាកជាខ្លាំង។ គ្រួសារនេះមានតែរទេះគោមួយ ហើយត្រូវទៅខ្ចីគោគេដើម្បីយកមកភ្ជួរដី។ កសិករនេះបានជួបអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ (IDE) ហើយបានឃើញការបូមទឹកដោយជាន់នឹងជើង។ គាត់មើលឃើញថា ប្រដាប់បូមទឹកនោះអាចផ្តល់ប្រយោជន៍ដល់គ្រួសារគាត់ ប្រសិនបើគាត់អាចទិញវាយកទៅប្រើក្នុងកសិដ្ឋានគាត់។ គាត់បានយកប្រាក់ដែលគាត់សន្សំទុកបន្តិចបន្តួចទៅទិញប្រដាប់បូមទឹកនោះ ក្នុងតម្លៃ ១១ ម៉ឺនរៀល ស្មើនឹង ៣០ ដុល្លារអាមេរិក។ ការតម្លើងប្រដាប់បូមទឹកមិនអស់ថ្លៃច្រើនទេ ដោយសារគាត់ប្រើមែកឈើសម្រាប់ទ្រទ្រង់ ហើយក៏ពុំចាំបាច់ធ្វើលូបង្ហូរទឹកដែរ ព្រោះគាត់យកប្រដាប់បូមទឹកទៅដាក់ចំកណ្តាលស្រែតែម្តង ដើម្បីឱ្យទឹកដែលគាត់បូមហូរទៅស្រោចស្រពពាសពេញស្រែ។

កាលមិនទាន់បានទិញប្រដាប់បូមទឹកនេះ គាត់អាចដាំស្រូវវស្សាបានតែមួយដងគត់ក្នុងមួយឆ្នាំ ហើយអាចដាំឪឡឹកបានលើដីចំនួនតែ ១០អាប៉ុណ្ណោះ។ ប៉ុន្តែក្រោយពីដំឡើងប្រដាប់បូមទឹកហើយ គាត់អាចធ្វើស្រូវប្រាំងបានទៀត ហើយពង្រីកដីដាំឪឡឹកពី ១០អា ទៅ ៦០អា។ តែក្នុងរយៈពេលមួយឆ្នាំប៉ុណ្ណោះ គាត់រកប្រាក់បាន ៥០ ម៉ឺនរៀល ស្មើនឹង ១៤២ ដុល្លារ ដោយគ្រាន់តែលក់ផ្លែឪឡឹក និងរកបាន ១.១០០.០០០ រៀល (ស្មើនឹង ៣១៤ ដុល្លារ) ពីលក់ស្រូវប្រាំង។ គ្រួសារនេះសម្រេចយកលុយនេះទៅសង់ផ្ទះក្បឿងមួយខ្នង ហើយទិញមេគោមួយក្បាល ដើម្បីចិញ្ចឹមយកកូន។ គាត់នៅតែព្រួយបារម្ភអំពីអនាគតរបស់កូនចៅគាត់ ប៉ុន្តែឥឡូវនេះគាត់មានការទុកចិត្តកាន់តែច្រើនហើយ។ ឆ្នាំក្រោយ គាត់គ្រោងនឹងទិញប្រដាប់បូមទឹកមួយទៀត ដើម្បីពង្រីកផលិតកម្មកសិកម្មរបស់គាត់ ហើយគ្រោងនឹងជួលដី ២ ហិចតាថែមទៀត។ បន្ទាប់ទៅទៀត គាត់គ្រោងនឹងជីកស្រះមួយទំហំ ១០ ម៉ែត្រ បួនជ្រុងសម្រាប់ចិញ្ចឹមត្រី។

បច្ចេកវិទ្យាឈ្នាន់បូមទឹកបែបនេះ អាចជាឧបករណ៍ខ្លាំងក្លាមួយសម្រាប់បង្កើនប្រាក់ចំណូលជូនកសិករតូចតាចនៅកម្ពុជា។ អនុបាតរវាងចំណេញ និងចំណាយរបស់វា គឺ ៥ ទល់នឹង ១ ដោយមានអត្រាទាញចំណូលស្មើ ១០០ ភាគរយ។ ប្រដាប់បូមទឹកតូចៗឯទៀតៗ ក៏មានប្រើដែរនៅកម្ពុជា ដូចជាស្នប់ទឹករ៉ៃ ដែលជាឧបករណ៍ស្រោចស្រពតាមប្រពៃណីមានលក់ក្នុងតម្លៃ ៨៥ ដុល្លារ។

*ប្រភព : Frausto (២០០១); ធនាគារពិភពលោក (២០០៥ ក); http://www.ideas-at-work.org*

*__សារគន្លឹះ :__*

*ការពង្រីកប្រព័ន្ធធារាសាស្ត្រ គឺជាចំណុចស្នូល សម្រាប់បង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូល ជូនកសិករ។ ទឹកសម្រាប់ស្រោចស្រពអាចយកពីប្រភពផ្សេងៗ តាមកម្រិតតិច ឬច្រើន ដោយមានភាគីពាក់ព័ន្ធចូលរួមផង។*

## ៤.៣ បង្កើតឱ្យមានឥណទាន ដោយយកការប្រាក់ទាប

ធនាគារពាណិជ្ជកម្មកម្ពុជា មិនផ្តល់ប្រាក់កម្ចីសម្រាប់ប្រតិបត្តិការនៅជនបទ ឬសម្រាប់កិច្ចប្រតិបត្តិការកសិកម្មទេ។ ផ្ទុយទៅវិញ មានស្ថាប័នផ្តល់ឥណទានខ្នាតតូចជាងមួយរយ ដែលក្នុងនោះ មានស្ថាប័ន ៧ មានអាជ្ញាប័ណ្ណពីធនាគារជាតិ កំពុងតែផ្តល់ប្រាក់កម្ចីជូនកសិករ ហើយនិងអ្នកខ្ចីឯទៀតៗនៅជនបទ។ ស្ថាប័នឥណទានខ្នាតតូចជាច្រើនឱ្យអ្នករកស៊ី និងកសិករតូចតាចខ្ចីប្រាក់បន្តិចបន្តួចក្នុងរយៈពេលខ្លី។ លើសពីនេះទៀត ស្ថាប័នទាំងនោះ ផ្តល់ប្រាក់កម្ចីសម្រាប់ចំណាយប្រើប្រាស់ក្នុងគ្រួសារតាមរយៈកម្មវិធីប្រាក់កម្ចីជាក្រុម។ ប្រាក់កម្ចីបែបនេះមានការប្រាក់ពី ២ ភាគរយ ទៅ ៤ ភាគរយ ក្នុងមួយខែ។ ស្ថាប័នទាំងនេះ ក៏ជួយណែនាំឱ្យប្រជាពលរដ្ឋមូលដ្ឋានចេះសន្សំប្រាក់ដែរ។

ដោយហេតុថា ដើមទុនរបស់ស្ថាប័នឥណទានខ្នាតតូចទាំងនេះ មានមូលដ្ឋានមកពីប្រាក់ដែលប្រជាពលរដ្ឋ សាមញ្ញយកទៅសន្សំទុកនៅស្ថាប័ន និងប្រាក់ហ៊ុនរបស់អ្នកកាន់ភាគហ៊ុន ហើយភាគច្រើនទៀត គឺប្រាក់របស់ប្រទេសផ្តល់អំណោយផងដែរ លក្ខខណ្ឌចាំបាច់មួយក្នុងកិច្ចប្រតិបត្តិការឥណទានទូទៅ គឺអ្នកខ្ចីត្រូវសងវិញតាមពេលកំណត់។ បើមិនបានសងវិញតាមលក្ខខណ្ឌនេះទេ ម្ចាស់លុយដែលដាក់នៅក្នុងស្ថាប័នទាំងនោះនឹងអស់សេចក្តីទុកចិត្ត ហើយកិច្ចប្រតិបត្តិការនេះនឹងត្រូវបរាជ័យ។

កសិករសាមញ្ញជាច្រើននៅកម្ពុជា មិនមានទំនាក់ទំនងជាមួយប្រព័ន្ធធនាគារទំនើបទេ រួមទាំងស្ថាប័នឥណទានខ្នាតតូចទាំងនេះផងដែរ ពីព្រោះកសិករទាំងនោះ មិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីសងប្រាក់តាមកាលកំណត់ទេ។ កសិករខ្លះក៏មិនធ្លាប់បានលក់ដូរផលដំណាំរបស់គេផង ដូច្នេះពួកគេមិននៅក្នុងក្រុមមនុស្សដែលចេះប្រើប្រព័ន្ធធនាគារទេ។ ស្ថិតិបច្ចុប្បន្នបង្ហាញថា ក្នុងចំណោមមនុស្សពេញវ័យធ្វើការ ៥.២៩ លាននាក់ (គឺ១.៣២ លានគ្រួសារ) ដែលប្រកបរបរកសិកម្ម មានតែ ០.៤២ លាន ឬតិចជាង ១ ភាគ ៣ ទេ ដែលធ្លាប់បានប្រើស្ថាប័នឥណទាន។ គម្លាតនេះត្រូវបានឈ្នួញនៅមូលដ្ឋានជួយបំពេញ ដែលប្រហែលមិនមែនជាអ្នករកស៊ីផ្តាច់មុខទេ ប៉ុន្តែគេមានលុយឱ្យខ្ចី ហើយ

មានលទ្ធភាពអាចដឹងព័ត៌មានអំពីទីផ្សារ ដែលកសិករទាំងនោះមិនអាចដឹងបាន ។ ឈ្មួញទាំងនោះឱ្យខ្ចីបណ្ដាក់ជាសម្ភារៈបរិក្ខារ ( ឬខ្ចីជាប្រាក់សុទ្ធជំនួសសម្ភារៈ) ក្នុងការប្រាក់ពី ៧ ភាគរយ ទៅ ១០ ភាគរយ ក្នុងមួយខែ ។ អត្រាការប្រាក់ដ៏ខ្ពស់ទាំងនេះ ធ្វើឱ្យកសិករតូចតាចប្រថុយប្រថាននឹងស្ថានភាពដែលចាញ់ប្រៀបជានិច្ច ។

ប្រទេសខ្លះជួយឧបត្ថម្ភការប្រាក់ដល់កសិករតូចតាច ឬផ្ដល់ជាប្រាក់កម្ចីសម្រាប់ធ្វើកសិកម្មតាមរយៈធនាគាររដ្ឋ ។ ការជួយឧបត្ថម្ភដោយមិនយកកម្រៃបែបនេះ ប្រហែលមិនមានចីរភាពទេនៅកម្ពុជា ដោយសារតែមូលដ្ឋាននៃការដាក់ប្រាក់ចូលធនាគារនៅតូចពេក ។ វិធីនេះអាចអូសបន្លាយពេលមិនឱ្យកសិករអាចលូតលាស់ចេញផុតពីជីវភាពកសិកម្មសម្រាប់តែចិញ្ចឹមឆ្នាំង ។ផ្ទុយទៅវិញ ប្រសិនបើទីភ្នាក់ងារអន្តរជាតិ (ដូចជាធនាគារអភិវឌ្ឍន៍អាស៊ីជាដើម) មានប្រាក់កម្ចីយកការប្រាក់ទាបបែបនេះ សម្រាប់ឱ្យកម្ពុជាប្រើក្នុងឥណទានជនបទ ឬឥណទានកសិកម្ម ហើយធនាគារជាតិផ្ទេរប្រាក់នេះ ទៅធនាគារអភិវឌ្ឍន៍ជនបទសម្រាប់ឱ្យទៅកសិករខ្ចីតែម្ដង ដោយមិនមានឈ្មួញកណ្ដាលកេងចំណេញពីលើច្រើនពេកនោះ អ្នកជនបទនឹងអាចខ្ចីប្រាក់បានដោយមានការប្រាក់ទាបជាងសព្វថ្ងៃ ។ យ៉ាងហោចណាស់ក៏មានធនាគារពាណិជ្ជកម្មធំមួយដែរ ដែលចង់ឱ្យកសិករខ្ចីប្រាក់ ប្រសិនបើមានប្លង់ដីដាក់ធានា និងប្រសិនបើមានវិវាទ វិវាទនោះត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស[៥៧] ។

ដូច្នេះប្រសិនបើការចេញប្លង់ដីចប់ឆាប់ អភិបាលកិច្ចមូលដ្ឋាននឹងរីកចម្រើន ទីផ្សារក៏នឹងមានការប្រកួតប្រជែងល្អសម្រាប់ឱ្យកសិកម្មតូចតាចអាចរកផលចំណេញបាន ហើយដោយមានសេវាគាំទ្រកសិកម្មផង កសិករអាចរកផលចំណេញបានកាន់តែច្រើនភ្លាមមួយរំពេចដល់ពេលនោះ ទើបប្រាក់កម្ចីដែលមានការប្រាក់ទាបៗជាច្រើនហូរចូលទៅជនបទ ។

*__សារគន្លឹះ :__*

*សហគមន៍កសិករត្រូវការជំនួយគាំទ្រដើម្បីឱ្យពួកគេចេះប្រើប្រព័ន្ធធនាគារ ។ ដើម្បីឱ្យបានសម្រេចតាមទិសដៅនេះ ត្រូវរៀបចំឱ្យមានសម្ភារៈបរិក្ខារកសិកម្មទំនើប ដូចជា អគ្គិសនីសម្រាប់បូមទឹកស្រោចស្រព និងគ្រាប់ពូជដែលមានទិន្នផលខ្ពស់ជាដើម ព្រមទាំងមានជំនួយឧបត្ថម្ភសេវាទ្រទ្រង់កសិកម្មផងដែរ ។*

### ប្រអប់ ៤.៦ : ឥណទានខ្នាតតូចដែលមានប្រយោជន៍



អ្នកស្រី ធៀម ផល្លី អាយុ ២៥ ឆ្នាំ ឥឡូវនេះគាត់មានសង្ឃឹមលើអនាគតរបស់គាត់ឡើងវិញហើយ ហើយក៏បានបំភ្លេចចោលអតីតកាលដ៏ជូរចត់របស់គាត់ ។ ប៉ុន្មានឆ្នាំមុន កាលប្ដីគាត់ចាកចោលគាត់ទៅ អ្នកស្រី ផល្លី ក្រខ្លាំងណាស់ ហើយពុំមានមធ្យោបាយចិញ្ចឹមទារកអាយុ ២ ខែ របស់គាត់ទេ ។ គាត់ជាស្ត្រីដ៏អភ័ព្វមួយរូបនៅក្នុងភូមិ ។

គាត់និយាយថា ដោយសារប្ដីខ្ញុំចុះចោលទៅ ជីវិតខ្ញុំសែនវេទនា ហើយកូនខ្ញុំក៏នៅតូចណាស់ដែរ ។ ប៉ុន្តែតាមការណែនាំពីអ្នកភូមិផងរបងជាមួយ គាត់បានខ្ចីប្រាក់ ៥ ម៉ឺនរៀល ( ១២.៥០ ដុល្លា) ពីស្ថាប័នឥណទានខ្នាតតូចមួយ ។ គ្មានអ្នកណាជឿថា ទឹកប្រាក់តែបន្តិចបន្តួចនេះអាចផ្លាស់ប្ដូរជីវិតគាត់បានទេ ប៉ុន្តែលទ្ធផលជាក់ស្ដែង គួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ ។

ជាមួយនឹងប្រាក់បន្តិចបន្តួចនេះ ធៀម ផល្លី ចេញពីផ្ទះតាំងពីម៉ោង ៣ ភ្លឺ ជិះកង់កញ្ចាស់មួយ ដឹកអង្ករ ៥០ គីឡូ យកទៅលក់រាយនៅផ្សារ ។ ជាង ២ ឆ្នាំ គាត់តែងតែជិះកង់កាត់ភក់ និងដីរអិល ទៅលក់អង្ករនៅផ្សារ ។ ក្រោយមក ផល្លី អាចសន្សំលុយទិញបានម៉ូតូមួយ ហើយអាចបើកតូបលក់អីវ៉ាន់តូចមួយនៅផ្ទះគាត់ ក្នុងឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្ដាល ។

ផល្លី និយាយថា ខ្ញុំបានពង្រីកមុខរបរខ្ញុំបន្តិចម្ដងៗ រហូតទាល់តែខ្ញុំអាចបើកតូបលក់ឥវ៉ាន់នៅមុខផ្ទះខ្ញុំនេះតែម្ដង ។ សព្វថ្ងៃនេះ តូបរបស់ ផល្លី មានលក់អង្ករ បន្លែ ត្រី និងសាច់ផ្សេងៗ ។

នៅក្នុងកិច្ចប្រជុំកំពូលថ្នាក់ជាតិស្ដីអំពីឥណទានខ្នាតតូច លោក ដាក់ក្លីស ហ្កាដណឺ តំណាងប្រចាំប្រទេសនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបានរំលឹកថា ជោគជ័យនៃឥណទានខ្នាតតូចអាស្រ័យទៅលើសេវាកម្មផ្នែកហិរញ្ញវត្ថុ ដែលចេះតែមានជាបន្តបន្ទាប់ជូនអតិថិជន មិនមែនគ្រាន់តែឱ្យប្រាក់ខ្ចីតែម្ដងនោះទេ ។ ការរក្សាឱ្យមានសេវាកម្មហិរញ្ញវត្ថុទូលំទូលាយ និងប្រកបដោយចីរភាពបែបនេះ គឺជាសារៈសំខាន់សម្រាប់អភិវឌ្ឍមូលដ្ឋាន និងឧបត្ថម្ភហិរញ្ញវត្ថុខ្នាតតូចសម្រាប់អតិថិជន ។

ផល្លី នៅតែបន្តប្រើប្រាស់ស្ថាប័នឥណទានខ្នាតតូចនេះតទៅទៀត ។

---

*(៥៧) ប្រភព : Acharya, Kim, Chap និង Meach (២០០៣) ។*

## ៤.៤ ការធានាលំនឹងតម្លៃលក់

ដូចអាជីវករឯទៀតៗដែរ កាលណាផលកសិកម្មលក់បានថ្លៃខ្ពស់ កសិករខំផលិតកាត់តែច្រើន ៖ គឺពួកគាត់រកដី ដើម្បីដាំបន្ថែម ឬព្យាយាមធ្វើឱ្យបានទិន្នផលខ្ពស់ ឬព្យាយាមធ្វើទាំង ២ មុខ ។ លទ្ធផលបែបនេះ កើតមានចំពោះប្រទេសនានា និងចំពោះផលកសិកម្មផ្សេងៗ ។ ការវិភាគស្ថិតិនៅក្នុងខេត្តនានា ស្តីពីអត្រាទិន្នផលដែល ទទួលបាន និងតម្លៃស្រូវនៅក្នុងស្រែ បញ្ជាក់ឱ្យឃើញថា ពេលណាស្រូវមានតម្លៃខ្ពស់ ទិន្នផលស្រូវកើន (រូបភាព ៤.៧) [៥៨] ។ ដូច្នេះតម្លៃលក់ខ្ពស់អាចជួយឱ្យអត្រាទិន្នផលឡើងខ្ពស់ និងជួយឱ្យកសិកររកប្រាក់ចំណូលបានច្រើន ។

*ដូចអាជីវករឯទៀតៗដែរ កាលណាផលិតផលកសិកម្មលក់បានតម្លៃខ្ពស់ គាត់ក៏ខំផលិតឱ្យកាត់តែច្រើន : គឺពួកគាត់នឹងរកដីដាំបន្ថែម ឬព្យាយាមធ្វើឱ្យបានទិន្នផលខ្ពស់ ឬព្យាយាមធ្វើទាំង ២មុខ*

***រូបភាព ៤.៧ : វិភាគស្ថិតិស្តីពីតម្លៃស្រូវ និងអត្រាទិន្នផលក្នុងខេត្តនីមួយៗ នៅឆ្នាំ ២០០៥***




| ល.រ | ខេត្ត |
|---|---|
| ១ | បន្ទាយមានជ័យ |
| ២ | បាត់ដំបង |
| ៣ | កំពង់ចាម |
| ៤ | កំពង់ឆ្នាំង |
| ៥ | កំពង់ស្ពឺ |
| ៦ | កំពង់ធំ |
| ៧ | កំពត |
| ៨ | កណ្តាល |
| ៩ | កែប |
| ១០ | កោះកុង |
| ១១ | ក្រចេះ |
| ១២ | មណ្ឌលគិរី |
| ១៣ | ឧត្តរមានជ័យ |
| ១៤ | ប៉ៃលិន |
| ១៥ | ភ្នំពេញ |
| ១៦ | ព្រះវិហារ |
| ១៧ | ព្រៃវែង |
| ១៨ | ពោធិ៍សាត់ |
| ១៩ | រតនៈគីរី |
| ២០ | សៀមរាប |
| ២១ | ក្រុងព្រះសីហនុ |
| ២២ | ស្ទឹងត្រែង |
| ២៣ | ស្វាយរៀង |
| ២៤ | តាកែវ |

*ចំណាំ : មេគុណសហទំនាក់ទំនង = ០.៥៩៧ ត្រូវនឹង ៣២.៧ ភាគរយ នៃបម្រែបម្រួល ។*
*ប្រភព : សម្រាប់អត្រាទិន្នផល – ក្រសួងកសិកម្ម សម្រាប់តម្លៃយកតាមទិន្នន័យមូលដ្ឋានក្រុមប្រឹក្សាឃុំសង្កាត់នៃក្រសួងផែនការ ។*

---

*(៥៨) សូមមើល* Sik *(១៩៩៩) សម្រាប់កិច្ចពិភាក្សាបន្ថែមលើប្រធានបទនេះ*

ក្នុងការលក់ដូរផលដំណាំរបស់ខ្លួន កសិករបានទទួលផលតិចជាងគេបំផុត។ មូលហេតុមួយ គឺដោយសារពួកគេខ្វះព័ត៌មានចេញពីមូលហេតុជាប់បំណុល និងដោយសារកសិករទាំងនោះខ្វះលុយ

កាលពីអំឡុងឆ្នាំ ១៩៨១ ទៅ ១៩៨៩ រដ្ឋាភិបាលបានប្រមូលទិញស្រូវទាំងអស់ពីកសិករក្នុងតម្លៃទោងទាត់មួយ។ ក្រោយពីនោះមក ទីផ្សារទាំងអស់បានក្លាយជាឯកជនវិញ។ បច្ចុប្បន្ននេះ ទីផ្សារស្រូវស្ថិតនៅក្នុងដៃឈ្មួញច្រើនប្រភេទ ពោលគឺឈ្មួញតូចតាចជាអ្នកប្រមូលទិញស្រូវពីកសិករ ឈ្មួញលក់ដុំ ម៉ាស៊ីនកិនស្រូវ ឈ្មួញលក់ចែកចាយ ឈ្មួញលក់រាយ និងឈ្មួញដទៃៗទៀត (រូបភាព៤.៨)។ ទីផ្សារសម្រាប់ផលដំណាំផ្សេងៗទៀត ដូចជា ពោត សណ្តែកសៀង ជាដើម ក៏មានឈ្មួញកណ្តាលច្រើនដែរ ដោយមានយកកម្រៃជើងសារផ្សេងៗ កម្រៃដឹកជញ្ជូន និងកម្រៃផ្សេងៗទៀត។

## សេចក្តីសង្កេតខ្លះៗ ទៅលើប្រព័ន្ធបច្ចុប្បន្ន :[៥៩]

ក. ក្នុងការលក់ដូរផលដំណាំរបស់ខ្លួន កសិករបានទទួលផលតិចជាងគេបំផុត។ មូលហេតុមួយ គឺដោយសារពួកគេខ្វះព័ត៌មាន មូលហេតុមួយទៀត គឺការជាប់បំណុល និងដោយសារកសិករទាំងនោះ ត្រូវការលុយដែលជាកត្តាបង្ខំឱ្យពួកគេលក់ផលដំណាំរបស់គេចេញយ៉ាងឆាប់រហ័សតាមតម្លៃដែលមាននៅពេលនោះ។ ការទទួលព័ត៌មានមិនស្មើគ្នានេះ មានផលប៉ះពាល់លើដំណាំឯទៀតៗដែរ : ជនជាតិភាគតិចលក់គ្រាប់ស្វាយចន្ទីរបស់ខ្លួនក្នុងតម្លៃ ៤០០ រៀល ក្នុង ១ គីឡូក្រាម នៅខេត្តរតនគីរី ប៉ុន្តែអ្នកឯទៀតៗលក់គ្រាប់ស្វាយចន្ទី ក្នុងគុណភាពដូចគ្នានៅទីផ្សារដូចគ្នា បានតម្លៃជិត ១០០០ រៀលក្នុង ១ គីឡូ[៦០]។

ខ. ថ្លៃលក់ និងថ្លៃទិញខុសគ្នាខ្លាំងពេក (១ : ១.៧) រវាងតម្លៃដែលកសិករលក់ និងតម្លៃដែលអ្នកប្រើប្រាស់ ទិញដូចតម្លៃស្រូវដែរ (រូបភាព ៤.៩)។ ពិតហើយថា ការកិនស្រូវទទួលនូវភាគខ្លះនៃតម្លាតថ្លៃ ប៉ុន្តែអ្នកកិនបានកន្ទក់ និងអង្កាម ដែលមានតម្លៃស្មើនឹងតម្លៃកិន ថែមទាំងមានចំណេញគិតទុកជាមុនជាធម្មតាទៀតផង។

គ. ស្ថានការណ៍អាក្រក់បំផុត គឺពេលណាអ្នកឱ្យលុយខ្ចីដើរតួជាអ្នកផ្តល់សម្ភារៈបរិក្ខាកសិកម្មផង ជាអ្នកប្រមូលទិញស្រូវផង ដែលបង្ខំកសិករឱ្យនៅក្រោមការត្រួតត្រាទាំងស្រុងរបស់ឈ្មួញ ដែលជាអ្នកឱ្យលុយខ្ចី។ នៅពេលប្រមូលផលកសិករលក់ផលិតផលទាំងអស់របស់ខ្លួនឱ្យទៅឈ្មួញក្នុងតម្លៃមួយដ៏ទាបដែលកំណត់ជាមុនហើយស្រេច។ ពេលណាតម្លៃទីផ្សារឡើងថ្លៃដល់កំពូល គឺឈ្មួញជាអ្នកចំណេញ មិនមែនកសិករទេ (រូបភាព ៤.១០)។

*រូបភាព ៤.៨ : ទីផ្សារស្រូវនៅកម្ពុជា*




*ប្រភព : Chea និង Sik (២០០១)*

(៥៩) ប្រភព : សូមមើល Sok, Chea និង Sik (២០០១); Nou (២០០៥)។

(៦០) Dapice, Vallely and Wilkinson (២០០៦)។

*រូបភាព ៤.៩ : តម្លៃខុសគ្នារវាងស្រូវ និងអង្ករ និងតម្លៃខុសគ្នារវាងកសិករ និងអ្នកប្រើប្រាស់ (ជាភាគរយ) ឆ្នាំ ២០០៣*




*ប្រភព : គណនាចេញពីទិន្នន័យក្រសួងកសិកម្ម និងរាជរដ្ឋាភិបាល (២០០៣)*

*រូបភាព ៤.១០ : និន្នាការតម្លៃស្រូវ និងអង្ករ (ផ្កាខ្ញី) នៅកម្ពុជា*



*ប្រភព : ក្រសួងកសិកម្ម (ទិន្នន័យដើម)*

*អ្នកស្រែពិតជាបានផលប្រយោជន៍ច្រើនពីតម្លៃស្រូវដែលលក់បានខ្ពស់នៅក្នុងស្រែ*

អ្នកស្រែពិតជាបានចំណេញច្រើន ប្រសិនបើស្រូវនៅក្នុងស្រែលក់បានថ្លៃខ្ពស់។ ខាងក្រោមនេះ ជាជម្រើសមួយចំនួនដែលត្រូវពិចារណា[៦១] :

*ជម្រើសទី ១ :*

កសិករម្នាក់ៗមិនអាចធ្វើអ្វីកើតទេ ទៅលើតម្លៃលក់ផលិតផលរបស់ខ្លួន ប៉ុន្តែបើរួមកម្លាំងគ្នា គេអាចលក់ផលិតផលទាំងនោះបានតម្លៃខ្ពស់។ អង្គការកសិករដែលជួយឱ្យកសិករ អាចលក់ផលដំណាំរបស់ខ្លួនបានកម្រៃខ្ពស់ មិនមានទាល់តែសោះនៅកម្ពុជា។ មានអង្គការមិនមែនរដ្ឋាភិបាលច្រើនកំពុងប្រឹងប្រែងក្នុងទិសដៅនេះ[៦២]។ ដើម្បីឱ្យកសិករលក់ផលិតផលបានថ្លៃល្អ គម្រោងមួយកំពុងតែដាក់ឱ្យល្បងពិសោធន៍នៅខេត្តព្រៃវែង និងខេត្តកំពត តាមរយៈអង្គការកសិករមួយឈ្មោះទីផ្សារចំហសម្រាប់ស្រូវ។ ក្នុងគម្រោងនេះត្រូវមានឃ្លាំងស្តុកស្រូវរួមមួយ ដើម្បីឱ្យកសិករខ្ចីលុយផ្អែកលើចំនួនស្រូវរបស់ខ្លួនជាជាងលក់ស្រូវទាំងបង្ខំចិត្ត ហើយទុកស្រូវគាត់សម្រាប់លក់នៅពេលណាស្រូវឡើងថ្លៃខ្ពស់បំផុត។ ការដកពិសោធន៍នេះគួរពិនិត្យពិច័យឱ្យបានហ្មត់ចត់ ដើម្បីត្រៀមពង្រីកការល្បងពិសោធន៍នៅកន្លែងទីទៃៗទៀត។

*ជម្រើសទី ២ :*

កសិករច្រើននាក់រួមគ្នាចុះកិច្ចសន្យាជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងអស់រួមគ្នាដែរ ក្នុងតម្លៃមួយដែលបានចរចានិងព្រមព្រៀងគ្នា ដោយកសិករសន្យាថា នឹងលក់ស្រូវរបស់ខ្លួនទៅឱ្យម្ចាស់រោងម៉ាស៊ីនកិនស្រូវនៅពេលប្រមូលផល។ កិច្ចព្រមព្រៀងត្រូវធ្វើជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ ជាទូទៅ មិនមែនជាមួយតែរោងម៉ាស៊ីនណាមួយដោយឡែកពីគ្នាទេ ហើយកិច្ចព្រមព្រៀងនេះ ត្រូវតែចរចាសារជាថ្មីរាល់ៗឆ្នាំ ទើបកសិករបានផលប្រយោជន៍ច្រើនបំផុត។ ជម្រើសនេះខុសអំពីជម្រើសទី ១ ត្រង់ចំណុចដែលកសិករទាំងអស់មិនចាំបាច់មានឃ្លាំងស្តុកស្រូវរួមទេ។ ដើម្បីឱ្យជម្រើសនេះសម្រេចជោគជ័យ ត្រូវមានម៉ាស៊ីនកិនស្រូវទំនើបៗនៅមូលដ្ឋានឱ្យបានច្រើន និងឆាប់បំផុត។

*ជម្រើសទី ៣ :*

នេះជាជម្រើសទី ២ ដែលមានទ្រង់ទ្រាយកាន់តែប្រិតប្រៀងជាងមុន ពោលគឺជាកិច្ចព្រមព្រៀងផ្លូវការមួយរវាងកសិករជាច្រើនជាមួយនឹងក្រុមហ៊ុនកែច្នៃ (ផលិតផលកសិកម្ម) ធ្វើជាម្ហូបអាហារ។ នៅកម្ពុជា កិច្ចព្រមព្រៀងបែបនេះនៅមានកម្រិតខ្លាំងណាស់ ប៉ុន្តែយ៉ាងហោចណាស់ ក៏មានកិច្ចព្រមព្រៀងដែលបានជោគជ័យ ២ ករណីហើយដែរ គឺករណីអង្គរក្រអូប និងថ្នាំជក់[៦៣]។

## ទ្រង់ទ្រាយនៃកសិកម្មក្នុងកិច្ចសន្យា មានដូចតទៅនេះ :[៦៤]

ក. ក្រុមហ៊ុនកែច្នៃកសិផលធំមួយ ចុះកិច្ចសន្យាទិញកសិផលពីកសិករតូចតាចជាច្រើនក្នុងតម្លៃ និងចំនួនដែលបានកំណត់ជាមុន។

ខ. ត្រូវមានការត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់លើគុណភាព និងសម្ភារៈបរិក្ខាដែលប្រើក្នុងការផលិតកសិផល។

គ. កសិផលត្រូវតែមានបរិមាណក្នុងកម្រិតអប្បបរមាមួយជាដាច់ខាត បើពុំនោះសោត ក្រុមហ៊ុននឹងមិនឃើញផលប្រយោជន៍អ្វីក្នុងការចុះកិច្ចសន្យាជាមួយកសិករទេ។ ដើម្បីធ្វើយ៉ាងនេះ បានកសិករត្រូវមានឧបករណ៍គ្រប់គ្រាន់ ដូចជា ប្រព័ន្ធស្រោចស្រព ដែលអាចគ្រប់គ្រងបាន និងគ្រឿងយន្តផ្សេងៗសម្រាប់ប្រើក្នុងការផលិត។

ឃ. កសិករអាចចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនដោយផ្ទាល់ ឬកសិករបង្កើតសហករណ៍ធំៗសិន ហើយឱ្យសហករណ៍ទាំងនោះចុះកិច្ចសន្យាជាមួយក្រុមហ៊ុន (ជាជំនួសកសិករទាំងអស់)។ ក្នុងករណីខ្លះទៀត សហករណ៍ខ្លួនឯងក៏អាចបង្កើតសិប្បកម្មកែច្នៃដែរ ប៉ុន្តែគំនិតនេះនៅមិនទាន់អាចធ្វើទៅបានទេបច្ចុប្បន្ននេះ។

---

*(៦១) ករណីមួយស្តីអំពីលក្ខខណ្ឌពាណិជ្ជកម្មសមស្របសម្រាប់ផលិតករ, កសិករសាមញ្ញ ត្រូវបានធ្វើឡើងដោយ UNDP នៅកន្លែងផ្សេងទៀត។ សូមមើល http://www.undp-povertycentre.org/pub/IPCOnePager24.pdf.*

*(៦២) អង្គការ CEDAC កំពុងបង្កើតសមាគមកសិករនៅខេត្តតាកែវ និងកំពត។*

*(៦៣) ACI (២០០៥); http://www.angkorrice.com.*

*(៦៤) Golletti (២០០៤)*

## តើកសិករខ្មែរបានផលប្រយោជន៍ពីកសិកម្មជាប់កិច្ចសន្យា ឬពីប្រព័ន្ធលក់ដូរជាក្រុម ឬទេ?

ក. នៅកសិដ្ឋានទាំងឡាយណា ដែលជិតផ្លូវឡាន និងផ្លូវរថភ្លើងកសិករអាចទទួលផលប្រយោជន៍ច្រើន។

ខ. កសិករទាំងឡាយណាដែលអាចប្រើប្រាស់ដីរបស់ខ្លួនទាំងអស់ ឬក៏មួយផ្នែក ដើម្បីផលិតផលដំណាំសម្រាប់លក់នៅទីផ្សារឱ្យបានច្រើន ទោះបីជាកសិករតូចតាចក៏ដោយ ក៏អាចទទួលផលចំណេញបានដែរ។ កសិករក្រីក្រជាងគេបំផុតប្រហែលជាមិនអាចទទួលផលពីប្រព័ន្ធនេះភ្លាមៗបានទេ ដោយហេតុថាកសិករទាំងនោះ ពុំអាចផលិតកសិផលតាមគុណភាព និងបរិមាណដែលត្រូវការ។ ប៉ុន្តែកសិករតូចៗ ដែលអាចផលិតបានច្រើនលើសពីសេចក្តីត្រូវការក្នុងគ្រួសារ ក៏អាចចូលរួមប្រកបដោយជោគជ័យបានដែរ។

គ. ការប្រមូលផ្តុំកសិករជាក្រុម គឺជាការលំបាកបំផុត ប៉ុន្តែមិនមែនធ្វើមិនកើតទេ។ មានករណីច្រើនដែរដែលធ្លាប់បានជោគជ័យ។ សមាជិកនៃអង្គការដែលបានជោគជ័យពិតជាបានផលប្រយោជន៍។

ឃ. កសិករប្រាកដជាចំណេញ ប្រសិនបើថ្លៃលក់កសិផលមិនធ្លាក់ចុះ និងមានការចរចាគ្នាទៅវិញទៅមកអំពីទំនាក់ទំនងរវាងថ្លៃផលិត និងទំនិញឡើងថ្លៃ។

ង. ដូចគ្នានេះដែរ កសិករអាចចំណេញប្រសិនបើបច្ចេកវិទ្យានានា និងមធ្យោបាយសម្រាប់ប្រើប្រាស់បច្ចេកវិទ្យា ទាំងនោះត្រូវបានផ្ទេរទៅឱ្យកសិករ។

ច. រក្សាតម្លៃនៅមូលដ្ឋានបានកាន់តែខ្ពស់ ផលប្រយោជន៍នៅមូលដ្ឋានក៏បានកាន់តែច្រើន។

*ជម្រើសទី ៤ :*

នៅក្នុងប្រទេសជាច្រើន (ជាចម្បង គឺអាស៊ីអាគ្នេយ៍ អាស៊ីខាងកើត អាស៊ីបូព៌ា និងនៅអឺរ៉ុបភាគច្រើន) កសិផលកសិកម្មតែងតែទទួលបានការធានាថ្លៃលក់ យ៉ាងហោចណាស់ ក៏ក្នុងកម្រិតអប្បបរមាតាមរយៈប្រព័ន្ធថ្លៃគាំទ្រអប្បបរមា (MSP)។ ប្រព័ន្ធ MSP នេះ មិនចាំបាច់ឱ្យរដ្ឋាភិបាលទិញទាំងអស់ទេ។ មិនដូចកាលពីទសវត្សរ៍ឆ្នាំ ១៩៨០ ដែលត្រូវតែលក់កសិផលទាំងអស់ទៅជូនរដ្ឋាភិបាលក្នុងតម្លៃមួយដែលត្រូវបានកំណត់ជាមុន។ ប្រព័ន្ធ MSP គ្រាន់តែកំណត់តម្លៃក្នុងកម្រិតមួយ ដើម្បីការពារកសិករទប់ទល់នឹងការធ្លាក់ថ្លៃប្រចាំរដូវតែប៉ុណ្ណោះ។ ឈ្មួញឯកជនក៏អនុវត្តប្រព័ន្ធនេះបានដែរ ឱ្យតែមានការឧបត្ថម្ភបន្ថែមពីរដ្ឋាភិបាលសម្រាប់បំពេញគម្លាតនៃតម្លៃរវាងថ្លៃលក់នៅទីផ្សារ និងថ្លៃដែលប្រព័ន្ធ MSP នេះបានទិញ ជាពិសេសនៅពេលណាដែលថ្លៃលក់នៅទីផ្សារធ្លាក់ចុះទាបជាងតម្លៃដែលទិញពីកសិករ។ ផ្ទុយទៅវិញ ប្រសិនបើថ្លៃលក់នៅទីផ្សារឡើងខ្ពស់លើសកម្រិតអប្បបរមានេះ រដ្ឋាភិបាលតម្រូវឱ្យឈ្មួញឯកជនបង់ពន្ធជូនរដ្ឋ។ ប្រព័ន្ធបែបនេះត្រូវបានគេមើលឃើញថា ប្រាក់ជួយឧបត្ថម្ភ (តម្លៃដែលខាត) និងប្រាក់បង់ពន្ធ (លើប្រាក់ចំណេញ) នឹងទូទាត់គ្នាទៅវិញទៅមកបាននាពេលខាងមុខ។

ប៉ុន្តែប្រព័ន្ធ MSP នេះក៏មានចំណុចខ្សោយរបស់វាដែរ។ វាមិនបានលើកទឹកចិត្តឱ្យកសិករខំប្រឹងបង្កើនប្រសិទ្ធភាព និងលើកកម្ពស់ការដាំដំណាំច្រើនមុខទេ។ នៅប្រទេសខ្លះ ប្រព័ន្ធនេះធ្វើឱ្យមានឱនភាពថវិកាយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះក្នុងបរិបទស្រុកខ្មែរប្រព័ន្ធនេះ ប្រហែលជាប្រើមិនទាន់បានទេ។

ទាំងនេះ គឺជាជម្រើសបួនបែប ប៉ុន្តែក៏អាចមានជម្រើសដទៃៗទៀតដែរ។ គោលបំណង គឺការពារផលប្រយោជន៍កសិករទប់ទល់នឹងសម្ពាធបញ្ចុះថ្លៃស្រូវក្នុងអំឡុងពេលប្រមូលផល ហើយដាក់បញ្ចូលចំណាយផ្សេងៗទៅជាបន្ទុករបស់ឈ្មួញ។ ចំណាយអស់ទាំងនោះ មិនគួរឱ្យកសិករទទួលបន្ទុកទេ។

*ទិសដៅ គឺការពារកសិករកុំឱ្យជួបប្រទះនឹងសម្ពាធនៃតម្លៃស្រូវចុះថោកក្នុងពេលប្រមូលផល ដើម្បីជាប្រយោជន៍ឱ្យកសិករ ហើយធ្វើឱ្យចំណាយផ្សេងៗទៅជាបន្ទុករបស់ឈ្មួញ*

## ៤.៥ ទីផ្សារលក់ត្រី និងសត្វពាហនៈ

### *ផ្នែកទីផ្សារត្រី*

ផលត្រីកម្ពុជាភាគច្រើនត្រូវបានប្រើប្រាស់ក្នុងប្រទេស មួយផ្នែកធំនៃផលត្រីទាំងនោះ គេបរិភោគនៅក្នុងអនុតំបន់ជាតិ ដែលជាកន្លែងគេចាប់ត្រីបាន។ ត្រីត្រូវគេបរិភោគស្រស់ ប៉ុន្តែ ១០ ភាគរយ នៃចំនួនត្រីទាំងអស់ គេហាលថ្ងៃឱ្យស្ងួត ប្រឡាក់អំបិល ឆ្អើ ធ្វើប្រហុក-ផ្អក ឬធ្វើទឹកត្រី។ វិធីកែច្នៃត្រីភាគច្រើនពុំបានប្រើឧបករណ៍ទំនើបទេ ប៉ុន្តែមានក្រុមហ៊ុនឯកជនធំមួយ កំពុងតែប្រើបច្ចេកទេសទំនើបនៅក្នុងទីក្រុងភ្នំពេញ។ លើសពីនេះទៀត នៅក្រុងព្រះសីហនុ មានសិប្បកម្មកែច្នៃ ៣ ដែលមានជំនាញខាងកែច្នៃ និងនាំចេញបង្គារ យៀវហឺ ត្រចៀកថ្ករ ដែលមានការត្រួតពិនិត្យគុណភាពត្រឹមត្រូវ HACCP [៦៥]។ ហើយត្រីខ្លះត្រូវបានគេយកទៅលក់ក្រៅប្រទេសជាចម្បង គឺប្រទេសថៃ និងវៀតណាម។ ពាណិជ្ជកម្មអន្តរជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងមួយផ្នែក ដោយក្រុមហ៊ុនមួយដែលរៀបចំដោយរដ្ឋាភិបាលដែលចាត់តាំងភ្នាក់ងារឯកជនឱ្យប្រមូលទិញផលនេសាទដោយបង់ពន្ធជូនរដ្ឋតាមកំណត់។ ផលនេសាទមួយចំនួនធំ ត្រូវបាននាំចេញដោយមិនឆ្លងតាមប្រព័ន្ធផ្លូវការដើម្បីគេចវេសពីការិយាធិបតេយ្យ។

---

*(៦៥) ការពិនិត្យគុណភាពត្រឹមត្រូវ និងវិភាគនូវគ្រោះថ្នាក់នៃអាហារសមុទ្រ HACCP ផ្តល់អាជ្ញាប័ណ្ណដោយមជ្ឈមណ្ឌលសុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភនៃរដ្ឋបាលឱសថ និងម្ហូបអាហាររបស់សហរដ្ឋអាមេរិក។*

*ផលប៉ះពាល់នៃការឡើងថ្លៃទាំងនេះ មានឥទ្ធិពលទាំងទៅលើឈ្មួញតូចតាច និងផលិតករតូចតាចផងដែរ ប៉ុន្តែភាគច្រើន គឺប៉ះពាល់ខ្លាំងទៅលើអ្នកនេសាទតូចតាច*

រហូតមកទល់ឆ្នាំ ២០០១ ផលនេសាទមួយផ្នែកធំដែលលក់ចេញទៅក្រៅបាន គឺជាផលនេសាទរបស់ឡូត៍នេសាទ ដែលត្រូវបានប្រមូលទិញដោយឈ្មួញនៅតាមច្រាំងទន្លេ និងទីផ្សារមួយចំនួន។ ការកាត់បន្ថយឡូត៍នេសាទ បានបើកឱកាសឱ្យអ្នកនេសាទសាមញ្ញអាចរកត្រីបានច្រើនជាងមុន។ ប៉ុន្តែកន្លែងឡើងច្រាំងសម្រាប់យកត្រីមកលក់ក៏កាន់តែច្រើន ហើយកន្លែងនីមួយៗ មានត្រីសម្រាប់លក់តែបន្តិចបន្តួច។ កត្តានេះបណ្តាលឱ្យមានបញ្ហាផ្នែកទីផ្សារ ព្រោះការប្រមូលត្រីតែបន្តិចបន្តួចពីកន្លែងច្រើនផ្សេងៗគ្នាតាមច្រាំងទន្លេនេះ មិនអំណោយផលសម្រាប់ធ្វើជំនួញទេ។

អ្នកនេសាទលក់តាមតម្លៃត្រី ដែលឈ្មួញកណ្តាលទៅទិញនៅមាត់ច្រាំងដែលជាតម្លៃមិនសូវជាល្អប៉ុន្មានទេ។ ឈ្មួញកណ្តាលបានផលពី ៦៥-៧៥ ភាគរយ រីឯអ្នកនេសាទបានត្រឹមតែ ២៥ ឬ ៣៥ ភាគរយ តែប៉ុណ្ណោះ (រូបភាព ៤.១១)។ កិច្ចសន្យាសង្គម និងកិច្ចសន្យាពាណិជ្ជកម្ម តាមរយៈប្រាក់កម្ចីដែលមានការប្រាក់ខ្ពស់ គឺជាចំណងចងអ្នកនេសាទតូចតាចជាមួយនឹងឈ្មួញកណ្តាល។ ឈ្មួញកណ្តាលឱ្យប្រាក់អ្នកនេសាទខ្ចីជាមុន ដល់ឆ្នាំបន្ទាប់ អ្នកនេសាទត្រូវសងវិញជាត្រី ក្នុងតម្លៃមួយដែលបានកំណត់ជាមុនហើយស្រេច។ ធ្វើបែបនេះ ឈ្មួញកណ្តាលគ្រប់គ្រងទាំងស្រុងលើមុខរបរនេះ ហើយអ្នកនេសាទមិនអាចធ្វើអ្វីកើតទាល់តែសោះ ដោយសារពួកគេខ្វះមធ្យោបាយរកទីផ្សារ និងខ្វះមធ្យោបាយហិរញ្ញវត្ថុ[៦៦]។

*រូបភាព ៤.១១ : តម្លៃត្រីដែលខុសគ្នាពីទន្លេសាបទៅភ្នំពេញ*



*ប្រភព :* *Yim and McKenny (2003)*

ចំណាយលើការដឹកជញ្ជូនខ្ពស់ (យានយន្តយឺត ផ្លូវអាក្រក់) គួបជាមួយនឹងឧបករណ៍រក្សាត្រីមិនបានល្អ បណ្តាលឱ្យខូចខាតផលនេសាទអស់ច្រើន ដែលជាហេតុនាំឱ្យកើនតម្លៃលើឯកតានីមួយៗ ការបង់លុយក្រៅប្រព័ន្ធ ក៏នាំឱ្យថ្លៃដើមកាន់តែថ្លៃថែមទៀតដែរ។ ផលនេសាទមួយផ្នែកត្រូវបានលក់ទៅប្រទេសថៃ ដែលជាកន្លែងមានភាពមិនប្រាកដប្រជាមួយទៀត ដោយសារឈ្មួញថៃវាយតម្លៃជាប្រាក់បាត រីឯតម្លៃដឹកជញ្ជូនផ្សេងៗនៅកម្ពុជាគិតជាប្រាក់ដុល្លារ។ ការឡើងចុះនៃអត្រាប្តូរប្រាក់បាត និងដុល្លារមានផលប៉ះពាល់អវិជ្ជមានដល់អ្នកនេសាទខ្មែរ។ ទីបញ្ចប់ ប្រេងឥន្ធនៈឡើងថ្លៃ ដែលផ្ទុយនឹងតម្លៃត្រីដែលចុះថោក មានផលប៉ះពាល់អវិជ្ជមានខ្លាំងទៅលើអ្នកនេសាទស្រដៀងគ្នាទៅនឹងផលប៉ះពាល់អវិជ្ជមានចំពោះកសិករដែរ។ ផលប៉ះពាល់នៃការឡើងថ្លៃទាំងនេះ មានឥទ្ធិពលទាំងទៅលើឈ្មួញតូចតាច និងផលិតករតូចតាច ប៉ុន្តែប៉ះពាល់ខ្លាំងជាងគេ គឺទៅលើអ្នកនេសាទតូចតាចចុងក្រោយបំផុត។

---

(66) Yim and McKenney (២០០៣); Rab, Hap, Seng, Ahmed and Viner (២០០៥); Sok (២០០៥).

## ប្រអប់ ៤.៧ : ការជួញដូរត្រី - ការសង្កេតតាមមូលដ្ឋានពីដើមទសវត្សរ៍ឆ្នាំ ២០០០

*ការសង្កេតទី ១ : ប្រាក់បង់ថ្លៃនាំចេញខ្ពស់*

អ្នកនាំទំនិញទៅលក់នៅប្រទេសថៃត្រូវបង់ប្រាក់ ២៨ ដង (រួមទាំង ៣ ដង នៅក្នុងទឹកដីប្រទេសថៃផងដែរ) ក្នុងនោះមាន ៨ ដង ត្រូវបង់ឱ្យនគរបាលសេដ្ឋកិច្ច ៣ ដង បង់ឱ្យផ្នែកនេសាទខេត្ត ២ ដង បង់ឱ្យអាវុធហត្ថ និងភាគីដទៃៗទៀត ដែលការបង់ខ្លះស្របច្បាប់ ខ្លះទៀតក៏មិនស្របច្បាប់។ ក្នុងចំណោមការចំណាយទាំងអស់នេះ ការបង់ពន្ធឱ្យគយថៃ (ដោយមិនមានមូលដ្ឋានច្បាប់) គឺជាការបង់ដែលខ្ពស់ជាងគេបំផុត គឺច្រើនជាងពីរដងនៃពន្ធផ្លូវការជូនគយកម្ពុជា។ ការបង់សំខាន់ៗដទៃទៀត គឺបង់ជូន KAMFIMEX ដែលជាការបង់ពន្ធផ្លូវ ហើយបង់ជូនអាជ្ញាធរនៃនាយកដ្ឋាននេសាទ និងការិយាល័យនេសាទខេត្តនៅប៉ោយប៉ែត។ ប្រាក់ដែលត្រូវបង់ទាំងអស់នេះ ស្មើនឹង ៣៣ ភាគរយ នៃប្រាក់ចំណេញរបស់អ្នកនាំចេញ ហើយ ៥២ ភាគរយ សម្រាប់ថ្លៃដឹកជញ្ជូនថ្លៃពលកម្ម និងថ្លៃកិច្ចការផ្សេងៗទៀត នៅសល់តែ ១៥ ភាគរយទេ ដែលជាប្រាក់ចំណេញសុទ្ធសាធ។

*ការសង្កេតទី ២ : ការដឹកជញ្ជូនមានតម្លៃខ្ពស់*

ត្រីស្រស់ក៏គេដឹកយកទៅលក់នៅប្រទេសថៃដែរ។ ពីទន្លេសាបទៅប៉ោយប៉ែត ឈ្មួញកណ្តាលត្រូវចំណាយ ដឹកជញ្ជូន ១ គីឡូ ថ្លៃ ៥ បាត (ដឹកមួយឡានទម្ងន់ ៣០ តោន) សម្រាប់ថ្លៃដឹកជញ្ជូន (តម្លៃប្រេងម៉ាស៊ូត និងចំណាយផ្សេងៗ) តម្លៃផ្លូវ និងតម្លៃនៅតាមកុងត្រូលនានា។ ពួកគេត្រូវបង់បន្ថែមថ្លៃអាជ្ញាប័ណ្ណមួយក្នុងតម្លៃ ១០ ម៉ឺនរៀល មួយជើង និងឈ្នួលកម្មករ ៤០ ម៉ឺនរៀល ក្នុងមួយខែ។ នៅព្រំដែន ឃ្លាំងស្តុកទំនិញថ្លៃពី ៣-៤ ម៉ឺនរៀល (ក្នុងមួយឡាន-មួយជើង) ទោះបីមានតែឈ្មួញធំៗដែលប្រើឃ្លាំងនេះក៏ដោយ។ ការធ្វើបែបនេះមិនចម្រើនក្នុងផ្លូវសេដ្ឋកិច្ចទេ ដោយឡែកវាជាការខ្ជះខ្ជាយចំណាយច្រើន។ ទឹកកកសម្រាប់ស្តុករក្សាត្រីស្រស់ក្នុងឃ្លាំងថ្លៃ ៥ ម៉ឺនរៀល។ បន្ថែមលើតម្លៃទាំងអស់នេះ គឺមានតម្លៃឆ្លងព្រំដែន ១០ ម៉ឺនរៀល ពន្ធគយថៃ (៥០០ បាត ក្នុងមួយតោន) ព្រមទាំងការសូកបន្ថែមទៀតដើម្បីឆ្លងព្រំដែន។ ឈ្មួញតូចៗឆ្លងព្រំដែន និងលក់ទំនិញរបស់ខ្លួនឱ្យតែអស់តាមតម្លៃគេកំណត់។ ចំណាយសម្រាប់ដឹកទំនិញតាមកប៉ាល់មកលក់នៅទីក្រុងភ្នំពេញវិញ គឺទាបជាង ពីព្រោះចម្ងាយផ្លូវជិតជាងចំណុចឆែកឆេរតិចជាង ហើយការបង់លុយក្រៅផ្លូវការក៏តិចដែរ។ ក៏ប៉ុន្តែនៅភ្នំពេញថ្លៃលក់ទំនិញទាំងនេះ ក៏ទាបជាងថ្លៃលក់នៅប៉ោយប៉ែតដែរ។

*ប្រភព : សេចក្តីសង្កេត ១ Achaya, Kim, Chap and Meach (២០០៦); សេចក្តីសង្កេត ២ Rab, Hap, Seng, Ahmed and Viner (២០០៥)*

## ប្រអប់ ៤.៨ : ថ្លៃដឹកជញ្ជូនខ្ពស់ ដែលអ្នកភូមិនៅទន្លេសាបជួបប្រទះ

ភូមិជាច្រើននៅរាយប៉ាយតាមដងទន្លេសាប ភាគច្រើននៃអ្នកភូមិ គឺជាអ្នកនេសាទ ដែលមានដីបន្តិចបន្តួច ហើយដីទាំងនោះលិចទឹកនៅរដូវវស្សា គេធ្វើដំណើរទៅមកបានដោយសារទូកនៅគ្រប់រដូវ។ ជីវភាពចម្បងរបស់ពួកគេពឹងផ្អែកលើរបរនេសាទត្រី។ ដូច្នេះឧបករណ៍នេសាទ និងតម្លៃដឹកជញ្ជូនថោក និងព័ត៌មានស្តីអំពីតម្លៃលក់-ដូរផលនេសាទមានសារៈសំខាន់ណាស់ សម្រាប់ជីវភាពរស់នៅរបស់គេ។

ទស្សនកិច្ចដល់ទីកន្លែងនៅខេត្តកំពង់ឆ្នាំង បានរកឃើញថា ថ្លៃប្រេងម៉ាស៊ូតនៅភូមិអស់ទាំងនោះ មានតម្លៃប្រហែល ២០-២៥ ភាគរយ ខ្ពស់ជាងថ្លៃលក់នៅផ្សារដែលមានចម្ងាយតែ ២-៣ គីឡូម៉ែត្រប៉ុណ្ណោះ។ ដូចគ្នានេះដែរ ត្រីស្រស់ និងផលិតផលធ្វើពីត្រី ដែលគេលក់ឱ្យឈ្មួញ ដែលទៅទិញដល់ភូមិទាំងនោះ ថោកជាងពី ១០-២០ ភាគរយ បើប្រៀបធៀបទៅនឹងថ្លៃលក់នៅទីផ្សារទាំងនោះ។ រីឯទឹកកកសម្រាប់ស្តុករក្សាត្រីស្រស់នៅភូមិទាំងនោះ ក៏ថ្លៃខ្ពស់ជាងទឹកកកដែលលក់នៅផ្សារដែរ។

នៅតាមកន្លែងលក់ត្រីនីមួយៗ ត្រីដែលមានគុណភាពអាចលក់ចេញបានមានតែបន្តិចបន្តួច ហេតុនេះការដឹកជញ្ជូន តាមទូកមានតម្លៃខ្ពស់។ ឈ្មួញកណ្តាលគ្រប់គ្រងលើប្រាក់កម្ចី និងតម្លៃទិញដូរទាំងស្រុង គឺគេឱ្យខ្ចីប្រាក់ជាមុន ហើយប្រមូលយកត្រីសងជំនួសប្រាក់កម្ចីនោះវិញ ក្នុងអាត្រាការប្រាក់ពី ៤-៦ ភាគរយក្នុងមួយខែ។ ថ្វីត្បិតតែសហគមន៍នេសាទជាច្រើនបានបង្កើតប្រាក់សន្សំតាមក្រុមក៏ដោយ ក៏ចំនួននៃប្រាក់សន្សំសព្វថ្ងៃនេះនៅតិចពេក មិនទាន់អាចប្រើប្រាស់ជាដើមទុនរកស៊ីបាន ពោលគឺប្រាក់ទាំងអស់នេះប្រើបានសម្រាប់តែខ្ចីយកទៅទិញស្បៀងអាហារនៅក្នុងរដូវខ្វះខាត។ ដើម្បីដោះស្រាយបញ្ហាដែលបានរៀបរាប់ខាងលើនេះ ត្រូវមានប្រព័ន្ធដឹកជញ្ជូន និងប្រព័ន្ធទំនាក់ទំនងថោក។

បច្ចុប្បន្ននេះ សហគមន៍គ្រប់គ្រងការនេសាទយកចិត្តទុកដាក់តែទៅលើការគ្រប់គ្រងធនធាន : បញ្ហា អេកូឡូស៊ី ឧបករណ៍នេសាទ និងការឃ្លាំមើលប្រឆាំងនឹងការនេសាទខុសច្បាប់ និងវិស័យផ្សេងៗខ្លះទៀតតែប៉ុណ្ណោះ។ រីឯការរកទីផ្សារ ការរៀបចំប្រព័ន្ធឥណទាន ឬការគ្រប់គ្រងតម្លៃលក់ត្រី មិនមាននៅក្នុងរបៀបវារៈនៃកិច្ចការរបស់សហគមន៍នេសាទទេ។

*ប្រភព : ទស្សនកិច្ចដល់ទីកន្លែង នៅខេត្តកំពង់ឆ្នាំង ខែ កញ្ញា-ធ្នូ ឆ្នាំ ២០០៦*

គួរយកមេរៀនតាមបទពិសោធន៍ប្រទេសដទៃៗទៀត ដែលទីផ្សារសហគមន៍លក់ត្រីសាច់មានដំណើរការល្អ

*រូបភាព ៤.១២ : បណ្តាញលក់ត្រីទឹកសាប*




*ប្រភព : ដកស្រង់អំពី Sok (២០០៥), Rab, Hap, Seng, Ahmed and Viner (២០០៥), and Acharya, Kim, Chap and Meach (២០០៣)*

តើត្រូវធ្វើយ៉ាងណាដើម្បីលើកកម្ពស់ផលិតភាព និងបង្កើនទីផ្សារសម្រាប់ផលិតករតូចតាចរួមទាំងអ្នកនេសាទត្រី ដែលជាស្ត្រីហើយនិងអ្នកកែច្នៃផលត្រី ?

ក. ក្នុងការផ្តើមប្រើប្រាស់បច្ចេកទេសនេសាទទំនើប ការចាប់ត្រីដោយម្ចាស់ឡូតិ៍នេសាទ និងអ្នកនេសាទត្រីឯកជន មានការខុសគ្នាកាន់តែធំឡើង ។ ស្ត្រី និងជនជាតិភាគតិច ដែលជាអ្នកនេសាទត្រីទទួលផលប៉ះពាល់នេះ ធ្ងន់ជាងគេ[៦៧] ។ ជាការសំខាន់ត្រូវផ្តល់ឱ្យអ្នកទាំងនោះនូវឧបករណ៍នេសាទទំនើបខ្លះ (ដូចជា មង និងទូកធ្វើដោយជ័រផ្លាស់ស្ទិកជាដើម) ថែមទាំងការខំប្រឹងប្រែងចែករំលែកបទពិសោធន៍ជូនអ្នកទាំងនោះ រួមទាំងស្ត្រីផង ។ ជួនកាល ការផ្តល់ឧបករណ៍នេសាទទំនើប អាចជួយបង្កើតការងារដល់អ្នកភូមិនៅខាងក្រោយទៀតផង ។ ការឧបត្ថម្ភអស់ទាំងនេះ អាចធ្វើបានតាមរយៈផែនការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងលើកស្ទួយជីវភាពរបស់ពលរដ្ឋ ។

ខ. ថ្លៃលក់ត្រីនៅតាមច្រាំង ដែលសព្វថ្ងៃនេះលក់តាមតែឈ្មួញឱ្យថ្លៃ គួរតែធ្វើឱ្យល្អប្រសើរជាងសព្វថ្ងៃ ។ វិធីលក់ត្រីរួមគ្នា អាចជាមធ្យោបាយជួយឱ្យអ្នកនេសាទលក់ត្រីបានតម្លៃល្អប្រសើរជាង (ប្រអប់ ៤.៩) ។ សហគមន៍នេសាទត្រី គួរតែអាចបង្កើតយន្តការសម្រាប់ការពារតម្លៃលក់ត្រី[៦៨][៦៩] ។

គ. កន្លែងយកត្រីទៅលក់សព្វថ្ងៃនេះមិនមានឧបករណ៍គ្រប់គ្រាន់ទេ ។ សហករណ៍លក់ត្រីរបស់ក្រុមអ្នកនេសាទ ត្រូវតែមានធនធានផ្ទាល់ខ្លួន សម្រាប់រៀបចំឱ្យមានឧបករណ៍ប្រើប្រាស់ ដូចជា ការរកទឹកកកសម្រាប់រក្សាត្រី ឬមានទូទឹកកកសម្រាប់បង្កកត្រីរួមគ្នា ឧបករណ៍ដឹកជញ្ជូនខ្លះ ទូរស័ព្ទទាក់ទង និងដើមទុនមួយចំនួនតូច សម្រាប់ជួយរំដោះកសិករក្រីក្រចេញអំពីអន្ទាក់របស់ភ្នាក់ងារកេងប្រវ័ញ្ច ។

ឃ. គួរពិចារណាលើការកែច្នៃដើម្បីបង្កើនគុណភាពត្រី ជាជាងទុកឱ្យគ្រួសារនីមួយៗ យកត្រីទៅហាល ប្រឡាក់ អំបិល ឆ្អើរ ឬធ្វើអ្វីផ្សេងៗទៀត តាមដែលអ្នកនេសាទយល់ថាចំណេញ ។ ផលិតករស្ត្រីដែលមានតួនាទីចម្បងក្នុងការកែច្នៃត្រី អាចនឹងបានផលជាពិសេស អំពីផែនការនេះ ។

ង. រដ្ឋាភិបាលគួរបង្កលក្ខណៈងាយស្រួលតាមផែនការនេះ ដោយកាត់បន្ថយការបង់ប្រាក់នៅតាមផ្លូវ បន្ទាបតម្លៃភាស៊ីនៅផ្សារ និងបង្កើនចំនួនផ្សារសម្រាប់លក់ត្រី ឧទាហរណ៍ ដូចជាសព្វថ្ងៃនេះ នៅភ្នំពេញមានចំណុចសម្រាប់លក់ត្រីតែ ៣ កន្លែងទេ ។

គួរយកមេរៀនតាមពិសោធន៍ប្រទេសដទៃៗទៀត ដែលទីផ្សារសហគមន៍លក់ត្រីមានដំណើរការល្អ ។ SIF FS ដែលជាសមាគមលើកស្ទួយ និងបង្កើនទីផ្សារលក់ត្រី ហើយនិង AMUL សហករណ៍ទឹកដោះគោ អាចយកជាឧទាហរណ៍ក្នុងវិស័យនេះបាន ។ (ប្រអប់ ៤.១០) ។

(៦៧) ស្ត្រីមានតួនាទីចម្បងក្នុងការកែច្នៃ និងលក់ត្រី ។ សូមមើល Kusakabe, Prak, Ubolratana, Napaporn (2005).

(៦៨) អង្គការ Oxfam (២០០៥) វាយតម្លៃស្ថានភាពបច្ចុប្បន្ននៃសហករណ៍ ហើយរកឃើញថា ព័ត៌មានទាំងឡាយមិនបានចែកចាយទៅដល់កសិករទេ ហើយអង្គការកសិករ ក៏មិនទាន់ចាប់កំណើតដែរ ។ ចំណុចនេះទាមទារឱ្យមានការពង្រឹង ។

(៦៩) ប្រទេស Norway ក៏មានការចរចាតម្លៃលក់ត្រីដែរ ។ ទាំងសាធារណរដ្ឋកូរ៉េ ទាំងប្រទេសជប៉ុន សុទ្ធតែមានសហករណ៍សម្រាប់លក់ត្រី (the Zengoren) ។ Sok (២០០៥), Bush និង Minh (២០០៥) និង Kurien, So និង Mao (២០០៦) បានដាក់ស្នើវិធីនេះសម្រាប់កម្ពុជា នៅក្នុងសហគមន៍អ្នកនេសាទត្រី ។

**ប្រអប់ ៤.៩ : ភារកិច្ចទទួលខុសត្រូវរបស់ប្រព័ន្ធទីផ្សារលក់ត្រីសហគមន៍នៅកម្ពុជា**

***ការងារជាមូលដ្ឋាន :***

ក. បង្កើតសហករណ៍សម្រាប់អ្នកនេសាទត្រី ដែលត្រូវយកត្រីរបស់ខ្លួន ពោលគឺយ៉ាងហោចណាស់មួយថ្ងៃម្តងទៅចំណុចរួមមួយ ឬទុកឱ្យតំណាងម្នាក់របស់អ្នកនេសាទទាំងនោះ ដើរតួជាភ្នាក់ងាររបស់ពួកគេ ដេញថ្លៃលក់ត្រីជំនួសអ្នកនេសាទទាំងនោះ ។

ខ. បង្កើតប្រព័ន្ធចែកចាយព័ត៌មាន និងរៀបចំឱ្យមានដើមទុនសម្រាប់នេសាទឱ្យអ្នកនេសាទខ្ចីក្នុងការប្រាក់សមរម្យ ។

គ. បង្កើតអង្គភាពបង្កកត្រី( ឬសិប្បកម្មធ្វើទឹកកក-អាចអញ្ជើញសហគ្រាសឯកជនឱ្យបង្កើតសិប្បកម្មធ្វើទឹកកកក្នុងកិច្ចធានាព្រមព្រៀងលក់ទឹកកកទាំងអស់ឱ្យសហករណ៍អ្នកនេសាទ ព្រមទាំងបង្កើតទីតាំងត្រួតពិនិត្យគុណភាពត្រីនៅតាមច្រាំងទន្លេដែលយកត្រីទៅលក់ ។

ឃ. ចរចាដើម្បីកាត់បន្ថយការទារឱ្យបង់ប្រាក់ក្រៅផ្លូវការ និងកាត់បន្ថយចំណុចឆែកឆេរ ។

***ការងារកម្រិតខ្ពស់ :***

ក. ដឹកជញ្ជូនផលិតផលត្រីពីច្រាំងទន្លេទៅទីផ្សារធំៗដោយខ្លួនឯង ប្រសិនបើឈ្មួញកណ្តាលមិនចង់ ឬលក្ខខណ្ឌរបស់គេមិនល្អ ។ ដើម្បីធ្វើដូច្នេះ ទូក ឬឡានដឹកត្រី ត្រូវបំពាក់ឧបករណ៍ម៉ាស៊ីនត្រជាក់ ឬឧបករណ៍រក្សាគុណភាពត្រី ។

ខ. ជម្រុញឱ្យបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចបែបវិមជ្ឈការ ដោយមានការរួមចំណែកតាមខ្សែបណ្តោយសម្រាប់រកទីផ្សារលក់ត្រី ។

គ. ជួយបង្កើតតម្លៃបន្ថែមនៃសិប្បកម្មវេចខ្ចប់ ឬឧបករណ៍ដទៃទៀត សម្រាប់ផលនេសាទទាំងឡាយណា ដែលមិនអាចលក់បានភ្លាមៗ ។

ដោយសារស្ត្រីតែងតែជាផលិតករ និងជាឈ្មួញតូចតាច ពួកគេនឹងធ្លាក់ចេញពីប្រព័ន្ធនេះ ប្រសិនបើមិនមានការយកចិត្តដាក់ពិសេសណាដើម្បីធានាឱ្យមានទីកន្លែងមួយសម្រាប់ពួកគេទេនោះ ។

## ***ការចិញ្ចឹមសត្វ***[៧០]

ការចិញ្ចឹមសត្វរួមចំណែកប្រហែល ១៦ ភាគរយ ទៅលើសេដ្ឋកិច្ចផ្នែកកសិកម្ម ។ ជាទូទៅ គឺជាសកម្មភាពប្រចាំគ្រួសារ ហើយដែលផ្តល់ប្រាក់ចំណូលបន្ថែមជូនគ្រួសារ ។ ការចិញ្ចឹម គោ ជ្រូក ពពែ ចៀម និងមាន់-ទា ពិតជាមានការរីកចម្រើនខ្ពស់ ។ លើសពីនេះទៀត ការចិញ្ចឹមសត្វស៊ីសង្វាក់គ្នាល្អណាស់ ជាមួយនឹងក្របខ័ណ្ឌទូទៅនៃប្រព័ន្ធកសិកម្មទំនើប ។ ការនាំសត្វពាហនៈទៅលក់ក្រៅប្រទេសមានសក្តានុពលខ្ពស់ដោយនៅឆ្នាំ ២០០៤ គោ ពី ៨-១៥ ម៉ឺនក្បាល បាននាំចេញក្រៅផ្លូវការ ។ ប៉ុន្តែចំនួនផ្លូវការនៃការនាំចេញទាបជាងនេះឆ្ងាយណាស់-តែ ១០.៦ ពាន់ក្បាលប៉ុណ្ណោះ ស្មើនឹង ២ ភាគរយ នៃចំនួនសត្វដែលប្រទេសអាស៊ានបានលក់ចេញ ។ វិស័យចិញ្ចឹមសត្វ រួមមាន :

ក. ការចិញ្ចឹមសត្វនៅកម្ពុជា មិនផ្តល់អាហារនៅក្នុងទ្រុង ឬថៃទាំងដូចនៅប្រទេសជាច្រើនដែលលក់សត្វពាហនៈទេ ។ ប្រសិនបើសកម្មភាពចិញ្ចឹមសត្វមានការគ្រប់គ្រងប្រសើរជាងនេះ ការចិញ្ចឹមសត្វពិតជាអាចបង្កើតប្រាក់ចំណូលច្រើនសម្រាប់សេដ្ឋកិច្ចជនបទ ។

ខ. ពាណិជ្ជកម្មសាច់សត្វពាហនៈ មានបញ្ហាពុករលួយនៅក្នុងការដឹកជញ្ជូន និងការឆ្លងព្រំដែន ។ នេះនាំឱ្យតម្លៃឡើងខ្ពស់ និងការផ្ទេរផ្ទួរអូសបន្លាយ ដែលជាកត្តាបណ្តាលឱ្យខាតបង់ថែមទៀត ។ ការខាតបង់នីមួយៗ ប៉ះពាល់ដល់ប្រាក់ចំណូលរបស់កសិករ ហើយក៏ជាការលើកទឹកចិត្តឱ្យមានការរត់ពន្ធ ។ ត្រង់ចំណុចនេះ ការត្រួតពិនិត្យអំពើពុករលួយ គឺជាការមានសារប្រយោជន៍ ។

គ. កម្ពុជាត្រូវតែប្រឹងប្រែងបង្កើតតំបន់សុវត្ថិភាព ការពារជម្ងឺអុតក្តាមនៅក្នុងប្រទេស ដើម្បីទប់ទល់ទៅនឹងការនាំសត្វពាហនៈឆ្លងដែនចូលពីប្រទេសថៃ និងឡាវ ដែលជាប្រទេសមិនទាន់បានជោគជ័យក្នុងការបង្កើតតំបន់គ្មានជម្ងឺនេះនៅឡើយទេ ។

ឃ. ចាំបាច់ត្រូវទប់ស្កាត់ជម្ងឺផ្តាសាយបក្សីឱ្យបានទាំងស្រុង ថ្វីត្បិតតែធ្លាប់បានទទួលជោគជ័យខ្លះៗរួចមកហើយក្តី ។

ពេទ្យសត្វគ្មានព្រំដែន (VSF) បានផ្តើមបង្កើតក្រុមពេទ្យសត្វភូមិមួយចំនួនកាលពីឆ្នាំ ១៩៩៦ ។ ៥ ឆ្នាំក្រោយមក ដោយមានជំនួយពីពេទ្យសត្វគ្មានព្រំដែន ធនាគារពិភពលោក និង IFAD ក្រុមប្រឹក្សារដ្ឋមន្ត្រី បានទទួលស្គាល់ពេទ្យសត្វភូមិអស់ទាំងនោះ ។ នៅឆ្នាំ ២០០៤ ក្រសួងកសិកម្មបានរាយការណ៍ថា បានបង្កើតពេទ្យសត្វ ភូមិចំនួន ៤៤៤៩ នាក់ ស្មើនឹង ៧៥ ភាគរយ នៃពេទ្យសត្វភូមិ ដែលត្រូវការទាំងអស់ (ចំនួន ៥៩០៦ នាក់ សម្រាប់មួយឃុំ ៤ នាក់) ។ ក្នុងរយៈពេល ៨ ឆ្នាំ តមក (១៩៩៦-២០០៤) កសិករតូចតាចចំនួន ២ លាននាក់ ទទួលបានសេវាពីពេទ្យសត្វភូមិទាំងនេះ ប្រកបដោយលទ្ធផលជាទីពេញចិត្ត ។ ប៉ុន្តែរហូតមកទល់ឆ្នាំ ២០០៤ មាន ៨០ភាគរយ នៃកន្លែងចិញ្ចឹមមាន់ទាំងអស់ មិនទាន់ទទួលបានសេវាពីពេទ្យសត្វភូមិនៅឡើយទេ ។ ការប្រមូលផ្តុំផលប្រយោជន៍តាមរយៈសេវារបស់ពេទ្យសត្វភូមិមានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យរីកចម្រើនដល់ផលិតភាពនៃការចិញ្ចឹមសត្វនៅកម្ពុជា ។

កម្ពុជាអាចចំណេញអំពីសេរីភាវូវនីយកម្មនៃពាណិជ្ជកម្មនៅអាស៊ាន (និងអាស៊ានបូក ៤) ហើយជម្រុញការនាំសត្វពាហនៈទៅលក់នៅស្រុកក្រៅឱ្យកាន់តែច្រើននៅក្នុងចំណោមប្រទេសអាស៊ាន និងប្រទេសចិន ។ ចំពោះកិច្ចការនេះ ការធ្វើឱ្យប្រសើរឡើងដល់វិធីថែរក្សាសត្វ គឺជាសារៈសំខាន់ ។ គួរពិនិត្យលទ្ធភាពទៅលើតម្លៃបន្ថែមនៃទំនិញនាំចេញ ដូចជា សាច់ និងទឹកដោះគោជាដើម ។

(៧០) ផ្នែកនេះដកស្រង់ចេញពី Ear (២០០៥) ។

### ប្រអប់ ៤.១០ : ជម្រើសថ្មីក្នុងការរកទីផ្សារលក់ផលិតផលដែលអាចខូចរលួយ – ឧទាហរណ៍ ប្រទេសឥណ្ឌា

***សហករណ៍រកទីផ្សាររបស់អ្នកនេសាទ :***

សហព័ន្ធសង្គមអ្នកនេសាទនៅឥណ្ឌាខាងត្បូង (SIFFS) ជាអង្គការមិនមែនរដ្ឋាភិបាលធ្វើការក្នុងផ្នែកនេសាទត្រីសមុទ្រ។ សហព័ន្ធ (SIFFS) ជាអង្គភាពកំពូលមួយនៃអង្គការនានារបស់ក្រុមអ្នកនេសាទត្រីតូចតាច ដែលមានរចនាសម្ព័ន្ធចាត់តាំងជាបីថ្នាក់។

ដោយមានអ្នកនេសាទត្រីជាសមាជិកជាង ៦ ពាន់នាក់ ត្រូវបានរៀបចំឡើងដោយប្រមូលផ្តុំជា ១០០ ក្រុមនេសាទធំៗ នៅក្នុងស្រុក ៨ នៃប្រទេសឥណ្ឌាភាគខាងត្បូង ក្នុងពីរទសវត្សរ៍កន្លងមក សហព័ន្ធនេះបានផ្តោតលើការពង្រឹងឡូត៍នេសាទត្រីតូចតាច។ នៅឆ្នាំ ២០០៤ សហព័ន្ធនេះរកប្រាក់បាន ៥ លានដុល្លារអាមេរិក។ ជាអង្គការមួយដែលរកទីផ្សារសម្រាប់លក់ត្រី សហព័ន្ធ (SIFFS) ឥឡូវផ្តល់សេវាមួយចំនួនធំជូនអ្នកនេសាទត្រី ទាំងសមាជិក ទាំងមិនមែនសមាជិក។ ការរកទីផ្សារលក់ត្រី គឺជាវិស័យចម្បងមួយ ដែលត្រូវតែធ្វើអន្តរាគមន៍ជាប្រចាំ។

ការត្រួតត្រាលើកន្លែងយកត្រីឡើងច្រាំងលក់ (តាមមាត់សមុទ្រ) គឺជាកិច្ចការនៅកម្រិតថ្នាក់ភូមិនៃសង្គមអ្នកនេសាទត្រី ប៉ុន្តែយកត្រីទៅលក់នៅទីផ្សារហួសពីមាត់សមុទ្រ ស្ថិតទាំងស្រុងនៅក្នុងដៃរបស់ឈ្មួញ ភ្នាក់ងារ និងក្រុមហ៊ុនឯកជន។ ថ្វីត្បិតតែពាណិជ្ជកម្មឯកជន ជាទូទៅមានប្រសិទ្ធភាពក៏ដោយ ក៏មានរដូវខ្លះ ប្រភេទខ្លះ និងនៅទីផ្សារខ្លះ ការអនុវត្តផ្តាច់មុខបណ្តាលឱ្យប៉ះពាល់ជាខ្លាំងដល់ផលប្រយោជន៍អ្នកនេសាទ។ សហព័ន្ធ (SIFFS) បានស្វះស្វែងរកវិស័យថ្មីៗ សម្រាប់ទីផ្សារលក់ត្រី ទាំងត្រីស្រស់ ទាំងត្រីកែច្នៃ តាមរយៈការសាកល្បង ការល្បងពិសោធន៍ក្នុងការនាំត្រីទៅលក់ឯក្រៅ។

ប៉ុន្តែសាកលភាវូបនីយកម្មបានបង្កើតឱ្យមានទាំងឱកាសថ្មី ទាំងការគំរាមកំហែងថ្មី។ សហព័ន្ធ (SIFFS) មានជំនឿថា ប្រសិនបើគុណភាពត្រីមិនមានការរីកចម្រើនទាំងការថែទាំ ទាំងការរក្សាទុកនៅលើទូក និងនៅលើច្រាំងឱ្យបានប្រសើរឡើងទេ អ្នកនេសាទត្រីប្រហែលជាទទួលបរាជ័យនៅក្នុងទីផ្សារអន្តរជាតិ។ ដោយសារហេតុនេះ អាទិភាពរបស់សហព័ន្ធ (SIFFS) គឺកម្មវិធីបង្កើនគុណភាពថែទាំ និងរក្សាត្រី។ សហព័ន្ធ (SIFFS) ក៏ផ្តើមគំនិតយកត្រីទៅលក់នៅទីផ្សារក្នុងស្រុកតាមរយៈហាងលក់ត្រីរាយៗនៅក្រុង Trivandrum។ ហាងនេះទទួលលក់ត្រីដែលសេសសល់ពីការនាំចេញ។

***សហករណ៍លក់ទឹកដោះគោ*** *AMUL :*

បង្កើតនៅឆ្នាំ ១៩៤៦ សហករណ៍ AMUL ផ្តើមចលនារៀបចំសហករណ៍ទឹកដោះគោនៅប្រទេសឥណ្ឌា ភាគខាងលិច ហើយបានបង្កើតអង្គការសហករណ៍កំពូលមួយឈ្មោះ សហករណ៍ Gujarat នៃសហព័ន្ធចំកាត់រកទីផ្សារលក់ទឹកដោះគោ (GCMMF) ដែលសព្វថ្ងៃនេះ ជាសម្បត្តិរួមរបស់អ្នកផលិតទឹកដោះគោប្រហែល ២,២ លាននាក់ នៅក្នុងខេត្ត អុញ្ជរាត ប្រទេសឥណ្ឌា។ ដំបូងផ្តើមពីសហករណ៍រកទីផ្សារលក់ទឹកដោះគោ ក្រោយមកផ្តើមចូលរួមក្នុងសិប្បកម្មកែច្នៃទឹកដោះគោ។ ផលិតផលទាំងឡាយ រួមមាន ម្សៅទឹកដោះគោ ភេសជ្ជៈទឹកដោះគោ លាយជាតិផ្លែឈើ ទឹកដោះគោចម្រាញ់ ប៊ឺរ ប្រូម៉ា សូកូឡា ការ៉េម ជាតិក្រេមទឹកដោះគោ ហើយនិងផលិតផលធ្វើពីទឹកដោះគោជាច្រើនប្រភេទផ្សេងៗទៀត បន្ថែមទៅលើទឹកដោះគោអនាម័យសុទ្ធ។ ប្រាក់ចំណូលប្រចាំឆ្នាំ ២០០៥ មានចំនួន ៣៨ ពាន់លានរូបពី ស្មើនឹង ៨៥0 លានដុល្លារអាមេរិក។

ទិសដៅបឋមរបស់អង្គការនេះ គឺបង្កើតបណ្តាញសហករណ៍ ដើម្បីផ្តល់សេវាដ៏មានគុណភាព ហើយនិងផលិតផលនានា ជូនអតិថិជនដែលជាអ្នកទទួលទានទឹកដោះគោ និងដើម្បីជួយអ្នកផលិតទឹកដោះគោឱ្យបានប្រាក់កម្រៃច្រើន។ បច្ចេកវិជ្ជាព័ត៌មាន (IT) បានដើរតួសំខាន់មួយក្នុងការអភិវឌ្ឍកេរ្តិ៍ឈ្មោះរបស់អង្គការ AMUL។ ភូមិនីមួយៗមានមន្ទីរផ្តល់ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច ដែលជាចំណុចងាយស្រួលសម្រាប់ទំនាក់ទំនងតាមប្រព័ន្ធអ៊ិនធឺណេត និងសកម្មភាពអភិបាលកិច្ចឯទៀតៗ តាមប្រព័ន្ធអេឡិចត្រូនិច ដែលជារួមមានតម្លៃលក់ ការលក់ដូរ ការដឹកជញ្ជូន និងគុណភាព។ ផ្នែកភស្តុភារសម្របសម្រួលការប្រមូលទិញទឹកដោះគោចំណុះ ១០ លានលីត្រ ក្នុង ១ថ្ងៃ ពីសង្គមសហករណ៍ភូមិចំនួន ១ ម៉ឺនភូមិនៅទូទាំងខេត្ត អុញ្ជរាត ហើយបន្ទាប់មករក្សាទុក កែច្នៃ និងផលិតចេញជាផលិតផលទឹកដោះគោនៅសិប្បកម្មក្នុងស្រុក ១២ នៃសហជីពកែច្នៃទឹកដោះថ្នាក់ស្រុក។ ការសាងសង់ស្ថានីយស្វ័យប្រវត្តិសម្រាប់ប្រមូលទិញទឹកដោះគោចំនួន ៤ ពាន់ស្ថានីយ៍ ជួយប្រមូលផ្តុំព័ត៌មានស្តីអំពីសមាជិក កម្រិតខ្លាញ់នៅក្នុងទឹកដោះគោ ចំណុះទឹកដោះគោទាំងអស់ដែលប្រមូលបាន និងចំនួនទឹកប្រាក់ដែលបង់ជូនសមាជិកម្នាក់ៗ។ កិច្ចការនេះជាសក្ខីភាពដែលមិនអាចកាត់ថ្លៃបានក្នុងការធានានៅសមធម៌ និងតម្លាភាពនៅទូទាំងអង្គការ AMUL។ ដើម្បីសម្រួលដល់ការដឹកជញ្ជូនទឹកដោះគោ សហករណ៍បានជួល ឬប្រើប្រាស់រថយន្ត ម៉ាស៊ីនត្រជាក់មួយចំនួនធំ។

*ប្រភព : http://www.siffs.org និង http://www.amul.com*

***សារគន្លឹះ :***

*១. ត្រូវជួយពង្រឹងសហគមន៍ ក្នុងផែនការរកទីផ្សារលក់ត្រី ដើម្បីជួយអ្នកនេសាទឱ្យលក់ត្រីរបស់ខ្លួនបានតម្លៃល្អ។ ក្នុងផែនការទាំងនេះ គឺត្រូវមានធុងទឹកកកសម្រាប់ស្តុកត្រី ឬឡានមានទូទឹកកកសម្រាប់ដឹកត្រី ហើយនិងឃ្លាំងរក្សាត្រី ដើម្បីទប់ស្កាត់កុំឱ្យខូចគុណភាពត្រីដែលនាំឱ្យលក់បានតម្លៃថោក។*

*២. ផ្លូវសម្រាប់ពាណិជ្ជកម្មត្រូវធ្វើឱ្យប្រសើរឡើង ហើយលក្ខខណ្ឌពាណិជ្ជកម្មមិនត្រូវស្មុគស្មាញពេកទេ ដើម្បីជួយសម្រួលដល់ការលក់ត្រី និងសត្វពាហនៈឱ្យមានប្រសិទ្ធភាព និងបង្កើនប្រាក់ចំណូលដល់អ្នកផលិត។*

## ៤.៦ សកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម

សង្គមមួយដែលពឹងផ្អែកតែលើកសិកម្ម ត្រូវតែមានសកម្មភាពផ្សេងៗទៀត ដែលជាសកម្មភាពមិនមែនកសិកម្ម និងក្រៅកសិដ្ឋាន ដើម្បីបន្ថែមតម្លៃលើផលដំណាំរបស់ខ្លួន និងបង្កើនការងារ ។ ក្នុងន័យនេះ មានជម្រើសពីរ :

ក. បន្ថែមតម្លៃលើផលដំណាំកសិកម្មដែលមានសព្វថ្ងៃ ដូចជា : ស្រូវ ត្រី ផ្លែឈើ ហើយនិងផលិតផលកសិកម្មដទៃទៀត ។ មានសក្តានុពលជាច្រើន ក្នុងការកែច្នៃផលិតផលកសិកម្មឆៅ ( ឧ. ផ្លែឈើ និងបន្លែប្រចាំរដូវ) នៅស្រុកស្រែចំការ ។

ខ. ពង្រីកសកម្មភាពចេញក្រៅពីផ្នែកកសិកម្ម : ផលិតវត្ថុធ្វើដោយដៃ ធ្វើក្អមឆ្នាំង រវៃអំបោះ ចិញ្ចឹមដង្កូវ នាង ធ្វើសូត្រ ផលិតសម្ភារៈសំណង់ ជួសជុលម៉ាស៊ីន និងសេវាដទៃៗទៀត[៧១] ។

ឧស្សាហកម្មខ្នាតតូច និងមធ្យម (រួមទាំងនៅទីជនបទផង) ស្ថិតនៅក្នុងក្របខ័ណ្ឌនៃចំណុចស្នូលមួយរបស់យុទ្ធសាស្ត្រចតុកោណក្នុងវិស័យអភិវឌ្ឍន៍ផ្នែកឯកជន ។ ដូច្នេះមានការទទួលស្គាល់ជាពិសេសនូវសារៈសំខាន់នៃផ្នែកនេះ ។

### ប្រអប់ ៤.១១ : ករណីសិក្សាអំពីការបន្ថែមតម្លៃលើអាហារ



***កសិដ្ឋានចិញ្ចឹមមាន់មួយ : គុណភាពល្អនាំទៅរកជោគជ័យ***

ដោយមានការធានាគុណភាពត្រឹមត្រូវ ព្រមទាំងមានទីផ្សារច្បាស់លាស់ កសិករចិញ្ចឹមមាន់ម្នាក់នៅចម្ងាយប្រហែល ៥០ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញបានពង្រីកដើមទុនមួយជាដប់ ពោលគឺពី ១ ម៉ឺន ទៅ ១០ ម៉ឺនដុល្លារអាមេរិក ពីឆ្នាំ ១៩៩៤-២០០១ ។ គាត់ចេះបច្ចេកទេសចិញ្ចឹមមាន់តាមរយៈក្រុមហ៊ុនថៃមួយនៅភ្នំពេញ ។ កាលពីគាត់ធ្វើការនៅឯសហគ្រាសចិញ្ចឹមមាន់មួយក្នុងប្រទេសថៃ គាត់បានរៀនសូត្រអំពីបច្ចេកទេសចិញ្ចឹមមាន់ និងមុខរបររកស៊ីក្នុងវិស័យនេះ ។ ក្រោយមកទៀត ដើម្បីរក្សាគុណភាព គាត់ទិញកូនមាន់ពីក្រុមហ៊ុនថៃ ព្រោះគាត់មើលឃើញថា កូនមាន់ទាំងនេះបានឆ្លងកាត់វិទ្យាសាស្ត្រចិញ្ចឹមត្រឹមត្រូវ (ផ្តល់ពងធំ និងត្រូវខ្នាត ហើយមេមាន់មួយៗផ្តល់ពងច្រើន) ចំណីមាន់ក៏គាត់ទិញពីក្រុមហ៊ុនថៃដែរ ហើយខ្លួនគាត់ដែលជាម្ចាស់ ក៏ចេះច្នៃប្រឌិតផ្សំចំណីមាន់ និងចំណីសត្វដែលមានគុណភាពខ្ពស់ ។ ដើមទុនទាំងអស់សម្រាប់សម្ភារៈបរិក្ខារ និងការចំណាយប្រចាំថ្ងៃ គឺជាដើមទុនផ្ទាល់របស់គាត់ ឬបានមកតាមរយៈក្រុមហ៊ុនថៃ ដោយពុំចាំបាច់ទៅធនាគារឡើយ ។

សាច់មាន់ និងពងមាន់ជាង ៨០ ភាគរយ គាត់លក់ទៅឱ្យភោជនីយដ្ឋានធំៗ សណ្ឋាគារ និងផ្សារទំនើបជាច្រើនក្នុងទីក្រុងភ្នំពេញ ។ ហេតុដែលគាត់លក់បានថ្លៃជាងកសិករឯទៀត ដោយសារតែពងមាន់គាត់ធំៗជាងគេ ។ ប៉ុន្តែនៅតែមានការប្រកួតប្រជែងខ្លាំងពីកសិករក្នុងស្រុក ព្រមទាំងពងមាន់ថោកៗពីបរទេស ។ ដោយសារស្វាគមន៍ឱ្យមានការប្រកួតប្រជែង មានសាច់មាន់និងពងមាន់រត់ពន្ធឆ្លងដែន ដែលបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់របររកស៊ីរបស់ខ្មែរដែលកំពុងកកើត ។ រាជរដ្ឋាភិបាលបានព្យាយាមទប់ស្កាត់អំពើរត់ពន្ធអស់ទាំងអស់នេះ ប៉ុន្តែមិនបានជោគជ័យប៉ុន្មានទេ ។ ឈ្មួញលក់ដុំទទួលទិញទំនិញនាំចូលអស់ទាំងនេះ គឺជាកត្តាជម្រុញឱ្យផលិតផលក្នុងស្រុកធ្លាក់ថ្លៃ និងធ្វើឱ្យកសិករខ្មែរបាត់បង់ប្រាក់ចំណេញ ។

កន្លងមក មានការព្យាយាមបង្កើតសមាគមកសិករចិញ្ចឹមមាន់ ដើម្បីការពារតម្លៃសាច់មាន់ និងពងមាន់ ។ ប៉ុន្តែកង្វះចំណេះដឹង និងបទពិសោធន៍ធ្វើឱ្យដំណើរការនេះរាំងស្ទះ ។

***គុណភាពធានាជោគជ័យឱ្យឡដុតនំប៉័ងមួយ***

កាលពីឆ្នាំ ១៩៧៩ មានឡនំប៉័ងខ្មែរមួយ ផ្តើមលក់នំប៉័ងនៅក្នុងស្រុក ។ ដល់ឆ្នាំ ១៩៩៥ ឡនំប៉័ងនោះបានរីកដុះដាលទៅជាឡដ៏ធំមួយ ។ សព្វថ្ងៃឡនេះបានលក់នំផ្សេងៗរបស់ខ្លួនទៅឱ្យប្រទេសជិតខាង ថ្វីត្បិតតែនៅមានបញ្ហាជាច្រើនក្តី ។

ម្ចាស់ហាងនេះមានឱកាសបើកហាងក្នុងចំណោមអ្នកបើកហាងដំបូងគេ ។ ហាងនេះមានប្រើម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ និងមានឧបករណ៍សម្រាប់លាយម្សៅមី និងដុតនំ ។ គ្រឿងម៉ាស៊ីនទាំងអស់នាំចូលពីប្រទេសចិន រីឯប្រដាប់វេចខ្ចប់នាំចូលពីប្រទេសថៃ ដែលមានការអូសបន្លាយ និងមានតម្លៃខ្ពស់ ដោយសារការដឹកជញ្ជូនយឺត ហើយត្រូវបង់ប្រាក់បន្ថែម ។ ការព្យាយាមជួលក្រុមហ៊ុនក្នុងស្រុក ឱ្យផ្តល់សម្ភារៈវេចខ្ចប់ មិនបានជោគជ័យទេ ដោយសារខ្វះគុណភាព និងតម្លៃខ្ពស់ពេក ។

ក្រោយពីទទួលទំនិញទាំងនោះហើយ ហាងទាំងមូលក៏ត្រូវបានបង់ប្រាក់ផ្តាច់ ។ ចំពោះដើមទុនសម្រាប់ចំណាយប្រចាំថ្ងៃវិញ ម្ចាស់ហាងតែងតែខ្ចីប្រាក់ពីធនាគារមួយ ក្នុងការប្រាក់ ២២ ភាគរយ ក្នុងមួយឆ្នាំ ។ ផលិតផលថោកៗពីបរទេសប្រកួតប្រជែងជាមួយផលិតផលគាត់ ។ ទំនិញរត់ពន្ធ អគ្គិសនីថ្លៃ ថ្លៃដឹកជញ្ជូនខ្ពស់ និងការបង់ប្រាក់ក្រៅផ្លូវការ ធ្វើឱ្យគាត់បាត់បង់ផលចំណេញ ។ ថ្លៃលក់ឡើងចុះជាខ្លាំង ពី ៣០ ទៅ ៥០ ភាគរយ ដោយសារទីផ្សារធ្លាក់ថ្លៃ ។ ម្ចាស់ហាងលក់បានតម្លៃល្អ តែចំពោះអតិថិជនអន្តរជាតិភាគច្រើនដែលជាខ្មែរនៅបរទេសមកទស្សនាកម្ពុជា ។

*ប្រភព : Sok និង Acharys (២០០៣)*

---

*(៧១) ប្រហែល ៧០ ភាគរយ នៃផ្លែឈើ និងបន្លែ ត្រូវបាននាំចូលពីបរទេស ប៉ុន្តែមានសក្តានុពលទូលំទូលាយសម្រាប់បំពេញបន្ថែមលើការនាំចូល យោងតាមក្រុមការងារបច្ចេកទេស - កសិកម្ម និងទឹក (២០០៦) ។*

*សកម្មភាពកែច្នៃស្រូវ មានសក្តានុពលធំធេង ប៉ុន្តែខ្វះដើមទុន*

## ផ្នែកកែច្នៃម្ហូបអាហារ

ផ្នែកកែច្នៃម្ហូបអាហារមួយមាននៅស្រុកខ្មែរ ទាំងបែបបុរាណ និងបែបទំនើប ប៉ុន្តែមិនមានទិន្នន័យអង្កេតទូលំទូលាយនៅឡើយទេ។ សកម្មភាពកែច្នៃស្រូវ-អង្ករ មានសក្តានុពលធំធេង ប៉ុន្តែខ្វះដើមទុន។ បច្ចេកវិទ្យានៅអត្តខាត់ មិនទាន់ទំនើប និងតម្លៃអគ្គិសនីខ្ពស់ នាំឱ្យការអភិវឌ្ឍផ្នែកនេះ ជួបប្រទះនឹងការលំបាកច្រើន។ ជារឿយៗ ស្រូវត្រូវបានលក់ចេញទៅប្រទេសថៃ និងប្រទេសវៀតណាម ហើយទិញអង្ករពីប្រទេសទាំងនោះចូលមកស្រុកខ្មែរវិញ។ ធ្វើយ៉ាងនេះ នាំឱ្យកម្ពុជាខាតបង់ទាំងការងារខាតបង់ ទាំងតម្លៃបន្ថែម។ ការវេចខ្ចប់អាហារ (បន្លែផ្លែឈើ និងសាច់) បានចាប់ផ្តើមក្នុងលក្ខណៈជាខ្នាតតូច និងការកែច្នៃត្រី និងបង្គា ក៏បានចាប់ផ្តើមដែរ។ សព្វថ្ងៃនេះ សកម្មភាពទាំងនេះនៅមានតិចតួច ហើយប្រមូលផ្តុំតែនៅជិតទីប្រជុំជនធំៗ។ ដូច្នេះការបង្កើតការងារសម្រាប់ពលករនៅតាមជនបទនៅមានកម្រិតទាបនៅឡើយ[៧២]។

## មូលដ្ឋានគ្រឹះសម្រាប់ជោគជ័យក្នុងការកែច្នៃម្ហូបអាហារ គឺ :

ក. ត្រូវមានការផ្គត់ផ្គង់ផលិតផលឆៅជាប់ជានិច្ច មិនចេះដាច់ និងប្រកបដោយគុណភាព។
ខ. ត្រូវមានសម្ភារៈដឹកជញ្ជូនមានប្រសិទ្ធភាព (សម្រាប់ផលិតផលដែលអាចខូចរលួយ ត្រូវមានធុងទឹកកកសម្រាប់រក្សាគុណភាព)
គ. ត្រូវមានប្រព័ន្ធវេចខ្ចប់ធំមួយ និងមានប្រព័ន្ធទីផ្សារ។

ទាំងអស់នេះទាមទារឱ្យមានបច្ចេកវិទ្យា កសិកម្ម និងឧស្សាហកម្ម អង្គការអាជីវកម្ម និងដើមទុនបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធជាពិសេស អគ្គិសនីនៅជនបទ។ ទោះបីជាយ៉ាងនេះក្តី អ្នកវិនិយោគបរទេសមិនហ៊ានមករកស៊ីក្នុងវិស័យទិញដូរម្ហូបអាហារទេ ដោយសារតែគុណភាពផលិតផល និងការផ្គត់ផ្គង់មិនប្រាកដប្រជា។ អាជីវកម្មក្នុងស្រុកជាច្រើនក៏មានក្តីបារម្ភដូចគ្នានេះដែរ។ ដូច្នេះតើត្រូវធ្វើយ៉ាងណា ? ជម្រើសនានា រួមមាន :

ក. បង្កើនផលិតភាពកសិកម្ម និងបង្កើតផលិតផលច្រើនមុខ។ ជាទូទៅ រោងចក្រកែច្នៃម្ហូបអាហារនឹងកើតនៅកន្លែងណា និងនៅពេលណាដែលមានផលិតផលច្រើនបរិបូណ៌សម្រាប់ទីផ្សារ។
ខ. បង្កើតបច្ចេកវិទ្យាសម្រាប់ជួយគាំទ្រដល់វិស័យកសិកម្ម។
គ. ធានាឱ្យមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដោយបំពាក់អគ្គិសនី ដែលមានតម្លៃថោកនៅជនបទ រក្សាតម្លៃទំនិញឱ្យបានច្បាស់លាស់ ដោយមានតម្លាភាពផ្នែកអភិបាលកិច្ច ដែលជាបុរេលក្ខខណ្ឌសម្រាប់វិនិយោគថ្នាក់មូលដ្ឋានក្នុងវិស័យកសិកម្មកែច្នៃ។
ឃ. បង្កលក្ខណៈងាយស្រួលដល់ឥណទានដែលមានការប្រាក់ទាប។
ង. បង្កើតសហគ្រាសខ្នាតតូច និងមធ្យមសម្រាប់កែច្នៃ វេចខ្ចប់ និងបង្កើតប្រព័ន្ធដឹកជញ្ជូននៅមូលដ្ឋាន។

ដោយសារកិច្ចការនេះមានទំហំធំគួរសម រដ្ឋាភិបាលមិនចាំបាច់ប្រឹងប្រែងធ្វើកិច្ចការនេះទាំងស្រុងទេ។ ជាការចាប់ផ្តើម ប្រសិនបើមានថាមពលអគ្គិសនីថោក ហើយមិនចេះដាច់ នោះផ្នែកឯទៀតៗនឹងចូលមកដោយខ្លួនឯង។

## ផ្នែកមិនមែនម្ហូបអាហារ[៧៣]

សេវាកម្ម និងសិប្បកម្ម ក្រៅពីអាហារខ្លះបើកដំណើរការនៅតាមជនបទ ថ្វីត្បិតតែនៅឆ្ងាយពីសកម្មភាពទំនើបៗនៅទីប្រជុំជនក៏ដោយ។ សិប្បកម្មទាំងនោះ រួមមាន :

ក. តម្បាញសូត្រ និងរវៃអំបោះ
ខ. ឡឥដ្ឋ
គ. សិប្បកម្មកែច្នៃឈើ និងផលិតគ្រឿងសង្ហារឹម
ឃ. តម្បាញកន្ទេលអំពីផ្តៅ និងសរសៃធម្មជាតិឯទៀតៗ
ង. ចម្លាក់ថ្ម
ច. ក្តួមឆ្នាំង និងវត្ថុធ្វើដោយដៃដទៃទៀត
ឆ. ប្រព័ន្ធទឹកប្រើប្រាស់ និងប្រព័ន្ធផ្លូវដឹកជញ្ជូន (អនុវត្ត និងជួសជុល)
ជ. ស្បែកសត្វ
ឈ. ប្រព័ន្ធអគ្គិសនីនៅជនបទ-ម៉ាស៊ីនភ្លើងសម្រាប់ចែកចាយភ្លើងប្រើប្រាស់ និងសាកអាគុយនៅតាមភូមិជាដើម
ញ. លក់ដូររាយរង និងដឹកជញ្ជូនផ្សេងៗ។

---

*(៧២) ប្រហែល ៧០ ភាគរយនៃផ្លែឈើ និងបន្លែ ត្រូវបាននាំចូលពីបរទេស ប៉ុន្តែមានសក្តានុពលទូលំទូលាយសម្រាប់បំពេញបន្ថែមលើការនាំចូលយោងតាមក្រុមការងារបច្ចេកទេស-កសិកម្ម និងទឹក (២០០៦)។*

*(៧៣) MPDF (២០០៥) ផ្តល់នូវតារាងវិស័យឧស្សាហកម្មមួយចំនួនដែលអាចធ្វើនៅកម្ពុជា។ ប៉ុន្តែពុំឃើញមានការបង្ហាញពីឧបសគ្គដែលនាំឱ្យការពង្រីកវិស័យទាំងនោះរាំងស្ទះ។*

ភាគច្រើននៃសកម្មភាពទាំងនេះ ប្រើបច្ចេកវិទ្យាមិនទាន់សម័យ ដែលមានតម្លៃខ្ពស់ ហើយមានផលិតភាពទាប - លើសពីនេះទៀត ត្រូវជួបនឹងការគំរាមកំហែងពីឥវ៉ាន់នាំចូលពីបរទេស ។ កម្មករម្នាក់ធ្វើការមួយថ្ងៃបានប្រាក់ឈ្នួលពី ៣០០០ ទៅ ៦០០០ រៀល ភាគច្រើនជាកិច្ចការប្រចាំរដូវ ឬមិនពេញម៉ោង ។ របររកស៊ីនានាស្ថិត នៅក្រោមការត្រួតត្រាពីពួកឈ្មួញ ដែលមានបណ្ដាញទំនាក់ទំនងទីផ្សារ ( ប្រអប់ ៤.១២) ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏សកម្មភាពអស់ទាំងនោះផ្ដល់សេវាចាំបាច់នានានៅតាមជនបទ និងបង្កើតការងារនៅទីនោះជាច្រើនដែរ ។ សកម្មភាព និងសេវាទាំងនោះ ជាគន្លឹះសំខាន់មួយជួយបន្ធូរបន្ថយបន្ទុកពឹងផ្អែកលើកសិកម្ម និងនេសាទត្រី ។ ទីភ្នាក់ងារអភិវឌ្ឍន៍នានាបានប្រឹងប្រែងបញ្ចូលបច្ចេកវិទ្យាទំនើប បណ្ដុះបណ្ដាលបុគ្គលិក និងបង្កើតទីផ្សារក្នុងវិស័យសិប្បកម្មមិនមែនម្ហូបអាហារ ( អង្គការ Artisans D'Angkor បានជួយជម្រុញបច្ចេកវិទ្យាទំនើប និងជួយរកទីផ្សារ ធនាគារអេស៊ីលីដាផ្ដល់ប្រាក់កម្ចី និងភ្នាក់ងារដទៃទៀត មានចែងពិស្ដារនៅក្នុង ( ប្រអប់ ៤.១៣) ។ សកម្មភាពអស់ទាំងនេះ ពិតជាមានប្រសិទ្ធភាព ។

## ប្រអប់ ៤.១២ : តម្បាញសូត្រនៅកម្ពុជា



សិប្បកម្មសូត្រនៅកម្ពុជាមានទីតាំងនៅខេត្ត ៤ : កណ្ដាល តាកែវ ព្រៃវែង និងកំពង់ចាម ។ ៨៥ ភាគរយនៃសិប្បកម្មតម្បាញសូត្រមាននៅខេត្តកណ្ដាល និងតាកែវ ។ អំបោះសូត្រនាំចូលពីប្រទេសវៀតណាម យកមកត្បាញចេញជាសំពត់នៅប្រទេសកម្ពុជា ។

សកម្មភាពតម្បាញសូត្រស្ទើរតែទាំងអស់ធ្វើនៅក្នុងរង្វង់គ្រួសារ ។ ធ្វើបែបនេះ ដើម្បីកុំឱ្យអស់ឈ្នួលច្រើន ហើយអ្នកធ្វើការទាំងអស់រស់នៅ និងហូបចុកនៅផ្ទះតែម្ដង ។ ឈ្មួញកណ្ដាល ឬពាណិជ្ជករជាអ្នកគ្រប់គ្រងទីផ្សារ ពោលគឺពួកគេផ្ដល់អំបោះសូត្រទៅឱ្យអ្នកត្បាញនៅក្នុងភូមិ ហើយប្រមូលទិញសំពត់សូត្រពីអ្នកភូមិយកទៅលក់នៅទីផ្សារខាងក្រៅ ។ តាមវិធីនេះ ឈ្មួញកណ្ដាលតភ្ជាប់អ្នកតម្បាញសូត្រជាច្រើនពាន់នាក់ទៅក្នុងបណ្ដាញនៃអង្គភាពផលិតដ៏ធំមួយដែលមើលមិនឃើញ ។ បន្ទាប់មកទៀត ពួកឈ្មួញកណ្ដាលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកអ្នកលក់ដុំ ដែលជាអ្នកដាក់តម្លៃ ។ ការត្រួតត្រានៅគ្រប់ដំណាក់កាល ធ្វើឡើងតាមទំនាក់ទំនងក្នុងសង្គម និងក្នុងបណ្ដាញមិនមែនធ្វើតាមប្រព័ន្ធស្ថាប័នណាមួយទេ ។

ប៉ុន្តែ វិធីនេះក៏មានចំណុចខ្វះខាតដែរ ព្រោះវាមិនមានឱកាសទទួលបានបច្ចេកវិទ្យាថ្មី និងទទួលបានការវិវឌ្ឍក្នុងវិស័យសិប្បកម្ម និងទីផ្សារ ។ រីឯអ្នកត្បាញវិញ ក៏មិនមានឱកាសបានជួបប្រទះចំណេះថ្មីៗ ហើយសិប្បកម្មក្នុងគ្រួសារបែបនេះ ក៏មិនបានទទួលយកអ្នកថ្មីឱ្យមានឱកាសបានចូលរៀនផងដែរ ក្រៅពីសមាជិកគ្រួសារខ្លួន ។ អ្នកត្បាញទាំងអស់ធ្វើតាមតែគេចេះពីមុនមក ហើយមិនបានច្នៃប្រឌិតតាមសេចក្ដីត្រូវការទីផ្សារទេ ដូច្នេះហើយបានជាមិនមានអ្វីថ្មី ។ សូត្រខ្មែរមិនមែនជាទំនិញសម្រាប់នាំចេញទេ ហើយក៏មិនមានអ្វីច្រើនដែលអាចទាក់ទាញភ្ញៀវទេសចរណ៍បានដែរ ។ សូត្រខ្មែរជាង ៩៥ ភាគរយ លក់ដូរ-ប្រើប្រាស់តែនៅក្នុងស្រុក ។

អ្នកត្បាញភាគច្រើនជាស្ត្រី ដែលមានចំនួនប្រហែល ២ ម៉ឺននាក់ ក្នុងឆ្នាំ ២០០៣ កើនពី ១ ម៉ឺននាក់ ក្នុងឆ្នាំ ២០០០ ។ ម្នាក់ៗរកប្រាក់បានពី ៤០ ទៅ ៥០ ដុល្លារ ក្នុង ១ ខែ អាស្រ័យទៅលើទីតាំងលក់ដូរ និងប្រភេទនៃសំពត់សូត្រ ។

បើចង់ឱ្យតម្បាញសូត្រនេះ មានតម្លៃប្រសើរជាងសព្វថ្ងៃ ដើម្បីជួយលើកកម្ពស់ជីវភាពអ្នកត្បាញសូត្រ ចាំបាច់ត្រូវរៀបចំជាអង្គការចាត់តាំងត្រឹមត្រូវ ព្រមទាំងបំពាក់បច្ចេកវិទ្យាទំនើបផង ។ ដំបូង ពួកឈ្មួញកណ្ដាលត្រូវរកទីផ្សារសម្រាប់លក់សូត្រឱ្យបានច្រើនជាងសព្វថ្ងៃ និងត្រូវដឹងពីប្រភេទក្បាច់-ក្រឡាសំពត់ហូលដែលពេញនិយម ។ បន្ទាប់មក សំពត់សូត្រទាំងនេះត្រូវធ្វើតាមការនិយមរបស់ទីផ្សារ និងត្រូវចេះផ្លាស់ប្ដូរក្បាច់ក្បូរ ដើម្បីឆ្លើយតបទៅនឹងការចង់បានរបស់អតិថិជន ។ ដើម្បីធ្វើយ៉ាងនេះបានចាំបាច់ត្រូវប្រើបច្ចេកវិទ្យាទំនើប ។ ត្រូវរៀបចំស្ដង់ដារពលកម្មឱ្យសមស្រប ដូចដែលអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារមួយចំនួនបាននិងកំពុងព្យាយាមធ្វើ ។ ឧបសគ្គចម្បងក្នុងគម្រោងនេះ គឺប្រសិនបើសកម្មភាពតម្បាញសំពត់សូត្រនេះធ្វើនៅតែក្នុងរង្វង់គ្រួសារ និងក្នុងបណ្ដាញនៃសង្គម នោះការខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាលមិនអាចធ្វើអន្តរាគមន៍បានទេ លុះត្រាតែកិច្ចអន្តរាគមទាំងនោះ ធំទូលាយគ្រប់គ្រាន់អាចជ្រាបចូលទៅក្នុងបណ្ដាញសង្គមគ្រួសារទាំងនោះបាន ។

*ប្រភព : Seng, Dongleman និង tier Horst ( ២០០៦) Acharya, Kim Chap និង Meach ( ២០០៣)*

ដើម្បីលើកកម្ពស់សកម្មភាពក្នុងវិស័យនេះ ត្រូវមានការជំរុញឱ្យខ្លាំងមួយ ពោលគឺដំឡើងគុណភាព បច្ចេកវិទ្យា និងបង្កើនការប៉ិនប្រសប់របស់មនុស្ស បង្កើតនិងជម្រុញបណ្ដាញទីផ្សារឱ្យបានច្រើន និងពង្រីកស្ថាប័ន ឥណទាន ឱ្យទូលំទូលាយ ។ បន្ថែមលើនេះទៀត ដើម្បីឱ្យសកម្មភាពទាំងនេះដុះដាលបាន ចាំបាច់ត្រូវមានហេដ្ឋារចនាសម្ព័ន្ធល្អ ។

**ប្រអប់ ៤.១៣ : អាជីវករនៅខេត្ត មណ្ឌលគិរី បានផលប្រយោជន៍ពីប្រាក់កម្ចីរបស់អេស៊ីលីដា**

***អតិថិជនទី ១***

អ្នកស្រី ទី សុខលៀប អ្នកលក់គ្រឿងទេសម្នាក់នៅភូមិកណ្តាល ខេត្តមណ្ឌលគិរី បានខ្ចីលុយពីឯកជនម្នាក់ក្នុងការប្រាក់ ១០ ភាគរយ ក្នុង ១ ខែ។ ក្នុងកម្រិតការប្រាក់បែបនេះ របររកស៊ីគាត់មិនបានផលចំណេញឡើយ។ ក្រោយមក គាត់បានខ្ចីប្រាក់ពីធនាគារអេស៊ីលីដាក្នុងការប្រាក់ទាបជាង។ គាត់បានយកប្រាក់នេះធ្វើដើមទុនទិញទំនិញជាច្រើនក្នុងតម្លៃថោក។ ឥឡូវនេះ មុខរបរគាត់ដើរល្អណាស់ គាត់ទិញទំនិញ ២ សប្តាហ៍ម្តង ដោយដឹកតាមឡានតាក់ស៊ីពីភ្នំពេញ។ កាលពីគាត់មិនទាន់ខ្ចីប្រាក់ពីធនាគារអេស៊ីលីដា គាត់លក់បានតែ ១៥០.០០០ ទៅ ២០០.០០០ រៀលក្នុង១ថ្ងៃប៉ុណ្ណោះ ប៉ុន្តែក្រោយពីគាត់បានប្រាក់កម្ចីអេស៊ីលីដា របរលក់ដូរគាត់កើនដល់ ៤០០.០០០ រៀលក្នុងមួយថ្ងៃ។ ឥឡូវនេះ គ្រួសារគាត់រស់យ៉ាងស្រួល ហើយថែមទាំងអាចផ្គត់ផ្គង់សេចក្តីត្រូវការសម្រាប់អនាគតកូនគាត់ទៀត។

***អតិថិជនទី ២***

អ្នកស្រី ហេង ឆាយលី ជាអ្នកលក់គ្រឿងសំណង់នៅក្នុងភូមិចំបក់ ខេត្តមណ្ឌលគិរី គាត់បានខ្ចីប្រាក់ពីធនាគារអេស៊ីលីដា យកទៅទិញឡានដឹកទំនិញធុនតូចមួយ ក្នុងតម្លៃ ១៥.០០០ ដុល្លារ។ ពីមុនគាត់ជួលឡានគេដឹកសម្ភារៈសំណង់ ដូចជា ដីខ្សាច់ ឥដ្ឋ ដែក ប្រេងឥន្ធនៈ និងស៊ីម៉ង់ពីភ្នំពេញ។ ជួនកាលគាត់បាត់បង់មុខរបរ ព្រោះគាត់មិនអាចផ្គត់ផ្គង់សម្ភារៈទាន់ពេលវេលា ដោយសារការដឹកជញ្ជូនមិនទៀងទាត់។ ឥឡូវនេះ ដោយសារគាត់មានឡានផ្ទាល់ខ្លួនមួយ គាត់អាចផ្គត់ផ្គង់សម្ភារៈឱ្យអតិថិជនគាត់បានទៀងទាត់ និងទាន់ពេលវេលា។ ពីដើមគាត់លក់បានត្រឹមតែ ៤០០ ទៅ ៥០០ ដុល្លារ ប៉ុន្តែឥឡូវនេះ ការលក់ដូររបស់គាត់កើនពី ១០០០ ទៅ ១៥០០ ដុល្លារ។

ធនាគារអេស៊ីលីដាបានរកឃើញថា សូម្បីនៅតំបន់ជនបទដាច់ស្រយាលក៏ដោយ ធនាគារមិនគ្រាន់តែឱ្យខ្ចីប្រាក់ប៉ុណ្ណោះទេ គឺអាចជាស្ថាប័នសម្រាប់សន្សំប្រាក់ផងដែរ។ នៅខេត្តមណ្ឌលគិរី ប្រាក់ដែលឱ្យខ្ចីភាគច្រើន គឺជាប្រាក់សន្សំនៅក្នុងខេត្ត មិនមែនជាប្រាក់យកពីក្រៅចូលទៅក្នុងខេត្តទេ។

*ប្រភព : ធនាគារ អេស៊ីលីដា, ទំនាក់ទំនងឯកជន*

*__សារគន្លឹះ__ :*

*មុខរបរដែលផ្អែកលើសកម្មភាពកសិកម្ម ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធមួយ ដែលងាយប្រែផ្លាស់ពីកសិកម្មសម្រាប់ហូបចុក ទៅជាកសិកម្មដែលមានគុណតម្លៃសម្រាប់លក់នៅទីផ្សារ។ កសិករត្រូវតែចេះរួមដៃគ្នាផលិតដំណាំកសិកម្មឱ្យបានច្រើនគ្រប់គ្រាន់សម្រាប់លក់នៅទីផ្សារ។ ដូចគ្នានេះដែរ ផលិតកម្មផ្អែកមិនមែនម្ហូបអាហារ ក៏ត្រូវការជម្រុញឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីឱ្យមានហិរញ្ញវត្ថុ និងទីផ្សារគ្រប់គ្រាន់។*

## ៤.៧ សេចក្តីសរុប

ដើម្បីជម្រុញសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យទូលំទូលាយនៅជនបទ ត្រូវលើកកម្ពស់គុណភាពបច្ចេកវិទ្យា និងបង្កើតបរិយាកាសប្រកួតប្រជែងនៅទីផ្សារ។

- ដើម្បីជម្រុញការប្រើសម្ភារៈបរិក្ខាកសិកម្មឱ្យកាន់តែច្រើនថែមទៀត ត្រូវធានាឱ្យមានសម្ភារៈបរិក្ខាគ្រប់គ្រាន់ និងលក់ជើីជូនកសិករក្នុងតម្លៃដែលមានកំណត់ទុកជាមុនច្បាស់លាស់ប្រកបដោយការប្រាក់សមស្រប។ ផលចំណេញពីផលិតភាព ត្រូវមានកម្រិតខ្ពស់គ្រប់គ្រាន់សម្រាប់ទូទាត់ទៅលើការខាតបង់ក្នុងដំណើរការនៃមុខរបរ នៅពេលណាថ្លៃដើមកើនឡើងលឿនជាងថ្លៃលក់។

- ជីវបច្ចេកវិទ្យាទាំងអស់ដុះលូតលាស់ល្អណាស់ កាលណាមានប្រព័ន្ធស្រោចស្រពល្អ។ បើចង់ដំឡើងផលិតភាពដំណាំ និងបង្កើនប្រាក់ចំណូលជូនកសិករ ត្រូវពង្រីកប្រព័ន្ធស្រោចស្រពឱ្យបានឆាប់បំផុត។ វាលទំនាបនៅកម្ពុជា មានទឹកច្រើនជាងប្រទេសភាគច្រើនដទៃទៀត ដូច្នេះមានសក្តានុពលច្រើនណាស់ ក្នុងការពង្រីកប្រព័ន្ធស្រោចស្រពឱ្យទូលំទូលាយជាងសព្វថ្ងៃ។

- ការរក្សាថ្លៃលក់ឱ្យនឹងន អាចជួយកសិករ និងផលិតករតូចតាច ហើយអាចប៉ាន់ស្មានបានទៅលើបរិយាកាសសេដ្ឋកិច្ចនៅទីផ្សារ។ ចំណុចនេះសំខាន់ណាស់ ពីព្រោះកសិករភាគច្រើនអាចស្តុកផលិតផលរបស់គេទុកលក់ ពេលណាមានតម្លៃខ្ពស់។ វិធីរក្សាតម្លៃលក់ឱ្យមានលំនឹងមានគំរូមួយចំនួននៅលើពិភពលោក ដូចជា (១) បង្កើតធនាគារស្រូវ (២) ចុះកិច្ចសន្យាជាមួយម៉ាស៊ីនកិនស្រូវ (៣) ធ្វើកសិកម្មក្នុងកិច្ចសន្យា (សម្រាប់ផលដំណាំផ្សេងពីស្រូវ) ឬ (៤) បង្កើតប្រព័ន្ធគាំទ្រតម្លៃអប្បបរមា។ វិធីទាំងនេះអាចយកមកប្រើប្រាស់តែមួយ ឬលើសពីមួយក៏បាន។

- ទីផ្សារលក់ដូរត្រី និងសត្វពាហនៈ បច្ចុប្បន្ននេះមានបញ្ហាពុករលួយ និងការិយាធិបតេយ្យ ព្រមទាំងបញ្ហាបណ្តាញទីផ្សារខ្វះប្រសិទ្ធភាព។ ដោយសារតែបញ្ហាអស់ទាំងនេះ កសិករ និងអ្នកនេសាទ ដែលជាអ្នកផលិតទទួលបានប្រាក់ចំណូលបន្តិចបន្តួចសម្រាប់រស់តែប៉ុណ្ណោះ។ ជាការចាំបាច់បំផុត គឺត្រូវបង្កើតបណ្តាញលក់ដូរនៅក្នុងសហគមន៍ និងបំពាក់បច្ចេកវិទ្យាទំនើប។ កម្ពុជាគួរយកបទពិសោធន៍ប្រកបដោយជោគជ័យពីប្រទេសឯទៀតៗមកល្បងអនុវត្ត។

- សកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្មក្នុងទម្រង់កែច្នៃម្ហូបអាហារមានសក្តានុពលទូលំទូលាយណាស់នៅកម្ពុជា។ នៅក្នុងសិប្បកម្មកែច្នៃម្ហូបអាហារ ការគ្រប់គ្រងល្អលើបណ្តាញផ្គត់ផ្គង់ និងហេដ្ឋារចនាសម្ព័ន្ធ ដែលថោកថ្លៃអាចជួយជម្រុញសកម្មភាពទាំងអស់នេះឱ្យរីកដុះដាល។

*សកម្មភាពក្រៅកសិដ្ឋាន និងមិនមែនកសិកម្ម ក្នុងទម្រង់កែច្នៃម្ហូបអាហារមានសក្តានុពលទូលំទូលាយណាស់*

***រូបភាព ៤.១៣ : ការដំឡើងប្រាក់ចំណូលជូនកសិករ និងប្រាក់ចំណូលនៅជនបទ - សង្ខេប***



*ប្រភព : អត្ថបទនៃជំពូកនេះ និងផ្អែកនៅក្នុងជំពូក ៣*

# ជំពូក ៩





ជំពូក ៩

# គំនិតផ្តួចផ្តើមលើកគម្រោងការខ្នាតធំ ដើម្បីលើកកម្ពស់ជីវភាពនៅជនបទ និងលើកកម្ពស់ការអភិវឌ្ឍមនុស្ស

ការបង្កើនប្រាក់ចំណូលនៅជនបទទាមទារឱ្យមានជម្រើសផ្សេងៗច្រើនជាងយុទ្ធសាស្ត្រ និងជម្រើសតាមវិស័យនីមួយៗ ដូចដែលបានបង្ហាញខាងដើម។ គំនិតផ្តួចផ្តើមលើកគម្រោងការខ្នាតធំនានា គឺជាកត្តាចាំបាច់ដូចដែលមានបង្ហាញមួយចំនួននៅក្នុងជំពូកនេះ។ គំនិតទាំងនោះរួមមាន : (១) ការផ្តល់ថាមពលអគ្គិសនីនៅតាមជនបទ ការធ្វើឱ្យប្រសើរឡើងដល់មធ្យោបាយដឹកជញ្ជូន និងរៀបចំទីប្រជុំជនតាមតំបន់ប្រកបដោយតុល្យភាព (២) ការបង្កើតហេដ្ឋារចនាសម្ព័ន្ធតាមរយៈកម្មវិធីការងារសាធារណៈដែលបង្កើតសមិទ្ធផល និងសេវាកម្មដ៏មានសារប្រយោជន៍ដល់អ្នកក្រ (៣) ការអភិវឌ្ឍសង្គម ជាពិសេសតាមរយៈការអប់រំវិជ្ជាជីវៈ និងការពង្រីកសេវាកម្មសុខាភិបាល (៤) មានគោលនយោបាយសកម្មសម្រាប់ជួយដល់ជនជាតិដើមភាគតិច និង (៥) មានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរឹងមាំ សម្រាប់តាមដានមើលលទ្ធផលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

## ៩.១ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងរៀបចំទីប្រជុំជនប្រកបដោយតុល្យភាពតាមតំបន់

### *ការផ្តល់អគ្គិសនីតាមជនបទ*

បច្ចុប្បន្ននេះ គ្រួសារនៅតាមជនបទចំនួន ៧,៩ ភាគរយ បានតភ្ជាប់ខ្សែបណ្តាញអគ្គិសនីសម្រាប់ប្រើប្រាស់។ ចំនួន ១,៣ ភាគរយ មានថាមពលអគ្គិសនីដោយប្រើម៉ាស៊ីនភ្លើង ហើយ ១៧,៤ ភាគរយ ប្រើអាគុយដែលបញ្ចូលភ្លើងដោយម៉ាស៊ីនម៉ាស៊ូត[៧៤]។ ថាមពលពីខ្សែបណ្តាញអគ្គិសនីស្ថិតនៅក្នុងបរិមាណមានកម្រិត ដោយសារខ្វះម៉ាស៊ីនភ្លើងផង និងដោយសារបណ្តាញបញ្ជូនថាមពលមិនគ្រប់គ្រាន់ផង។ ម៉ាស៊ីនភ្លើងភាគច្រើននៅតាមខេត្ត ឬនៅតាមមូលដ្ឋាន មានសភាពចាស់ទ្រុឌទ្រោម និងខ្វះប្រសិទ្ធភាព ព្រមទាំងឧស្សាហ៍ខូច។ ម៉ាស៊ីនភ្លើងទាំងនោះ ក៏ជួបប្រទះនឹងកង្វះខាតហិរញ្ញវត្ថុផងដែរ។ ថាមពលអគ្គិសនីមួយផ្នែកតូចដែលប្រើនៅតាមបណ្តាខេត្តជាប់ព្រំដែន មានប្រភពពីប្រទេសជិតខាង។

តម្លៃអគ្គិសនីជាមធ្យមគឺចន្លោះពី ១.២០០ ទៅ ២.០០០ រៀល (០.៣០ ទៅ ០.៥០ ដុល្លារអាមេរិក) ក្នុងមួយគីឡូវ៉ាត់ម៉ោង តម្លៃនេះខ្ពស់បន្តិច បើប្រៀបធៀបទៅនឹងតម្លៃអគ្គិសនីនៅប្រទេសដទៃ ដែលមានតម្លៃចន្លោះពី ០.១០ ទៅ ០.១២ ដុល្លារអាមេរិក។ អគ្គិសនីមានតម្លៃខ្ពស់ ធ្វើឱ្យមូលដ្ឋានចំណូលខ្សោយដែលជាមូលហេតុមួយ មិនអាចមានលទ្ធភាពបំពាក់ម៉ាស៊ីនភ្លើងថ្មីៗ ជាពិសេស គឺពួកអ្នកលក់ថាមពលអគ្គិសនីឯកជន។ សេវានេះ ជាចម្បង គឺសម្រាប់ប្រើប្រាស់បំភ្លឺតាមគ្រួសារតែប៉ុណ្ណោះ។ អ្នកផ្គត់ផ្គង់សេវាថាមពលអគ្គិសនីតិចជាង ១០ ភាគរយ តែប៉ុណ្ណោះ ដែលអាចផ្តល់ថាមពលលើសពីការប្រើប្រាស់សម្រាប់បំភ្លឺតាមគ្រួសារ។ ម៉ាស៊ីនភ្លើងមិនអាចផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់សម្រាប់វិស័យឧស្សាហកម្ម[៧៥] ហើយក្នុងតម្លៃបែបបច្ចុប្បន្ននេះ ការប្រើក្នុងវិស័យឧស្សាហកម្មភាគច្រើនមិនមានប្រសិទ្ធភាពទេ។

ប៉ុន្តែការផ្គត់ផ្គង់អគ្គិសនីតាមជនបទ គឺជាចំណុចសំខាន់សម្រាប់ធ្វើឱ្យទំនើបដល់ប្រព័ន្ធធារាសាស្ត្រ សិប្បកម្មខ្នាតតូច និងមធ្យមពាណិជ្ជកម្ម និងការប្រើប្រាស់តាមគ្រួសារ។ ក្នុងស្មារតីនេះ ច្បាប់ស្តីអំពីអគ្គិសនីឆ្នាំ ២០០១ ផ្តល់ភារកិច្ចទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ និងការរៀបចំជូនរដ្ឋាភិបាល ដែលមានផែនការធ្វើជាដៃគូជាមួយវិស័យឯកជននៅក្នុងដំណើរការបញ្ជូន និងចែកចាយបន្ថែមពីលើការទិញថាមពលអគ្គិសនីពីប្រទេសជិតខាងផង។

(៧៤) ប្រភព : អង្កេតពាក់កណ្តាលជំរឿនប្រជាជនកម្ពុជា ២០០៤ (ICPS -២០០៤)

(៧៥) ប្រភព : Dapice, Valley and Wilkinson ២០០៦ ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនជាមួយ EDC

ការផ្គត់ផ្គង់ និងបញ្ជូនអគ្គិសនីតាមខ្សែបណ្ដាញ កំពុងគ្រោងដាក់ពង្រាយនៅក្នុងតំបន់ភាគខាងត្បូង (គឺខេត្តតាកែវ កំពត និងក្រុងព្រះសីហនុ) ដោយប្រើថាមពលវារីអគ្គិសនីធំៗ ដែលមានទីតាំងនៅខេត្តកំពត និងកោះកុង និងរោងចក្រផលិតថាមពលអគ្គិសនីប្រើធ្យូងថ្មនៅក្រុងព្រះសីហនុ។ រំពឹងថាទីតាំងទាំងនេះនឹងអាចផ្ដើមដំណើរការបាននៅឆ្នាំ ២០១០។ ការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាមសម្រាប់ខេត្តកំពង់ចាម ក្រចេះ ក៏ត្រូវបានរៀបចំជាគម្រោងរួចហើយដែរ។ ចំណែកឯកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនីពីប្រទេសថៃសម្រាប់តំបន់ពាយ័ព្យ ក៏នឹងត្រូវចូលជាធរមាននៅពេលណាដែលខ្សែបណ្ដាញចែកចាយអគ្គិសនីត្រូវបានតភ្ជាប់ដល់ខេត្តបាត់ដំបង និងសៀមរាប ប្រហែលជានៅឆ្នាំ ២០០៨។ ខ្សែបណ្ដាញចែកចាយអគ្គិសនីមួយខ្សែសម្រាប់តភ្ជាប់ពីខេត្តបាត់ដំបង ទៅទីក្រុងភ្នំពេញរំពឹងថានឹងរួចរាល់នៅឆ្នាំ ២០១០។

ក្នុងពេលឆាប់ៗខាងមុខនេះ ប្រសិនបើបានឧស្ម័នពីរ៉ែប្រេងដែលទើបតែរកឃើញនៅក្នុងសមុទ្រ រោងចក្រអគ្គិសនីដុតឧស្ម័ន អាចផលិតថាមពលអគ្គិសនីក្នុងតម្លៃទាបបាន ទោះបីជាថាមពលវារីអគ្គិសនីអាចមានផលប្រយោជន៍ច្រើនជាងចំពោះបរិស្ថានក៏ដោយ។

ក្នុងស្ថានភាពបន្ទាន់ ដើម្បីបង្កើនការផ្គត់ផ្គង់អគ្គិសនី ដំណើរការដំឡើងសម្ភារៈថ្មីៗសម្រាប់ផលិតថាមពល និងដំណើរការកែលម្អឧបករណ៍ចាស់ៗ គួរតែធ្វើដំណាលគ្នា។ ទំហំវិនិយោគអាចអាស្រ័យទៅតាមទំហំអតិបរមានៃការប្រើប្រាស់ (ឧទាហរណ៍ : ការប្រើប្រាស់ច្រើនប្រភេទ ដូចជា ប្រព័ន្ធធារាសាស្ត្រ ឧស្សាហកម្មនៅជនបទ ឧបករណ៍ត្រជាក់រក្សាត្រី-សាច់ និងការប្រើប្រាស់ក្នុងគ្រួសារ)។ គួរពិចារណាលើចំណុចមួយចំនួនខាងក្រោមនេះ :

ក. ដើម្បីពង្រាយការផ្គត់ផ្គង់ថាមពលទៅតាមភូមិ ប្រការសំខាន់ត្រូវមានបណ្ដាញចែកចាយចេញពីបណ្ដាញមេ ក្នុងករណីខ្លះ ការបំពាក់ថាមពលអគ្គិសនីនៅជនបទមិនអាចធ្វើទៅបាន ដោយសារតែខ្វះខ្សែបណ្ដាញលំដាប់ចែកចាយសម្រាប់ពង្រាយថាមពល។

ខ. នៅតាមតំបន់ដាច់ស្រយាល ដែលខ្សែបណ្ដាញអគ្គិសនីមិនអាចទៅដល់ជម្រើសមួយទៀត គឺអគ្គិសនីពីថាមពលពន្លឺព្រះអាទិត្យ ដូច្នេះការយកពន្ធគយលើការនាំចូលឧបករណ៍ថាមពលពន្លឺព្រះអាទិត្យនេះ ត្រូវតែកាត់បន្ថយ។ ប៉ុន្តែនៅមានជម្រើសមួយទៀត គឺការទាញយកថាមពលអគ្គិសនីពីវារីអគ្គិសនីខ្នាតតូច ដែលជាបច្ចេកវិទ្យាគេបានសាកល្បង និងពិសោធន៍ប្រើប្រាស់នៅក្នុងប្រទេសមួយចំនួនរួចហើយ។ ជម្រើសចុងក្រោយ គឺការទាញយកជីវឧស្ម័នពីកាកសំណល់សម្រាប់ដុតម៉ាស៊ីនភ្លើងខ្នាតតូច និងខ្នាតមធ្យម ឥឡូវនេះ ជាបច្ចេកវិទ្យាអាចប្រើប្រាស់បាន និងអាចមានផលចំណេញដល់សេដ្ឋកិច្ចទៀតផង។

គ. ការខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងដល់ម៉ាស៊ីនភ្លើងតូចៗមួយចំនួនដែលកំពុងប្រើបច្ចុប្បន្ន ក៏អាចជួយផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យមានស្ថិរភាពផងដែរ។

ឃ. ការធ្វើឱ្យថាមពលអគ្គិសនីមានតម្លៃថោក គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់។ ដើម្បីឱ្យមានការប្រកួតប្រជែង ត្រូវកំណត់អត្រាតម្លៃឱ្យនៅចន្លោះពី ៣០០-៥០០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង។

ង. ឧស្សាហកម្ម/កសិឧស្សាហកម្ម/កសិកម្ម និងសហករណ៍ជលផល គួរលើកទឹកចិត្តឱ្យពួកគេផលិតថាមពលអគ្គិសនីដោយខ្លួនឯងក្នុងករណីណាដែលមានសក្ដានុពលខ្ពស់សម្រាប់ទាញយកគុណតម្លៃ។

## ប្រអប់ ៥.១ : ករណីសិក្សា : អគ្គិសនីនៅតាមជនអាចបង្កើតការងារបានច្រើនសម្រាប់អ្នកក្រ



អស់រយៈពេលជាង១ឆ្នាំហើយ លោក ឌុង លី ជាអ្នកដឹកនាំសហគមន៍នៅកន្លែងផលិតថាមពល អគ្គិសនីមួយនៅភូមិអន្លុងតាម៉ី ខេត្តបាត់ដំបង។ ម៉ាស៊ីនភ្លើងតូចរបស់គាត់ដំណើរការ ៨ ម៉ោងក្នុង ១ ថ្ងៃ ហើយផ្គត់ផ្គង់អគ្គិសនីជូន ៨១ គ្រួសារ។ ដោយគាត់ផ្គត់ផ្គង់អគ្គិសនីក្នុងកម្លាំង ១0 KVA អ្នកប្រើប្រាស់ទាំងអស់ ត្រូវបានអនុញ្ញាតឱ្យប្រើបានតែទូរទស្សន៍ ១ គ្រឿង និងអំពូលវែងចំនួន ២ ហើយត្រូវបង់ថ្លៃចំនួន ១,៥00 រៀល (0,៣៧ ដុល្លារអាមេរិក) ក្នុង ១ គីឡូវ៉ាត់។ តម្លៃនេះវានៅទាបសមរម្យបើធៀបទៅនឹងតំបន់ផ្សេងៗទៀត ដែលមានតម្លៃរហូតដល់ ៤,000 រៀល (១ ដុល្លារអាមេរិក) ក្នុង១គីឡូវ៉ាត់។

ប៉ុន្តែអ្នកខ្លះបានព្យាយាមប្រើអគ្គិសនីកាន់តែច្រើនថែមទៀត ដោយប្រើម៉ាស៊ីនចាក់ DVD ម៉ាញ៉ៃដែលបណ្តាលឱ្យរអាក់រអួលដល់ចរន្តអគ្គិសនី។ ក្នុងឆន្ទៈចង់បំពេញតាមសេចក្តីត្រូវការនៅក្នុងសហគមន៍គាត់ លោក ឌុង លី សង្ឃឹមថាថ្ងៃណាមួយម៉ាស៊ីនភ្លើងតែមួយរបស់គាត់នឹងដំណើរការបានល្អ ហើយមិនមានការខកចិត្តទៀតឡើយ។

ឆ្លើយតបទៅនឹងសេចក្តីត្រូវការនេះ នៅខែ មករា ឆ្នាំ ២00៦ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានគាំទ្រដល់គម្រោងមួយតាមរយៈថវិកាជំនួយខ្នាតតូច ដែលឧបត្ថម្ភដោយថវិកាសម្រាប់កិច្ច - ការបរិស្ថានសកល។ គម្រោងនោះ ដែលបានដំណើរការរហូតដល់ខែមករា ឆ្នាំ ២00៧ បានបំពាក់ម៉ាស៊ីនភ្លើងកម្លាំង ២0 KVA ជំនួសម៉ាស៊ីនចាស់របស់ ឌុង លី ហើយគម្រោងនេះបានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋចំនួន ១៨0 គ្រួសារ ថែមទៀតនៅក្នុងភូមិជាប់គ្នាចំនួន ២។

ងិន ណារីរៈ ប្រធានគ្រប់គ្រងគម្រោងមានប្រសាសន៍ថា "គម្រោងនេះមានទិសដៅផ្តល់អគ្គិសនីដល់ភូមិនៅជនបទ ដោយប្រើប្រភពថាមពលកកើតឡើងវិញ ១00 ភាគរយ ហើយប្រើតែដើមឈើ ដែលដាំដុះនៅក្នុងសហគមន៍មូលដ្ឋានតែប៉ុណ្ណោះ"។

ដូចគ្នាទៅនឹងម៉ាស៊ីនចាស់របស់ ឌុង លី ដែរ ម៉ាស៊ីនភ្លើងថ្មីនេះដើរដោយការដុតដើមកន្ធំថេត ដែលដាំដុះនៅក្នុងសហគមន៍មូលដ្ឋានជាប្រភេទដើមឈើដែលដុះលឿន ជារុក្ខជាតិដុះក្នុងតំបន់ត្រូពិក អាចលូតលាស់បាននៅលើដីដែលមានជីជាតិតិច ហើយអាចគ្មានទឹកបាន។ មែកវាគេអាចកាត់ប្រមូលផលបាន ៤ ទៅ ៥ ដង ក្នុង ១ ឆ្នាំ ដោយវាលូតលាស់លឿនអាចផ្គត់ផ្គង់ជីវឧស្ម័នបានជាប្រចាំ។ តាំងពីគេចាប់ផ្តើមអាជីវកម្មនេះ ប្រជាពលរដ្ឋអាចផ្គត់ផ្គង់ដើមកន្ធំថេតបានគ្រប់គ្រាន់ជាប្រចាំ ក្នុងតម្លៃ ១២ ដុល្លារ ក្នុង ១តោន។ ចំណែកឯប្រជាពលរដ្ឋដែលមិនទាន់មានអគ្គិសនីប្រើប្រាស់ម៉ាស៊ីនភ្លើងនេះ ផ្តល់ការងារដល់មនុស្សចំនួន ៤ នាក់ ដើម្បីសាកអាគុយក្នុងតម្លៃ ១000 រៀល ក្នុងអាគុយ ១ គ្រឿង។

រហូតមកដល់ពេលនេះ ការផ្គត់ផ្គង់អគ្គិសនីដែលអាចពឹងពាក់បាននេះ បានបង្កើតមុខរបរ និងការងារបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋក្នុងភូមិដែលធ្លាប់តែដើរស្វែងរកការងារនៅទីឆ្ងាយ។ ឌុង លី បាននិយាយថា "ចាប់តាំងពីមានអគ្គិសនីប្រើប្រាស់មក អ្នកភូមិអាចបើកហាងលក់កាហ្វេ ហាងអ៊ុតសក់ កន្លែងជួសជុលម៉ាញ៉េ និងកន្លែងសាកអាគុយ ហើយក្មេងៗឥឡូវនេះ អាចទៅរៀនភាសាអង់គ្លេសនៅពេលព្រលប់ផងដែរ"។ គាត់បន្ថែមទៀតថា "នៅពេលណាមានអគ្គិសនីគ្រប់គ្រាន់ ប្រជាពលរដ្ឋអាចប្រើក្នុងគោលបំណងជាច្រើនផ្សេងទៀត ដូចជា បូមទឹកដាក់ស្រែចំការជាដើម "។

"នេះពិតជាលទ្ធផលរំពឹងទុកជាក់ស្តែងរបស់គម្រោងនេះ " តាមប្រសាសន៍របស់លោក ឡាយ ឃីម ឧបការីរបស់តំណាងប្រចាំប្រទេស ដែលទទួលបន្ទុកការងារផ្នែកបរិស្ថាន។ "យើងសង្ឃឹមថានឹងបង្កើនការងារ និងបង្កើនប្រាក់ចំណូល តាមរយៈសកម្មភាពផលិតកម្មបែបពាណិជ្ជកម្ម ដោយប្រើអគ្គិសនីដែលមានតម្លៃថោក ហើយទន្ទឹមគ្នានេះដែរ ក៏អាចជួយលើកស្ទួយបរិស្ថានដោយការដាំដើមឈើនៅតាម សហគមន៍មូលដ្ឋាន "។

## មធ្យោបាយដឹកជញ្ជូន

*ការដឹកជញ្ជូនរហ័ស និងថោកអាចជួយកាត់បន្ថយថ្លៃផលិត និងថ្លៃរស់នៅផងដែរ*

តំបន់ជនបទរបស់កម្ពុជា ចាំបាច់ត្រូវតែតភ្ជាប់គ្នាដោយប្រព័ន្ធដឹកជញ្ជូនឆាប់រហ័ស ដើម្បីធ្វើទំនើបកម្មបំពាក់ឧស្សាហកម្ម និងសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត ការដឹកជញ្ជូនរហ័ស និងថោក អាចជួយកាត់បន្ថយថ្លៃផលិត និងថ្លៃរស់នៅផងដែរ។ ថ្វីត្បិតតែផ្លូវលំជនបទ និងផ្លូវជាតិមួយចំនួនត្រូវបាន និងកំពុងសាងសង់ និងជួសជុលឡើងវិញ[៧៦] ក៏ដោយ ក៏នៅត្រូវការផ្លូវជាច្រើនថែមទៀត សូម្បីតែសព្វថ្ងៃនេះ នៅតំបន់មួយចំនួននៃប្រទេសកម្ពុជា ការចេញចូលពីប្រទេសជិតខាងងាយស្រួលជាងការធ្វើដំណើរពីក្នុងប្រទេស។

មធ្យោបាយដឹកជញ្ជូនរហ័សសម្រាប់ផ្ទុកទំនិញច្រើន និងសម្ភារៈធ្ងន់ៗ ឬដឹកអ្នកដំណើរច្រើនទាមទារឱ្យមានបណ្ដាញផ្លូវរថភ្លើងតភ្ជាប់ក្រុងសំខាន់ៗ ទៅនឹងតំបន់ទីប្រជុំជនជុំវិញក្រុង។ សូម្បីតែអគ្គិសនីនៅជនបទក៏ដោយ ក៏ត្រូវមានការដឹកជញ្ជូនធ្យូងថ្មក្នុងបរិមាណច្រើន និងគ្រឿងម៉ាស៊ីនធន់ធ្ងន់ ដែលមានតែរថភ្លើងទេ ដែលជាមធ្យោបាយដឹកជញ្ជូនប្រសើរបំផុត ពីព្រោះការដឹកជញ្ជូនតាមរថយន្តអាចមានតម្លៃថ្លៃលើសពីនេះបីដង។ ប្រព័ន្ធផ្លូវរថភ្លើងរបស់កម្ពុជា មានប្រមាណ ៧៥០ គ.ម ភ្ជាប់ពីទីក្រុងភ្នំពេញទៅកាន់ខេត្តបាត់ដំបង និងសេរីសោភ័ណ កាត់តាមខេត្តពោធិ៍សាត់ និងពីទីក្រុងភ្នំពេញទៅកាន់ក្រុងព្រះសីហនុកាត់តាមខេត្តកំពត។ ក្នុងពេលឆាប់ៗខាងមុខនេះ ផ្លូវរថភ្លើង ប្រវែងប្រមាណ ៤៦ គ.ម នឹងត្រូវបានតភ្ជាប់ពីសេរីសោភ័ណទៅដល់ប៉ោយប៉ែតព្រំប្រទល់ប្រទេសថៃ។ បច្ចុប្បន្ននេះ ផ្លូវរថភ្លើងគ្រាន់តែអាចដឹកជញ្ជូនទំនិញ និងដឹកជញ្ជូនមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះ។ មធ្យោបាយផ្ទុកទំនិញធំៗមានសភាពទ្រុឌទ្រោម ហើយមួយផ្នែកធំមិនអាចប្រើការបាន និងប្រព័ន្ធផ្ដល់សញ្ញា ក៏នៅចាស់បុរាណផងដែរ។

ផ្លូវដឹកជញ្ជូនអាស៊ី (Trans-Asia) ត្រូវបានគ្រោងនឹងតភ្ជាប់ពីប្រទេសសិង្ហបុរីទៅកាន់ខេត្តគុនមីង ភាគខាងត្បូងនៃប្រទេសចិនតភ្ជាប់ទីក្រុង និងប្រទេសជាច្រើនដែលនៅតាមនោះ។ ផ្លូវនេះចូលប្រទេសកម្ពុជាតាមច្រកប៉ោយប៉ែត ឆ្លងកាត់ទីក្រុងភ្នំពេញ ខេត្តកំពង់ចាម ទៅកាន់ព្រំដែនប្រទេសវៀតណាម។ គម្រោងផ្លូវដែកដែលកាត់ច្រើនប្រទេសនេះ នឹងជួយពង្រឹងការតភ្ជាប់គ្នាលើដីរវាងប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ វិស័យដឹកជញ្ជូន រួមមាន :

- ក. ពិតហើយ ផ្លូវដែកនេះនឹងបង្កើតរបៀងឆ្លងកាត់ពីផ្នែកបស្ចិមទៅបូព៌ា ប៉ុន្តែផ្លូវដែកទៅភាគខាងត្បូង ដែលតភ្ជាប់ទៅកំពង់ផែក្រុងព្រះសីហនុ ក៏ត្រូវស្ដារឡើងវិញជាបន្ទាន់ផងដែរ។
- ខ. បណ្ដាញតភ្ជាប់ពីផ្នែកខាងជើងទៅភាគខាងត្បូងប្រទេសក៏មានភាពចាំបាច់ផងដែរ ដើម្បីជួយតភ្ជាប់ទីផ្សារ និងប្រជាពលរដ្ឋនៅក្នុងប្រទេស។
- គ. ការកែលម្អពីផ្លូវដែកតែមួយខ្សែឱ្យទៅជាពីរខ្សែ នឹងជួយបង្កើនល្បឿនចរាចរបានយ៉ាងល្អប្រសើរ។
- ឃ. ប្រសិនបើផ្លូវដែកនេះតភ្ជាប់ទីក្រុងមួយចំនួនដែលរំពឹងថា នឹងជាអនាគតមណ្ឌលកំណើនសេដ្ឋកិច្ច នោះសក្ដានុពលលូតលាស់ផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ទីក្រុងទាំងនោះមុខជានឹងឡើងខ្ពស់។ ប៉ុន្តែដើម្បីឱ្យអាចសម្រេចទៅបាន ចាំបាច់ត្រូវតែមានការវិនិយោគបន្ថែម។
- ង. ធ្វើឱ្យការដឹកទំនិញ និងដឹកអ្នកដំណើរមានតម្លៃទាប គឺជាការប្រសើរបំផុត។ មធ្យោបាយដឹកជញ្ជូនដែលមានតម្លៃថោក និងអាចបណ្ដាលឱ្យអ្វីៗទៀត មានតម្លៃថោកដែរអាចជម្រុញឱ្យសកម្មភាពដទៃទៀតកើនឡើង។ ដូច្នេះមិនត្រូវចាត់ទុកផ្លូវរថភ្លើងថាជាសហគ្រាសមួយ ដែលដាច់ដោយឡែកទេ។
- ច. ប្រទេសជាច្រើនកំពុងផ្លាស់ផ្លូវរថភ្លើងបច្ចុប្បន្នរបស់គេពីផ្លូវធម្មតា (ដូចផ្លូវរថភ្លើងស្រុកខ្មែរ) ទៅជាផ្លូវរថភ្លើងទំនើប ដែលមានទំហំទូលាយជាង ដូច្នេះគេឈប់ប្រើទូរថភ្លើងរបស់គេសព្វថ្ងៃ ដែលនៅមានគុណភាពល្អនៅឡើយ។ កម្ពុជាអាចចរចាទិញទូរថភ្លើងទាំងនោះក្នុងតម្លៃសមរម្យបាន។

## នគរូបនីយកម្ម និងទីផ្សារ

រហូតមកដល់ពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍជាច្រើនមាននៅតែក្នុង និងជុំវិញទីក្រុងភ្នំពេញ និងមួយផ្នែកនៅកំពង់ផែក្រុងព្រះសីហនុ។ ចំណែកឯខេត្តសៀមរាបវិញ ជាកន្លែងទាក់ទាញភ្ញៀវទេសចរដែលទៅទស្សនាប្រាសាទបុរាណ។ ជាការពិតហើយ នគរូបនីយកម្មមានទំនោរគ្របដណ្ដប់តែតាមតំបន់ខ្លះៗ ដូច្នេះហើយបានជាមានមនុស្សជាច្រើនធ្វើចំណាកស្រុកពីតំបន់មួយទៅតំបន់មួយទៀត ដើម្បីស្វែងរកការធ្វើ[៧៧]។

---

*(៧៦) សូមមើល ងី (២០០៦) សំរាប់ព័ត៌មានថ្មីអំពីការអភិវឌ្ឍផ្លូវ*

*(៧៧) អង្គការពលកម្មអន្តរជាតិ (២០០៦)*

*ពលរដ្ឋជាច្រើនមិនបានទទួលការផ្គត់ផ្គង់ជីវភាពរស់នៅគ្រប់គ្រាន់ពីធនធានដីធ្លីទេ ។ ភាពគ្មានដីធ្លីក៏កំពុងតែកើនឡើងផងដែរ*

ការខិតខំលើកស្ទួយដល់ការបន្ថែមគុណតម្លៃលើផលកសិកម្ម និងជម្រុញឱ្យមានកសិឧស្សាហកម្មនៅជនបទ អាចនឹងទទួលបានជោគជ័យ ប្រសិនបើមានប្រជាពលរដ្ឋផ្តុំគ្នារស់នៅជិតៗនោះ រួមទាំងមានសម្ភារៈបរិក្ខារនៃហេដ្ឋារចនាសម្ព័ន្ធជាបន្ថែមទៅលើទីផ្សារផងនោះ ។ ការបង្កើតទីប្រជុំជនប្រកបដោយតុល្យភាពក្នុងតំបន់ អាចជួយលើកស្ទួយដល់ស្ថាប័ននយោបាយមូលដ្ឋាន និងស្ថាប័នសង្គមដែលអាចធ្វើឱ្យលទ្ធិប្រជាធិបតេយ្យកាន់តែស៊ីជម្រៅ ។ ការអភិវឌ្ឍផ្លូវដឹកជញ្ជូន គឺជាមធ្យោបាយមួយ ដើម្បីលើកស្ទួយដល់ការលូតលាស់របស់ទីក្រុងរណបតូចៗ ព្រោះថាទាំងពីរនេះមានកម្លាំងផ្តុំគ្នា ។ កម្ពុជាមានគុណសម្បត្តិត្រង់ថា ប្រជាពលរដ្ឋភាគច្រើនរស់នៅជិតបណ្តាញផ្លូវថ្នល់សំខាន់ៗ ជិតផ្លូវរថភ្លើង ឬផ្លូវទឹក ដូច្នេះការស្វះស្វែងរកដំណោះស្រាយក្នុងវិស័យនេះមិនមែនជារឿងថ្មី ឬក៏ត្រូវចំណាយច្រើនណាស់ណានោះទេ ។

ចំណុចចាប់ផ្តើមសម្រាប់អភិវឌ្ឍទីប្រជុំជនរណប គឺគួរតភ្ជាប់ទៅតំបន់ខ្សែក្រវ៉ាត់ភាគខាងត្បូង (ក្រុងព្រះសីហនុ ខេត្តកំពត និងក្រុងកែប) ដោយសារតំបន់នេះមានបណ្តាញផ្លូវដែករួចស្រេចហើយ និងបណ្តាញអគ្គិសនី ក៏រំពឹងថា នឹងត្រូវបានតភ្ជាប់មុនគេដែរ ។ តំបន់ទាំងនេះស្ថិតនៅជិតសមុទ្រ ដែលអាចតភ្ជាប់ទៅមធ្យោបាយដឹកជញ្ជូនផ្លូវទឹក ។ ក្នុងពេលឆាប់ៗខាងមុខនេះ ក្រុងព្រះសីហនុក៏នឹងត្រូវបានតភ្ជាប់ខ្សែបណ្តាញដឹកជញ្ជូនតាមអាកាសផងដែរ ។ តំបន់នីមួយៗនៃតំបន់ទាំងនេះ មានសក្តានុពលបង្កើនផលកសិកម្មសម្រាប់ទីផ្សារ ហើយដោយសាររបៀងនេះ មានប្រជាពលរដ្ឋរស់នៅច្រើនគួរសមផងដែរ តំបន់នីមួយៗនេះអាចធ្វើជាតំបន់ឧស្សាហកម្មនឹងក្លាយទៅជាតំបន់ទេសចរណ៍ដែលមានតម្លៃទាប[៧៨] ។

***សារគន្លឹះ :***

*បំពាក់អគ្គិសនីនៅជនបទឱ្យមានតម្លៃថោក មធ្យោបាយដឹកជញ្ជូនតាមផ្លូវដែក និងបង្កើតឧស្សាហកម្មច្រើនប្រភេទ នឹងជួយលើកតម្កើងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងផ្តល់ជីវភាពរស់នៅកាន់តែប្រសើរជូនប្រជាពលរដ្ឋនៅតាមស្រុកស្រែ ។*

## ៥.២ ការបង្កើតហេដ្ឋារចនាសម្ព័ន្ធដោយមានបច្ចេកវិទ្យាស្រូបយកកម្លាំងពលកម្មច្រើន[៧៩]

ប្រជាពលរដ្ឋជាច្រើនមិនបានទទួលការផ្គត់ផ្គង់ជីវភាពរស់នៅគ្រប់គ្រាន់ពីធនធានដីធ្លីទេ ។ ភាពគ្មានដីធ្លីក៏កំពុងតែកើនឡើងផងដែរ ។ ខណៈដែលសេដ្ឋកិច្ចកំពុងតែរីកចម្រើនដ៏លឿន ក្នុងកំឡុងពេលបួនប្រាំឆ្នាំកន្លងទៅនេះ ប្រាក់កម្រៃឈ្នួលនៅជនបទសម្រាប់កម្មករក្នុងចំណោមអ្នកក្រីក្របំផុត ដែលគ្មានជំនាញ គឺ ៤០០០ រៀលក្នុងមួយថ្ងៃ (តម្លៃក្នុងឆ្នាំ ២០០០) ហើយមិនបានបង្ហាញឱ្យឃើញថាប្រហែលជានឹងកើនទេ ក្នុងពេលថ្មីៗនេះ (តារាងទី ៥.១) ។

***តារាងទី ៥.១ : ការប្រែប្រួលនៃប្រាក់ឈ្នួលពិតប្រចាំថ្ងៃរបស់កម្មករស៊ីឈ្នួលធ្វើស្រែពីឆ្នាំ ២០០០ ដល់ ២០០៦ (តម្លៃក្នុងឆ្នាំ ២០០០)***



*ប្រភព : ការពិនិត្យលើការអភិវឌ្ឍកម្ពុជា (បញ្ហាផ្សេងៗ ក្រុមពលករដែលងាយរងគ្រោះ "សង្កេតការណ៍សេដ្ឋកិច្ច" - សូចនាករនានា)*

---

*(៧៨) របៀងពាណិជ្ជកម្មត្រូវបានគ្រោងរួចហើយនៅក្នុងប្រទេស ប៉ុន្តែរបៀងទាំងនោះ ដូចជាសម្រាប់បម្រើសេវាកម្មពាណិជ្ជកម្មទៅកាន់ប្រទេសជិតខាង ជាងការបង្កើតការងារច្រើនសម្រាប់យុវជននៅតាមជនបទ ។*

*(៧៩) ប្រទេសជាច្រើន ទាំងប្រទេសលូតលាស់លឿន ទាំងប្រទេសលូតលាស់យឺត បានអនុម័តកម្មវិធីប្រឆាំងនឹងភាពក្រីក្រដោយផ្ទាល់ ដែលកម្មវិធីខ្លះក៏មានពាក់ព័ន្ធដល់ការបង្កើតសមិទ្ធផលដែរ ប៉ុន្តែកម្មវិធីខ្លះទៀតក៏មិនមានពាក់ព័ន្ធទេ ។*

ពលរដ្ឋក្រីក្រកម្ពុជាអាចទទួលផលប្រយោជន៍ធំធេងពីកម្មវិធីការងារសាធារណៈផ្សេងៗ ដើម្បីបម្រើគោលបំណងពីរ គឺ ៖

ក. ជួយកាត់បន្ថយភាពក្រីក្រតាមរដូវ និងភាពអត់ ឬខ្វះការងារធ្វើតាមតំបន់ជនបទនានា

ខ. បង្កើតសមិទ្ធផល និងសេវាកម្មនានាដែលមានប្រយោជន៍សម្រាប់សេដ្ឋកិច្ច ។

អ្វីដែលបង្កប់នៅក្នុងសេចក្ដីសម្អាងទាំងនោះ គឺគំនិតក្នុងការពង្រឹងអំណាចដល់អ្នកក្រីក្រ (តាមរយៈការផ្ដល់ការងារ) និងវិមជ្ឈការសេដ្ឋកិច្ច ដែលទាំងពីរនេះជាលក្ខខណ្ឌដំបូងសម្រាប់ឱ្យសម្រេចបាននូវការអភិវឌ្ឍមនុស្ស ។

កម្មវិធីនានាដូចជាមូលនិធិសង្គម និងកម្មវិធីស្បៀងពលកម្មរបស់កម្មវិធីស្បៀងអាហារពិភពលោក គឺជាគម្រោងដែលបានទទួលជោគជ័យនៅក្នុងប្រទេស ។ កម្មវិធីការងារសាធារណៈនានា ត្រូវបានផ្ដួចផ្ដើមឡើងដោយក្រុមប្រឹក្សាឃុំ និងក្រុមឧបាសកជើងវត្តនានា ដែលបានបង្កើតជាសមិទ្ធផលខ្នាតតូចៗ (ដូចជា ដាក់លូ ផ្លូវលំតាម មូលដ្ឋាន ស្ពានអាងទឹក ជាដើម) ដោយប្រើកម្មករដែលនៅតាមភូមិ ។ សេចក្ដីស្នើត្រង់ចំណុចនេះស្រដៀងតែគ្នាទេ គឺគ្រាន់តែស្នើឱ្យដាក់ការបង្កើតការងារជាចំណុចស្នូលរបស់វាតែប៉ុណ្ណឹង ។ លើសពីនេះទៀត មានការលើកយោបល់ថា កម្មវិធីនេះគួរតែមានផ្នែកកសាងសមត្ថភាពនៅពីក្នុងតែម្ដង ។ ការចូលរួមពីវិស័យឯកជន និងការផ្ដល់ហិរញ្ញវត្ថុរួមគ្នាក្នុងដំណាក់កាលណាមួយនោះ ក៏ត្រូវបានស្នើឡើងដែរ ។

**ប្រអប់ ៥.២ ៖ សមិទ្ធផលដែលបង្កើតឡើង ក្រោមកម្មវិធីផ្ដល់ការងារជួយផ្ដល់បន្ថែមតម្លៃពិត**

*សំណួរ ៖* តើការបន្ថែមតម្លៃពិត ដែលបង្កើតឡើងដោយគម្រោងផ្សេងៗ ក្រោមកម្មវិធីដែលត្រូវការពលកម្មច្រើនមានទំហំសមហេតុសមផលដែរ ឬទេ - បើនិយាយឱ្យចំទៅ គឺថាតើគម្រោងទាំងនេះមានប្រយោជន៍គ្រប់គ្រាន់ ដើម្បីយកទៅជួយក្នុងវិស័យកសិកម្ម និងជនបទបាន ឬទេ ?

*ចម្លើយ ៖* ជាទូទៅ ប្រសិនបើគម្រោងទាំងនេះលើកកាលវិភាគមិនឱ្យប៉ះពាល់ដល់រដូវដែលត្រូវការពលកម្មច្រើនសម្រាប់ធ្វើកសិកម្ម បញ្ហាខាងលើនេះអាចសម្រាលបាន ។ វាលទំនាបដីសណ្ដទន្លេមេគង្គ និងតំបន់បឹងទន្លេសាប ដែលមានប្រជាពលរដ្ឋរស់នៅកុះករ មានកម្លាំងពលកម្មច្រើនបរិបូណ៌ អាចបញ្ចប់គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទនេះ ។ ដូចឃើញនៅក្នុងទិន្នន័យនៃប្រទេសបង់ក្លាដេស ដែលមានប្រជាពលរដ្ឋរស់នៅកុះករអញ្ចឹងដែរ វិស័យកសិកម្មទទួលបានផលប្រយោជន៍ពិតប្រាកដមែន ពីព្រោះកសិករតូចតាចដែលបម្រើការក្នុងកម្មវិធីការងារសាធាណៈទាំងនេះ បានយកប្រាក់កម្រៃដែលគេរកបានទៅប្រើលើដីធ្លីរបស់គេដើម្បីបង្កើនទិន្នផល ។

ឧទាហរណ៍ដែលធ្វើឱ្យចាប់អារម្មណ៍ជាងគេបំផុតនោះ គឺនៅក្នុងប្រទេសចិនមានសម្បត្តិធនធានក្នុងទ្រង់ទ្រាយធំមួយ ត្រូវបានបង្កើតឡើងក្នុងចន្លោះពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ ទៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ។ ក្រោមកម្មវិធី យីហ្គុង-ដាយហ្សេន (Yigong-Daizhen) ផ្លូវថ្នល់ជនបទប្រវែង ១៣០,០០០ គ.ម និងស្ពានចំនួន ៨,០០០ ត្រូវបានស្ថាបនាឡើងតភ្ជាប់ភូមិចំនួន ១០,០០០ ភូមិ និងផ្គត់ផ្គង់ទឹកស្អាតសម្រាប់បរិភោគជូនប្រជាពលរដ្ឋជនបទ ចំនួន ២១ លាននាក់ ។

*ប្រភព ៖ អង្គការពលកម្មអន្តរជាតិ-Bappenas (២០០៥); Ling និង Zhongyi (១៩៩៥)*

កម្មវិធីបែបនេះមានគំរូជាច្រើន ដែលអាចយកជាមេរៀនបាន[៨០] ។ ដើម្បីជោគជ័យនៃកម្មវិធីនេះ ត្រូវគោរពតាមបុរេលក្ខខណ្ឌប្រាំដូចខាងក្រោមនេះ ៖

ក. កម្មវិធីការងារត្រូវតែអាចបទបែនបាននៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យត្រូវទៅតាមសេចក្ដីត្រូវការការងារជាមួយនឹងការផ្គត់ផ្គង់ ។

ខ. កម្មវិធីការងារគួរតែមានគោលដៅទៅរកអ្នកក្រ ការងារមួយចំនួនធំគួរតែជាការងារធ្វើដោយដៃ ហើយប្រាក់កម្រៃប្រចាំថ្ងៃគួរតែក្នុងចន្លោះ ៤.០០០ រៀលក្នុងមួយថ្ងៃ ដើម្បីទាក់ទាញអ្នកដែលត្រូវការពិតប្រាកដ ។

គ. ត្រូវតែមានផែនការការងារដែលមានសារប្រយោជន៍ចំពោះសេដ្ឋកិច្ច និងសង្គម ដែលអាចយកមកប្រើបានភ្លាមៗនៅក្នុងចន្លោះរយៈពេលខ្លីៗ ។

ឃ. ចាំបាច់ត្រូវមានប្រព័ន្ធតាមដាន និងវាយតម្លៃមួយដ៏រឹងមាំ ។

ង. ការពង្រឹងសមត្ថភាពនៅនឹងកន្លែងការងារខ្លះៗ អាចបញ្ចូលជាផ្នែកមួយនៃកញ្ចប់កម្មវិធី ។

***<u>សារគន្លឹះ</u> ៖*** *កម្ពុជាគួរតែផ្ដើមគំនិតបង្កើតកម្មវិធីការងារសាធារណៈដែលស្រូបយកកម្លាំងពលកម្មច្រើន ដើម្បីផ្ដល់ការងារទៅអ្នកដែលត្រូវការការងារពិតប្រាកដក្នុងពេលដែលពួកគាត់ខ្វះខាត ហើយនិងជួយបង្កើតសមិទ្ធផលនៅជនបទ ដែលមានសារប្រយោជន៍ ដូចជា ផ្លូវតូចៗ បន្ថែមប្រព័ន្ធលូទឹក និងប្រព័ន្ធទំនប់ទឹកផ្សេងៗ ។*

ទំនោរបច្ចុប្បន្ន ដែលមានសិស្ស ឈប់រៀនក្រោយពី បានរៀនចប់ត្រឹម ថ្នាក់ទី១ ឬថ្នាក់ទី៣ គឺជាការព្រួយបារម្ភ ចំពោះអនាគតនៃ បរិមាណធនធាន មនុស្សនៅតាមជនបទ

## ៥.៣ ការអភិវឌ្ឍសង្គម

### ការបង្កបង្កើតធនធាន (សតិបញ្ញា) មនុស្ស

ការបង្កបង្កើតធនធានមនុស្ស គឺជាចំណុចស្នូលមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដូចជាវិស័យដទៃទៀតដែរ ការអភិវឌ្ឍជនបទតាមបែបទំនើបទាមទារឱ្យមានបច្ចេកវិទ្យាទំនើប ដូច្នេះបើមិនមានធនធានមនុស្សគ្រប់គ្រាន់ទេ នោះប្រហែលជាមានផលវិបាកធំហើយ។ ហើយប្រជាពលរដ្ឋដែលអាចប្រើប្រាស់បច្ចេកវិទ្យាទំនើបនេះបាន និងអាចរកប្រាក់ចំណូលបានគ្រាន់បើ គឺមានតែប្រជាពលរដ្ឋដែលមានការអប់រំ និងមានគុណសម្បត្តិគ្រប់គ្រាន់ខាងផ្នែកបច្ចេកទេស។

*ការអប់រំកម្រិតបឋមសិក្សា*

ការអប់រំបឋមសិក្សាជាសាកល ត្រូវបានតម្កល់ទុកក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ហើយដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានប្តូរផ្តាច់ធ្វើឱ្យបានជោគជ័យ។ បច្ចុប្បន្ននេះ ការដែលសិស្សឈប់រៀនក្រោយពីបានរៀនចប់ត្រឹមថ្នាក់ទី ១ ឬថ្នាក់ទី ៣ គឺជាការព្រួយបារម្ភចំពោះអនាគតនៃបរិមាណធនធានមនុស្សនៅតាមជនបទ។ ការបញ្ចប់ការសិក្សានៅបឋមសិក្សាអាចសម្រេចជោគជ័យបានច្រើន ប្រសិនបើ :

- ក. ការអប់រំមិនត្រូវមានការបង់ថ្លៃអ្វីទាំងអស់។ បច្ចុប្បន្ននេះ វាកំពុងមានភាពបន្ទុចបង្អាក់ជាច្រើន ដូចជាតម្រូវឱ្យសិស្សជនបទក្នុងម្នាក់ៗ បង់ថ្លៃសម្លៀកបំពាក់ឯកសណ្ឋាន និងបង់ប្រាក់ក្រៅប្រព័ន្ធឱ្យគ្រូប្រហែល ៥៤.០០០ រៀល ក្នុងមួយឆ្នាំ យោងទៅលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ២០០៤ (SES-04)។
- ខ. សិស្សទាំងឡាយណាដែលរៀនមិនទាន់គេ ដោយសារខ្វះជំនួយគាំទ្រពីឪពុកម្តាយ (ឪពុកម្តាយអាចមិនចេះអក្សរ) ឬដោយសារជាប់រវល់រួមចំណែកក្នុងពលកម្មខ្លះ (ដូចជា នេសាទត្រី ឬកែច្នៃត្រី) ឬដោយសារបុព្វហេតុដទៃទៀត ត្រូវឱ្យសិស្សទាំងនោះរៀនបំពេញបន្ថែមក្នុងថ្នាក់ពិសេស។
- គ. ត្រូវផ្តល់អាហារបន្ថែមឱ្យសិស្ស ដើម្បីដោះស្រាយបញ្ហាសិស្សក្រីក្រខ្វះអាហារ។ ការផ្តល់អាហារថ្ងៃត្រង់ឱ្យសិស្សនៅសាលាជួយសម្រួលក្នុងការរក្សាឱ្យមានសិស្សរៀនបានច្រើន និងជួយឱ្យសិស្សមូលអារម្មណ៍លើការសិក្សា។
- ឃ. ត្រូវឱ្យប្រាក់ខែគ្រូបង្រៀនសមល្មមអាចរស់បាន។ សាលាក៏អាចជ្រើសរើសយុវជន ដែលមានចំណេះដឹងនៅតាមមូលដ្ឋានឱ្យស្ម័គ្រចិត្តធ្វើជាគ្រូជំនួយ។

ត្រូវយកចិត្តទុកដាក់ឱ្យបានពិសេសមែនទែនចំពោះសិស្សជាកុមារី នូវរាល់ទិដ្ឋភាពទាំងអស់ ពីព្រោះពួកគេឆាប់ឈប់រៀនជាងសិស្សប្រុសៗ។

*ការអប់រំវិជ្ជាជីវៈ*

ទីផ្សារពលកម្មនៅកម្ពុជា ត្រូវការកម្មករជំនាញក្នុងកម្រិតកណ្តាលជាច្រើន ដូចជា ជាងម៉ាស៊ីន អ្នកមេការ ជាងអគ្គិសនី ជាងរុំម៉ូទ័រ ជាងជួសជុលម៉ាស៊ីន ជាងកំបោរ និងជាងផ្សេងៗទៀតជាដើម។ អ្នកជំនាញពីប្រទេសក្រៅកាន់មុខតំណែងទាំងនេះ អ្នកខ្លះស្របច្បាប់ និងខ្លះទៀតមិនស្របច្បាប់។

សេចក្តីត្រូវការការងារធ្វើក៏ច្រើនដូចគ្នាដែរ។ ឆ្នាំក្រោយៗទៅ ជនវ័យក្មេងជាង ២០០.០០០ នាក់ តាមសហគមន៍ជនបទនានាប្រហែលជានឹងចេះអក្សរ ឬទទួលបានការអប់រំផ្សេងៗជារៀងរាល់ឆ្នាំ ហើយភាគច្រើននឹងស្វែងរកការងារធ្វើតាមជម្រើសផ្សេងៗ ក្រៅពីការងារកសិកម្ម។ ប៉ុន្តែគ្រាន់តែចេះអក្សរ ឬមានសញ្ញាប័ត្រពីសាលាបឋមសិក្សាមិនអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីរកការងារក្រៅពីកសិដ្ឋានដែលបានកម្រៃថ្លៃបានឡើយ។ ដូច្នេះទាមទារឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនបន្ថែមទៀត។

ការអប់រំវិជ្ជាជីវៈមិនមែនជារឿងថ្មីទេសម្រាប់កម្ពុជា។ តាមកម្រិតផ្លូវការ គឺមានកម្មវិធីបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈ និងផ្នែកបច្ចេកទេសនៅតាមថ្នាក់រៀន ក៏ដូចជានៅតាមបណ្តាសហគ្រាសធំៗផងដែរ។ សម្រាប់ស្ត្រី មានកម្មវិធីបណ្តុះបណ្តាលពិសេសដាច់ដោយឡែក។ ចំពោះសិស្សដែលឈប់រៀន គឺមានមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមខេត្តចំនួន ៣០ មណ្ឌល ដែលផ្តល់មុខវិជ្ជាផ្សេងៗ ក្នុងរយៈពេលពីមួយសប្តាហ៍ដល់ប្រាំមួយខែ (នៅគ្រប់ខេត្តទាំងអស់)។ ទោះបីយ៉ាងនេះក្តី ចំនួនសិស្សចុះឈ្មោះចូលរៀននៅមានកម្រិតតិចតួច។ ក្នុងឆ្នាំ ២០០៥ មានតែ ១២០០ នាក់ប៉ុណ្ណោះ បានរៀនចប់មជ្ឈមណ្ឌលបណ្តុះបណ្តាលតាមខេត្តទាំងអស់ ដែលជាចំនួនតិចជាងពីអតីតកាលបន្តិច[៨១]។

---

(៨០) សូមមើល ឧ. Deveaux S និង C Solomon (២០០៥) អង្គការពលកម្មអន្តរជាតិ - Bappenas (២០០៥)

(៨១) អង្គការពលកម្មអន្តរជាតិ (២០០៦)

ការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវតែពង្រឹង និងពង្រីក ដើម្បីបំពេញចន្លោះខ្វះខាត ដោយពង្រាយឱ្យទូលំទូលាយតាមតំបន់ ដើម្បីបង្កលក្ខណៈឱ្យអ្នកក្រតាមជនបទអាចរៀនបាន។ ការបណ្តុះបណ្តាលនេះត្រូវតែឆ្លើយតបទៅតាមសេចក្តីត្រូវការ ដោយយោងតាមការកំណត់របស់ការស្ទង់មើលជំនាញតាមផ្នែក ដែលកំណត់អំពីសេចក្តីត្រូវការកម្មករជំនាញតាមប្រភេទ និងតាមទីតាំង។ ការខំប្រឹងប្រែងពិសេសមួយដើម្បីបណ្តុះបណ្តាលក្មេងស្រីៗ អាចតភ្ជាប់ចន្លោះខ្វះខាតខាងផ្នែកយេនឌ័រ[៨២] ។

### ប្រអប់ ៥.៣ : គំរូផ្សេងៗក្នុងការផ្តល់ជំនាញវិជ្ជាជីវៈដែលមានតម្លៃទាប

ក. មជ្ឈមណ្ឌលបណ្តុះបណ្តាលខ្នាតតូចៗនៅតាមទីតាំងយុទ្ធសាស្ត្រនានាអាចបម្រើ មិនត្រឹមតែសម្រាប់សេចក្តីត្រូវការដំបូងៗប៉ុណ្ណោះទេ ថែមទាំងអាចផ្តល់វគ្គបណ្តុះបណ្តាលនៅពេលបន្តបន្ទាប់ទៀត។ ផ្នែកបុគ្គលិកអាចមានគ្រូម្នាក់ និងសម្ភារៈបណ្តុះបណ្តាលបន្តិចបន្តួចនៅជាប់ជាមួយនឹងអាគាររោងជាងជួសជុលរបស់ឧស្សាហកម្ម និងសហគ្រាសខ្នាតតូចៗ។ សិក្ខាកាមអាចត្រូវនាំមកកាន់អាគាររោងជាងនេះ ដើម្បីទទួលការបណ្តុះបណ្តាលជាមួយសកម្មភាពជួសជុលតែម្តង។

ខ. វគ្គបណ្តុះបណ្តាលចល័ត គឺជាជម្រើសមួយសម្រាប់សិក្ខាកាមដែលពុំមានលទ្ធភាពធ្វើដំណើរ ដោយសារបញ្ហាថវិកា និងខ្វះពេលវេលា។ ជម្រើសផ្សេងៗទៀតសម្រាប់វគ្គបណ្តុះបណ្តាលចល័ត គឺផ្ទុកសម្ភារៈបណ្តុះបណ្តាលលើឡានធំមួយ ហើយដឹកទៅកាន់ភូមិមួយម្តងៗតាមពេលកំណត់ជាក់លាក់។ ការបណ្តុះបណ្តាលចល័តបែបនេះ ក៏មានសារប្រយោជន៍ផងដែរ ក្នុងការពង្រីកជំនាញតាមកន្លែងធ្វើការ អាចជួយពង្រឹងសមត្ថភាពដល់ជាងកាត់ដេរ ជាងជួសជុលម៉ាស៊ីន ជាងអគ្គិសនី និងជួយបង្កើនសមត្ថភាពកម្មករស្រដៀងៗគ្នានេះទៀតដែរ។ បន្ថែមលើនេះទៀត គ្រូបណ្តុះបណ្តាលវគ្គចល័ត អាចរកឃើញបញ្ហាជាក់ស្តែង ដែលសិក្ខាកាមប្រឈមមុខ ហើយដើរតួជាអ្នកដោះស្រាយបញ្ហា។

មុខវិជ្ជា និងមេរៀនបណ្តុះបណ្តាលសម្រាប់រយៈពេលពីពីរបីសប្តាហ៍ទៅពីរបីខែ អាចជួយផ្តល់ជំនាញវិជ្ជាជីវៈ និងការអនុវត្តជាក់ស្តែងផ្សេងៗដល់សិស្សដែលឈប់រៀនពីវិទ្យាល័យ ឬសិស្សដែលមិនទាន់បានរៀនចប់សាលាបឋមសិក្សា។ មេរៀនខ្លះមាននៅតាមអ៊ីនធឺណែត។

*ប្រភព : Acharya, Iyer និង Basak (២០០៥)*

## សំណើជាក់លាក់ រួមមាន :

ក. វគ្គបណ្តុះបណ្តាលទ្រង់ទ្រាយធំសម្រាប់ក្មេងប្រុស-ស្រី អាយុពី ១៤ ទៅ ១៧ ឆ្នាំ ដែលប្រហែលជាបានបញ្ចប់ការសិក្សាពីថ្នាក់ទី ៣ ទៅទី ៨ ឬ ទី៩ ហើយចាកចោលសាលា។ អ្នកទាំងនេះជាអ្នកចេះអក្សរនៅវ័យក្មេង ល្មមអាចចូលប្រឡូកក្នុងទីផ្សារពលកម្ម និងរៀនវគ្គបណ្តុះបណ្តាលអនុវត្តផ្ទាល់បានក្នុងរយៈពេលពី ៦ ទៅ ១៥ សប្តាហ៍ ក្នុងមុខជំនាញសម្រាប់អាជីវកម្មនានា ដែលជួយឱ្យពួកគេអាចរកការងារសមស្របបានធ្វើ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលត្រូវដាក់ពង្រាយតាមទីតាំងភូមិសាស្ត្រសមស្រប ដើម្បីឱ្យសិក្ខាកាមស្រួលទៅរៀន។ ប្រសិនបើវគ្គបណ្តុះបណ្តាលនេះ មានរួមបញ្ចូលមេរៀនផ្នែកបង្កើតមុខរបរឬរបៀបរកការងារធ្វើ ហើយថែមទាំងមានភ្ជាប់ជាមួយនឹងទម្រង់កម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់បង្កើតមុខរបរផងនោះ សិក្ខាកាមនឹងមានសមត្ថភាពគ្រប់គ្រាន់អាចចូលប្រឡូកក្នុងទីផ្សារការងារបាន។ ការរៀបចំកន្លែងសម្រាប់ឱ្យសិស្សស្រីស្នាក់នៅ គឺជាការចាំបាច់ ដើម្បីកុំឱ្យពួកគេគេចវេសចេញពីការរៀនសូត្រ។

ខ. វគ្គបណ្តុះបណ្តាលជំនាញថ្នាក់កណ្តាល : សព្វថ្ងៃនេះមានកម្មករដែលមានជំនាញពីថ្នាក់កណ្តាលដល់ថ្នាក់វិស្វករ និងនិស្សិតដែលបានបញ្ចប់វិជ្ជាជីវៈ ហើយដែលអាចធ្វើជាមេការ អ្នកគូរប្លង់ ឬកម្មករតាមហាង។ បន្ទាប់ពីបានសិក្សាអស់រយៈពេល ១០ ទៅ ១២ ឆ្នាំ វគ្គបណ្តុះបណ្តាល ១ ឆ្នាំ ខាងពហុបច្ចេកទេសផ្នែកវិស្វកម្ម និងជំនាញផ្សេងៗ ពាក់ព័ន្ធវិស័យសេវាកម្មទាំងនោះ គឺជាការគ្រប់គ្រាន់។ ទំនាក់ទំនងការងារ ដូចជាទីភ្នាក់ងារជួយរកការងារ ឬផ្សារភ្ជាប់ទៅនឹងឥណទានសម្រាប់បង្កើតមុខរបរនឹងជួយឱ្យសិក្ខាកាមមានជម្រើសកាន់តែប្រសើរឡើងក្នុងការរកការងារធ្វើ។

គ. សេវាបណ្តុះបណ្តាល និងគាំទ្រផ្នែកផ្សេងៗ គឺជាផ្នែកមួយសម្រាប់ឈានទៅបន្តការសិក្សាតទៅទៀត ទោះជាសម្រាប់កម្មករ ឬសហគ្រិនក្តី។ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ការចេញដំណើរឆ្ពោះទៅរកឧស្សាហូបនីយកម្ម ជំនួយគាំទ្រផ្នែកបច្ចេកទេស និងទីផ្សារសម្រាប់ពង្រីកអាជីវកម្មមានសារៈសំខាន់ណាស់។ ប្រសិនបើមិនមានជំនួយគាំទ្រនេះតាមរយៈទីផ្សារទេ គឺរដ្ឋាភិបាល ឬអ្នកផ្តល់ជំនួយត្រូវតែផ្តល់ឱ្យ យ៉ាងហោចណាស់ ក៏សម្រាប់មួយរយៈខ្លីសិនដែរ។

---

*(៨២) មានគំរូជាច្រើនក្នុងកិច្ចការនេះ ( ប្រអប់ទី ៥.៣) ។*

*ការអប់រំកម្រិតឧត្តមសិក្សា*

បច្ចុប្បន្ននេះកម្ពុជាមានសាលាជាច្រើនសម្រាប់កម្រិតឧត្តមសិក្សាដែលឧបត្ថម្ភដោយរដ្ឋាភិបាលនិងវិស័យឯកជន។ក្នុងឧត្តមសិក្សានេះម្ចាស់ជំនួយបានផ្តល់ជាជំនួយខ្លះៗ និងកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ។ ប៉ុន្តែទំហំនៃមុខវិជ្ជាដែលផ្តល់ឱ្យទាំងនោះនៅមានកម្រិត។ ហេតុនេះហើយបានជាមានអតុល្យភាពរវាងមុខជំនាញ ដែលកម្ពុជាត្រូវការ និងអ្នកជំនាញដែលកម្ពុជាអាចផលិតបាន ពោលគឺបុគ្គលិកជំនាញ ដូចជា វិស្វករ ស្ថាបត្យករ អ្នកគូរប្លង់ បុគ្គលិកផ្នែកព័ត៌មានវិទ្យា កម្មវិធីកុំព្យូទ័រ គ្រូពេទ្យ និងមុខជំនាញស្រដៀងៗគ្នាដទៃទៀតនៅមានចំនួនតិចតួចណាស់ ហើយសម្បូណ៌តែអ្នកមានសញ្ញាប័ត្រទូទៅ ដូចជាគណនេយ្យករ និងការគ្រប់គ្រង។ លើសពីនេះ ស្តង់ដារសិក្សាប្រែប្រួលខុសៗគ្នាពីមហាវិទ្យាល័យមួយទៅមហាវិទ្យាល័យមួយទៀត និងពីសាកលវិទ្យាល័យមួយទៅមហាវិទ្យាល័យមួយទៀត។ ចុងបញ្ចប់ មុខវិជ្ជាខ្លះ បង្រៀនជាភាសាអង់គ្លេស ខ្លះជាភាសាបារាំង និងខ្លះទៀតជាភាសាខ្មែរ។

### ប្រអប់ ៥.៤ : ការបង្កបង្កើតធនធានមនុស្សតាមរយៈសេវាអភិវឌ្ឍន៍អាជីវកម្ម

សម្រាប់ប្រទេសជាច្រើនដែលមិនទាន់អភិវឌ្ឍន៍ ការពង្រឹងផលិតកម្មមានសារៈសំខាន់។ មធ្យោបាយមួយក្នុងទិសដៅនេះ គឺត្រូវបង្កើតសេវាអភិវឌ្ឍន៍អាជីវកម្ម (BDS)។

សេវាអភិវឌ្ឍន៍អាជីវកម្ម រួមមាន ការបណ្តុះបណ្តាលសេវាប្រឹក្សានិងផ្តល់យោបល់ ជំនួយរកទីផ្សារព័ត៌មាន ការបង្កើតនិងបញ្ជូនបច្ចេកវិទ្យា និងការជម្រុញទំនាក់ទំនងអាជីវកម្ម និងកិច្ចការស្រដៀងគ្នានេះជាច្រើនទៀត។ សេវាអភិវឌ្ឍន៍ពាណិជ្ជកម្មត្រូវការទាំងយុទ្ធសាស្ត្រ ទាំងប្រតិបត្តិការ។ សេវាសម្រាប់ប្រតិបត្តិការ គឺសេវាដែលគេត្រូវការ និងត្រូវផ្តល់ឱ្យប្រចាំថ្ងៃ រីឯសេវាយុទ្ធសាស្ត្រវិញ គឺគេត្រូវការសម្រាប់ធ្វើផែនការ និងពង្រីកអាជីវកម្មក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ សេវាអភិវឌ្ឍន៍អាជីវកម្មនេះ អាចជាសេវាមួយៗដាច់ៗពីគ្នា ក៏ដូចជាសេវាជាក្រុម ដោយអាស្រ័យទៅតាមសេចក្តីត្រូវការនៃទីផ្សារ។

អ្នកដើរតួផ្សេងៗនៅក្នុងសេវាអភិវឌ្ឍន៍អាជីវកម្មនេះ គឺសហគ្រាសឯកជន (ជាអតិថិជន) អ្នកសម្របសម្រួល (អ្នកផ្តល់យោបល់ ទីប្រឹក្សាគោលនយោបាយ) អ្នកផ្តល់សេវា (អ្នកបញ្ជាក់ផលិតផល អ្នកផ្គត់ផ្គង់បច្ចេកវិទ្យា អ្នកដោះស្រាយបញ្ហា គ្រូបណ្តុះបណ្តាល) ព្រមទាំងម្ចាស់ជំនួយ រដ្ឋាភិបាល។ ទំនាក់ទំនងគ្នារវាងភ្នាក់ងារផ្សេងៗ គឺ :

អ្នកផ្តល់ជំនួយ រដ្ឋាភិបាល ⟶ អ្នកសម្របសម្រួលសេវាកម្មអភិវឌ្ឍន៍អាជីវកម្ម ⟶ អ្នកផ្តល់សេវា ⟶ អតិថិជន

អតិថិជនចង់បានសេវាកម្មតាមសេចក្តីត្រូវការរបស់គេ និងតាមតម្លៃរបស់សេវានោះ។ ក្រុមអ្នកផ្តល់សេវា ក៏ជាទីភ្នាក់ងារឯកជនធ្វើតាមតែសេចក្តីត្រូវការ ដើម្បីរកប្រាក់ចំណេញ រីឯអ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល ឬរដ្ឋាភិបាល គាំទ្រអ្នកសម្របសម្រួលនៅដំណាក់កាលចាប់ផ្តើមនៃការអភិវឌ្ឍ ប៉ុន្តែនៅទីបញ្ចប់ អ្នកសម្របសម្រួល ក៏ក្លាយជាអ្នកធ្វើតាមទីផ្សារដែរ។ ជួនកាល សូម្បីតែធនាគារខ្លះ ក៏ដើរតួនាទីជាអ្នកសម្របសម្រួលដែរ។ នៅក្នុងប្រទេសមួយចំនួន ធានាគារពិសេសៗ ដែលគេស្គាល់ថាជាធនាគារអភិវឌ្ឍន៍ ក៏បានដើរតួក្នុងការផ្តល់សេវាតាមរបៀបទាំងនេះដែរ។

រដ្ឋ ឬអ្នកផ្តល់ជំនួយនានា អាចផ្តល់សេវាដទៃមួយចំនួនទៀត ដែលជួយពង្រឹងវិស័យឯកជន ដរាបណាសេវាទាំងអស់នេះមិនមែនជាការផ្តល់ជំនួយដោយផ្ទាល់ ឬការឧបត្ថម្ភជាប្រាក់កាស។ ពួកគេអាចផ្តល់វគ្គបណ្តុះបណ្តាល (ក្នុងប្រទេស ឬក្រៅប្រទេស) សេវាគាំទ្រក្នុងការបង្កើតឧស្សាហកម្ម ឬទីប្រជុំឃ្លាំងផ្ទុកឧបករណ៍បច្ចេកវិជ្ជា ការស្ថាបនាសម្ភារៈសម្រាប់ប្រើប្រាស់រួមគ្នា (ឧ. ទូទឹកកកធំៗសម្រាប់អ្នកនេសាទតូចតាចរក្សាត្រីទុក) ជួយបង្កើតមណ្ឌលគូរប្លង់ ឬធ្វើគម្រោងផ្សេងៗ សម្រាប់អាជីវកម្មនានា (ដូចជា រោងសិប្បកម្មកាត់ដេរ ឬរោងចក្រផលិតស្បែកធន់តូច) ឬជួយរៀបចំសមាគមក្រុមអាជីវករ។

ចាំបាច់ត្រូវសិក្សាស្រាវជ្រាវអំពីសេចក្តីត្រូវការទីផ្សារ ប្រភពមូលនិធិ និងផ្នែកឯទៀតៗ ក្នុងសកម្មភាពសេវាអភិវឌ្ឍន៍អាជីវកម្ម។

*ប្រភព : ធនាគារពិភពលោក (២០០១) អង្គការពលកម្មអន្តរជាតិ (២០០១)*

## វិធីសាស្ត្រកែលម្អការអប់រំមាន :

ក. កែតម្រូវអតុល្យភាពរវាងការផ្គត់ផ្គង់ និងសេចក្តីត្រូវការតាមជំនាញផ្សេងៗ ដោយបញ្ចូលមុខវិជ្ជាបច្ចេកទេសឱ្យបានច្រើនទៅក្នុងកម្មវិធីសិក្សា : ក្នុងស្មារតីនេះ ត្រូវប៉ាន់ប្រមាណទៅលើសេចក្តីត្រូវការធនធានមនុស្សសម្រាប់ពីរបីឆ្នាំទៅមុខ ។ នៅប្រទេសជាច្រើន គេតែងតែធ្វើយ៉ាងនេះជាធម្មតា ហើយកិច្ចការនេះមិនពិបាកធ្វើទេ ។ អង្គការពលកម្មអន្តរជាតិ (ILO) មានឯកសារទាំងនេះស្រាប់ ។

ខ. បង្កើតកម្រិតស្តង់ដារគុណភាពអប្បបរមាសម្រាប់ការអប់រំ : ដើម្បីធ្វើយ៉ាងនេះបាន ត្រូវបង្កើតអង្គភាពមួយសម្រាប់ទទួលស្គាល់គុណភាពអប់រំ ។ អណត្តិនៃសកលវិទ្យាល័យ និងមហាវិទ្យាល័យទាំងអស់ដាច់ខាត ត្រូវទៅចុះបញ្ជីជាមួយអង្គភាពនេះ ដើម្បីកំណត់គុណភាពសញ្ញាប័ត្រឱ្យត្រឹមត្រូវតាមបទដ្ឋានដែលកំណត់ដោយអង្គភាពនេះ ។

គ. សេវាអប់រំត្រូវធ្វើឱ្យមានតុល្យភាពក្នុងតំបន់ : បច្ចុប្បន្ននេះ មហាវិទ្យាល័យនានានៅក្រៅក្រុងភ្នំពេញ បង្រៀនមុខវិជ្ជាផ្នែកវិទ្យាសាស្ត្រកសិកម្មជាចម្បង ។ ចាំបាច់ត្រូវតែដៅបញ្ជាក់ ដើម្បីសម្រេចបានតុល្យភាពរវាងតំបន់ក្នុងមុខវិជ្ជាផ្សេងៗគ្នានៅទីក្រុងដទៃទៀត ។

ឃ. ត្រូវធ្វើឱ្យការអប់រំកម្រិតឧត្តមសិក្សាធូរថ្លៃ : តម្លៃនៃការសិក្សាផ្នែកបច្ចេកទេសនៅទីណា ក៏ថ្លៃខ្ពស់ជាងថ្លៃសិក្សាផ្នែកមនុស្សសាស្ត្រ និងផ្នែកគ្រប់គ្រងដែរ ។ បើមិនមានកម្មវិធីជំនួយទូលំទូលាយសម្រាប់និស្សិតក្រីក្រទេ នោះគោលដៅនៃការបង្កបង្កើតជំនាញនៅតាមជនបទនឹងត្រូវបាត់បង់ ។ ទោះបីជាយ៉ាងណាក្តី គួរតែជួយផ្តល់ប្រាក់ឧបត្ថម្ភឱ្យបន្តការអប់រំទៅឧត្តមសិក្សាបាននៅប្រទេសណាដែលមានចំណូលទាប ប្រសិនបើនិស្សិតភាគច្រើនមិនមានប្រាក់គ្រប់គ្រាន់សម្រាប់សិក្សាបន្តទេនោះ ។

ការស្វះស្វែងបង្កើនធនធានមនុស្សមិនត្រូវភ្លេចគិតពីយេនឌ័រទេ ។ ស្ត្រីរួមចំណែកមួយផ្នែកធំនៅក្នុងការកែច្នៃត្រីធ្វើជាអាហារ ការលក់ដូរ សិប្បកម្ម និងនៅសិប្បកម្មកែច្នៃម្ហូបអាហារផ្សេងៗជាច្រើនទៀត ។ ដោយមានទំនើបកម្មនៃសកម្មភាពការងារ បុរសៗដែលមានការបណ្តុះបណ្តាលច្រើន មាននិន្នាការចាប់យកការងារជំនួសស្ត្រីក្នុងមុខការជំនាញនានា បោះបង់ស្ត្រីដែលធ្លាប់ធ្វើការងារកម្រិតទាបជាងទុកឱ្យនៅក្នុងការងារជាន់ទាបដដែល ។ ដូច្នេះចាំបាច់ត្រូវខំធ្វើយ៉ាងណា ធានាឱ្យស្ត្រីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅគ្រប់កម្រិតជានិច្ច[៨៣] ។

### *សេវាសុខាភិបាល*

ដីជាច្រើនកន្លែងត្រូវបានលក់ទាំងបង្ខំចិត្ត ដោយសារត្រូវការប្រាក់សម្រាប់ព្យាបាលសុខភាព ដែលជាសូចនាករបង្ហាញយ៉ាងច្បាស់ថា សេវាកម្មសុខភាពតាមជនបទ ត្រូវការពង្រីកឱ្យទូលំទូលាយ និងឱ្យស៊ីជម្រៅ ។ នៅក្នុងឯកសារ ការផ្តល់សេវាសុខភាពមើលទៅគួរឱ្យចាប់អារម្មណ៍ ។ រូបភាពទី ៥.២ បង្ហាញពីមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនៅក្នុងផ្ទៃប្រទេសទាំងមូល (ជាង ៩០០ មណ្ឌល) ។ បើគិតឱ្យសព្វគ្រប់ទៅ ចំនួននេះសមល្មមទៅនឹងដង់ស៊ីតេប្រជាពលរដ្ឋកម្ពុជាហើយ ។ ប៉ុន្តែទោះយ៉ាងនេះក្តី នៅមានចំណុចខ្វះខាតពីរចំណុចពោលគឺ :

ក. ប្រជាពលរដ្ឋច្រើនរស់នៅតាមកន្លែងដែលមានដីប្រកបរបរកសិកម្ម រីឯមណ្ឌលសុខភាព ឬមន្ទីរពេទ្យស្ថិតនៅតែជិតៗផ្លូវថ្នល់ ។ មណ្ឌលសុខភាពនៅឆ្ងាយពីភូមិតូចៗ ប្រហែលបីបួនគីឡូម៉ែត្រ ហើយដោយមិនសូវមានយានយន្តដឹកជញ្ជូន ការចូលទៅដឹកអ្នកជម្ងឺដល់ទីកន្លែងទាំងនោះប្រហែលជាលំបាក ។ បញ្ហាកាន់តែធ្ងន់ធ្ងរជាងនេះទៀត នៅប៉ែកខាងឦសាន ដែលមានប្រជាពលរដ្ឋតិច ហើយរស់នៅដាច់ស្រយាលពីគ្នា ។ ដូចគ្នានេះដែរ ការទទួលសេវាសុខភាពមានការពិបាកនៅតំបន់លិចទឹក ជាពិសេសនៅរដូវដែលតំបន់ទាំងនេះត្រូវទឹកលិច ។

ខ. ទំហំទាយជ្ជទានតាមមណ្ឌលនីមួយៗ ទាំងបុគ្គលិក ថ្នាំពេទ្យ ប្រដាប់រោគវិនិច្ឆ័យ មានចំនួនតិចជាងសេចក្តីត្រូវការជាក់ស្តែង ។ គ្មានសេវាសុខភាពដែលមិនបង់ប្រាក់ឡើយ លើកលែងតែជម្ងឺបន្តិចបន្តួច ឬការចាក់-ចែកថ្នាំ បង្ការរោគ (ឧ. រោគរបេង..) ។

---

*(៨៣) អង្គការពលកម្មអន្តរជាតិ (២០០៦) ។*

*ពលរដ្ឋទៅរស់នៅតាមកន្លែងមានដីប្រកបរបរកសិកម្ម រីឯមណ្ឌលសុខភាព ឬមន្ទីរពេទ្យស្ថិតនៅតែជិតៗផ្លូវថ្នល់*

***រូបភាពទី ៩.២ : ទីតាំងមន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅកម្ពុជា***



*ប្រភព :* http://www.nis.gov.kh

## ជម្រើសផ្សេងៗ ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការរក្សាសុខភាព

ក. បើយើងគិតថា បុគ្គលិកពេទ្យ ដែលបានរៀនសូត្រខ្ពង់ខ្ពស់ ហើយប្រហែលជាបានចំណាយប្រាក់ច្រើនសម្រាប់រៀនមុខវិជ្ជាពេទ្យនៅសាកលវិទ្យាល័យ ព្រមទៅធ្វើការនៅកន្លែងដាច់ស្រយាល ដែលមានកម្រៃទាប និងដែលមិនសូវមានអ្នកណាចង់បាននោះ គឺជាការច្រឡំធំហើយ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតឱ្យមានអាហាររូបករណ៍នៅតាមសាលាពេទ្យនានាដោយឧបត្ថម្ភទាំងស្រុងឱ្យសិស្សណាដែលរៀនពូកែ។ ពេលនោះជាផ្នែកមួយនៃកិច្ចសន្យាអាហាររូបករណ៍ គឺនិស្សិតបានដែលបញ្ចប់ការសិក្សា ត្រូវទៅបម្រើការនៅមន្ទីរពេទ្យជនបទ តាមពេលកម្រិតអប្បបរមាមួយ ឧទាហរណ៍ ៥ ឆ្នាំ។

ខ. គួរផ្ដល់ការបណ្ដុះបណ្ដាលបន្ថែមដល់ក្រុមពេទ្យជំនួយបច្ចុប្បន្ន ដែលបម្រើការនៅមណ្ឌលសុខភាពជនបទ សម្រាប់ឱ្យពួកគេធ្វើការក្នុងផ្នែក "បង្ការោគ" (ដូចជា ព័ត៌មានអំពីជម្ងឺឆ្លង ការបង្ការជម្ងឺសាមញ្ញ អនាម័យ និងការយល់ដឹងជម្ងឺអេដស៍ជាដើម) និងរោគវិភាគធម្មតា។ ពួកគេក៏អាចចែក ឬចាក់ថ្នាំបានដែរ សម្រាប់ជម្ងឺគ្រុនចាញ់ ជម្ងឺក្រពះ ឬជម្ងឺខ្វះទឹកក្នុងរាងកាយ ហើយពួកគេទាំងអស់នេះ គួរទៅធ្វើការតាមភូមិនានា។

### ប្រអប់ ៥.៥ : ទឹកបរិភោគ - បញ្ហា និងដំណោះស្រាយ

នៅគ្រប់កន្លែងតាមស្រុកស្រែ គេបរិភោគទឹកឆៅទាំងអស់គ្នា។ នេះមិនមែនមានន័យថា ប្រជាពលរដ្ឋមិនបានយល់អំពីគុណតម្លៃនៃការចម្អិន ឬច្រោះទឹកនោះទេ។ ផ្អែកតាមការស្ទង់មតិពួកគេភាគច្រើននិយាយថា នៅក្នុងរដូវវស្សាពេលដែលទឹកបឹង និងទឹកស្ទឹងឡើងល្អក់ គេប្រើចម្រោះ ដើម្បីច្រោះយកកករភក់ចេញ ឬក៏ដាំទឹក។ ពេលដែលសួរថា ហេតុអ្វីក៏មិនធ្វើតាមរបៀបហ្នឹងរហូតពេញមួយឆ្នាំទៅ គេឆ្លើយថា មិនចាំបាច់ទេ ព្រោះអីគេរស់នៅតាំងពីដើមមកដោយសារទឹកយ៉ាងនេះ តើចាំបាច់ធ្វើអ្វីទៀត ? ការយល់ដឹងអំពីអ្វីទៅដែលហៅថា "ទឹកស្អាត" គឺជាកត្តាសំខាន់ : ព្រោះបច្ចុប្បន្ននេះ ពួកគេគ្រាន់តែដឹងថា ទឹកល្អក់កករ តែពួកគេមិនដឹងថាមានមេរោគនៅក្នុងទឹកនោះទេ។ លើសពីនេះទៀត មានការយល់ដឹងតិចតួចណាស់ថា ដោយសារតែបរិភោគទឹកដែលមានមេរោគ ពួកគេកើតរោគផ្សេងៗ ឬធំលូតលាស់មិនបានល្អ។ ពិតណាស់ហើយថា ការមិនដាំទឹកបរិភោគមិនមែន ដោយសារអស់លុយច្រើនទេ ពីព្រោះគេអាចរកឱសដោយខ្លួនឯងបាន ឬក៏អាចទិញអុសបានពី ១ ទៅ ២ គ.ក្រ តម្លៃតែ ១០០ រៀល ដុតដាំទឹកសម្រាប់មួយគ្រួសារក្នុងមួយថ្ងៃ។

ដើម្បីសម្អាតទឹក មានដំណោះស្រាយជាច្រើនតាមបច្ចេកវិទ្យាដែលមានតម្លៃទាប ឬមិនចាំបាច់ចំណាយអ្វីទាល់តែសោះ។ ជាឧទាហរណ៍ ដាក់ទឹកក្នុងដបទឹកក្រូចកូកាកូឡាធម្មតា ដែលជាដបពណ៌ស ហើយដាក់ហាលថ្ងៃឱ្យត្រូវពន្លឺព្រះអាទិត្យ ២៤ ម៉ោង (ឬ ៤៨ ម៉ោងនៅថ្ងៃណាដែលមានមេឃស្រទុំ) នោះចំហាយវិទ្យុសកម្មពន្លឺព្រះអាទិត្យនឹងធ្វើឱ្យទឹកស្អាត ហើយកម្មរស្មីអ៊ុលត្រាវីយ៉ូលេនឹងសម្លាប់រាល់អតិសុខុមប្រាណ ដែលបង្កឱ្យគ្រោះថ្នាក់។ វិធានការណ៍ដទៃទៀត ដូចជាការប្រើសាច់ជូរក្លូរក្នុងទឹក ឬប៉ូតាស្យូម ពែម៉ង់កាណាត ដែលមានលក់ថោកៗនៅឱសថស្ថាន។

បុគ្គលិកបម្រើការផ្នែកសង្គមកិច្ច អាចបំពេញការងារនៅតាមសហគមន៍បាន ឬក៏រកអ្នកស្ម័គ្រចិត្តនៅតាមមូលដ្ឋានយកមកបណ្តុះបណ្តាល ដើម្បីឱ្យពួកគាត់បំពេញកិច្ចការ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងវិស័យអប់រំ និងពង្រីកការយល់ដឹងនិងចំណេះដឹងពីសុខភាព។

*ប្រភព : ទស្សនកិច្ចក្នុងខេត្តកំពង់ឆ្នាំង ខែកញ្ញា ដល់ ខែធ្នូ ឆ្នាំ ២០០៦ http://www.sodis.ch*

គ. ថ្នាំពេទ្យនៅកម្ពុជាពុំសូវសម្បូណ៌ ហើយថ្លៃទៀត។ ជម្រើសមួយ គឺទិញថ្នាំពេទ្យពីប្រទេសណាដែលជាប្រភពដើមផលិតថ្នាំពេទ្យទូទៅច្រើន ដែលមានតម្លៃបី-បួនដង ថោកជាងថ្នាំពេទ្យដែលមានម៉ាកយីហោស្រាប់។ ដំណោះស្រាយបន្តទៀត គឺត្រូវបំផុសឱ្យបង្កើតឧស្សាហកម្មផលិតឱសថក្នុងស្រុក ដោយមានកំណត់ស្តង់ដារគុណភាពថ្នាំត្រឹមត្រូវ។

ឃ. ថ្លៃបង់តាមមណ្ឌលសុខភាពអាចគិតតម្លៃតិចតួចបានហើយ ទុកឱ្យអ្នកជម្ងឺទទួលបន្ទុកពេញទីតែលើសោហ៊ុយធ្វើដំណើរចុះ។

ដូចមានពណ៌នានៅជំពូកទី ២ ទឹកស្អាតសម្រាប់បរិភោគ គឺជាអាទិភាពចម្បង ប៉ុន្តែនៅមិនទាន់មានការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ។ ដោយប្រកាន់ខ្ជាប់នូវសារៈសំខាន់នេះ សូមលើកយកបញ្ហាទឹកស្អាតមកនិយាយម្តងទៀត (នៅក្នុងប្រអប់ទី ៥.៥)។

### *សារគន្លឹះ :*

*ការវិនិយោគ និងការថ្នៃប្រឌិតឱ្យប្រសើរឡើងក្នុងវិស័យអប់រំត្រូវស្ថិតក្នុងអាទិភាពខ្ពស់ ដើម្បីឱ្យពលរដ្ឋអាចធ្វើការងារបានកម្រៃខ្ពស់។ ដូចគ្នានេះដែរ ផ្នែកសុខាភិបាលត្រូវតែចូលឱ្យបានជ្រៅទៅតាមស្រុកស្រែ ហើយគួរឱ្យមានតម្លៃថោក។ ការអប់រំល្អ និងសុខាភិបាលល្អ អាចជួយពង្រឹងឫសគល់នៃលទ្ធិប្រជាធិបតេយ្យ។*

*និយាយពីភាពក្រីក្រ និងការអភិវឌ្ឍមនុស្ស ប្រជាជនជាតិដើមក្រជាងគេ ។ ធ្ងន់ធ្ងរជាងនេះទៅទៀត ពួកអ្នកកាន់កាប់ព្រៃដីសម្បទាន បានរារាំងជនជាតិដើមជាច្រើនមិនឱ្យប្រើប្រាស់ទឹកដីដែលពួកគេធ្លាប់កាន់កាប់រស់នៅជាច្រើនសតវត្សរ៍មកហើយ*

## ៥.៤ ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិច ជាពិសេសនៅភាគឦសាន មានរបៀបរស់នៅ និងលំនៅស្ថានប្លែកពីគេ បើប្រៀបធៀបទៅនឹងដំណើរជីវិតរបស់ជនជាតិខ្មែរដែលទៅនៅទីនោះ ។ ពួកគេធ្វើកសិកម្មពនេចរ (ធ្វើស្រែចំការដោយផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ) ផលិតអ្វីៗពីព្រៃឈើ ពឹងពាក់អាស្រ័យលើព្រៃឈើ មានភាសាខុសៗគ្នា រស់នៅជាភូមិតូចៗ ដាច់ៗពីគ្នា និងធ្វើអ្វីៗទៀតខុសពីគេ ។ ចំណែកឯភាពក្រីក្រ និងការអភិវឌ្ឍមនុស្សវិញ ភាគឦសានស្ថិតនៅលំដាប់ថ្នាក់ទាបជាងគេ ហើយជនជាតិដើមភាគតិចនៅទីនោះក៏ក្រជាងគេដែរ ។ ធ្ងន់ធ្ងរជាងនេះទៅទៀត ពួកអ្នកកាន់កាប់ព្រៃ ដីសម្បទាន បានរារាំងជនជាតិដើមភាគតិចជាច្រើន មិនឱ្យប្រើប្រាស់ទឹកដី ដែលពួកគេធ្លាប់កាន់កាប់រស់នៅជាច្រើនសតវត្សរ៍មកហើយ ។ ភស្តុតាងបង្ហាញឱ្យឃើញថា ពួកគេកំពុងប្រឈមនឹងការបាត់បង់ដីធ្លី ដោយសារតែអ្នកខាងក្រៅចូលទៅប្រមូលទិញដីអស់ជាច្រើននៅតាមបណ្តាខេត្តទាំងនោះ ។ ពេលខ្លះមានផ្ទុះការប្រយុទ្ធតតាំងគ្នារវាងអ្នកមកតាំងលំនៅថ្មី និងសហគមន៍ជនជាតិដើមភាគតិច ជាពិសេស គឺជម្លោះដីធ្លី[៨៤] ។ ជម្លោះកាន់តែបង្ហាញឱ្យឃើញច្បាស់ឡើង នៅពេលដែលក្រុមហ៊ុនពាណិជ្ជកម្មផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលទាក់ទាញឱ្យមានការទិញដីសម្រាប់លក់យកចំណេញ ។ ជនជាតិដើមភាគតិច ដែលមិនបានចូលរួមគ្រប់គ្រាន់ទៅក្នុងប្រព័ន្ធទីផ្សារ គឺជាអ្នកចាញ់ទាំងស្រុង ។ ដោយសារព្រៃឈើថយចុះ និងប្រជាពលរដ្ឋកើនឡើង ជម្លោះរឹតតែខ្លាំងទៅៗ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះត្រូវមានវិធានការណ៍ ដូចតទៅនេះ :

ក. ជម្រុញឱ្យប្រតិបត្តិតាមផ្លូវច្បាប់ និងតាមស្មារតី នូវបញ្ញត្តិនានាស្តីអំពីដីធ្លីជនជាតិដើមភាគតិចនៅក្នុងច្បាប់ព្រៃឈើ និងច្បាប់ភូមិបាល ។ បន្ថែមលើនេះទៀត គួរផ្តើមចេញប្លង់ដីឱ្យសហគមន៍ និងរាល់ការកាប់ដើមឈើ ព្រមទាំងការធ្វើសម្បទានផ្សេងៗលើដីរបស់ជនជាតិដើមភាគតិច ត្រូវបញ្ឈប់ (ជំពូក ៣) ។

ខ. បង្កើតច្បាប់ហាមលក់ដូរ ឬដកហូតដីជនជាតិដើមភាគតិចក្នុងរយៈពេលកំណត់ណាមួយ អាចការពារពួកគេពីការលក់ដូរភ្លាមៗ និងឥទ្ធិពលអាក្រក់ពីខាងក្រៅ ។

គ. ការផ្តួចផ្តើមបង្កើតសហគមន៍ព្រៃឈើ គួរទុកជាអាទិភាពនៅតាមបណ្តាខេត្តនានា ដែលមានជនជាតិដើមភាគតិចរស់នៅ ។

ឃ. នៅក្នុងកញ្ចប់នៃគោលនយោបាយ គួរដាក់បញ្ចូលនូវការប្រឹងប្រែងពិសេសនានា ដើម្បីពង្រីកវិស័យអប់រំ សុខាភិបាល និងទឹកស្អាតសម្រាប់បរិភោគ ដោយមានបន្ថែមជំនាញផ្សេងៗ ព្រមទាំងព័ត៌មានអំពីផលិតផល និងទីផ្សារផង ។

***សារគន្លឹះ :***

*សិទ្ធិរបស់ជនជាតិដើមភាគតិចដែលមានការទទួលស្គាល់ដោយច្បាប់ និងដោយរដ្ឋធម្មនុញ្ញ ត្រូវតែមានការគោរព ព្រមទាំងមានវិធានការណ៍វិជ្ជមានការពារផលប្រយោជន៍ពួកគេ ។*

## ៥.៥ ការតាមដាន និងការវាយតម្លៃ

ប្រព័ន្ធតាមដាននិងវាយតម្លៃ ដែលដាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់តាមដានពិនិត្យមើលគោលដៅផ្សេងៗរបស់វាផ្អែកលើការបន្តតាមមើល ធាតុចូល/សកម្មភាព និងលទ្ធផល/ផលប្រយោជន៍ ។ ការងារនេះត្រូវធ្វើឡើងដោយក្រសួងពាក់ពន្ធ័នានា និងទម្រង់រដ្ឋបាលរបស់គេ ក្រោមកិច្ចសម្របសម្រួលរបស់វិទ្យាស្ថានជាតិស្ថិតិ ។ កិច្ចការនេះត្រូវបំពេញបន្ថែមដោយប្រព័ន្ធទិន្នន័យមួយដែលងាយយល់យកប្រជាពលរដ្ឋជាស្នូល និងមានតម្លាភាព ដែលមានការត្រួតពិនិត្យយ៉ាងទូលំទូលាយពីអ្នកប្រើប្រាស់តាមសហគមន៍ ។ ការនេះត្រូវតែមានការចូលរួមពីសំណាក់សវនកម្មសង្គមផងដែរ ។

***កម្មវិធីអភិវឌ្ឍន៍***

ទិន្នន័យស្តីពីអថេរសំខាន់ៗ ដូចជាមូលនិធិសម្រាប់កម្មវិធី និងសមិទ្ធផលរបស់កម្មវិធី ត្រូវចងក្រងសម្រាប់ភូមិ-ឃុំនីមួយៗ ។ ធ្វើយ៉ាងនេះ គឺដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅភូមិ-ឃុំវិញ អំពីការអនុវត្តការងារ ឬអំពីចំណុចខ្វះខាតរបស់ពួកគេ ហើយជូនដំណឹងដល់ភ្នាក់ងារអនុវត្តន៍ផែនការនានា ។ ទិន្នន័យដែលប្រមូលបានក្រោមកម្មវិធីក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាគំរូមួយសម្រាប់ធ្វើតាម ទោះបីជាសំណុំទិន្នន័យនោះត្រូវយកមកកែសម្រួល ដើម្បីផ្តោតឱ្យត្រូវទៅនឹងកម្មវិធីដោយផ្ទាល់តែម្តងក៏ដោយ ។ ផ្នែកខ្លះនៃទិន្នន័យអាចរៀបចំឡើងដោយអ្នកប្រើប្រាស់ខ្លួនឯងផ្ទាល់ដោយរួមគ្នាជាមួយនឹងភាគីឯករាជ្យនានា : ក្រុមនីមួយៗនៃពួកអ្នកប្រើទិន្នន័យ ឬអ្នកទទួលផលពីកម្មវិធីនេះ ត្រូវផ្តល់ការវាយតម្លៃរបស់ខ្លួនឱ្យបានទៀងទាត់ ហើយបន្ទាប់មក ទិន្នន័យនេះត្រូវប្រមូលផ្តុំនៅថ្នាក់ ភូមិ-ឃុំ ។

---

*(៨៤) សូមអាន Bottomley (២០០២) ។*

### *ដីធ្លី*

ទិន្នន័យនៃការកត់ត្រាដីធ្លីត្រូវបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ហើយចែកចាយឱ្យបានដល់ថ្នាក់មូលដ្ឋាន។ ការសំខាន់មួយទៀត គឺត្រូវកំណត់ឱ្យច្បាស់ ហើយផ្សព្វផ្សាយជាសាធារណៈ អំពីស្ថានភាពនៃការប្រើប្រាស់ដីធ្លី ដែលមិនមែនជាដីកម្មសិទ្ធិឯកជន ឧទាហរណ៍ ដីសាធារណៈដែលលិចទឹកខ្លះ ឬដីសម្បូរណ៍ព្រៃ ឬដីគ្មានដំណាំទុកសម្រាប់ស្មៅគោក្របី ឬសម្រាប់នេសាទត្រី ឬសម្រាប់អ្វីផ្សេងទៀតនៅក្នុងភូមិ។ ប្រសិនបើគេដឹងពីស្ថានភាពនៃការប្រើប្រាស់ដី នោះការប្រើប្រាស់ដីទាំងនោះនៅតាមមូលដ្ឋាន អាចមានការតាមដានត្រឹមត្រូវជាង ហើយអាចនឹងចៀសវាងជម្លោះបាន។

### *ស្ថិតិពាក់ព័ន្ធនឹងសុខុមាលភាពគ្រួសារ និងការផ្លាស់ប្តូរទីលំនៅ*

នៅថ្នាក់ឃុំ ត្រូវការឱ្យមានទិន្នន័យតាមប្រព័ន្ធលើអត្រាកើត ស្លាប់ រៀបការ មានផ្ទៃពោះ និងការផ្លាស់ប្តូរទីលំនៅតាមរដូវកាល ឬតាមរបៀបផ្សេងៗ។ ទិន្នន័យរបៀបនេះ ដែលមានសារប្រយោជន៍ដើម្បីតាមដានមើលការប្រែប្រួលប្រជាសាស្ត្រ ស្ថានភាពស្ត្រី ស្ថានភាពនៃសុខភាពគ្រួសារ និងការធ្វើផែនការគ្រួសារ អាចបង្កើតឡើងបានតាមប្រព័ន្ធរដ្ឋបាលសម្រាប់ពិនិត្យតាមដាន។

### *ការរក្សាស្ថិតិសំខាន់ៗនៅថ្នាក់មូលដ្ឋាន*

នៅថ្នាក់ភូមិ-ឃុំ ដំណើរការអនុវត្តកិច្ចការផ្សេងៗត្រូវតែមានតម្លាភាពជូនសាធារណជន។ ផ្ទាំងព័ត៌មានធំៗ ត្រូវបានរៀបចំបិទផ្សាយនៅពីក្រៅការិយាល័យភូមិ-ឃុំ ដោយរៀបរាប់ពិស្តារអំពីផ្នែកនៃការងារប្រជាពលរដ្ឋ អនុបាតភេទ រចនាសម្ព័ន្ធអាជីវកម្ម ផលិតភាពនៃដីធ្លី ប្រព័ន្ធធារាសាស្ត្រ ការអប់រំ និងអក្ខរកម្ម ការផ្លាស់ប្តូរ ទីលំនៅចេញ/ចូល ព័ត៌មានលម្អិតអំពីដីធ្លី សិស្សឈប់រៀននិងចូលរៀន សេចក្តីត្រូវការជាមូលដ្ឋាន ដូចជា ការផ្គត់ផ្គង់ទឹក ការផ្តល់ការរៀនសូត្រ មណ្ឌល/មន្ទីរសុខភាព និងស្ថានភាពនៃកម្មវិធីអភិវឌ្ឍន៍ (ឧ.: ការដាក់គោលដៅ និងការសម្រេចតាមគោលដៅ)។ ដូចអាចធ្វើទៅបាន ស្ថិតិត្រូវរៀបចំបង្ហាញតាមភេទដោយឡែកពីគ្នា។ ទិន្នន័យត្រូវពិនិត្យមើលសារឡើងវិញឱ្យបានទៀងទាត់ ឧ. ប្រាំមួយខែម្តង។ ការបិទផ្សាយរបៀបនេះ ជួយរំលឹកឱ្យដឹងជាប្រចាំនូវរាល់ការងារដែលបាន និងកំពុងអនុវត្ត និងសមិទ្ធកម្មនានា ឬរំលឹកឱ្យដឹងអ្វីៗដែលខ្វះខាត។

សវនកម្មពីសំណាក់សង្គមលើកម្មវិធីអភិវឌ្ឍន៍ ត្រូវតែធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីពង្រឹងសេចក្តីទុកចិត្តក្នុងចំណោមប្រជាពលរដ្ឋតូចតាច អំពីសេចក្តីស្មោះត្រង់របស់ភ្នាក់ងារអនុវត្ត។

### *សារគន្លឹះ :*

*ប្រព័ន្ធដ៏រឹងមាំមួយសម្រាប់វាយតម្លៃ និងតាមដានប្រកបដោយការចូលរួម ដោយមានទិន្នន័យតាមកន្លែងសាធារណៈ នឹងជួយឱ្យការអនុវត្តកម្មវិធីអភិវឌ្ឍន៍បានប្រសើរឡើង ហើយធានាឱ្យផលប្រយោជន៍ធ្លាក់ដល់ប្រជាពលរដ្ឋ។ ផលប្រយោជន៍ទាំងនេះនឹងបង្កើតបានជាមូលដ្ឋាននៃការទុកចិត្តទៅលើប្រព័ន្ធ។*

## ៥.៦ សេចក្តីសរុប

ការលើកកម្ពស់ជីវភាពរស់នៅតាមជនបទជាពិសេស និងលើកកម្ពស់ការអភិវឌ្ឍធនធាន (សតិបញ្ញា) មនុស្សជាទូទៅ ដែលទាមទារឱ្យមានដំណោះស្រាយច្រើនផ្នែក ដូចជា ផ្នែកសេដ្ឋកិច្ច សង្គម និងស្ថាប័ន។

*ការលើកកម្ពស់ជីវភាពរស់នៅតាមជនបទ ជាពិសេស និងលើកកម្ពស់ការអភិវឌ្ឍធនធាន (សតិបញ្ញា) មនុស្សជាទូទៅ ទាមទារឱ្យមានដំណោះស្រាយច្រើនផ្នែក ដូចជា ផ្នែកសេដ្ឋកិច្ច បែបសង្គម និងបែបស្ថាប័ន*

- ❖ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ត្រូវមានប្រព័ន្ធអគ្គិសនីតាមជនបទ ផ្លូវដឹកជញ្ជូនតាមរថភ្លើង និងការអភិវឌ្ឍមណ្ឌលឧស្សាហកម្ម និងទីប្រជុំជនបែបវិមជ្ឈការ។ ចំណុចចម្បងដែលគួរពិចារណាក្នុងជម្រើសនេះ គឺការបង្កើតឱ្យមានគុណតម្លៃ និងប្រាក់ចំណូលអតិបរមាក្នុងលក្ខណៈមួយ ដែលមានតុល្យភាពតាមភូមិសាស្ត្រឱ្យបានច្រើនបំផុតក្នុងមូលដ្ឋានមួយប្រកបដោយចីរភាព។ ដោយសារមានបណ្តាញផ្លូវរថភ្លើងស្រាប់ ហើយការស្តារឡើងវិញប្រហែលជាមិនពិបាកពេកទេ។
- ❖ កម្មវិធីការងារសាធារណៈដែលត្រូវការពលកម្មច្រើន ដែលមានគោលបំណងពីរយ៉ាង គឺបង្កើតឱ្យមានការងារតាមរដូវ និងសាងសង់សមិទ្ធផល អាចជួយបន្ធូរបន្ថយការអត់ការងារធ្វើតាមរដូវ និងដោះស្រាយបញ្ហាភាពក្រីក្រ។ កម្មវិធីរបៀបនេះ អាចជួយកសាងសមត្ថភាពមនុស្ស។

*ការបង្កបង្កើតធនធាន (សតិបញ្ញា) មនុស្សត្រូវដាក់បញ្ចូលក្នុងមុខវិជ្ជាបង្រៀនផ្សេងៗ ដែលអាចជួយធ្វើឱ្យវិស័យកសិកម្មទំនើបឡើង និងកែច្នៃវត្ថុធាតុដើមចេញពីផលកសិកម្មឱ្យមានគុណតម្លៃជាម្ហូបអាហារ និងដែលបង្កើតឱ្យមានជម្រើសមុខរបរ និងការងារដែលអាចរកបានកម្រៃច្រើន*

- ការកសាងធនធានមនុស្ស (ការអប់រំកម្រិតបឋមសិក្សា អប់រំវិជ្ជាជីវៈ ឧត្តមសិក្សា ការចែករំលែក ចំណេះដឹងអាជីវកម្ម) ត្រូវដាក់បញ្ចូលក្នុងមុខវិជ្ជាបង្រៀនផ្សេងៗ ដែលអាចជួយធ្វើឱ្យវិស័យកសិកម្មទំនើបឡើង និងកែច្នៃវត្ថុធាតុដើមចេញពីផលកសិកម្មឱ្យមានគុណតម្លៃជាម្ហូបអាហារ និងដែលបង្កើតឱ្យមានជម្រើសមុខរបរ និងការងារដែលអាចរកបានកម្រៃច្រើន។ អាទិភាពឯទៀតៗរួមមាន ការពង្រឹងសេវាសុខភាពជាមូលដ្ឋាន (រួមទាំងការអប់រំវិជ្ជាពេទ្យផង) ការធ្វើឱ្យសេវាសុខភាព និងថ្នាំពេទ្យថោកថ្លៃ ព្រមទាំងការឧបត្ថម្ភទឹកស្អាតសម្រាប់បរិភោគ។
- អភិបាលកិច្ចល្អ ត្រូវតែមានជាដាច់ខាត។ ប្រព័ន្ធតាមដាន និងវាយតម្លៃពិស្តារមួយ ដែលប្រជាពលរដ្ឋស្រួលប្រើ ដោយរួមទាំងប្រព័ន្ធតាមដានមើលខាងផ្នែករដ្ឋបាល គួរតែដាក់បញ្ចូលក្នុងកម្មវិធីអភិវឌ្ឍន៍ និងស្ថានភាពនៃការអភិវឌ្ឍមនុស្ស ក៏ដូចជាការអភិវឌ្ឍរាងកាយឱ្យមាំមួនផងដែរ។
- គោលនយោបាយ ត្រូវតែបញ្ជាក់ច្បាស់លាស់ពីសកម្មភាពវិជ្ជមានសម្រាប់លើកស្ទួយសិទ្ធិជនជាតិដើមភាគតិច និងធ្វើសមាហរណកម្មពួកគេទៅក្នុងឥទ្ធិពលសង្គមជាតិទូទៅ។

***រូបភាពទី ៥.៣ : សង្ខេបគម្រោងការខ្នាតធំ***



*ប្រភព : អត្ថបទនៅក្នុងជំពូកនេះ*

# ជំពូក ៦



៦

ជំពូក



# ការប្រើប្រាស់ធនធានប្រេងដើម្បីការអភិវឌ្ឍមនុស្ស

នៅឆ្នាំ ២០០៤ កម្ពុជាបានរកឃើញរ៉ែប្រេងកាត និងឧស្ម័នជាច្រើន ដែលនឹងអាចជាលទ្ធភាពសម្រាប់រកប្រាក់ចំណូលថ្មីនៅដើមឆ្នាំ ២០១០។ នេះគឺជាឱកាសតែមួយគត់ ដើម្បីធានាកំណើនរយៈពេលវែងរបស់ប្រទេសឱ្យចម្រើនឧត្តុង្គឧត្តមដល់សុខុមាលភាពមនុស្សទូទាំងកម្ពុជា និងពង្រឹងស្ថិរភាពដែលរកបានយ៉ាងលំបាក។

ឱកាសដ៏ល្អនេះមិនមានអ្វីដូចទេ ព្រោះរ៉ែប្រេងនិងឧស្ម័ននេះនៅក្នុងសមុទ្រ ដែលមិនមានម្ចាស់កម្មសិទ្ធិឯកជន ឬក្រុមហ៊ុនណាមួយអះអាងថាជាម្ចាស់ដីនេះបានឡើយ។ ដោយសារវាជាធនធានធម្មជាតិនៅក្នុងសមុទ្រកម្ពុជា ដូច្នេះវាជាសម្បត្តិរបស់ប្រជាជនកម្ពុជាទាំងអស់គ្នា។

នៅមិនទាន់អាចបញ្ជាក់បានទេថា អណ្តូងប្រេងនេះមានតម្លៃពាណិជ្ជកម្មធំប៉ុនណានោះ ប៉ុន្តែតាមភស្តុតាងបឋម គឺគួរឱ្យមានសង្ឃឹមច្រើនថ្វីត្បិតតែគេកំពុងតែប៉ាន់ប្រមាណ។ ការប៉ាន់តម្លៃផ្សេងៗនឹងចប់សព្វគ្រប់នៅចុងឆ្នាំ ២០០៧ នេះ។ ដោយប្រេងនៅក្នុងពិភពលោកមានតម្លៃ ៦០ ដុល្លារអាមេរិកក្នុងមួយធុង អណ្តូងរ៉ែនេះអាចផ្តល់ប្រាក់ចំណូលជាច្រើនទៅក្នុងថវិការដ្ឋាភិបាល។

ជំពូកនេះពិនិត្យមើលលើ (១) ប្រាក់ចំណូលពីប្រេងនិងពីឧស្ម័នដែលអាចក្លាយជា "ពរជ័យ" សម្រាប់ប្រទេសកម្ពុជាមិនមែនជា "បណ្តាសា" ហើយស្របជាមួយនោះដែរ គឺពិនិត្យមើលលើ (២) វិធីសម្គាល់សញ្ញានៃភាពអាសន្ន ដោយយោងតាមបទពិសោធន៍សកល។ ការធានាថា (៣) លក្ខណៈទូទៅនៃពរជ័យ ដោយឈរលើមូលដ្ឋាននៃបទពិសោធន៍សកលនោះ (៤) នឹងត្រូវនាំយកមកក្នុងប្រទេសទុកជាមូលដ្ឋានសម្រាប់លើកគោលនយោបាយកិច្ចការក្នុងវិស័យច្បាប់ វិស័យស្ថាប័ន និងវិស័យថវិកា គឺជាការសំខាន់។ ជាចុងក្រោយ (៥) ការចាត់ចែងចំណាយ ដោយប្រសិទ្ធភាពនឹងជួយវិនិយោគទៅក្នុងការរួមចំណែកធ្វើឱ្យចម្រើនរុងរឿង និងនិរន្តរភាពយូរអង្វែងដែលលេចចេញពីអណ្តូងប្រេង និងឧស្ម័ននេះ។

## ៦.១ ពរជ័យ ឬបណ្តាសា ?

ខណៈដែលប្រាក់ចំណូលពីប្រេង និងឧស្ម័នដែលគេរំពឹងទុកនោះ អាចជាឱកាសដ៏ធំជាងគេបំផុតមួយសម្រាប់កម្ពុជា របាយការណ៍ស្រាវជ្រាវលើវិស័យសង្គម-សេដ្ឋកិច្ច ដែលធ្វើឡើងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និងអាជ្ញាធរជាតិប្រេងកាតកម្ពុជា (CNPA) ក្នុងអំឡុងឆ្នាំ ២០០៥-២០០៦ ឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានផ្តល់ជាយោបល់យ៉ាងមុតមាំថា ប្រាក់ចំណូលនេះអាចជាការគំរាមកំហែងដ៏ធំបំផុតមួយទៅលើសុខុមាលភាព និងស្ថិរភាពយូរអង្វែងរបស់ប្រទេសផងដែរ[៨៥]។

ការសន្និដ្ឋានទាំងនេះ មានទីសម្អាងយ៉ាងរឹងមាំនៅលើបទពិសោធន៍ជាង ៤០ ឆ្នាំ កន្លងមក របស់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនដែលមានចំណូលតិច។ ប្រទេសកំពុងអភិវឌ្ឍន៍ដែលសម្បូណ៌ប្រេង ឧស្ម័ន និងរ៉ែ ច្រើនតែទទួលផលប៉ះពាល់អវិជ្ជមានពីចំណូលដ៏ស្តុកស្តម្ភដែលពាក់ព័ន្ធទៅនឹងប្រេង-ឧស្ម័ន និងរ៉ែទាំងនោះ ហើយមានប្រទេសខ្លះ មានអស្ថិរភាពទៀតផង[៨៦]។

ជាទូទៅ របាយការណ៍ស្រាវជ្រាវបង្ហាញថាអត្រាកំណើនសម្រាប់រយៈពេលយូររបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលសម្បូណ៌ប្រេងនិងរ៉ែ មានកម្រិត ៣០ ទៅ ៥០ ភាគរយ ទាបជាងអត្រាកំណើននៃប្រទេសកំពុងអភិវឌ្ឍន៍ដែលក្រប្រេង និងរ៉ែ។ លើសពីនេះទៀតប្រទេសដែលសម្បូណ៌រ៉ែជាច្រើនទទន់ខ្សោយជាងប្រទេសកំពុងអភិវឌ្ឍន៍ ដែលក្ររ៉ែក្នុងការបំពេញភារកិច្ចលើវិស័យផ្សេងៗមួយចំនួនដូចមានសូចនាករសេដ្ឋកិច្ច សង្គម និងនយោបាយ[៨៧]។

---

*(៨៥) សូមមើល ឧ. ការវិភាគ "A SWOT Analysis មួយលើសេដ្ឋកិច្ចកម្ពុជា" ដោយអ្នកស្រាវជ្រាវពីសាកលវិទ្យាល័យ Harvard ក្នុងកិច្ចសហការជាមួយ CNPA, SNEC និង UNDP និង "ការចៀសវាងបណ្តាសាធនធាន" មេរៀនពីបទពិសោធន៍អន្តរជាតិ ដោយ ODI ក្នុងកិច្ចសហការជាមួយ SNEC និង UNDP។*

*(៨៦) ក្នុងស្មារតីនេះពាក្យ "បណ្តាសាធនធាន" មានន័យថា "ព្រឹត្តការណ៍មួយរបស់ប្រទេសដែលផ្អែកទៅលើការនាំចេញធនធានធម្មជាតិ ហើយរកបានប្រាក់ចំណូលទូលំទូលាយជូនរដ្ឋាភិបាល ប៉ុន្តែផ្ទុយទៅវិញ នាំទៅរកការរាំងស្ទះសេដ្ឋកិច្ច និងក្នុងករណីខ្លះមានអស្ថិរភាពនយោបាយ"។ បណ្តាសាធនធាន អាចមានលក្ខណៈខុសៗពីគ្នា ដោយរួមទាំងការតម្លើងអត្រាប្តូរប្រាក់ខ្ពស់ហួសហេតុ ដែលបណ្តាលឱ្យខូចដល់ភាពប្រកួតប្រជែងក្នុងវិស័យមិនមែនធនធាន ជាពិសេស កសិកម្មនិងសិប្បកម្ម ការខាតបង់ដោយសារខ្ជះខ្ជាយ អំពើពុករលួយ ការកិបកេងយកផលប្រយោជន៍ពីអ្នកដទៃ និងការថយចុះការលើកទឹកចិត្តឱ្យមានការទទួលខុសត្រូវពីសំណាក់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋខ្លួន។*

*(៨៧) ឧទាហរណ៍ដ៏គួរឱ្យចាប់អារម្មណ៍ គឺប្រទេសរីកចម្រើននៅអាស៊ីជាច្រើនពុំសម្បូណ៌ប្រេងកាត ខណៈពេលដែលប្រទេសសម្បូណ៌រ៉ែ និងប្រេងនៅអាហ្វ្រិកនិងអាមេរិកឡាទីន បែរជាក្លាយជាប្រទេសក្រីក្រ និងជាប់បំណុលគេ។ ប្រទេសដែលទទួលបណ្តាសាធនធានទាំងនោះមាន លីហ្សេរីយ៉ា អង់ហ្គូឡា លីបេរីយ៉ា សេរ៉ាឡេអូន អេក្វាទ័រ វេណេហ្ស៊ុយអេឡា ប្រទេសហ្វីលីពីន ឆ្នាំ ៧០ និង ៨០ និងប្រទេសដទៃទៀត។*

## ៦.២ បទពិសោធពិភពលោកស្ដីពីបណ្ដាសាធនធាន

ការពិនិត្យមើលឡើងវិញទៅលើបទពិសោធនានារបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលរាតត្បាតញាំញីដោយឥទ្ធិពលអាក្រក់នៃបណ្ដាសាធនធានជាង ៤០ ឆ្នាំកន្លងមក បង្ហាញឱ្យឃើញនូវសញ្ញានៃភាពអាសន្នខ្លះៗ ដែលនាំឱ្យមានផលអាក្រក់យ៉ាងធ្ងន់ធ្ងរនៃបណ្ដាសាធនធាន។ ទាំងនេះ រួមមាន ការកើនឡើងនូវចំណូលជាសាច់ប្រាក់បរទេស ដែលបានមកពីការចម្រាញ់យកធនធានធម្មជាតិ ដែលមិនកើតឡើងវិញ រួមមានទាំង :

- ខ្វះតម្លាភាពផ្នែកហិរញ្ញវត្ថុ
- ខ្សោយក្នុងការចាត់ចែងហិរញ្ញវត្ថុ
- ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលផ្ទុះធ្លាយ និងដាច់ជាផ្នែកៗ
- មូលដ្ឋានពន្ធដារតូចចង្អៀត និងទន់ខ្សោយ
- សក្ដិភាពនៃអំពើពុករលួយធ្ងន់ធ្ងរ
- រដ្ឋគ្រប់គ្រងមិនត្រឹមត្រូវបណ្ដាលឱ្យមន្ត្រីទាញយកប្រយោជន៍ផ្ទាល់ខ្លួនតាមរយៈការប្រើអំណាចសាធារណៈ[៨៨]
- សមត្ថភាពទន់ខ្សោយក្នុងការគ្រប់គ្រងសេដ្ឋកិច្ចខ្នាតធំ បណ្ដាលឱ្យកើតជម្ងឺហូឡង់ដ៏[៨៩]
- មានខ្ចីប្រាក់ជាច្រើនដោយសម្អាងទៅលើអណ្ដូងប្រេង[៩០]

## ៦.៣ លក្ខណៈសម្បត្តិសម្រាប់សេចក្ដីចម្រើនរុងរឿង

ប្រទេសភាគតិចដែលសម្បូណ៌ប្រេង/ឧស្ម័ន/រ៉ែ ដែលទទួលបានពរជ័យពីផលប្រេង ក៏ប្រើប្រាស់លក្ខណៈទូទៅដូចៗគ្នាដែរ[៩១]។ លក្ខណៈទាំងនេះ មានទាំងក្ដីរំពឹងលើកំណើនចំណូលពីប្រេង ដែលបានមកពីការចម្រាញ់យកធនធានធម្មជាតិដែលមិនកើតឡើងវិញ រួមជាមួយនឹង :

- ផែនការឈានមុខ ដើម្បីគ្រប់គ្រង ចាត់ចែង និងវិនិយោគលំហូរហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព
- តម្លាភាពកម្រិតខ្ពស់
- ការចូលរួមដ៏ខ្ពង់ខ្ពស់ពីសំណាក់សភាទាំងពីរ ឬរដ្ឋសភាជាតិ នៅក្នុងសេចក្ដីសម្រេចសំខាន់ៗ
- ស្ថាប័នរដ្ឋមានការរៀបចំល្អ និងមានប្រសិទ្ធភាព
- អំពើពុករលួយមានកម្រិតទាបជាងសព្វថ្ងៃ ដោយមានប្រព័ន្ធតុលាការរឹងមាំ និងដំណើរការល្អ
- ប្រព័ន្ធព័ត៌មាន និងសង្គមស៊ីវិលមានដំណើរការត្រឹមត្រូវ
- សមត្ថភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយស័ក្ដិសិទ្ធិ
- ការមិនចូលចិត្តឱ្យមានកំណើនបំណុល
- ការគ្រប់គ្រង និងវិនិយោគប្រាក់ចំណូលប្រកបដោយប្រសិទ្ធភាព ដើម្បីចៀសវាងការដាក់អត្រាប្ដូរប្រាក់ខ្ពស់ហួសហេតុពេក និងដើម្បីលើកកម្ពស់សេដ្ឋកិច្ចចម្រុះ
- ការចំណាយលើវិនិយោគក្នុងអត្រាមួយដែលធានាប្រសិទ្ធភាព និងសមធម៌យូរអង្វែងនៅក្នុងដែនសមត្ថភាពរបស់រដ្ឋ និងលទ្ធភាពដែលប្រទេសអាចស្រូបយកបាន និងជាធម្មតា ត្រូវពង្រឹងដោយមូលនិធិធនធានធម្មជាតិមួយ ដែលមានការរៀបចំល្អ និងមានតម្លាភាព។

---

*(៨៨) ឧទាហរណ៍ដែលលើកឡើងជាញឹកញាប់នៅទីនេះ រួមមាន អតីតរបបគ្រប់គ្រងនៅក្នុងប្រទេស នីហ្សេរីយ៉ា លីបេរីយ៉ា សេរ៉ាឡេអូន និងអតីតប្រទេស ហ្សាអៀរ។*

*(៨៩) "ជម្ងឺហូឡង់ដ៏" គឺលទ្ធភាពដំឡើងអត្រាប្ដូរប្រាក់ខ្ពស់ហួសពេក និងការបាត់បង់អស់ជាច្រើននូវភាពប្រកួតប្រជែងគ្នាក្នុងវិស័យផលិតផលមិនមែនប្រេង ដែលអាចលក់ដូរបាន ជាពិសេស គឺកសិកម្ម និងសិប្បកម្ម ហើយធ្វើឱ្យមូលដ្ឋាននៃសកម្មភាពសេដ្ឋកិច្ចកាន់តែតូចទៅៗ បង្កើនភាពឥតការងារធ្វើ និងបន្ថយប្រាក់ចំណូល។ ការចុះថយនៃសេដ្ឋកិច្ចចម្រុះ និងការពឹងផ្អែកកាន់តែច្រើនឡើងលើវត្ថុធាតុដើម បណ្ដាលឱ្យប្រទេសកាន់តែឆាប់មានអស្ថិរភាពសេដ្ឋកិច្ច ដោយសារទីផ្សារលក់ដូរវត្ថុធាតុដើមមិននឹងន។*

*(៩០) គួរឱ្យហួសចិត្ត ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ ដែលជំពាក់បំណុលច្រើនជាងគេ ក៏គឺជាប្រទេសដែលសម្បូណ៌រ៉ែ។*

*(៩១) ប្រទេសដែលគេនិយាយច្រើនជាងគេថាជាប្រទេសមានជោគជ័យពីធនធាន គឺប្រទេសណ័រវេស្ស៊ កាណាដា (រដ្ឋអាល់ប័រតា) សហរដ្ឋអាមេរិក (រដ្ឋអាឡាស្កា) អូស្ត្រាលី ឈីលី និងបុតស្វាណា។ ប្រទេសទីម័រខាងកើត ជាប្រទេសកំពុងអភិវឌ្ឍន៍ដែល ថ្មីៗនេះ ទើបនឹងអនុម័តយកបទពិសោធន៍របស់ប្រទេសដទៃៗជាច្រើន ក្នុងការគ្រប់គ្រងធនធានប្រេងកាតក្នុងសមុទ្រពីជាង ៤០ ឆ្នាំកន្លងមក ដែលអាចជាគំរូល្អមួយសម្រាប់កម្ពុជា។*

*រដ្ឋធម្មនុញ្ញកម្ពុជា ផ្ដល់នូវផែនទីមគ្គុទ្ទេសក៍ដ៏មានប្រសិទ្ធភាព ឆ្ពោះទៅរកពរជ័យពីផលប្រេង*

## ៦.៤ ការធានានូវពរជ័យពីផលប្រេងជូនកម្ពុជា

ច្បាស់ណាស់ ការសម្រេចបាននូវពរជ័យពីផលប្រេងសម្រាប់កម្ពុជាមិនមែនចេះតែធ្វើបានដោយស្វ័យប្រវត្តិទេ ប៉ុន្តែជាសំណាងល្អ បទពិសោធន៍អន្តរជាតិអាចផ្ដល់នូវការណែនាំដ៏មានតម្លៃ ។

រដ្ឋធម្មនុញ្ញកម្ពុជា ផ្ដល់នូវផែនទីមគ្គុទ្ទេសក៍ដ៏មានប្រសិទ្ធភាព ឆ្ពោះទៅរកពរជ័យពីផលប្រេង ។ រដ្ឋធម្មនុញ្ញណែនាំឱ្យរដ្ឋរៀបចំផែនការជាក់លាក់មួយ សម្រាប់គ្រប់គ្រងធនធាន ដូចជា ប្រេង និងឧស្ម័ន ហើយផែនការនេះ ត្រូវមានការសម្រេចដោយសម្លេងរបស់ប្រជាពលរដ្ឋតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ[៩២] ។ (ផែនការឈានមុខ និងការចូលរួមទូលំទូលាយនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចបែបនេះ គឺជាលក្ខណៈសម្បត្តិដ៏សំខាន់មួយ សម្រាប់សេចក្ដីចម្រើនរុងរឿងនៅក្នុងប្រទេស ដែលលក់ប្រេងចេញខ្លះសម្រេចបានជោគជ័យ ។

លើសពីនោះទៀត យោងតាមបរិបទនៃស្ថាប័ន និងការអភិវឌ្ឍរបស់កម្ពុជា បទពិសោធន៍អន្តរជាតិអាចស្នើបានថា យន្តការការពារសំខាន់ៗក្នុងផ្នែកគោលនយោបាយផ្នែកច្បាប់ និងផ្នែកស្ថាប័ន ត្រូវរៀបចំឱ្យមានស្រេចមុនលំហូរនៃចំណូលប្រេង ដើម្បីធានាឱ្យកម្ពុជាអាចចៀសផុតពីបណ្ដាសា ហើយជួបតែសេចក្ដីចុំថ្កើងរុងរឿងពីចំណូលប្រេង ។

### វិស័យគោលនយោបាយ

ត្រូវកំណត់ឱ្យច្បាស់នូវគោលនយោបាយស្ដីអំពីរបៀបគ្រប់គ្រង និងចាត់ចែងចំណូលពីប្រេង និងឧស្ម័ន ។ ត្រូវមានតម្លាភាពក្នុងគោលនយោបាយផ្ដល់សម្បទានប្រេង និងឧស្ម័ន ដើម្បីផ្ដល់ផលប្រយោជន៍អតិបរមាជូនប្រទេសទាំងមូល ។ ត្រូវមានតម្លាភាពលើប្រភេទ និងចំនួននៃការបង់ប្រាក់ និងលំហូរហិរញ្ញវត្ថុ ដែលបានពីការចេញអាជ្ញាប័ណ្ណ ការរុករក ការអភិវឌ្ឍ និងការទាញយក ហើយនិងជាទូទៅ គឺគោលនយោបាយច្បាស់លាស់លើកម្រិតនៃតម្លាភាពនៅក្នុងផ្នែកនេះទាំងមូល[៩៣] ។

ប្រេង និងឧស្ម័ននៅសមុទ្រ គឺជាបេតិកភ័ណ្ឌរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ដូច្នេះការផ្ដល់ព័ត៌មាន និងផ្ដល់ឱកាសទូលំទូលាយជូនសាធារណជនពិភាក្សាគ្នាលើអនាគតនៃការប្រើប្រាស់ចំណូលពីប្រេង និងឧស្ម័ន គឺជាការចាំបាច់ ។ ដើម្បីបង្កើនប្រសិទ្ធភាព និងផលប្រយោជន៍ជាអតិបរមាជូនប្រទេសជាតិ ការផ្ដល់សម្បទានប្រេង និងឧស្ម័ន ឱ្យទៅក្រុមហ៊ុនបរទេសត្រូវធ្វើការដេញថ្លៃតាមដំណើរការប្រកួតប្រជែងគ្នា ។ លើសពីនេះទៀត ដើម្បីផ្ដល់ព័ត៌មានឱ្យបានកាន់តែប្រសើរសម្រាប់ការពិភាក្សាជាសាធារណៈទាក់ទងទៅនឹងការលើកផែនការ និងការធ្វើសេចក្ដីសម្រេចប្រកបដោយប្រសិទ្ធភាព កិច្ចព្រមព្រៀងចែករំលែកផលិតកម្មទូលំទូលាយមួយ ដែលគូសបញ្ជាក់អំពីរបៀបរបបចែករំលែកផលិតកម្ម ប្រភេទលំហូរហិរញ្ញវត្ថុចូលទៅក្នុងប្រទេស គួរតែដាក់ជូនសាធារណជនឱ្យបានជ្រាបដោយងាយស្រួល (ឧទាហរណ៍ : ចុះក្នុងសៀវភៅរាជកិច្ច ឬដាក់ផ្សាយក្នុងវិបសាយជូនសាធារណជន) ។

### វិស័យច្បាប់ :

ត្រូវមានច្បាប់ប្រេងកាតមួយដែលរៀបរៀងយ៉ាងហ្មត់ចត់ល្អ ដើម្បីគ្រប់គ្រងផ្នែកនេះ នៅក្នុងបរិបទដ៏ទូលំទូលាយលើវិស័យច្បាប់ និងស្ថាប័ននៃកម្ពុជា ដោយឈរលើមូលដ្ឋាននៃការចែករំលែកការទទួលខុសត្រូវដ៏សមស្របមួយនៅក្នុងរដ្ឋ និងរវាងផ្នែកនានារបស់រដ្ឋ និងផ្នែកមិនមែនរបស់រដ្ឋ ។ ស្រដៀងគ្នានេះដែរ ច្បាប់គ្រប់គ្រងប្រាក់ចំណូលមួយដែលរៀបរៀងយ៉ាងហ្មត់ចត់ល្អ នឹងជួយធ្វើឱ្យប្រសើរឡើងដល់របៀបគ្រប់គ្រង និងចាត់ចែងប្រាក់ចំណូលពីប្រេងកាត ព្រមទាំងការប្រើប្រាក់ចំណូលនេះទៅធ្វើវិនិយោគ ដើម្បីសេចក្ដីចម្រើនរុងរឿងជូនប្រជាពលរដ្ឋ និងជូនជាតិ ។ ការសំខាន់មួយទៀត គឺថាច្បាប់ទាំងនេះ ត្រូវតែច្បាស់លាស់ និងស៊ីសង្វាក់គ្នាល្អជាមួយនឹងច្បាប់ដទៃទៀត (ឧ. គឺច្បាប់ស្ដីអំពីពន្ធដារ និងបរិស្ថានជាដើម) ។

### វិស័យស្ថាប័ន :

តាមស្ថានភាពបច្ចុប្បន្ននៃស្ថាប័នកម្ពុជាដែលកំពុងអភិវឌ្ឍនេះ ចាំបាច់ត្រូវតែមានមូលនិធិប្រេងកាតមួយ ដែលរៀបចំឱ្យបានហ្មត់ចត់ និងមានតម្លាភាពល្អ សម្រាប់កាត់បន្ថយហានិភ័យនៃជម្ងឺហូឡង់ដ៏ និងផលអាក្រក់ដទៃទៀតនៃបណ្ដាសាធនធានឱ្យនៅតិចបំផុត ។

---

*(៩២) មាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញមានចែងថា រដ្ឋត្រូវលើកផែនការប្រាកដប្រជាមួយក្នុងការគ្រប់គ្រងធនធាននានា ដូចជា ប្រេង និងឧស្ម័ន ហើយនិងចាត់ចែងធនធានទាំងនេះ សម្រាប់ធ្វើឱ្យចម្រើនឡើងដល់សុខុមាលភាព និងកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ហើយអំណាចនេះត្រូវប្រើប្រាស់តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ ។*

*(៩៣) រដ្ឋាភិបាលបានផ្ដួចផ្ដើមទំនាក់ទំនងការងារជាមួយនឹងកម្មវិធីតម្លាភាពនៃឧស្សាហកម្មចម្រាញ់យកផល (EITI) ដើម្បីជួយក្នុងដំណើរការនេះ ។*

ដូចបានអនុវត្តនៅប្រទេសមានជោគជ័យភាគច្រើនដែលបានចៀសផុតអំពីបណ្ដាសាលំហូរហិរញ្ញវត្ថុ ដែលបានមកពីប្រេង និងឧស្ម័ន ដំបូងគេដាក់បញ្ចូលទៅក្នុងមូលនិធិមួយ ដែលរៀបចំយ៉ាងហ្មត់ចត់ និងមានតម្លាភាពល្អ មុននឹងយកទៅជូនរដ្ឋាភិបាលប្រើប្រាស់តាមរយៈការចាត់ចែងថវិកាជាតិ សម្រាប់ផ្ដល់ហិរញ្ញវត្ថុទៅលើវិនិយោគនានា ដែលបានគ្រោងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការផ្ទេរប្រាក់ចំណូលនេះទៅក្នុងថវិកាជាតិ ត្រូវធ្វើក្នុងអត្រាមួយ ដែលជួយបង្កលក្ខណៈឱ្យមានវិនិយោគប្រកបដោយភាពស័ក្ដិសិទ្ធិ និងមានប្រសិទ្ធភាពក្នុងស្ថានភាព ដែលប្រទេសកំពុងអភិវឌ្ឍន៍ស្ថាប័ន[៩៤] និងក្នុងកម្រិតសមត្ថភាពដែលអាចស្រូបបាន។ វិធីដោះស្រាយដែលឈរលើមូលដ្ឋាននៃមូលនិធិប្រេងកាតបែបនេះ អាចនឹងជួយធានាឱ្យការចំណាយលើវិនិយោគផ្សេងៗទៀតមានប្រសិទ្ធភាព និងមានសមភាពយូរអង្វែង។

ជាទូទៅ ការពង្រឹងបន្ថែមទៅលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុ គឺប្រាកដជាកត្តាសំខាន់ណាស់ ដើម្បីចៀសវាងបណ្ដាសាធនធាន។ ការដែលរដ្ឋាភិបាលកំពុងបន្តប្រឹងប្រែងកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គឺជាការសំខាន់ខ្លាំងណាស់នៅចំពោះមុខសក្ដានុពលនៃកំណើនចំណូលពីប្រេង និងឧស្ម័ន នៅដើមឆ្នាំ ២០១០។ ប៉ុន្តែនៅក្នុងវិស័យប្រេងកាតនេះ ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័ននានា ចាំបាច់ត្រូវតែចែករំលែកគ្នាឱ្យបានសមស្រប។ សមត្ថភាពនៃអាជ្ញាធរជាតិប្រេងកាតកម្ពុជា ក៏ត្រូវការពង្រឹងនៅក្នុងផ្នែកបច្ចេកទេសមួយចំនួនធំដែរ រីឯការចែករំលែកការទទួលខុសត្រូវជាមួយស្ថាប័នដទៃទៀតរបស់រដ្ឋាភិបាល ក៏ប្រហែលជាត្រូវកំណត់ឱ្យច្បាស់ថែមទៀតផងដែរ។

## ៦.៥ វិនិយោគដើម្បីសេចក្ដីចម្រើនរុងរឿងទាំងអស់គ្នា និងស្ថិរភាពយូរអង្វែង

សក្ដានុពលនៃការប្រឈមមួយទៀតរបស់កម្ពុជា គឺការប្រើប្រាស់ចំណាយឱ្យមានប្រសិទ្ធភាព តាមរយៈដំណើរការចាត់ចែងថវិកា និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីកាត់បន្ថយហានិភ័យនៃបណ្ដាសាធនធានឱ្យនៅតិចបំផុត និងបង្កើនលទ្ធភាពទទួលពរជ័យឱ្យបានច្រើនបំផុត។ គំហើញដំបូងពីការស្រាវជ្រាវ ដែលកំពុងបន្តឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និងអាជ្ញាធរជាតិប្រេងកាតកម្ពុជា (CNPA) កំពុងតែមានពន្លឺត្រចះត្រចង់ឡើង[៩៥]។

ការវិភាគសេដ្ឋកិច្ចកម្ពុជា តម្រាប់តាមគំរូបែបបរិមាណតាមសេណារីយ៉ូផ្សេងៗគ្នា ស្ដីពីប្រេង និងឧស្ម័ន បានផ្ដល់ការរកឃើញដំបូងដែលស្របគ្នាជាទីបំផុតទៅនឹងការសន្និដ្ឋានឯទៀតៗនៃរបាយការណ៍នេះ។ ជាពិសេស ដោយសារតែតំបន់ទីជនបទកម្ពុជាភាគច្រើនមានប្រពលភាពមូលធនទាប ការវិភាគសេដ្ឋកិច្ចអនុវត្តតាមគំរូបែបបរិមាណបានបញ្ជាក់សង្កត់ធ្ងន់ថា វិធីដ៏មានប្រសិទ្ធភាពបំផុតសម្រាប់កម្ពុជាដើម្បីកាត់បន្ថយហានិភ័យនៃជម្ងឺហូឡង់ដ៏ និងឥទ្ធិពលឯទៀតៗ នៃបណ្ដាសាធនធានឱ្យនៅទាបបំផុតជាអប្បបរមា គឺត្រូវយកប្រាក់ចំណូលពីប្រេង និងឧស្ម័នមួយផ្នែកធំ ទៅវិនិយោគក្នុងការអភិវឌ្ឍជនបទ។

ការវិនិយោគនៅជនបទក្នុងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការអប់រំមូលដ្ឋាន ការបណ្ដុះបណ្ដាល និងការផ្ដល់សេវាផ្សព្វផ្សាយទូលំទូលាយ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការបំពាក់អគ្គិសនីនៅជនបទ ប្រព័ន្ធធារាសាស្ត្រ និងផ្លូវថ្នល់ នឹងផ្ដល់នូវផលប្រយោជន៍ច្រើនបំផុត។ លទ្ធផលដ៏ទូលំទូលាយនេះ គឺដោយសារបច្ចុប្បន្ននៅជនបទមានប្រពលភាពមូលធនទាប ដូចដែលបានពិគ្រោះយោបល់ខាងលើ។

វិនិយោគនៅជនបទក្នុងវិស័យធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ ពិតជាអាចផ្ដល់វិសាលភាពឧត្ដុង្គឧត្ដមបំផុតសម្រាប់ពិពិធកម្មសេដ្ឋកិច្ច ការបង្កើតការងារ ការបង្កើនប្រាក់ចំណូលក្នុងវិស័យកសិកម្ម និងសិប្បកម្ម និងការរក្សាចីរភាពអត្រាកំណើនបានយ៉ាងល្អតទៅយ៉ាងយូរ។ លើសពីនេះទៀត ការវិភាគសេដ្ឋកិច្ចតាមគំរូបែបបរិមាណ ក៏បានចង្អុលបង្ហាញនូវផលប៉ះពាល់ជាវិជ្ជមានយ៉ាងរឹងមាំលើសូចនាករសមធម៌ ដែលបង្កើតជាមូលដ្ឋាននៃស្ថិរភាពសង្គមដ៏យូរលង់។

ផ្ទុយស្រឡះទៅវិញ ដោយសារចំណែកកើនឡើងនៃអនាគតកំណើនប្រាក់ចំណូលនៅតំបន់ទីប្រជុំជន ហានិភ័យនៃជម្ងឺហូឡង់ដ៏ (ភាពប្រថុយប្រថាននឹងគ្រោះថ្នាក់ដោយសារមិនមានការប្រកួតប្រជែង និងមិនមានកំណើនការងារគ្រប់គ្រាន់) និងការបាត់បង់ការប្រកួតប្រជែងក្នុងវិស័យកសិកម្ម វិស័យសិប្បកម្ម និងវិស័យទេសចរណ៍ នឹងកាន់តែកើនខ្ពស់ឡើង។ នៅក្នុងសេណារីយ៉ូនេះ សូចនាករ សមធម៌ នឹងស្រុតចុះយ៉ាងឆាប់រហ័ស ដែលជាប្រផ្នូលមិនល្អសម្រាប់ស្ថិរភាពសង្គម និងសុខុមាលភាពមនុស្សរយៈពេលវែង។ ស្រដៀងគ្នានេះដែរ សេណារីយ៉ូនេះ ក៏មានទំនោរធ្វើឱ្យការប្រមូលផ្ដុំដីធ្លី និងភាពមិនស្មើគ្នាដែលធ្ងន់ធ្ងររួចទៅហើយនោះ កាន់តែយ៉ាប់យ៉ឺនឡើងថែមទៀត។

*(៩៤) មូលនិធិដែលដាក់ចូលទៅក្នុងមូលនិធិប្រេងកាតអាចបន្តកើនឡើងជាលំដាប់ តាមអត្រាការប្រាក់អន្តរជាតិដោយសុវត្ថិភាព ដែលនឹងជួយបង្កើនសុខភាព និងការអប់រំបានយូរហួសពីពេលដែលអស់ប្រេងពីបាតសមុទ្រ និងធានាស្ថិរភាពសេដ្ឋកិច្ច-សង្គម និងស្ថិរភាពហិរញ្ញវត្ថុ។*

*(៩៥) ដោយសារចាំបាច់ត្រូវមានផែនការល្អជាមុនចំពោះលទ្ធភាព ដែលអាចកើតមានមួយចំនួន ការស្រាវជ្រាវដែលកំពុងបន្តនេះ ដៅទៅវិភាគ និងរកបរិមាណនៃផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងវិស័យប្រេង និងឧស្ម័ន ដោយប្រើជាលើកទីមួយនូវគំរូសេដ្ឋកិច្ច CGE។ សេចក្ដីព្រាងអំពីការរកឃើញទាំងឡាយនឹងមានចេញនៅចុងឆ្នាំ ២០០៧ សម្រាប់ពិគ្រោះយោបល់ និងកែលម្អ។*

*វិធីដ៏មាន ប្រសិទ្ធភាពបំផុត សម្រាប់កម្ពុជា កាត់បន្ថយហានិភ័យ នៃជម្ងឺហុល្លង់ដ៏ និងឥទ្ធិពលឯទៀតៗ នៃបណ្ដាសាធនធាន ឱ្យនៅទាបបំផុត គឺត្រូវយកប្រាក់ ចំណូលពីប្រេង និងឧស្ម័នមួយ ផ្នែកធំទៅវិនិយោគ ក្នុងការអភិវឌ្ឍជនបទ*

*ក្នុងខណៈដែលមូលនិធិថ្មីដ៏ច្រើនសន្ធឹកសន្ធាប់នេះផ្តល់ឱកាសសម្រាប់ធ្វើឱ្យប្រសើរដល់ស្ថានភាពសង្គមកិច្ច និងសេដ្ឋកិច្ច រដ្ឋាភិបាលត្រូវតែរូតរះធ្វើការកែទម្រង់ស្ថាប័នឱ្យទូលំទូលាយ*

ដូចគ្នានេះដែរ ការវិភាគមុនៗស្នើឡើងថា ការធ្វើឱ្យមានតុល្យភាពល្អរវាងការហូបចុក ប្រើប្រាស់ និងចំណាយលើវិនិយោគ គឺជាការសំខាន់។ ល្បឿនឥទ្ធិពលនៃជម្ងឺហូឡង់ដ៏នឹងកើនឡើង កាលណាយកប្រាក់ចំណូលថ្មីទៅប្រើសម្រាប់ការហូបចុក ប្រើប្រាស់។ ផលប៉ះពាល់នឹងក្លាយជាអវិជ្ជមាន ជាពិសេស ទៅលើការវិនិយោគ និងការប្រកួតប្រជែងរបស់ផ្នែកឯកជន។ ការនាំទំនិញចូលក៏នឹងកើនឡើងដល់កម្រិតមួយដែលមិនអាចគ្រប់គ្រងបានដែរ។

ជាសំណាងល្អ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាល សង្កត់យ៉ាងធ្ងន់ទៅលើការអភិវឌ្ឍជនបទ និងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានសារៈសំខាន់ដល់ការធានា ដាក់អាទិភាពខ្ពស់បំផុតដល់តំបន់ជនបទ ហើយនិងកំណត់យកការវិនិយោគនៅជនបទជាចម្បង។ ជាសង្ខេប ការវិនិយោគឱ្យបានច្រើនជាមួយប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលប្រើអនាគតប្រាក់ចំណូលពីប្រេង និងឧស្ម័ន ហើយដោយមានការកែទម្រង់អភិបាលកិច្ច ដែលត្រូវការជាចាំបាច់អមជាមួយផងនោះ គឺជាមធ្យោបាយដែលមានប្រសិទ្ធភាពខ្ពស់បំផុតសម្រាប់ចៀសវាងបណ្តាសាធនធាន។

## ៦.៦ សេចក្តីសរុប

ការរកឃើញប្រេងនិងឧស្ម័ននៅកម្ពុជានឹងនាំទៅរកកំណើនប្រាក់ចំណូលយ៉ាងស្តុកស្តម្ភជូនរដ្ឋាភិបាល។ ក្នុងពេលដែលមានមូលនិធិថ្មីដ៏ច្រើនសន្ធឹកសន្ធាប់ នេះជាឱកាសផ្តល់សម្រាប់ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច រដ្ឋាភិបាលត្រូវតែរូតរះធ្វើការកែទម្រង់ស្ថាប័នឱ្យទូលំទូលាយ ដើម្បីចៀសវាងបណ្តាសាធនធាន ដែលធ្លាប់បានប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលផលិតឧស្ម័នភាគច្រើន។

- ការសិក្សាថ្មីៗនៅកម្ពុជាបានសន្និដ្ឋានថា ប្រាក់ចំណូលដែលបានមកពីផ្នែកប្រេង និងឧស្ម័ន គឺជាឱកាសដ៏ធំបំផុតផង និងជាការគំរាមកំហែងធំបំផុតផង។ ហេតុដែលគេយល់ឃើញដូច្នេះ ពីព្រោះប្រទេសផលិតប្រេងភាគច្រើនដែលមានចំណូលទាប ឬមធ្យម មានអនាគតកំណើនសេដ្ឋកិច្ចទាបជាងប្រទេសដែលក្រធនធាន ពី ៣០ ទៅ ៥០ភាគរយ។

- ការស្រាវជ្រាវអន្តរជាតិដ៏ទូលំទូលាយទៅលើប្រទេសកំពុងអភិវឌ្ឍន៍បានរកឃើញថា កត្តាដែលបណ្តាលឱ្យបណ្តាសាធនធានកើតនៅប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន គឺ : តម្លាភាពហិរញ្ញវត្ថុមានកម្រិត អភិបាលកិច្ច ហិរញ្ញវត្ថុទន់ខ្សោយ ប្រព័ន្ធពន្ធដារ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុចាស់គំរិល មានអំពើពុករលួយ រដ្ឋាភិបាលប្រព្រឹត្តមិនត្រឹមត្រូវដោយចេតនា គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចមិនមានប្រសិទ្ធភាព និងមានការខ្ចីប្រាក់ដោយយកប្រេងជាសំណង។

- ប្រទេសមួយចំនួន ដែលប្រាកដជាបានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ខ្លួន រីកចម្រើនដោយសារប្រាក់ចំណូលពីធនធានធម្មជាតិដែលមិនកកើតឡើងវិញ គឺសុទ្ធតែមានលក្ខណៈស្រដៀងៗគ្នា។ លក្ខណៈទាំងនោះ រួមមាន : មានការជឿនលឿនក្នុងការគ្រប់គ្រង និងចាត់ចែងធនធាន និងការយកធនធានទាំងនោះទៅធ្វើវិនិយោគ មានតម្លាភាពខ្ពស់ មានសេចក្តីសម្រេចរួមគ្នា មានស្ថាប័នសាធារណៈរឹងមាំ គ្មានឬមានអំពើពុករលួយតិចតួច មានប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការរឹងមាំ មានប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិលសកម្ម មានម៉ាក្រូសេដ្ឋកិច្ចចម្រុះសមស្រប និងមានចំណាយសាធារណៈ ដែលរក្សាតុល្យភាពរវាងចំណាយសម្រាប់អភិវឌ្ឍន៍បន្ទាន់ និងការចាំបាច់ត្រូវសងរំលោះប្រាក់បំណុល ដោយមានការត្រិះរិះដល់សមត្ថភាពស្រូបយក និងការអភិវឌ្ឍយូរអង្វែង។

- ក្នុងខណៈដែលកម្ពុជាមានវិធានការណ៍ធានាទទួលបានពរជ័យពីប្រេង ដោយរួមមានទាំងផែនទីមគ្គុទ្ទេសក៍ស្របច្បាប់មួយ ដើម្បីរៀបចំផែនការជាក់លាក់សម្រាប់ចាត់ចែងគ្រប់គ្រងអនាគតប្រាក់ចំណូល ដែលរួមបញ្ចូលគ្នានូវគំនិតពីរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងការកែទម្រង់មួយចំនួន ដែលនៅមិនទាន់បានចប់សព្វគ្រប់នៅឡើយ។ គោលនយោបាយគ្រប់គ្រងផ្នែកប្រេង និងឧស្ម័នប្រកបដោយតម្លាភាពមួយចាំបាច់ត្រូវតែមាន ដើម្បីជាប្រយោជន៍ដល់សង្គមទាំងមូល។ ក្នុងប្រព័ន្ធយុត្តិធម៌ទាមទារត្រូវតែមានច្បាប់គ្រប់គ្រងប្រេងកាត និងប្រាក់ចំណូលប្រកបដោយប្រសិទ្ធភាព។ ជាអវសាន ការកសាងសមត្ថភាពស្ថាប័ន គឺជាការចាំបាច់សម្រាប់អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាជ្ញាធរជាតិប្រេងកាតកម្ពុជា និងក្រសួង-ស្ថាប័ននានារបស់រដ្ឋាភិបាល។

- ការយកចិត្តទុកដាក់ ត្រូវតែផ្តោតរួមបញ្ចូលទាំងទៅលើការអភិវឌ្ឍយូរអង្វែង។ កិច្ចការនេះអាចសម្រេចបានដោយសារការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាព និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ។ ការវិភាគសេដ្ឋកិច្ចលើកម្រិតនៃសក្តានុពលប្រាក់ចំណូលស្នើថា ការវិនិយោគនៅជនបទ ប្រហែលជាអាចជួយបញ្ចៀសនូវបណ្តាសាធនធានបានច្រើនជាអតិបរមា។ ហេតុផលសម្រាប់បញ្ហានេះ រួមមាន ការបង្ការទប់ស្កាត់ជម្ងឺហូឡង់ដ៏ដែលនឹងអាចកើតឡើង ប្រសិនបើមានការវិនិយោគច្រើនពេកនៅទីប្រជុំជន ដែលនឹងកាត់បន្ថយភាពប្រកួតប្រជែងក្នុងផ្នែកសេដ្ឋកិច្ចដទៃទៀត ការពង្រីកមូលដ្ឋានសេដ្ឋកិច្ចតាមរយៈការបង្កើនសមត្ថភាពមនុស្ស និងសមត្ថភាពកសិកម្ម និងការធានាឱ្យមានការចែករំលែកផលប្រយោជន៍ប្រកបដោយសមធម៌ ដែលទាំងអស់នេះនឹងនាំទៅរកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដ៏យូរអង្វែងរបស់កម្ពុជា។

# អវសានកថា





# អវសានកថា

*“ពេលណាយើងចាប់យកឱកាសបាន ឱកាសនោះនឹងកើនកាន់តែច្រើនឡើង”*
*ប្រសាសន៍សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃ ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧*

មួយទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងវិស័យមួយចំនួនដែលមានសារៈសំខាន់ក្នុងការអភិវឌ្ឍមនុស្ស។ ទោះជាយ៉ាងនេះក្តី ភាពក្រីក្រ និងភាពក្បែរភាពក្រីក្រនៅតែមានច្រើននៅឡើយ ជាពិសេសនៅទីជនបទដែលជាកន្លែងប្រជាជនភាគច្រើនកំពុងរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត។ ស្រដៀងគ្នានេះដែរ សូចនាករអភិវឌ្ឍន៍មនុស្សជាច្រើននៅតែបន្តឆ្លុះបញ្ចាំងពីលក្ខណៈរស់នៅដ៏លំបាកនៅតាមទីជនបទ។ ពិតណាស់ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅឆ្នាំ ២០១៥ និងធ្វើឱ្យចម្រើនដល់សុខុមាលភាពមនុស្សនៅកម្ពុជា ត្រូវយកចិត្តទុកដាក់ពិសេសលើការធ្វើឱ្យប្រសើរឡើងដល់ជីវភាពរស់នៅតាមទីជនបទ។

កត្តាដែលត្រូវខិតខំពុះពារជាចម្បងមួយនៅកម្ពុជា គឺការចាត់ចែងឱ្យមានដំណើរឆ្លងកាត់ដ៏រលូនពីសង្គមមួយ ដែលនៅតែមានមូលដ្ឋានកសិកម្មក្រីក្រខ្លាំង និងមានប្រជាជន ៨៥ ភាគរយ កំពុងប្រកបមុខរបរនេះ ឱ្យក្លាយទៅជាសង្គមទំនើបមួយបែបទីក្រុងដែលមានការរីកចម្រើនរួមគ្នា និងស្ថិរភាពដ៏យូរអង្វែង។ នៅក្នុងតំបន់នេះ ប្រទេសកំពុងអភិវឌ្ឍឯទៀតៗដែលទទួលជោគជ័យ គឺសុទ្ធតែផ្តើមចេញពីសេដ្ឋកិច្ចជនបទរស់រវើកមួយឈរលើមូលដ្ឋាននៃកសិដ្ឋានតូចៗប្រចាំគ្រួសារដែលជាគ្រឹះនៃស្ថិរភាពជនបទ ប្រកបដោយមុខរបរគ្រប់គ្រាន់សម្រាប់ជីវភាពជនបទ មុននឹងកើតមានជាឧស្សាហកម្មផ្តល់សេវា និងសិប្បកម្មកែច្នៃ ដែលនឹងផ្តល់ការងារល្អប្រសើរជាង ជាពិសេសនៅទីប្រជុំជន។

ចំពោះកម្ពុជា ក្នុងដំណាក់កាលដំបូងនៃការផ្លាស់ប្តូរពីភាពក្រីក្រនៅជនបទនេះ ការប្រើប្រាស់ប្រាក់ចំណូល និងទ្រព្យសម្បត្តិ ជាពិសេសគឺដីធ្លី បានក្លាយជាចំណុចដែលគេយកចិត្តទុកដាក់ខ្ពស់រួចទៅហើយ។ ស្ថានភាពដ៏អាក្រក់បំផុតមួយ ដែលអាចចៀសវាងបាន គឺការប្រមូលទុកដីធ្លី និងការប្រើប្រាស់ដីធ្លីទាំងនោះមិនមានប្រសិទ្ធភាពនៅជនបទ ដែលអាចបណ្តាលឱ្យអ្នកជនបទជាច្រើនគ្មានជម្រើសណាក្រៅតែពីធ្វើចំណាកស្រុកទៅកាន់ទីប្រជុំជន ដើម្បីស្វែងរកជីវភាពរស់នៅមួយប្រសើរជាងមុន។ ក៏ប៉ុន្តែឧស្សាហកម្មនៅទីប្រជុំជនពុំមានពេលគ្រប់គ្រាន់ដើម្បីអភិវឌ្ឍ និងបង្កើតការងារសម្រាប់ពលរដ្ឋទាំងនោះឡើយ។ ផលអាក្រក់ដែលបណ្តាលមកពីប្រាក់ចំណូលពីធនធានប្រេង និងឧស្ម័ននៅក្នុងសមុទ្រនាអនាគត គឺជាការមួយដែលត្រូវពុះពារយ៉ាងម៉ឺងម៉ាត់នៅថ្ងៃមុខ។ ចាំបាច់ត្រូវមានវិធានការដោះស្រាយទាន់ពេលវេលាដើម្បីបញ្ឈប់ និងបញ្ច្រាសទៅក្រោយវិញនូវនិន្នាការខ្លះៗ ដែលគួរឱ្យបារម្ភខ្លាំង។

នេះគឺជាពេលវេលាត្រឹមត្រូវសម្រាប់ធ្វើសេចក្តីសម្រេចដ៏ចាំបាច់ និងលើកស្ទួយកម្ពុជាឱ្យឡើងដល់កម្រិតអភិវឌ្ឍន៍ខ្ពស់មួយដែលមានការរីកចម្រើនរួមគ្នា និងមានស្ថិរភាពយូរអង្វែង។ ដំណាក់កាលដំបូងនៃស្ថិរភាពនយោបាយក្នុងអំឡុងប្រាំបីឆ្នាំកន្លងមក គួបផ្សំនឹងអត្រាកំណើនសេដ្ឋកិច្ចខ្ពស់នៅទីជនបទ ផ្តល់ឱកាសសំខាន់មួយសម្រាប់បង្កើនល្បឿនអនុវត្តកំណែទម្រង់ខ្លះៗ ដែលបានគ្រោងធ្វើជាយូរមកហើយៗដែលត្រូវការជាចាំបាច់សម្រាប់ដោះស្រាយសេដ្ឋកិច្ចកម្ពុជា ដែលមានតម្លៃខ្ពស់ពង្រីកឱ្យទូលំទូលាយ និងបង្កើនឱ្យបានច្រើនមុខនូវកំណើនក្នុងវិស័យកសិកម្ម និងសិប្បកម្ម ព្រមទាំងបង្កើតឱកាសនិងជម្រើសច្រើនថែមទៀត ជូនពលរដ្ឋកម្ពុជាចំនួនពាក់កណ្តាលដែលមិនសូវមានភ័ព្វវាសនា។

ការអនុវត្តច្បាប់ដីធ្លី និងច្បាប់ព្រៃឈើឱ្យមានប្រសិទ្ធភាព និងប្រកបដោយសមធម៌ គឺជាការចាំបាច់។ ស្រដៀងគ្នានេះដែរ ការបង្កើនតម្លាភាព ការផ្តល់ព័ត៌មានសំខាន់ៗជូនសាធារណៈឱ្យបានច្រើនថែមទៀត និងការអនុញ្ញាតឱ្យសាធារណជនថ្នាក់មូលដ្ឋាន បានចូលរួមធ្វើសេចក្តីសម្រេច គឺជាការចាំបាច់ផងដែរ។ ធ្វើយ៉ាងនេះអាចជួយកាត់បន្ថយព័ត៌មានមិនស្មើគ្នាលើវិស័យមួយចំនួន ដែលបណ្តាលឱ្យអ្នកជនបទងាយរងគ្រោះដោយសារការកេងយកចំណេញពីសំណាក់ជនមួយចំនួនតូចដែលមានលទ្ធភាពទទួលបានព័ត៌មានល្អជាង។

ការអនុម័តជាបន្ទាន់ និងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយមួយឱ្យមានប្រសិទ្ធភាព នឹងអាចជួយទ្រទ្រង់ប្រកបដោយប្រសិទ្ធភាពដល់ការប្រឹងប្រែងទាំងនេះ ដោយបំបាត់ឱ្យអស់នូវការិយាធិបតេយ្យនៃការបង់ប្រាក់ក្រៅប្រព័ន្ធ និងកាត់បន្ថយរបៀបធ្វើសេចក្តីសម្រេច និងរបៀបធ្វើការ ដែលបណ្តាលឱ្យតម្លៃលើប្រព័ន្ធសេដ្ឋកិច្ចថ្លៃជាងតម្លៃការងារនៅប្រទេសជិតខាង។ តម្លៃដ៏ខ្ពស់បែបនេះធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមិនអាចប្រកួតប្រជែង និងមិនអាចរីកចម្រើនបាន។

ដូចដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ របស់រដ្ឋាភិបាលសង្កត់ធ្ងន់លើការធ្វើឱ្យចម្រើនដល់អភិបាលកិច្ច រួមទាំងការបង្កើនវិនិយោគសាធារណៈឱ្យបានសន្ទឹកសន្ធាប់នៅជនបទ ជាពិសេសគឺសមត្ថភាពមនុស្ស (ក្នុងវិស័យអប់រំ និងសុខាភិបាល) ផលិតភាពកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍវិស័យឯកជន។

ច្បាស់ណាស់ ការសំខាន់ គឺត្រូវអនុវត្តយុទ្ធសាស្ត្រ និងផែនការទាំងនោះឱ្យបានជោគជ័យ។ ដោយសារស្ថាប័ននៅតែមានសមត្ថភាពទន់ខ្សោយនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវផ្តោតជាចម្បងលើសមត្ថភាពអនុវត្តបច្ចុប្បន្ន ដែលទំនងជាអាចផ្តល់ប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ចបានខ្ពស់។ ការប្រឹងប្រែងអស់ទាំងនេះអាចនឹងមានការជួយពង្រឹងបន្ថែមតាមរយៈការចាត់ចែងដ៏ប្រយ័ត្នប្រយែង និងការវិនិយោគប្រាក់ចំណូលដ៏ទូលំទូលាយពីប្រេង និងឧស្ម័ន ដែលនឹងផ្តើមឡើងនៅឆ្នាំ ២០១០។ ដោយធ្វើការរួមគ្នាកិច្ចការទាំងនេះ នឹងជំរុញឱ្យមានការខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យចម្រើនដល់សុខុមាលភាពមនុស្ស សមធម៌ និងស្ថិរភាពសេដ្ឋកិច្ច និងសង្គមកិច្ចយូរអង្វែង ដែលអាចធានាបានថា ក្តីសង្ឃឹមរបស់ប្រទេសកម្ពុជា និងក្តីសង្ឃឹមរបស់ពលរដ្ឋកម្ពុជា ប្រាកដជានឹងសម្រេចបាននូវសព្វសាធុការពរនៅក្នុងទសវត្សរ៍ខាងមុខនេះជាមិនខាន។

## ប្រអប់ទី ៧.១ : កត្តាផ្សំសំខាន់ៗសម្រាប់ជីវភាពចម្រុងចម្រើននៅជនបទ

### *អភិបាលកិច្ចមានប្រសិទ្ធភាព*

១. ការអនុវត្តច្បាប់ដីធ្លី ច្បាប់ព្រៃឈើ និងច្បាប់នេសាទ ឱ្យមានប្រសិទ្ធភាព និងសមធម៌
២. ការបង្កើនតម្លាភាព ការផ្តល់ព័ត៌មានចាំបាច់ជូនសាធារណៈជនឱ្យបានច្រើនថែមទៀត និងការអនុញ្ញាតឱ្យសាធារណៈជនថ្នាក់មូលដ្ឋានបានចូលរួមធ្វើសេចក្តីសម្រេចនៅថ្នាក់វិមជ្ឈការ
៣. ការអនុម័ត និងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយមួយដ៏មានប្រសិទ្ធភាព ដើម្បីជួយលុបបំបាត់មូលហេតុដែលបណ្តាលឱ្យមានតម្លៃខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច

### *ការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងសមធម៌*

១. ការបង្កើនល្បឿនចេញប្លង់ដីជូនគ្រួសារកសិករ ដែលមានកសិដ្ឋានតូចៗ
២. ចែកដីសេសសល់ដែលមានគុណភាព ជូនទៅគ្រួសារកសិករដែលគ្មានដី ឬដែលស្ទើរតែគ្មានដីសោះ តាមរយៈការធ្វើសម្បទានដីសង្គមកិច្ច ដោយមានសេវាទ្រទ្រង់គ្រប់គ្រាន់ និងហេដ្ឋារចនាសម្ព័ន្ធ
៣. កែទម្រង់ប្រកបដោយចីរភាពនូវដីសម្បទានសេដ្ឋកិច្ច ដើម្បីឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ច និងសមធម៌
៤. អនុវត្តច្បាប់ពន្ធដារមួយ ដែលមានការរៀបចំល្អ ដើម្បីរារាំងការទិញទំនិញទុកលក់ដំឡើងថ្លៃ និងរកប្រាក់ចំណូលសម្រាប់សេវាសាធារណៈសំខាន់ៗនៅមូលដ្ឋាន
៥. ពិនិត្យលើការបែងចែកដីច្រើនហួសហេតុ និងជំរុញឱ្យមានការគ្រប់គ្រងជាលក្ខណៈសហគមន៍ចំពោះដី ដែលមិនអាចបង្រួមចូលគ្នាបាន
៦. ការពារសិទ្ធិកាន់កាប់ដី និងសិទ្ធិប្រើប្រាស់ដីព្រៃណីរបស់ជនជាតិដើមភាគតិច ចេញប្លង់ដីសហគមន៍ដ៏ចាំបាច់ និងធានាឱ្យមានការចូលរួមសមស្របពីសហគមន៍ជនជាតិដើមក្នុងការសម្រេចលើការអភិវឌ្ឍមូលដ្ឋាន

### លើកកម្ពស់ផលិតភាពកសិដ្ឋាន

១. បង្កើនព័ត៌មានទីផ្សារទាន់ពេលវេលា បង្កើនសេវាទ្រទ្រង់កសិកម្មដ៏មានគុណភាព និងបង្កើនជីវបច្ចេកវិទ្យា ផ្សព្វផ្សាយឱ្យដល់ស្រទាប់មហាជនទូទៅអំពីគំនិតច្នៃប្រឌិតនានា ដូចជា ប្រព័ន្ធប្រពលវប្បកម្មស្រូវជាដើម
២. ពង្រីកធារាសាស្ត្រច្រើនប្រភេទ ជាពិសេសគឺធារាសាស្ត្រដែលបង្កើនការផ្គត់ផ្គង់ទឹកបរិភោគ
៣. កាត់បន្ថយឧបសគ្គដល់ការប្រកួតប្រជែងតម្លៃទិញសម្ភារៈកសិកម្ម និងតម្លៃលក់ផលិតផលកសិកម្ម
៤. បង្កើនលទ្ធភាពខ្ចីប្រាក់ដែលមានការប្រាក់សមល្មម ដោយធ្វើឱ្យចម្រើនឡើងដល់ច្បាប់គ្រប់គ្រងហិរញ្ញប្បទានខ្នាតតូច និងការលើកទឹកចិត្ត
៥. វិនិយោគដោយចីរភាពក្នុងការផ្តល់អគ្គិសនីជនបទ។ បន្ទាយខ្សែភ្លើងពីប្រទេសថៃ និងវៀតណាម
៦. វិនិយោគទៅក្នុងការអភិវឌ្ឍ និងស្តារផ្លូវជនបទ
៧. ជួយសម្រួលដល់ការបង្កើតក្រុម និងសមាគមកសិករ ដើម្បីធ្វើឱ្យរីកចម្រើនដល់អំណាចតថ្លៃ ពង្រីកប្រព័ន្ធលក់ដូរក្រោយពេលប្រមូលផលហើយ និងរៀបចំឱ្យមានលក្ខខណ្ឌសម្រាប់កសិករជាប់កិច្ចសន្យា។

### ការធ្វើឱ្យវិស័យនេសាទសម្បូណ៌រុងរឿង

១. បង្កើត និងពង្រឹងសហគមន៍នេសាទ ដើម្បីការពារផលប្រយោជន៍ក្នុងការទិញ-លក់
២. ជ្រើសយកឡូត៍នេសាទជំនួញមួយចំនួនដាក់ជាតំបន់ការពារសម្រាប់ឱ្យទឹកសម្បូណ៌ត្រីឡើងវិញ និងធានាចីរភាព
៣. ជួយសម្រួលដល់ផ្នែកឯកជន និងសហគមន៍នេសាទវិនិយោគទៅក្នុងការកែច្នៃផលិតផលនេសាទឱ្យមានតម្លៃខ្ពស់
៤. ជួយបង្កើតមុខរបរឱ្យគ្រួសារអ្នកនេសាទដែលងាយរងគ្រោះ

### ពង្រីក និងបង្កើតការងារក្រៅកសិដ្ឋានឱ្យបានច្រើនមុខ

១. កំចាត់ចោលឱ្យអស់នូវប្រភពដែលបណ្តាលឱ្យមានតម្លៃខ្ពស់ហួសហេតុលើការដឹកជញ្ជូន សេវាកំពង់ផែ ថាមពល និងសេវាចំបាច់ដទៃទៀតសម្រាប់ផលិត និងបង្កើតទីផ្សារ
២. ជំរុញវិនិយោគ និងការប្រកួតប្រជែងក្នុងមុខរបរម៉ាស៊ីនកិនស្រូវ
៣. ជំរុញវិធីធ្វើកសិកម្មចម្រុះមុខសម្រាប់គ្រួសារកសិករដែលមានដីតូចៗ និងជំរុញកសិដ្ឋានធំៗឱ្យដាំដំណាំ សម្រាប់លក់យកប្រាក់
៤. ជំរុញការបង្កើតឧស្សាហកម្មជនបទកែច្នៃផលកសិកម្ម ផលិតវត្ថុធ្វើដោយដៃ និងផលិតសម្ភារៈបរិក្ខារឱ្យមានគុណភាពខ្ពស់ ដោយផ្តល់ការបណ្តុះបណ្តាល ផ្តល់ឥណទាន និងផ្តល់របៀបទំនាក់ទំនងទីផ្សារ
៥. ជំរុញកម្មវិធីសាធារណការដែលមានលក្ខណៈសន្សំសំចៃ ដោយផ្តល់ការងារជូនអ្នកក្រីក្រនៅក្នុងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធជនបទ
៦. ស្វែងរកលទ្ធភាពបង្កើតប្រព័ន្ធផ្លូវរថភ្លើងឡើងវិញ ដើម្បីលើកទឹកចិត្តពាណិជ្ជកម្ម និងឧស្សាហកម្មផ្សេងៗ ភ្ជាប់ទៅនឹងប្រព័ន្ធផ្លូវរថភ្លើងនេះ

### វិនិយោគធនធានមនុស្ស (សមត្ថភាពសតិបញ្ញា)

១. បង្កើនការចូលរៀន និងអត្រារៀនចប់សាលាបឋមសិក្សា ដោយកាត់បន្ថយចំណាយលើការរៀនសូត្រចំពោះសិស្សក្រីក្រ ផ្តល់អាហារថ្ងៃត្រង់ដើម្បីលើកទឹកចិត្តឱ្យសិស្សទាំងនោះនៅរៀនទៀងទាត់រហូតដល់ចប់ និងផ្តល់ប្រាក់បៀវត្សរ៍គ្រប់គ្រាន់សម្រាប់លើកទឹកចិត្តគ្រូបង្រៀន
២. ពង្រីកការបណ្តុះបណ្តាលបច្ចេកទេស និងអប់រំវិជ្ជាជីវៈ ជាពិសេសនៅកម្រិតបឋម
៣. បង្កើនសេវាសុខាភិបាល និងកាត់បន្ថយតម្លៃព្យាបាលជម្ងឺ និងតម្លៃថ្នាំពេទ្យ
៤. ផ្សព្វផ្សាយបច្ចេកទេសថោកៗដែលមានស្រាប់ជូនមហាជនប្រើប្រាស់សម្រាប់ផលិតទឹកស្អាតបរិភោគ

| ប្រអប់លេខ | ចំណងជើង | |
|---|---|---|

## តារាងរូបភាព


| ប្រអប់លេខ | ចំណងជើង | ទំព័រ |
|---|---|---|
| ១.១ | អនុបាតផលិតភាពពលកម្មរវាងផ្នែកកសិកម្ម និងមិនមែនកសិកម្មពីឆ្នាំ ១៩៩៧ និងឆ្នាំ ២០០៤ | ១៦ |
| ២.១ | អត្រាផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០០៥ *(២០០០រៀលក្នុងមួយដុល្លារ)* | ២១ |
| ២.២ | ការរួមចំណែកនៃផលសសតាមផ្នែកនានានៅកម្ពុជា ឆ្នាំ ១៩៩៣-២០០៥ | ២២ |
| ២.៣ | ការកើតឡើងនៃភាពក្រីក្រនៅកម្ពុជា តាមតំបន់ភូមិសាស្ត្រទូលំទូលាយ ឆ្នាំ ២០០៣-២០០៤ | ២៣ |
| ២.៤ | ទំនាក់ទំនងរវាងអត្រារាប់ចំនួនអ្នកក្រីក្រនៅតាមខេត្ត *(ឆ្នាំ ២០០៣-០៤)* និងមធ្យមភាគនៃទិន្នផលស្រូវវស្សាប្រចាំខេត្ត *(មធ្យមភាគ ឆ្នាំ ២០០៣-០៥)* | ២៥ |
| ២.៥ | អត្រាអក្ខរកម្មមនុស្សពេញវ័យនៅកម្ពុជា ឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៤ | ២៦ |
| ២.៦ | អត្រាអក្ខរកម្មតាមកម្រិតប្រជាពលរដ្ឋ ក្នុងឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៤ | ២៦ |
| ២.៧ | អាត្រាសិស្សរៀននៅថ្នាក់បឋមសិក្សាក្នុងខេត្តនីមួយៗ | ២៧ |
| ២.៨ | អត្រាពិតចូលរៀនថ្មីក្នុងខេត្តនីមួយៗ ឆ្នាំ ២០០៥-២០០៦ | ២៨ |
| ២.៩ | ចំនួនឆ្នាំជាមធ្យមដែលទទួលបានការអប់រំនៅឆ្នាំ ២០០៣-២០០៤ | ២៨ |
| ២.១០ | អាត្រាមរណៈទារកសម្រាប់ខេត្តនីមួយៗ | ២៩ |
| ២.១១ ក | មរណភាពទារក និងកុមារ ឆ្នាំ ២០០០ និងឆ្នាំ ២០០៥ | ៣០ |
| ២.១១ ខ | មរណភាពទារក-ទារិកា និងកុមារ-កុមារី ឆ្នាំ ១៩៩៥-២០០៥ | ៣០ |
| ២.១២ | ស្ថានភាពអាហារូបត្ថម្ភសម្រាប់កុមារតាមទីកន្លែង និងភេទ ឆ្នាំ ២០០៥ | ៣១ |
| ២.១៣ | ស្ថានភាពអាហារូបត្ថម្ភរបស់កុមារក្នុងខេត្តនីមួយៗ ឆ្នាំ ២០០៥ | ៣១ |
| ២.១៤ | ចំនួនភាគរយនៃរចនាសម្ព័ន្ធលំនៅដ្ឋានបណ្តោះអាសន្ន ឆ្នាំ ២០០៤ | ៣២ |
| ២.១៥ | សមាមាត្រប្រជាពលរដ្ឋមានទឹកស្អាតទទួលទានសម្រាប់ខេត្តនីមួយៗ ឆ្នាំ ២០០៤ | ៣៣ |
| ២.១៦ | សន្ទស្សន៍ភាពក្រីក្រសម្រាប់មនុស្សក្នុងប្រទេសអាស៊ីមួយចំនួន ឆ្នាំ ២០០៤ | ៣៦ |
| ២.១៧ | សន្ទស្សន៍អភិវឌ្ឍន៍មនុស្សតាមខេត្តនីមួយៗ ឆ្នាំ ២០០៤ | ៣៦ |
| ២.១៨ | សន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ខេត្តនីមួយៗ ពាក់ព័ន្ធនឹងភាពមិននឹងននៃលំនៅដ្ឋាន ឆ្នាំ ២០០៤ | ៣៧ |
| ២.១៩ | សន្ទស្សន៍ភាពក្រីក្រ *(HPI)* តាមខេត្តនីមួយៗ ឆ្នាំ ២០០៤ | ៣៨ |
| ៣.១ | ទិដ្ឋភាពទូទៅនៃប្រភេទដីធ្លី និងទឹកស្របច្បាប់នៅកម្ពុជា | ៤៤ |
| ៣.២ | ការចែកដីកសិកម្មជាផ្នែកតូចៗ *(%)* ឆ្នាំ ២០០៣-២០០៤ | ៤៦ |
| ៣.៣ | មធ្យមភាគដីកសិកម្មក្នុងគ្រួសារនីមួយៗ *(ជាហិចតា)* តាមអង្កេតផ្សេងៗគ្នា | ៤៦ |
| ៣.៤ | ទំហំដីសម្បទានក្រោមកិច្ចព្រមព្រៀងដែលមានចុះហត្ថលេខាត្រឹមត្រូវប្រចាំខេត្តនីមួយៗ ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ | ៤៧ |
| ៣.៥ | ការប៉ាន់ប្រមាណលើភាពឥតដីធ្វើកសិកម្ម | ៤៨ |
| ៣.៦ | មូលហេតុនៃការលក់ដូរដី និងផលវិបាកនៃវិសមភាព និងភាពគ្មានដីធ្លី | ៤៩ |
| ៣.៧ | អាត្រាទិន្នផលស្រូវ *(ជាតោន/ហិចតា)* តាមទំហំដីក្នុងរដូវប្រាំង និងរដូវវស្សា និងរដូវរួមគ្នា ឆ្នាំ ២០០៣-២០០៤ | ៥១ |
| ៣.៨ | ទំហំកសិដ្ឋាន និងអាត្រាទិន្នផល *(តោន/ហិចតា)* លទ្ធផលសិក្សាពីភូមិ ៩ | ៥១ |
| ៣.៩ | ទំហំកសិដ្ឋាន និងផលកម្រៃ *(ជាពាន់រៀល/គ្រួសារ)* លទ្ធផលសិក្សាពីភូមិ ៩ | ៥២ |
| ៣.១០ | វិវាទដីធ្លីជនបទ *(តាមចំនួន ១០០០ គ្រួសារ ឆ្នាំ ២០០៥)* សម្រាប់ខេត្តនីមួយៗ | ៥៨ |
| ៣.១១ | មូលហេតុខ្លះៗនៃវិវាទដីធ្លី | ៥៩ |
| ៣.១២ | ត្រីដែលចាប់បាននៅកម្ពុជា ឆ្នាំ ១៩៨០-២០០៤ | ៦០ |
| ៣.១៣ | ឡូត៍នេសាទ : ឡូត៍នេសាទបច្ចុប្បន្ន និងឡូត៍នេសាទដែលត្រូវបានលុបចោល ក្នុងឆ្នាំ ២០០១ | ៦២ |
| ៣.១៤ | សេចក្តីសង្ខេបអំពីដីធ្លី ធនធានធម្មជាតិ និងជីវភាពរស់នៅតាមជនបទ | ៦៧ |
| ៤.១ | អត្រាកំណើនតាមផ្នែក-សកម្មភាពកសិកម្ម និងសកម្មភាពដទៃទៀតដែលពាក់ព័ន្ធ *(ក្នុងតម្លៃ ២០០០រ)* ឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៥ | ៧០ |
| ៤.២ | អត្រាទិន្នផលស្រូវ *(ជាតោនក្នុងមួយហិចតា ឆ្នាំ ២០០៤)* ទិន្នន័យពីផលិតករ និងអ្នកលក់ស្រូវចេញមួយចំនួនដែលយើងបានជ្រើសរើស | ៧១ |
| ៤.៣ | ចលនាតម្លៃផលិតផលកសិកម្មផ្សេងៗ និងតម្លៃប្រេងម៉ាស៊ូត និងជីអ៊ុយរ៉េ | ៧២ |
| ៤.៤ | ភាគរយនៃស្រែវស្សាដែលមានប្រព័ន្ធស្រោចស្រពបន្ថែម ឆ្នាំ ២០០៥ | ៧៦ |
| ៤.៥ | តំបន់ងាយទឹកលិច | ៧៧ |
| ៤.៦ | តំបន់ងាយរាំងស្ងួត | ៧៨ |

| | | |
|---|---|---|
| ៤.៧ | វិភាគស្ថិតិស្ដីពីតម្លៃស្រូវ និងអត្រាទិន្នផលក្នុងខេត្តនីមួយៗ នៅឆ្នាំ ២០០៥ | ៨១ |
| ៤.៨ | ទីផ្សារស្រូវនៅកម្ពុជា | ៨២ |
| ៤.៩ | តម្លៃខុសគ្នារវាងស្រូវ និងអង្ករ និងតម្លៃខុសគ្នារវាងកសិករ និងអ្នកប្រើប្រាស់ (*ជាភាគរយ*) ឆ្នាំ ២០០៣ | ៨៣ |
| ៤.១០ | និន្នាការតម្លៃស្រូវ និងអង្ករ (*ផ្កាខ្ញី*) នៅកម្ពុជា | ៨៣ |
| ៤.១១ | តម្លៃត្រីដែលខុសគ្នាពីទន្លេសាបទៅភ្នំពេញ | ៨៦ |
| ៤.១២ | បណ្ដាញលក់ត្រីទឹកសាប | ៨៨ |
| ៤.១៣ | ការដំឡើងប្រាក់ចំណូលជូនកសិករ និងប្រាក់ចំណូលនៅជនបទ - សង្ខេប | ៩៥ |
| ៥.១ | ការប្រែប្រួលនៃប្រាក់ឈ្នួលពិតប្រចាំថ្ងៃរបស់កម្មករស៊ីឈ្នួលធ្វើស្រែពីឆ្នាំ ២០០០ ដល់ ២០០៦ (*តម្លៃក្នុងឆ្នាំ ២០០០*) | ១០២ |
| ៥.២ | ទីតាំងមន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅកម្ពុជា | ១០៨ |
| ៥.៣ | សង្ខេបគម្រោងការខ្នាតធំ | ១១២ |

| ប្រអប់លេខ | ចំណងជើង | ***តារាងប្រអប់អត្ថបទ*** |
|---|---|---|
| ១.១ | កម្ពុជា - ប្រវត្តិថ្មីៗខ្លះ | ១៥ |
| ២.១ | ការតភ្ជាប់ប្រព័ន្ធទូរស័ព្ទទៅកាន់ភូមិ-ឃុំ | ២៤ |
| ២.២ | ការគណនារកសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | ៣៥ |
| ៣.១ | ចំណាត់ថ្នាក់ដីធ្លី | ៤៣ |
| ៣.២ | ដីកសិកម្មក្នុងរយៈពេលមួយសតវត្សរ៍កន្លងមក | ៤៤ |
| ៣.៣ | កសិដ្ឋានតូចៗ និងប្រសិទ្ធភាព-ខ្លឹមសារៈសំខាន់សម្រាប់ការជជែកវែកញែក | ៥០ |
| ៣.៤ | ការប្រមូលផ្ដុំដីធ្លី និងការរៀបចំដីសារឡើងវិញ - បទពិសោធន៍អន្តរជាតិ | ៥៣ |
| ៣.៥ | ក្រុមសាមគ្គីកសិករតូចៗ - ប្រទេសស្រីលង្កា | ៥៤ |
| ៣.៦ | សម្លេងរបស់ជនជាតិដើម | ៥៥ |
| ៣.៧ | ឡូត៍នេសាត្រី - ប្រវត្តិសាវតារខ្លះៗ | ៦២ |
| ៣.៨ | ការគ្រប់គ្រងព្រៃឈើ - ការពិនិត្យលើប្រវត្តិសាស្ត្រ | ៦៤ |
| ៣.៩ | ព្រៃសហគមន៍ | ៦៥ |
| ៤.១ | ប្រព័ន្ធប្រពលវប្បកម្មស្រូវនៅកម្ពុជា (*SRI*) | ៧៣ |
| ៤.២ | ជោគជ័យពីការដាំដំណាំច្រើនមុខនៅក្នុងកសិដ្ឋានកម្ពុជាមួយ | ៧៤ |
| ៤.៣ | វិធីដាំដុះតាមប្រព័ន្ធកសិកម្មទំនើប និងយន្តការជួយទ្រទ្រង់កសិកម្ម-ពិសោធន៍ពីប្រទេសថៃ កោះតៃវ៉ាន់ ខេត្តមួយនៃប្រទេសចិនដីគោក និងវៀតណាម | ៧៥ |
| ៤.៤ | ការធ្វើលំនឹងគុណភាពដី – វិធីដាំដុះតាមប្រព័ន្ធកសិកម្មទំនើបនៅប្រទេសចិន | ៧៥ |
| ៤.៥ | ការយកទឹកប្រើប្រាស់ក្នុងតម្លៃថោកនៅកម្ពុជា | ៧៩ |
| ៤.៦ | ឥណទានខ្នាតតូចដែលមានប្រយោជន៍ | ៨០ |
| ៤.៧ | ការជួញដូរត្រី-ការសង្កេតតាមមូលដ្ឋានពីដើមទសវត្សរ៍ឆ្នាំ ២០០០ | ៨៧ |
| ៤.៨ | ថ្លៃដឹកជញ្ជូនខ្ពស់ ដែលអ្នកភូមិនៅទន្លេសាបជួបប្រទះ | ៨៧ |
| ៤.៩ | ភារកិច្ចទទួលខុសត្រូវរបស់ប្រព័ន្ធទីផ្សារលក់ត្រីសហគមន៍នៅកម្ពុជា | ៨៩ |
| ៤.១០ | ជម្រើសថ្មីក្នុងការរកទីផ្សារលក់ផលិតផលដែលអាចខូចរលួយ-ឧទាហរណ៍ ប្រទេសឥណ្ឌា | ៩០ |
| ៤.១១ | ករណីសិក្សាអំពីការបន្ថែមតម្លៃលើអាហារ | ៩១ |
| ៤.១២ | តម្បាញសូត្រនៅកម្ពុជា | ៩៣ |
| ៤.១៣ | អាជីវករនៅខេត្ត មណ្ឌលគីរី បានផលប្រយោជន៍ពីប្រាក់កម្ចីរបស់អេស៊ីលីដា | ៩៤ |
| ៥.១ | ករណីសិក្សា : អគ្គិសនីនៅតាមជនអាចបង្កើតការងារបានច្រើនសម្រាប់អ្នកក្រ | ១០០ |
| ៥.២ | សមិទ្ធផលដែលបង្កើតឡើង ក្រោមកម្មវិធីផ្ដល់ការងារជួយផ្ដល់បន្ថែមតម្លៃពិត | ១០៣ |
| ៥.៣ | គំរូផ្សេងៗក្នុងការផ្ដល់ជំនាញវិជ្ជាជីវៈដែលមានតម្លៃទាប | ១០៥ |
| ៥.៤ | ការបង្កបង្កើតធនធានមនុស្សតាមរយៈសេវាអភិវឌ្ឍន៍អាជីវកម្ម | ១០៦ |
| ៥.៥ | ទឹកបរិភោគ-បញ្ហា និងដំណោះស្រាយ | ១០៩ |
| ៧.១ | កត្តាផ្សំសំខាន់ៗសម្រាប់ជីវភាពចម្រុងចម្រើននៅជនបទ | ១២១ |

# ពាក្យបំព្រួញ

| | |
|---|---|
| ACI | ទីប្រឹក្សាអន្តរជាតិផ្នែកកសិអាហារ |
| Affirmative action | គំនិតផ្តួចផ្តើមគោលនយោបាយដែលមានបំណងការពារផលប្រយោជន៍ជនជាតិភាគតិច |
| AMUL | សហជីពទឹកដោះគោអាណាន់ដ៍ ចំកាត់ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| Bappenas | គណៈកម្មាធិការផែនការជាតិឥណ្ឌូណេស៊ី |
| BDS | សេវាកម្មអភិវឌ្ឍន៍ធុរកិច្ច |
| CARDI | វិទ្យាស្ថានអភិវឌ្ឍន៍ និងស្រាវជ្រាវកសិកម្មកម្ពុជា |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CEDAC | មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CF | សហគមន៍ព្រៃឈើ |
| CG | ក្រុមពិភាក្សាពិគ្រោះយោបល់ |
| CIPS | អង្កេតអន្តរជំរឿនទូទៅប្រជារាស្ត្រកម្ពុជា |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CNPA | អាជ្ញាធរជាតិប្រេងកាតកម្ពុជា |
| CMEA | ក្រុមប្រឹក្សាសង្គហជំនួយសេដ្ឋកិច្ច |
| DAN | បណ្តាញវិភាគកិច្ចអភិវឌ្ឍ |
| Danida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| DHS | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| EDC | អគ្គិសនីកម្ពុជា |
| EFCT | ក្រុមស្នូលនៃវេទិកាបរិស្ថាន |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ELC | ដីសម្បទានសេដ្ឋកិច្ច |
| EMI | សូចនាករតាមដានពិនិត្យការអប់រំ |
| FMD | ជម្ងឺអុតក្តាម |
| GCMMF | សហព័ន្ធសហករណ៍លក់ទឹកដោះខេត្តគុចារ៉ាដ |
| GDI | សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GEM | រង្វាស់ការផ្តល់សិទ្ធិអំណាចដល់យេនឌ័រ |
| GTZ | ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| HACCP | កម្មវិធីវិភាគគ្រោះថ្នាក់ និងត្រួតពិនិត្យចំណុចគ្រោះថ្នាក់ |
| HD | ការអភិវឌ្ឍមនុស្ស |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស |
| HDR | របាយការណ៍អភិវឌ្ឍន៍មនុស្ស |
| HDRC | មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស |
| HIV/AIDS | មេរោគអេដស៍/ជម្ងឺអេដស៍ |
| HPI | សន្ទស្សន៍ភាពក្រីក្រសម្រាប់មនុស្ស |
| HYV | ពូជផ្តល់ទិន្នផលខ្ពស់ |
| IFAD | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| ICTSD | មជ្ឈមណ្ឌលសម្រាប់ពាណិជ្ជកម្មដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព |
| IL | អក្ខរកម្មតាមកម្រិត |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IMR | អនុបាតមរណភាពកុមារ |
| IPS | សេវាកម្មវេចខ្ចប់បញ្ចូលគ្នា |

| | |
|---|---|
| IRN | បណ្ដាញអន្តរទន្លេ |
| IT | ព័ត៌មានវិទ្យា |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| Krom Samaki Nesat | ក្រុមសាមគ្គីនេសាទ |
| KWh | គីឡូវ៉ាត់ម៉ោង |
| LADIT | ឯកសារព័ត៌មានស្ដីពីភាពឥតដីធ្លី និងការអភិវឌ្ឍ |
| LASED | វិភាជន៍ដីធ្លីសម្រាប់អភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MFA | កិច្ចព្រមព្រៀងផ្នែកនាំចេញសម្លៀកបំពាក់ |
| MOP | ក្រសួងផែនការ |
| MPDF | កម្មវិធីអភិវឌ្ឍន៍ផ្នែកឯកជនប្រចាំតំបន់មេគង្គ |
| MRRP | គម្រោងស្ដារ និងសាងសង់មហាវេលី |
| MSP | កម្រិតតម្លៃអប្បបរមាសម្រាប់ផ្ដល់ជំនួយ |
| MW | ម៉េហ្គាវ៉ាត់ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NHDR | របាយការណ៍ជាតិអភិវឌ្ឍន៍មនុស្ស |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NTFP | ផលិតផលព្រៃឈើក្រៅពីឈើហ៊ុប |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| PPP | ភាពស្មើនៃអំណាចទិញ |
| PTC | មណ្ឌលបណ្ដុះបណ្ដាលថ្នាក់ខេត្ត |
| Public action | សកម្មភាពរដ្ឋាភិបាលដើម្បីបង្កើនសេវាសង្គម និងសេវាសាធារណៈ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SCW | អង្គការសង្គ្រោះសត្វព្រៃកម្ពុជា |
| SES-97 | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ១៩៩៧ |
| SES-04 | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ២០០៤ |
| SIFFS | សមាគមអ្នកនេសាទត្រីនៃសហព័ន្ធឥណ្ឌាភាគខាងត្បូង |
| SLC | ដីសម្បទានសហគមន៍ |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SRI | ប្រព័ន្ធប្រពលវប្បកម្មស្រូវ |
| Swidden | កសិកម្មពនេចរ |
| T&V | បណ្ដុះបណ្ដាល និងទស្សនកិច្ច |
| TVET | ការបណ្ដុះបណ្ដាលការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNHCHR | ស្នងការជាន់ខ្ពស់សហប្រជាជាតិសម្រាប់ជនភៀសខ្លួន |
| UNICEF | មូលនិធិសហប្រជាជាតិសម្រាប់កុមារ |
| UNTAC | អាជ្ញាធរអន្តរកាលសហប្រជាជាតិប្រចាំកម្ពុជា |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ |
| VAHW | ពេទ្យសត្វភូមិ |
| VSF | ពេទ្យសត្វគ្មានព្រំដែន |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |
| WUA | សមាគមអ្នកប្រើប្រាស់ទឹក |






Acharya S, S Iyer and A Basak 2005, *Towards Strengthening District Planning for Human Development,* Human Development Resource Centre, New Delhi: UNDP Country Office

Acharya S, S Kim, S Chap, and Y Meach 2003, 'Off-Farm and Non-Farm Activities and Employment in Cambodia,' DAN, in *Off-Farm and Non-Farm Jobs in SEATE and Thailand: Rationale and Synthesis of Country Studies,* Phnom Penh: CDRI

ACI (Agrifoods Consultants International) 2005, *Final Report of the Cambodian Agrarian Study,* Prepared for RGC and World Bank, Bethesda (Maryland)

Anand S and A Sen 2000, 'The Income Component in the Human Development Index,' *Journal of Human Development,* Vol.1 No. 1

Anders J and A Kokko 2006, *(Land and Human Development),* Discussion Paper, Insights for Action, Phnom Penh: UNDP Cambodia Country Office (early draft)

Auffret, P 2003, *Rural Poverty in Cambodia: Impact of Land Distribution and Alternative Policies,* World Bank: Washington

Ballard B and S So 2004, *Cambodia Land Titling Program: Baseline Survey Project, Final Report, Rural Phase 1,* Phnom Penh: CDRI/Ministry of Land Management, Urban Planning and Construction

Barret CB 1993, 'On Price Risk and the Inverse Farm Size-Productivity Relationship,' *Department of Agricultural Economics Staff Paper Series No. 369,* Madison: University of Wisconsin

Biddulph R 2000, *Making the Poor More Visible,* Phnom Penh: Oxfam GB

Biddulph R 2004, *Poverty and Social Impact Assessment of Social Land Concessions in Cambodia: Landlessness Assessment,* Phnom Penh: Oxfam GB

Boserup E 1965, *The Conditions for Agricultural Growth,* Chicago: Aldine

Bottomley R 2002, 'Contested Forests: An Analysis of the Highlander Response to Logging, Rattanakiri Province, Northeast Cambodia,' *Critical Asian Studies* Vol. 34 No. 4, 587-606

Bush SR and LN Minh 2005, *Fish Trade, Food and Income Insecurity: A Review of the Constraints and Barriers Faced by Small-Scale Fishers, Farmers and Traders in the Lower Mekong Basin,* Phnom Penh: Oxfam America

CDRI (Cambodia Development Resource Institute) 2005, *Annual Development Review 2004-05,* Phnom Penh

CDRI 2006, *Cambodia: National Synthesis Report,* Phnom Penh

CDRI 2007, *'We Are Living With Worry All the Time,'* Phnom Penh: CDRI

Chan S and S Acharya 2002, *Facing the Challenge of Rural Livelihoods – A Perspective from Nine Villages,* Working Paper 25, Phnom Penh: CDRI

Chan S, S Tep and S Acharya 2001, *Land Tenure in Cambodia – A Data Update,* Working Paper 19, Phnom Penh: CDRI

Chanda N 1986, *Brother Enemy,* New York: Collier

Chandler, D 1993, *A History of Cambodia,* Boulder: Westview Press

Chandler D 2006, 'Rhymes of Cambodian History,' paper presented at *Equity and Development – Exploring Issues and Options for Cambodia,* roundtable among research partners, Phnom Penh: World Bank Country Office

Christian S, KS Heov and B Khlok 2005, 'Natural Resources and Environment: Issues, Constraints and Challenges,' in CDRI *Annual Development Review 2004-05,* Phnom Penh

Dapice D, T Vellely and B Wilkinson 2006, *Improving the Lives of Cambodia's Rural Citizens: Raising Farm Family Incomes in Cambodia* Discussion Paper, Insights for Action, Phnom Penh: UNDP Cambodia Country Office (early draft)

Devereux S and C Solomon 2005, *Employment Creation Programmes: The International Experience,* Roundtable on National Guarantee Programme in India, 30-31 August, New Delhi: ILO

Dinravy K and A Groetschel 2004, *Potential Poverty and Social Impacts of Cambodia's Proposed Social Land Concession Programme – Presentation and Discussion of Results and Recommendations from the PSIA Exercise* Phnom Penh: Ministry of Land Management, Urban Planning and Construction, Oxfam, GTZ and World Bank

Ear S 1995, *Cambodia's Economic Development and History,* Undergraduate Economics Honours Thesis, Department of Economics, University of California, Berkeley, http://www.csua.berkeley.edu/~sophal

Ear S 2005, 'Political Economy of Pro-Poor Livestock in Cambodia,' in PPLPI Working Paper No. 26, *Living from Livestock,* Rome: Food and Agriculture Organisation (FAO)

Edwards S and I Magendzo 2002, *Dollarisation and Economic Performance: What Do We Really Know?,* Working Paper No. 65, Vienna: Oesterreichische Nationalbank

EFCT (Environment Forum Core Team) 2005, *Fast-Wood Plantations, Economic Concessions and Local Livelihoods in Cambodia – Field Investigations in Koh Kong, Kampong Speu, Pursat, Kampong Chhnang, Mondolkiri, Prey Veng and Svay Rieng Provinces,* Phnom Penh: NGO Forum

EIC 2006, *Cambodia: Agricultural Development Report – 2006,* Phnom Penh

Frausto K 2001, 'Developing Irrigation Options for Small Farmers,' Thematic Review IV.2 – *Assessment of Irrigation Options,* Institute of Developing Enterprises (US), http://www.dams.org

Goletti, F 2004a, *Agribusiness and Commercial Agriculture Short Course,* Agrifoods Consulting International, 19-23 January 2004, Manila: Asian Development Bank

GTZ (Gesellschaft fur Technische Zusammenarbeit) 2006, *Overview of Major Legal Categories of Lands and Waters in Cambodia,* Phnom Penh

Halabi K 2005, *Review of Experiences in Land Distribution in Cambodia,* Land Allocation for Social and Economic Development (LASED), Phnom Penh: Ministry of Land Management, Urban Planning and Construction, GTZ and World Bank.

Hap N, R Chuenpagdee and J Kurien 2006, *Livelihood Importance and Values of Tonle Sap Fisheries,* Policy Brief, Phnom Penh: Inland Fisheries Research and Development Institute, RGC/World Fish Centre

Hap N, L Seng and R Chuenpagdee 2006, *Socioeconomics and Livelihood Issues of Tonle Sap Lake Fisheries,* Phnom Penh: Inland Fisheries Research and Development Institute, RGC/World Fish Centre (http://www.ifredi.org)

Heov KS, B Khlok, K Hansen and C Sloth 2006, 'The Value of Forest Resources to Rural Livelihoods in Cambodia,' in *CDRI Policy Brief,* Issue 2

ICTSD (International Centre for Trade for Sustainable Development) 2005, *Untangling Fisheries and Trade: Towards Priorities for Action,* Geneva: Report of a Seminar, May

ILO (International Labour Organisation) 2001, *Business Development Services for Small Enterprises,* http://oracle02.ilo.org/dyn/empent.Portal.Portal?P.Prog=S&P=BD

ILO 2006, *Promoting Employment in Cambodia: Analysis and Options,* Working Paper (draft) prepared for the Ministry of Labour and Vocational Training, Ministry of Labour, Cambodia; Bangkok

ILO-Bappenas 2005, *A National Employment Guarantee Programme for Indonesia – An Approach,* Jakarta: International Labour Office

IMM 2005, *Understanding the Factors That Support or Inhibit Livelihood Diversification in Coastal Cambodia,* Innovation Centre, Rennes Drive, Exeter UK

IRN (Inter-Rivers Network) 2002, *Damming the Sesan River: Impact on Cambodia and Vietnam,* Briefing Paper, Inter-Rivers Network, http://www.irn.org

Kato E 2000, *Where Has All the Land Gone? Land Rights and Access in Cambodia,* Phnom Penh: Cambodia Land Project, Oxfam GB

Kim S 2005, *'The Socio-Economic Status of Coastal Fishing Communities, Including Health and HIV/AIDS,'* paper prepared for FAO GCP/RAS/199/SWE Strengthening Capacity in Fisheries Information Gathering for Management, Phnom Penh: FAO

Kim S, S Chan and S Acharya 2002, *Land, Rural Livelihoods and Food Security in Cambodia – A Perspective from Field Reconnaissance,* Working Paper 24, Phnom Penh: CDRI

Kurien, J, N So and So Mao 2006, *Cambodia's Aquarian Reforms: The Emerging Challenges for Policy and Research*, Phnom Penh: Inland Fisheries Research and Development Institute, RGC/World Fish Centre (http://www.ifredi.org)

Kusakabe K, S Prak, S Ubolratana, S Napaporn 2005, *Gendered Commodity Chain of Fish Border Trade from Cambodia to Thailand,* paper presented at the Conference on Trans-Border Issues in Greater Mekong Sub-Region, Ubonatchathani, Thailand, 30 June-2 July

Le Billon P 2002, 'Logging in Muddy Waters – Politics of Forest Exploitation,' in *Critical Asian Studies,* Vol. 34, No. 4, 563-586

Ling Z and J Zhongyi 1995, 'Yigong-Daizhen in China: A New Experience with Labour-Intensive Public Works in Poor Areas,' Chapter 4, in J von Braun (Ed.), *Employment and Poverty Reduction and Food Security,* Washington: IFPRI

Ly Chou Beang and Lao Sethaphal 2004, *Community Forestry in Cambodia,* Proceedings of a Regional Workshop on Forestry and Poverty Reduction, FAO (Bangkok)-Chinese Academy of Forestry (Beijing) http://www.fao.org/docrep/007/ad511e/ad511e00.htm

Mak S 2001, 'Continued Innovation in a Cambodian Rice-Based Farming System: Farmer Testing and Recombination of New Elements,' in *Agricultural Systems* No. 69, 137–149

Mak Sithirith 2005, *'The Hydrodynamics of the Tonle Sap Lake in Cambodia,'* mimeo

McKenny B and T Prom 2002, *Natural Resources and Rural Livelihoods in Cambodia – A Baseline Assessment,* Working Paper 23, Phnom Penh: CDRI

Moreno-Dodson B (Ed.) 2005, *Reducing Poverty on a Global Scale – Findings from the Shanghai Global Learning Initiative,* Washington: World Bank

Mouhot, H 1862, *Travels in Siam, Cambodia, Laos and Annam,* Bangkok: White Lotus, republished 2000

MPDF (Mekong Private Sector Development Facility) 2005, *Cambodia and WTO: A Guide to Business,* Phnom Penh: Ministry of Commerce/International Finance Corporation

Mysliwiec E 1988, *Punishing the Poor: International Isolation of Kampuchea,* Oxford: Oxfam

Nou K 2005, 'The Competitiveness of Cambodian Agriculture: Case of Maize, Soybeans and Cassava,' in CDRI *Annual Development Review 2004-05,* Phnom Penh

Ngy S 2006, *'Rural Development in Cambodia,'* mimeo, Phnom Penh: Ministry of Rural Development

Oxfam 2005, *Assessment and Learning from Community Fisheries Management Process,* Phnom Penh: Oxfam GB

Rab MA, N Hap, L Seng, M Ahmed and K Viner 2005, *Marketing Infrastructure, Distribution Channels and Trade Pattern of Inland Fisheries Resources Cambodia: An Exploratory Study,* Penang: World Fish Centre (http://www.ifredi.org)

RGC (Royal Government of Cambodia) 2003, *Cambodian Agricultural Finance Survey – Statistical Report,* National Institute of Statistics, Phnom Penh: Ministry of Planning (MOP)

RGC 2004, *Agricultural Statistics 2003-04*, Phnom Penh: MOP

RGC 2005, *Agricultural Statistics 2004-05,* Phnom Penh: MOP

RGC 2005a, *Cambodia Socioeconomic Survey 2004, Final Summary Report,* National Institute of Statistics, Phnom Penh: MOP

RGC 2006, *A Poverty Profile of Cambodia,* Phnom Penh: MOP

RGC 2006a, *National Strategic Development Plan 2006-2010,* Phnom Penh

RGC 2006b, *National Accounts of Cambodia 1993-2005,* Bulletin No. 10, National Institute of Statistics, Phnom Penh: MOP

RGC 2006c, *Agricultural Statistics 2005-06,* Phnom Penh: MOP

RGC 2006d, *Cambodia Education Sector Performance Analysis 2006, EC Technical Advisory Team,* Phnom Penh: Targeted EC Support to Pro-Poor Basic Reforms in Cambodia

SCW (Save Cambodian Wildlife)/Danida 2006, *The Atlas of Cambodia – National Poverty and Environment Maps,* Phnom Penh

Seng B, B Dongelmans B and J ter Horst 2006, *Silk Weavers in Cambodia*, Phnom Penh: Asia Foundation/USAID/Centre for Advanced Study
Sik, B 1998, *Rice Supply Response in Cambodia,* unpublished master's thesis, University of New England, Australia

SNEC (Supreme National Council of Cambodia)-Harvard University 2006, *A SWOT Analysis of the Cambodian Economy,* Phnom Penh: UNDP

So S, S Real, U Uch, R Sy B Ballard and S Acharya 2001, *Social Assessment of Land – A Field Study,* Working Paper 20, Phnom Penh: CDRI

Sok H, H Chea and B Sik 2001, *Annual Economic Review,* Phnom Penh

Sok V 2005, *'Fish Markets in Phnom Penh, Siem Reap and Sihanoukville,'* Working Paper 1, Department of Fisheries, Phnom Penh: Ministry of Agriculture, Fisheries and Forests (MAFF)

Sokh, H and S Ty 2005, *'Cambodia Community Forestry,'* mimeo, Department of Forestry, Phnom Penh: MAFF

TWG (Technical Working Group) – Agriculture and Water 2006, *Agriculture and Water Strategy 2006-2010* (draft report), 11 September 2006

Thanh NX 2005, *Cambodia: Land and Agricultural Development,* mimeo, Vietnam Programme, Kennedy School of Government, Cambridge: Harvard University

Thion S 1993, *Watching Cambodia,* Bangkok: White Lotus

Ty S, H Sokh and S Lao 2006, *Institutional Arrangements for Community Forestry in Cambodia,* Department of Forestry, Phnom Penh: MAFF

UNDP (United Nations Development Programme) 1995, *Human Development Report,* New York: Macmillan

UNDP 2006, *Human Development Report,* New York: Macmillan

UNDP-Planning Commission 2001, *National Human Development Report – India,* New Delhi

UNDP-HDRC (Human Development Resource Centre) 2006, *A Course in Human Development,* New Delhi: UNDP India Country Office

UNHCHR (United Nations High Commission for Human Rights) 2004, *Land Concessions for Economic Purposes in Cambodia – A Human Rights Perspective,* Phnom Penh

USAID (United States Agency for International Development) 2005, *Human Impact of Forest Conflict,* Washington (http://www.usaid.gov)

Vickery M, *Cambodia 1975-1982,* South End Press, 1984 (Questia Online Library),
http:// www.questia.com/library/book/cambodia-1975-1982-by-michael-vickery.jsp

Williams S 2000, *A Study of the Capacity of Five Provinces to Resolve Conflicts Over Land,* Phnom Penh: Cambodia Land Project, Oxfam: Great Britain

World Bank 2001, *Private Sector Development Strategy – Directions for the World Bank Group,*
http://rru.worldbank.org/strategy/documents/PSDStrategy-Dec3version.pdf

World Bank 2002, *Project Appraisal Document Report No. 22869-KH for Proposed Credit for Land Management and Administration Project,* Washington: Rural Development and Natural Resources Sector Unit, East Asia and Pacific Region

World Bank 2005, *Cambodia Rural Sector Strategy Note,* Phnom Penh

World Bank 2005a, *Shaping the Future of Water for Agriculture – A Sourcebook for Investment in Agriculture and Water Management,* Washington: The World Bank

World Bank, 2006, *Cambodia: Halving Poverty by 2015? Poverty Assessment 2006,* Report No. 35213-KH, Document of the World Bank, East Asia and the Pacific Region, Washington

World Bank 2006a, 'Cambodia in the Second Decade of Peace: Creating Shared Growth,' paper presented in *Equity and Development – Exploring Issues and Options for Cambodia,* roundtable among research partners, Phnom Penh: World Bank Country Office

Yim C and B McKenny, 2003, *Domestic Fish Trade: A Case Study of Fish Marketing from the Great Lake to Phnom Penh,* Working Paper 29, Phnom Penh: CDRI

Design by Graphic Roots: www.graphicroots.com.kh

**ក្រសួងផែនការ**

ផ្ទះលេខ ៣៨៦ មហាវិថីព្រះមុនីវង្ស - រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ៧២០ ៩០១-៥
ទូរសារ : (៨៥៥) ២៣ ២១០ ៩៤៤
អ៊ីម៉ែល : mop@cambodia.gov.kh
គេហទំព័រ : www.mop.gov.kh

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

ផ្ទះលេខ ៥៣ ផ្លូវប៉ាស្ទ័រ សង្កាត់បឹងកេងកង - ប្រអប់សំបុត្រលេខ ៨៧៧ - រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ២១៦ ១៦៧ ឬ ២១៤ ៣៧១
ទូរសារ : (៨៥៥) ២៣ ២១៦ ២៥៧ ឬ ២៧១ ០៤២
អ៊ីម៉ែល : registry.kh@undp.org
គេហទំព័រ : www.un.org.kh/undp